# គ្រិស្តបរិស័ទនៅក្នុងសហគមន៍

# The Christian in the Community



កម្មវិធីជីវិតគ្រិស្តបរិស័ទ

# គ្រិស្តបរិស័ទនៅក្នុងសហគមន៍

# The Christian in the Community

ការបោះពុម្ពលើកទី៦

Sixth Edition

ដោយលោក ដូណាល់ ស្តាកលេស (Donald Stuckless)

GLOBAL UNIVERSITY

Address of the Global University office in your area:

Cambodia Bible Institute (CBI) - Christian Life Program
#37M, St. 16, Sangkat Toeuk Thla,
Khan Sen Sok, Phnom Penh, CAMBODIA

Global University - Battambang CAM Office
Salaa Hope - AOG
Phom Romcheck 4, Khum Ratanak
Srok Battambang
Battambang, CAMBODIA

Developed in cooperation with Global University staff

School for Evangelism and Discipleship
Global University
1211 South Glenstone
Springfield, MO 65804
USA

Translated from the Sixth edition, 2010 (English)
First edition 2018 (Khmer)
©2018 Global University
All rights reserved
Khmer: *The Christian in the Community* by Donald Stuckless

Unless otherwise indicated, Scripture is taken from the Khmer Standard Version ©2005 United Bible Societies. Used by permission.

PN 06.13

www.globaluniversity.edu
www.globalreach.org (free pdf downloads)

Khmer version by Cambodia Bible Institute (CBI) Translation Office
Project Editor: Darin Clements
Head Translator: គឹម ឡុងឌី (Kim Longdi)
Translation Staff:
កែន សោភ័ណ្ឌ (Ken Sophorn)
ឈួន ស្រីទូច (Chhoun Srey Touch)
មុំ រ៉ាវី (Mom Ravee)
យត សៃអ៊ីម (Yoat Sayim)
ស៊ុន ប៊ុននី (Sun Bunny)
ហ៊ុយ សាម៉ី (Hoy Samey)
Additional Proofreading: រៀល ណាឡេង (Real Naleng)
Cover Design: ឆាត វាសនា (Chhat Veasna)

# មាតិកា


បុព្វកថា........6

កម្មវិធីជីវិតគ្រិស្តបរិស័ទ........7

មុនពេលអ្នកចាប់ផ្តើម........8


## ជំពូកទីមួយ


១ គំនិតអំពីសហគមន៍ The Idea of Community........17

២ សហគមន៍គ្រិស្តបរិស័ទ The Christian's Community........27

៣ ការរីកចម្រើននៅក្នុងសហគមន៍ Growing in Community........39

៤ ការប្រកាន់គោលជំហរនៅក្នុងសហគមន៍ Standing in Community........53

៥ ការសាងសង់នៅក្នុងសហគមន៍ Building in Community........61


## ជំពូកទីពីរ


៦ ការរៀនពីព្រះយេស៊ូ Learning from Jesus........73

៧ ការបញ្ចេញពន្លឺនៅក្នុងក្រុមជំនុំរបស់អ្នក Shining in Your Community........83

៨ សមាជិកភាពក្នុងក្រុមជំនុំសហគមន៍ Belonging in the Church Community........91

៩ ការបរិច្ចាគនៅកាន់សហគមន៍របស់អ្នក Contributing to Your Community........99

១០ ការបន្តនៅក្នុងសហគមន៍រ Continuing in Community........109


## ការវាយតម្លៃតាមជំពូក


ការវាយតម្លៃជំពូកទី១........121

ការវាយតម្លៃជំពូកទី២........127

ពាក្យពេចន៍ចុងក្រោយ........133

## កម្មវិធីជីវិតគ្រិស្តបរិស័ទ Christian Life Series

ជីវិតថ្មីរបស់បងប្អូន Your New Life

ព្រះគម្ពីររបស់បងប្អូន Your Bible

ព្រះយេស៊ូជានរណា Who Jesus Is

ក្រុមជំនុំ The Church

ការផ្សព្វផ្សាយដំណឹងល្អដោយខ្លួនឯងផ្ទាល់ Personal Evangelism

ក្រមសីលធម៌តាមព្រះគម្ពីរ Bible Ethics

នៅពេលបងប្អូនអធិស្ឋាន When You Pray

របៀបសិក្សាព្រះគម្ពីរ How to Study Bible

ដ៏ជួយការពាររបស់បងប្អូន Your Helpful Friend

ការថ្វាយបង្គំរបស់គ្រិស្តបរិស័ទ Christian Worship

អ្នកបម្រើព័ន្ធកិច្ចជាគ្រិស្តបរិស័ទ Christian worker

អាពាហ៍ពិពាហ៍និងគ្រួសារ Marriage and the Home

ផែនការរបស់ព្រះជាម្ចាស់ - ជម្រើសរបស់បងប្អូន God's Design-

ដំណឹងល្អតាមរយៈលោកយ៉ូហាន John's Gospel

យើងជឿ We Believe

ភារកិច្ចរបស់ក្រុមជំនុំ What Church Do

ព័ន្ធកិច្ចនៃការបង្រៀនThe Teaching Ministry

**គ្រិស្តបរិស័ទនៅក្នុងសហគមន៍ The Christian in the Community**

# បុព្វកថា

ប្រសិនបើបងប្អូនបានទទួលព្រះយេស៊ូគ្រិស្តជាព្រះសង្គ្រោះផ្ទាល់ខ្លួនរបស់បងប្អូន បងប្អូនមានបទពិសោធនៃការផ្លាស់ប្រែហើយនៅក្នុងជីវិតរបស់បងប្អូន។ ការផ្លាស់ប្តូរមួយនៅក្នុងចំណោមការផ្លាស់ប្តូរទាំងអស់នេះគឺប្រហែលជាការផ្លាស់ប្តូរអាកប្បកិរិយារបស់បងប្អូនចំពោះអ្នកដទៃ។ ទាំងអស់គ្នាមានការពាក់ព័ន្ធនៅក្នុងទំនាក់ទំនងជាមួយមនុស្សផ្សេងទៀត។ នៅក្នុងពាក្យមួយទៀត យើងទាំងអស់រស់នៅក្នុងសហគមន៍ជាមួយមនុស្សដទៃទៀត។

ជាធម្មតាយើងគិតថាសហគមន៍គឺជាកន្លែងដែលយើងរស់នៅ។ ប៉ុន្តែ បងប្អូននឹងរៀនបានថាសហគមន៍គឺពិសេសជាងកន្លែងដែលយើងរស់នៅ។ វាគឺជាអារម្មណ៍មួយ ឬ អកប្បកិរិយាដែលពួកយើងមានចំពោះអ្នកដទៃ។

តើបងប្អូនដឹងទេថា បងប្អូនអាចចូលរួមចំណែកសហគមន៍ជាច្រើន? ប្រហែលជាបងប្អូនក្លាយជាផ្នែកនៃសហគមន៍សាលា សហគមន៍ក្រុមជំនុំ ឬ សហគមន៍ការងារ។ ទាំងអស់នេះរួមគ្នា ជាសហគមន៍ធំរបស់បងប្អូន។

នៅក្នុងមុខវិជ្ជានេះ ពួកយើងនឹងរកឃើញគោលការណ៍នៃការរស់នៅក្នុងសហគមន៍ជាមួយមនុស្សផ្សេងទៀត។ គោលការណ៍សំខាន់មួយនៃសៀវភៅនេះសម្រាប់ការរស់នៅប្រចាំថ្ងៃរបស់បងប្អូនគឺ ការពឹងផ្អែកលើព្រះវិញ្ញាណដ៏វិសុទ្ធ។ ព្រះវិញ្ញាណដ៏វិសុទ្ធនឹងជួយបងប្អូនឱ្យទទួលយកការបង្រៀននេះ និងអនុវត្តន៍នៅក្នុងជីវិត។ សូមព្រះអង្គជួយបងប្អូនក្នុងពេលដែលបងប្អូនសិក្សានិង អនុវត្តតាមអ្វីដែលបងប្អូនរៀន។

វិធីទំនើបមួយនៃការបង្រៀនខ្លួនឯង ជួយអ្នកឱ្យរៀនពីគោលការណ៍យ៉ាងងាយស្រួល ហើយនឹងយកពួកវាទៅអនុវត្តភ្លាមៗ។

# កម្មវិធីជីវិតគ្រិស្តបរិស័ទ

## The Christian Life Series

*គ្រិស្តបរិស័ទនៅក្នុងសហគមន៍* ជាមុខវិជ្ជាមួយក្នុងចំណោមមុខវិជ្ជាចំនួន១៨ ក្នុងកម្មវិធីបង្កើតសិស្ស សម្រាប់អ្នកទើបនឹងជឿ។ កម្មវិធីជីវិតគ្រិស្តបរិស័ទជាការសិក្សាដើម្បីជួយសិស្ស ឱ្យរីកចម្រើនក្នុងទំនាក់ទំនងរបស់ពួកគេជាមួយព្រះគ្រិស្ត សិក្សាព្រះបន្ទូលរបស់ព្រះជាម្ចាស់ និងយល់ដឹងអំពីគោលបំណងរបស់ព្រះជាម្ចាស់ សម្រាប់ជីវិតរបស់ពួកគេកាន់តែប្រសើរជាងមុន។

សិស្សនឹងសិក្សាប្រធានបទគ្រិស្តបរិស័ទជាមូលដ្ឋាន នៅក្រោមផ្ទៃរឿងចំនួនប្រាំមួយ។ មុខវិជ្ជានីមួយៗមានលក្ខណៈជាកិច្ចសន្ទនា និងងាយស្រួលអាន។ តារាងខាងក្រោម បកស្រាយអំពីរបៀបដែលវគ្គនៃការសិក្សាត្រូវបានរៀបចំសម្រាប់កម្មវិធីជីវិតគ្រិស្តបរិស័ទ។

| | វគ្គទី១<br>**Unit One** | វគ្គទី២<br>**Unit Two** | វគ្គទី៣<br>**Unit Three** |
|---|---|---|---|
| ជីវិតខាងព្រលឹងវិញ្ញាណ<br>**Spiritual Life** | ជីវិតថ្មីរបស់បងប្អូន<br>Your New Life | នៅពេលបងប្អូនអធិស្ឋាន<br>When You Pray | គម្រោងការរបស់ព្រះជាម្ចាស់-ជម្រើសរបស់បងប្អូន<br>God’s Design—Your Choice |
| ព្រះគម្ពីរ<br>**The Bible** | ព្រះគម្ពីររបស់បងប្អូន<br>Your Bible | របៀបសិក្សាព្រះគម្ពីរ<br>How to Study the Bible | ដំណឹងល្អរៀបរៀងដោយលោកយ៉ូហាន<br>John’s Gospel |
| ទេវវិទ្យា<br>**Theology** | ព្រះយេស៊ូជានរណា<br>Who Jesus Is | ព្រះដ៏ជួយការពាររបស់បងប្អូន<br>Your Helpful Friend | យើងជឿ<br>We Believe |
| ក្រុមជំនុំ<br>**The Church** | ក្រុមជំនុំ<br>The Church | ការថ្វាយបង្គំរបស់គ្រិស្តបរិស័ទ<br>Christian Worship | ភារកិច្ចរបស់ក្រុមជំនុំ<br>What Churches Do |
| កិច្ចបម្រើ<br>**Service** | ការផ្សព្វផ្សាយដំណឹងល្អដោយខ្លួនឯងផ្ទាល់<br>Personal Evangelism | អ្នកបម្រើព័ន្ធកិច្ចជាគ្រិស្តបរិស័ទ<br>Christian Workers | ព័ន្ធកិច្ចនៃការបង្រៀន<br>The Teaching Ministry |
| ក្រមសីលធម៌របស់គ្រិស្តបរិស័ទ<br>**Christian Ethics** | ក្រមសីលធម៌តាមព្រះគម្ពីរ<br>Bible Ethics | អាពាហ៍ពិពាហ៍ និងគ្រួសារ<br>Marriage and the Home | គ្រិស្តបរិស័ទនៅក្នុងសហគមន៍<br>The Christian in the Community |

# មុនពេលអ្នកចាប់ផ្តើម

## របៀបប្រើសៀវភៅនេះ

សៀវភៅនេះ ត្រូវបានបែងចែកជាមេរៀនជំនួសឱ្យជំពូក។ មេរៀននីមួយៗ ចាប់ផ្តើមដោយទំព័រសំខាន់ៗចំនួនពីរ។ នៅបន្ទាប់ពីលេខនៃមេរៀននីមួយៗ មានចំណងជើង និងសេចក្តីផ្តើមខ្លីនៃមេរៀន។ នៅទំព័របន្ទាប់ជា *គម្រោង* សម្រាប់មេរៀន។ វាជាកំណត់ត្រាពីអ្វីដែលអ្នកអាចរំពឹងនឹងសិក្សានៅក្នុងមេរៀននេះ។

បន្ទាប់មកទៀត ជាគោលដៅនៃមេរៀន។ *គោលដៅ* គឺជាសេចក្តីណែនាំអំពីអ្វីដែលអ្នកគួរតែអាចធ្វើ បន្ទាប់ពីរៀនមេរៀននេះចប់។ សូមអានគោលដៅនីមួយៗដោយយកចិត្តទុកដាក់ ដោយពួកវានឹងជួយអ្នកឱ្យផ្តោតទៅលើចំណុចដ៏សំខាន់បំផុតនៃមេរៀននេះ។

ដើម្បីជួយអ្នកឱ្យសម្រេចគោលដៅបាន មេរៀននីមួយៗមានសំណួរ និងសកម្មភាព។ ចំណងជើងរង *លំហាត់អនុវត្តន៍* ជាសញ្ញាប្រាប់ឱ្យអ្នកឆ្លើយសំណួរអំពីមេរៀន ដែលបានរៀនរួចមកហើយ។ សូមកុំរំលងផ្នែកនេះ។ ការសរសេរចម្លើយនឹងជួយអ្នក ឱ្យអនុវត្តនូវអ្វីដែលអ្នកបានរៀនរួចហើយ។ អ្នកអាចឆ្លើយសំណួរភាគច្រើននៅក្នុងសៀវភៅរបស់អ្នក។ ប្រសិនបើគ្មានកន្លែងទំនេរគ្រប់គ្រាន់ ដើម្បីសរសេរចម្លើយរបស់អ្នកនៅក្នុងសៀវភៅនេះទេ សូមសរសេរចម្លើយទាំងនោះនៅក្នុងសៀវភៅសរសេរ ឬសៀវភៅកត់ត្រាផ្ទាល់ខ្លួន ដែលអ្នកអាចប្រើដើម្បីរំលឹកមេរៀននៅពេលក្រោយ។

ក្រោយពីឆ្លើយសំណួរ អ្នកអាចផ្ទៀងចម្លើយនៅចុងបញ្ចប់នៃមេរៀន ដែលមាននៅក្នុងផ្នែក *សូមផ្ទៀងចម្លើយរបស់អ្នក*។ សូមកុំមើលចម្លើយមុន រហូតដល់អ្នកបានសរសេរចម្លើយផ្ទាល់ខ្លួនរបស់អ្នករួចរាល់សិន។ ការធ្វើបែបនេះ នឹងជួយឱ្យអ្នកចងចាំអ្វីដែលអ្នកបានសិក្សាកាន់តែប្រសើរឡើង។ សូមកែចម្លើយទាំងឡាយ ដែលអ្នកឆ្លើយមិនទាន់បានត្រឹមត្រូវ។ ចម្លើយទាំងនោះមិនបានរៀបតាមលំដាប់លំដោយទេ ដូច្នេះ អ្នកនឹងមិនងាយនឹងមើលឃើញចម្លើយចំពោះសំណួរបន្ទាប់ឡើយ។

## របៀបឆ្លើយសំណួរសិក្សា

មុខវិជ្ជានេះ ប្រើសំណួរប្រភេទផ្សេងៗគ្នាជាច្រើន។ នៅខាងក្រោមនេះ មានគំរូនៃប្រភេទសំណួរទូទៅចំនួនបី និង របៀបនៃការឆ្លើយសំណួរទាំងនោះ។

### សំណួរពហុជ្រើសរើស

សំណួរពហុជ្រើសរើស ចង់ឱ្យអ្នកជ្រើសរើសចម្លើយមួយពីបណ្តាចម្លើយដែលគេបានផ្តល់ឱ្យ។

*ឧទាហរណ៍*

១. ព្រះគម្ពីរមានសរុបទាំងអស់

ក) ១០០ កណ្ឌ។

ខ) ៦៦ កណ្ឌ។

គ) ២៧ កណ្ឌ។

ចម្លើយត្រឹមត្រូវគឺ ខ) ៦៦ កណ្ឌ។ ក្នុងសៀវភៅមគ្គុទេសក៍សិក្សារបស់អ្នក ចូរគូសរង្វង់លើ **ខ)** ដែលបានបង្ហាញនៅខាងក្រោមះ

១. ព្រះគម្ពីរមានសរុបទាំងអស់

ក) ១០០ កណ្ឌ។

(ខ) ៦៦ កណ្ឌ។

គ) ២៧ កណ្ឌ។

### សំណួរខុស/ត្រូវ

សំណួរ ខុស/ត្រូវ ចង់ឱ្យអ្នកជ្រើសរើសយកប្រយោគណាដែល**ត្រឹមត្រូវ**។

*ឧទាហរណ៍*

២. តើប្រយោគណាដែលត្រឹមត្រូវ?

ក) ព្រះគម្ពីរមាន ១២០ កណ្ឌ។

(ខ) ព្រះគម្ពីរជាព្រះរាជសារសម្រាប់អ្នកជឿនៅសព្វថ្ងៃនេះ។

គ) អ្នកនិពន្ធព្រះគម្ពីរទាំងអស់ សរសេរជាភាសាហេប្រឺ។

(ឃ) ព្រះវិញ្ញាណដ៏វិសុទ្ធបានបំភ្លឺឱ្យតែងព្រះគម្ពីរ។

ប្រយោគ **ខ)** និង **ឃ)** ត្រឹមត្រូវ។ អ្នកគួរតែគូសរង្វង់ជុំវិញអក្សរទាំងពីរនេះ ដើម្បីបង្ហាញជម្រើសរបស់អ្នក ដូចអ្នកបានឃើញនៅខាងលើ។

**សំណួរផ្គូផ្គង**

សំណួរផ្គូផ្គង ចង់ឱ្យអ្នកផ្គូផ្គងអ្វីដែលស្របគ្នា ដូចជាឈ្មោះជាមួយការពណ៌នា ឬកណ្ឌគម្ពីរជាមួយអ្នកនិពន្ធ។

*ឧទាហរណ៍*

៣. ចូរសរសេរលេខសម្រាប់ឈ្មោះអ្នកដឹកនាំ (ខាងស្តាំ) នៅខាងមុខឃ្លានីមួយៗ ដែលពណ៌នាអំពីអ្វីដែលគាត់ធ្វើ (ខាងឆ្វេង)។

...១.... ក) បានទទួលបទបញ្ញានៅភ្នំស៊ីណៃ — ១) ម៉ូសេ

...២....ខ) បានដឹកនាំជនជាតិអ៊ីស្រាអែលឆ្លងកាត់ទន្លេយ័រដាន់ — ២) យ៉ូស្វេ

...២....គ) បានដើរជុំវិញក្រុងយេរីខូ

...១....ឃ) បានរស់នៅក្នុងដំណាក់របស់ស្តេចផារ៉ោន

ឃ្លា **ក)** និង **ឃ)** និយាយអំពី *ម៉ូសេ* ហើយឃ្លា **ខ)** និង **គ)** និយាយអំពី *យ៉ូស្វេ*។ អ្នកគួរតែសរសេរលេខ **១** នៅពីមុខ **ក)** និង **ឃ)** ហើយសរសេរលេខ **២** នៅពីមុខ **ខ)** និង **គ)** ដូចអ្នកបានឃើញនៅខាងលើ។

## ពាក្យណែនាំសម្រាប់ការសិក្សា

១. សូមញែកពេលស្ងាត់ស្ងៀម និងពេលវេលាទៀងទាត់សម្រាប់ការសិក្សារបស់អ្នក។ វានឹងងាយស្រួលផ្ចង់អារម្មណ៍ជាង ប្រសិនបើការសិក្សារបស់អ្នក ជាផ្នែកមួយនៃទម្លាប់ប្រចាំថ្ងៃនោះ។

២. សូមអធិស្ឋាននៅពេលដែលអ្នកសិក្សាមេរៀននីមួយៗ ដោយបើកព្រះគម្ពីរ ព្រមទាំងមានព្រះវិញ្ញាណដ៏វិសុទ្ធគង់នៅជាមួយ ហើយតាមរយៈមុខវិជ្ជានេះ អ្នកកំពុងតែស្ថិតនៅក្នុងថ្នាក់រៀនរបស់ព្រះវិញ្ញាណដ៏វិសុទ្ធ។ ចូរទូលសូមព្រះអម្ចាស់ ដើម្បីជួយឱ្យអ្នកយល់មេរៀននេះ និងអនុវត្តវា នៅក្នុងជីវិតរបស់អ្នក ។

៣. សូមអានសេចក្តីផ្តើមនៃមេរៀន គម្រោងមេរៀន និងគោលដៅដោយយកចិត្តទុកដាក់។

៤. សូមចាប់ផ្តើមអានមេរៀនដោយយកចិត្តទុកដាក់។ សូមមើលខគម្ពីរយោង និងសរសេរកំណត់ត្រាដែលអាចមានប្រយោជន៍។ ខគម្ពីរជួយធ្វើឱ្យចំណុចសំខាន់ក្នុងមេរៀននេះ កាន់តែមានប្រសិទ្ធភាព។

៥. ចូរឆ្លើយសំណួរសិក្សា នៅក្នុងចន្លោះដែលបានដាក់ជូន។ សូមប្រើសៀវភៅសរសេរ ឬសៀវភៅកត់ត្រាផ្ទាល់ខ្លួនរបស់អ្នកនៅពេលចាំបាច់។

៦. សូមគិតអំពីអ្វីដែលអ្នកបានរៀនរួចហើយ និងស្វែងរកវិធីដើម្បីអនុវត្តវា នៅក្នុងការពិភាក្សាជាមួយគ្រួសារ និងមិត្តភ័ក្តិ នៅក្នុងការសិក្សាព្រះគម្ពីរ ឬក្នុងឱកាសណាមួយ។

៧. សូមរៀនតាមសម្រួល។ គ្មានកណ្តឹងណានឹងរោទ៍ ដើម្បីបង្ខំអ្នកឱ្យសិក្សាមេរៀនថ្មីនោះឡើយ។

## ការវាយតម្លៃតាមជំពូក

នៅចុងបញ្ចប់នៃមុខវិជ្ជានេះ អ្នកនឹងឃើញ**ការវាយតម្លៃតាមជំពូក។ ក្រដាសសំណួរចម្លើយ**ត្រូវបានដាក់សញ្ញាសម្គាល់យ៉ាងច្បាស់ សម្រាប់ជំពូកនីមួយៗ។ សូមធ្វើតាមការណែនាំ ដែលបានដាក់ជូនដោយប្រុងប្រយ័ត្ន។ អ្នកត្រូវតែបំពេញ ហើយផ្ញើក្រដាសចម្លើយរបស់អ្នកទៅកាន់គ្រូបង្រៀនរបស់អ្នកសម្រាប់ការកែតម្រូវ។ ប្រសិនបើអ្នកមិនបានសិក្សាជាមួយសាកលវិទ្យាល័យគ្លូបល ( Global University) ទេនោះ អ្នកនៅតែទទួលបានផលប្រយោជន៍តាមរយៈការបំពេញការវាយតម្លៃតាមជំពូកដដែល។

## របៀបសិក្សាមុខវិជ្ជានេះ

មុខវិជ្ជានេះត្រូវបានសរសេរឡើង ដើម្បីឱ្យអ្នកអាចសិក្សាវាដោយខ្លួនឯងបាន។ យើងចូលចិត្តនិយាយថា គ្រូបង្រៀនគឺនៅក្នុងសៀវភៅនេះ។ ប៉ុន្តែ អ្នកក៏អាចសិក្សាមុខវិជ្ជានេះជាក្រុម ដូចជាក្រុមសិក្សាព្រះគម្ពីរតាមសប្តាហ៍ មជ្ឈមណ្ឌលសិក្សា ក្រុមតាមផ្ទះ និងកម្មវិធីយុវជន។ មុខវិជ្ជានេះ អាចត្រូវបានប្រើដើម្បីជាការទំនាក់ទំនង ឬជាធនធានសម្រាប់ព័ន្ធកិច្ចពន្ធនាគារ ក៏ដូចជាក្រុមជនជាតិភាគតិច ឬសហគមន៍ផ្សេងទៀតតាមរយៈកម្មវិធីនេះផងដែរ។ អ្នកនឹងឃើញថា ទាំងមាតិកា ទាំងវិធីសាស្ត្រនៃការសិក្សាល្អប្រសើរសម្រាប់គោលបំណងទាំងនេះ ។

ប្រសិនបើអ្នកសិក្សាមុខវិជ្ជានេះដោយខ្លួនឯង អ្នកអាចបំពេញកិច្ចការទាំងអស់របស់អ្នកតាមរយៈប្រៃសណីយ៍។ សូមកុំភ្លេចប្រើអាសយដ្ឋាននៃការិយាល័យសាកលវិទ្យាល័យគ្លូបល (Global University) របស់អ្នក។ ប្រសិនបើអ្នកសិក្សាជាក្រុម ឬតាមរយៈមជ្ឈមណ្ឌលបណ្តុះបណ្តាលសិស្ស សូមឱ្យប្រាកដថា អ្នកធ្វើតាមមេរៀនបន្ថែមដែលគ្រូរបស់អ្នកបានដាក់ឱ្យ។

លើសពីនេះទៅទៀត ក្រុមជំនុំរបស់អ្នកអាចជាដៃគូជាមួយនឹងសកលវិទ្យាល័យគ្លូបល (Global University) ដើម្បីបើកមជ្ឈមណ្ឌលបណ្តុះបណ្តាលសិស្សថែមទៀតផង។ សូមចូលមើលគេហទំព័រ www.globaluniversity.edu សម្រាប់ព័ត៌មាន និងជំនួយបន្ថែម។

## វិញ្ញាបនបត្រ

វិញ្ញាបនបត្រជាក្រុម ឬផ្ទាល់ខ្លួនម្នាក់ៗ មានសម្រាប់សិស្សដែលបានបញ្ចប់មុខវិជ្ជារបស់យើងដោយជោគជ័យ។ ឧទាហរណ៍ ប្រសិនបើអ្នកកំពុងសិក្សាតាមរយៈការិយាល័យជាតិ ឬមជ្ឈមណ្ឌលបណ្តុះបណ្តាលសិស្ស អ្នកអាចទទួលវិញ្ញាបនបត្រពីគ្រូដែលមកពីសាកលវិទ្យាល័យគ្លូបល (Global University) បាន។ ប្រសិនបើអ្នកសិក្សាផ្ទាល់ខ្លួន អ្នកអាចផ្ញើក្រដាសការវាយតម្លៃតាមជំពូក ដែលអ្នកបានបំពេញចប់ទៅកាន់ការិយាល័យតាមតំបន់របស់អ្នក។ ការិយាល័យជាតិ និងមជ្ឈមណ្ឌលបណ្តុះបណ្តាលសិស្ស អាចទទួលវិញ្ញាបនបត្រតាមរយៈការិយាល័យអន្តរជាតិ ឬតាមរយៈ Gospel Publishing House ក្នុងសហរដ្ឋអាមេរិក។

## សម្រាប់ជំនួយបន្ថែម

បញ្ជីសៀវភៅសម្រាប់ The School for Evangelism and Discipleship (SED), Discipleship Training Center Manual, the Study Center Agreement Form ហើយនឹង SED Order Form អាចយកចេញពីអ៊ីនធឺណេតបាន។ សម្ភារសិក្សាផ្សេងៗដែលអាចរកបានសម្រាប់មុខវិជ្ជានេះ រួមបញ្ចូលទាំងកាសែត។

សូមចូលមើលគេហទំព័រ www.globaluniversity.edu និង www.globalreach.org សម្រាប់ជាធនធានបន្ថែម។

## អំពីអ្នកនិពន្ធ

លោក Donald Stuckless គឺជាព្រឹទ្ធបូជាចារ្យនៃនិកាយក្រុមជំនុំព្រះជាម្ចាស់ (Assemblies of God) ។ គាត់បម្រើជាបេសកជនអស់រយៈពេលប្រាំបីឆ្នាំ នៅក្នុងអំឡុងពេលនេះគាត់គឺជាសាស្ត្រាចារ្យនៅវិទ្យាស្ថានព្រះគម្ពីនៃក្រុមជំនុំព្រះជាម្ចាស់រនៅទីក្រុង Bogota ប្រទេស Colombia និង ទីក្រុង Panama ប្រទេស Panama។ បច្ចុប្បន្នគាត់គឺជាគ្រូគង្វាលមួយនៅក្រុមជំនុំនៅសហរដ្ឋអាមេរិក។

លោក Stuckless បានទទួលសញ្ញាបត្រ បរិញ្ញាបត្រពី Central Bible College នៅក្នុងទីក្រុង Springfield រដ្ឋ Missouri និង អនុបណ្ឌិតពី Trinity Evangelicial Divinity School នៅទីក្រុង Chicago។

# ជំពូក

# ១

## <u>មេរៀន</u>


១ គំនិតអំពីសហគមន៍ The Idea of Community

២ សហគមន៍គ្រិស្តបរិស័ទ The Christian’s Community

៣ ការរីកចម្រើននៅក្នុងសហគមន៍ Growing in Community

៤ ការប្រកាន់គោលជំហានៅក្នុងសហគមន៍ Standing in Community

៥ ការកសាងនៅក្នុងសហគមន៍ Building in Community

មេរៀនទី

# ១

# គំនិតអំពីសហគមន៍

The Idea of Community

ទារកម្នាក់ទើបនឹងកើតមកធ្វើឱ្យគ្រួសារមានអំណរ។ ញាតិជិតខាងនាំយកអាហារមកជូនគ្រួសារ ហើយមិត្តភក្តិមកលេងជួយមើលថែទាំសមាជិកថ្មីរបស់គ្រួសារនោះ។

ប្រហែលជាអ្នកមានបទពិសោធន៍សប្បាយដូចជាពេលនេះផងដែរ។ ជាការលើកទឹកចិត្តដ៏ល្អនៅពេលដែលមានអ្នកយកចិត្តទុកដាក់ដល់គ្រួសារទាំងមូលយ៉ាងដូចច្នេះ! នេះគឺបង្ហាញទឹកចិត្តដ៏ល្អ នៅក្នុងសហគមន៍ ។

នៅក្នុងមេរៀននេះអ្នកនឹងសិក្សាពីសារតា និងគោលការណ៍តាមព្រះគម្ពីរអំពីសហគមន៍។ ការបង្ហាញទឹកចិត្តដ៏ល្អនៅក្នុងសហគមន៍ គឺជាគោលការណ៍សំខាន់ដំបូងដែលបង្រៀននៅក្នុងក្រុមជំនុំដើម។ ជាគោលការណ៍របស់ព្រះគ្រិស្តដែលបានបង្រៀនដល់យើងឱ្យចេះស្រឡាញ់ និងយកចិត្តទុកដាក់ថែរក្សាគ្នាទៅវិញទៅមក។ នៅក្នុងមេរៀននេះនឹងជួយដល់អ្នក ដើម្បីឱ្យយល់ដឹងពីសហគមន៍។ បន្ទាប់មក អ្នកនឹងយល់យ៉ាងច្បាស់ពីការល្អអស្ចារ្យដែលអ្នកត្រូវធ្វើជាផ្នែកមួយនៃសហគមន៍គ្រិស្តបរិស័ទ។

នៅពេលដែលអ្នកសិក្សានៅក្នុងមេរៀននេះ ចូរទូលសូមដល់ព្រះវិញ្ញាណដ៏វិសុទ្ធ ដើម្បីបង្ហាញអ្នកពីរបៀបបង្ហាញដួងចិត្តនៃការយកចិត្តទុកដាក់នៅក្នុងសហគមន៍ រាល់ទង្វើទាំងអស់របស់អ្នកជាមួយអ្នកដទៃ។

## គម្រោង

ក. អត្ថន័យនៃពាក្យថា សហគមន៍ The Meaning of Community

ខ. ភាពពេញលេញរបស់សហគមន៍ The Completeness of Community

គ. មូលដ្ឋានគ្រឹះតាមព្រះគម្ពីរអំពីសហគមន៍ The Biblical Basis for Community

## គោលដៅ

១. ពន្យល់ពីអត្ថន័យនៃពាក្យ*សហគមន៍*។

២. បង្ហាញថាពីអ្វីដែលជាកត្តាតម្រូវដើម្បីធ្វើឱ្យសហគមន៍អាចទៅរួច។

៣. ចូរលើកឧទាហរណ៍ជាក់ស្តែងអំពីសហគមន៍ដែលមាននៅក្នុងព្រះគម្ពីរ។

## ក. អត្ថន័យនៃពាក្យថា សហគមន៍ The Meaning of Community

**គោលដៅទី១. កំណត់និយមន័យនៃពាក្យ *សហគមន៍*។**

នៅក្នុងភាសាអង់គ្លេសពាក្យថា *សហគមន៍* ជាទូទៅបញ្ជាក់ពីមនុស្សដែលមានគោលបំណងដូចគ្នាជាមួយនឹងអ្នកដែលរស់នៅកន្លែងជាក់លាក់មួយ។ ជាភាសាអេស្ប៉ាញពាក្យថា*កុំនីដាដ* មិនមែនបញ្ជាក់ទាក់ទងនឹងតំបន់ ឬទីកន្លែងដែលមនុស្សរស់នៅឡើយ។ ប៉ុន្តែ ជាការបញ្ជាក់ពីសេចក្តីស្រឡាញ់ និងការយកចិត្តទុកដាក់ដែលមនុស្សម្នាក់មានអារម្មណ៍ចំពោះគ្នាទៅវិញទៅមក។ នេះគឺជាពាក្យពេចន៍ដែលប្រើពិពណ៌នាអំពី ពាក្យថា*សហគមន៍*។

សហគមន៍ ក៏អាចប្រើ ដើម្បីពិពណ៌នាក្រុមមនុស្សមួយក្រុមដែលធ្វើការរួមគ្នា ដើម្បីបុព្វហេតុរួម។ ជាឧទាហរណ៍នៅក្នុងប្រទេសខ្លះមនុស្សធ្វើការដោយមានរចនាសម្ពន្ធនៃរបៀបធ្វើការដូចគ្នា ដូចជាសហព័ន្ធពាណិជ្ជកម្មមួយ ដើម្បីឱ្យជំនួញរបស់គេមានដំណើរការល្អ។ សហព័ន្ធពាណិជ្ជកម្មបង្កើតឡើងចេញពីសមាជិកនៅក្នុង*សហគមន៍*។

ផ្នែកទីពីរនៃព្រះគម្ពីរ គឺព្រះគម្ពីរសម្ពន្ធមេត្រីថ្មី ដែលបានសរសេរឡើងជាលើកដំបូងជាភាសាក្រិក។ ពាក្យភាសាក្រិក *កូអ៊ីណូនា* នៅក្នុងកណ្ឌគម្ពីរសម្ពន្ធមេត្រីថ្មីប្រាប់យើងពីគំនិតទាក់ទងនឹង*សហគមន៍*។ ជារឿយៗ ពាក្យថា *កូអ៊ីណូនា* បកប្រែថា «សេចក្តីប្រកបគ្នា» ឬក៏ «ភាពជាដៃគូ»។ គឺវាបញ្ជាក់អំពីចំណុចពាក់ព័ន្ធគ្នារវាងអ្វីមួយទៅនឹងអ្វីមួយទៀត។ វាបង្ហាញពីទំនាក់ទំនងតាមរបៀបចំនួនពីរយ៉ាងដែលបញ្ជាក់ពីការឱ្យនិងការទទួល។ *កូអ៊ីណូនា* ក៏បកប្រែថា «ការចូលរួម» «ពិធីជប់លៀងរបស់ព្រះអម្ចាស់» និង «ការចែករំលែក» ដែរ។ ពាក្យនេះប្រើសម្រាប់ទំនាក់ទំនងដែលស្និទ្ធស្នាលដូចជាទំនាក់ទំនងខាងអាពាហ៍ពិពាហ៍ ។

នេះជាឧទាហរណ៍អំពីរបៀបដែលពាក្យថាកូអ៊ីណូនាប្រើប្រាស់នៅក្នុងព្រះគម្ពីរ។ ចូរក្រលេកមើលទៅក្នុងព្រះគម្ពីរ និងអានដោយប្រុងប្រយ័ត្ន។

1. យ៉ូហាន ១២:៦-ព្រះយេស៊ូនិងពួកសាវ័កប្រើថង់ប្រាក់រួមគ្នា (ប្រាក់ដែលគេប្រើប្រាស់ចំណាយទៅលើការចាយវាប្រចាំថ្ងៃរបស់គេ)។

2. ១ កូរិនថូស១០:១៦-*ការចែករំលែក*នៅក្នុងព្រះលោហិតរបស់ព្រះគ្រិស្ត គឺយើងបានរួមចំណែកនៅក្នុងពិធីជប់លៀងព្រះអម្ចាស់។

3. ១ យ៉ូហាន១:៣,៦-៧-*សេចក្ដីប្រកប*រវាងអ្នកជឿនិងព្រះជាម្ចាស់ដ៏ជាព្រះបិតា និង ព្រះយេស៊ូគ្រិស្តដែលជាព្រះបុត្រារបស់ព្រះអង្គ។

4. ១ កូរិនថូស ១០:២០- *ភាពជាដៃគូ* ការព្រមានមិនឱ្យធ្វើ«ដៃគូជាមួយវិញ្ញាណអាក្រក់»។

5. រ៉ូម ១៥:២៦-ការដាក់ប្រាក់ដង្វាយ ឬ ឱ្យកាដូរជាប្រាក់ ដែលគ្រិស្តបរិស័ទ ក្រុងយេរូសាឡឹមធ្វើតាមគ្រិស្តបរិស័ទក្រិក។

នៅក្នុងសេចក្ដីយោងទាំងនេះ គំនិតទាក់ទងនឹងការចែករំលែក ការប្រកបគ្នា និង ការចូលរួមត្រូវបានលើកយកមកនិយាយ ។ នេះគឺជាការពន្យល់ដ៏ល្អអំពី*សហគមន៍។*

## លំហាត់អនុវត្តន៍

---

១ ចូរគូសរង្វង់ពីមុខពាក្យដែលពិពណ៌នា ពីពាក្យថា *កូអ៊ីណូនា* ឬ ក៏សហគមន៍

ក) ការដាក់ដង្វាយ

ខ) បំណងចិត្ត

គ) ដៃគូ

ឃ) ការប្រកបគ្នា

ង) គ្រប់គ្រង

ច) ចែកចាយ

ចូរពិនិត្យមើលចម្លើយដែលផ្ដល់ជូននៅខាងក្រោយមេរៀន។

## ខ. ភាពពេញលេញរបស់សហគមន៍ The Completeness of Community

គោលដៅទី ២. បង្ហាញពីអ្វីដែលជាកត្តាតម្រូវដើម្បីធ្វើឱ្យសហគមន៍អាចទៅរួចៗ

យើងទាំងអស់គ្នាភាគច្រើនយល់ពីគំនិតសំខាន់ៗទាំងនេះ។ យើងយល់អំពីគំនិតសំខាន់ទាក់ទងនឹងការធ្វើស្រែចំការ ពីព្រោះយើងត្រូវការអាហារ។ ដើម្បីឱ្យគ្រាប់ពូជដាំបានដុះល្អគេត្រូវរៀបចំធ្វើដីជាមុនសិន។ នៅតាមប្រទេសមួយចំនួនមនុស្ស ប្រើចប ដើម្បីរៀបចំដីឱ្យបានល្អ។ នៅតាមប្រទេសមួយចំនួនទៀតគេប្រើគោដើម្បីភ្ជួរដី។ នៅកន្លែងមួយចំនួនទៀតគេប្រើត្រាក់ទ័រដើម្បីភ្ជួររាស់ដី។ ប៉ុន្តែ គំនិតសំខាន់ទាក់ទងនឹងការភ្ជួររាស់ដី គឺដូចគ្នាការច្រូយដីនិងលប់ដីគឺជាការដែលធ្វើឱ្យគ្រាប់ពូជកប់ចូលក្នុងដីនិងធ្វើឱ្យទឹកភ្លៀងអាចធ្វើឱ្យគ្រាប់ពូជដុះឡើងបាន។ បន្ទាប់មក ត្រូវខិតខំថែរក្សាដីឱ្យល្អដោយបោចស្មៅចេញដើម្បីឱ្យដើមដុះឡើង។ បន្ទាប់មក នៅពេលដែលដើមដុះឡើង ឬក៏មានផ្លែទុំហើយគេធ្វើការ ច្រូតកាត់ប្រមូលផល។

គំនិតមូលដ្ឋាននៃការភ្ជួររាស់ ដាំ រង់ចាំ និងប្រមូលផលមានដូចគ្នានៅតាមប្រទេសនីមួយៗនេះ។ វិធីសាស្ត្រប្រហែលជាមិនដូចគ្នាទេ ប៉ុន្តែ លទ្ធផលគឺដូចគ្នា ។

យើងអាចនិយាយដូចគ្នាដែរទាក់ទងនឹង*ការគិតអំពីសហគមន៍*។ វាមិនមានលក្ខណៈខុសគ្នាទេ ទោះបីអ្នករស់នៅក្នុងក្រុមគ្រួសារដែលមានគ្នាតិច ឬនៅក្នុងទីក្រុងដ៏ធំក៏ដោយ។ គំនិតសំខាន់អំពីសហគមន៍នោះមានលក្ខណៈដូចគ្នា។ សហគមន៍គឺមនុស្សរស់នៅជាមួយនឹងមនុស្ស។ សហគមន៍អាចកើតឡើងបាននៅកន្លែងដែលមានមនុស្ស៥០០០នាក់រស់នៅជាមួយគ្នា ឬ កន្លែងដែលមានមនុស្សតែពីរនាក់រស់នៅជាមួយគ្នា។

ការរស់នៅជាសហគមន៍ បញ្ជាក់ពីការយកចិត្តទុកដាក់។ ព្រះយេស៊ូមានព្រះបន្ទូលអំពីបុរសម្នាក់ឈ្មោះលោកឡាសានិងបុរសអ្នកមាន (លូកា ១៦:១៩-៣១)។ មិនមានការបង្ហាញណាមួយថាបុរសអ្នកមានធ្វើអំពើឃោរឃៅដាក់លើឡាសាឡើយ។ គាត់គ្រាន់តែមិនយកចិត្តទុកដាក់លើឡាសា ឬ ស្ថានភាពរបស់លោកប៉ុណ្ណោះ។ នៅក្នុងរឿងនេះបុរសអ្នកមានដែលមិនបានយកចិត្តទុកដាក់នឹងលោកឡាសាដែលបានស្លាប់ ហើយទៅស្ថាននរក ពីព្រោះតែគាត់មិនបានទទួលសេចក្ដីពិតអំពីព្រះជាម្ចាស់នៅពេលដែលគាត់នៅរស់។ ព្រះជាម្ចាស់បានបង្រៀនយើងឱ្យយកចិត្តទុកដាក់ជាមួយអ្នកដទៃ។

ព្រះយេស៊ូបានមានព្រះបន្ទូលអំពីបុរសយូដាដែលត្រូវចោរប្លន់និងវាយធ្វើបាបយ៉ាងដំណំ។ គាត់ត្រូវបានគេទុកចោលឱ្យស្លាប់នៅតាមផ្លូវ (លូកា ១០:៣០-៣៧)។ មានអ្នកកាន់សាសនាដ៏មុតមាំចំនួនពីនាក់បានដើរកាត់ ប៉ុន្តែ គេមិនបានយកចិត្តទុកដាក់នឹងបុរសដែលរងរបួសនោះទេ។ នៅទីបំផុតមានបុរសសាសន៍សាម៉ារីម្នាក់ដើរកាត់តាមផ្លូវនោះ។ តាមប្រពៃណីសាសន៍យូដា និង សាសន៍សាម៉ារីមិនមានទំនាក់ទំនងជាមួយគ្នាទេ។ ប៉ុន្តែ នៅភ្លាមនោះ ស្រាប់តែសាសន៍សាម៉ារីបានឈប់ និងរុំរបួសឱ្យបុរសសាសន៍យូដា និងដាក់គាត់នៅលើខ្នងលាព្រមទាំងយកទៅផ្ទះសំណាក់ផងដែរ។ គាត់បានប្រាប់ដល់ម្ចាស់ផ្ទះសំណាក់ឱ្យថែរក្សាបុរសនោះ គាត់ថែមទាំងចំណាយលើការថែរក្សាដល់បុរសម្នាក់នេះ។ នេះគឺជាគំរូនៃការប្រព្រឹត្តចេញពីដួងចិត្តដ៏ល្អនៅក្នុងសហគមន៍។

សេចក្តីស្រឡាញ់និងការយកចិត្តទុកដាក់ គឺជាដួងចិត្តដ៏ល្អនៅក្នុងសហគមន៍។ ការយកចិត្តទុកដាក់ គឺជាការថែរក្សាអ្នកដទៃ។ យើងត្រូវតែយកចិត្តទុកដាក់ជាមួយមនុស្សដែលនៅជុំវិញយើងក៏ដូចជាការយកចិត្តទុកដាក់ទូទាំងសាកលលោកទាំងមូល ឬក៏ពាសពេញពិភពលោកសម្រាប់អ្នកដែលរស់ផ្នែកផ្សេងៗទៀតនៃពិភពលោក។ ព្រះយេស៊ូមានព្រះបន្ទូល «បើអ្នកស្រឡាញ់គ្នាទៅវិញទៅមក មនុស្សទាំងអស់មុខជាដឹងថា អ្នករាល់គ្នាពិតជាសិស្សរបស់ខ្ញុំមែន»។

**លំហាត់អនុវត្តន៍**

---

២ សូមអានក្នុងព្រះគម្ពីរពីសាច់រឿងរបស់លោកឡាសា (លូកា ១៦:១៩-៣១) និង សាសន៍សាម៉ារីចិត្តល្អ (លូកា ១០:៣០-៣៧)។ ចូរគូសរង្វង់ពីមុខឧទាហរណ៍ដែលបង្ហាញអំពីដួងចិត្តដ៏ល្អនៅក្នុងសហគមន៍។

ក) រឿងឡាសា និង បុរសអ្នកមាន។

ខ) រឿង សាសន៍សាម៉ារីចិត្តល្អ។

៣ តើរឿងនេះបង្ហាញពីអាកប្បកិរិយាផ្សេងគ្នាយ៉ាងដូចម្តេចខ្លះ?

........................................................................................................................................................

៤ ចូរគូសរង្វង់ពីមុខអក្សរដែលទាក់ទងនឹង គំនិតអំពីសហគមន៍

ក) នៅក្នុងទីក្រុងដ៏ធំ

ខ) នៅភូមិដាច់ស្រយាល

គ) នៅក្នុងក្រុមតូចមួយ

ឃ) ទីកន្លែងដែលសិស្សរស់នៅម្នាក់ឯង

ង) រវាងមនុស្សពីរនាក់

ចូរត្រួតពិនិត្យមើលចម្លើយរបស់អ្នក ។

## គ. មូលដ្ឋានគ្រឹះតាមព្រះគម្ពីរអំពីសហគមន៍ The Biblical Basis For Community

**គោលដៅទី៣. ចូរលើកឧទាហរណ៍ជាក់ស្តែងអំពីសហគមន៍ដែលមាននៅក្នុងព្រះគម្ពីរ។**

ការលើកឡើងពីឧទាហរណ៍ខាងដើមអំពីក្រុមជំនុំត្រូវបានរកឃើញនៅក្នុងកណ្ឌដំបូងនៅក្នុងលោកុប្បត្តិជំពូក២ និងជំពូក៣។ នៅត្រង់នេះគឺនិយាយអំពីដំណើររឿងនៃកំណើតពិភពលោករបស់មនុស្សដំបូង គឺលោកអដាំ។ សហគមន៍នៅពេលនោះ គឺមានតែអដាំ និងព្រះជាម្ចាស់តែប៉ុណ្ណោះ។ ដោយព្រោះ តែលោកអដាំគ្មានអំពើបាបទាល់តែសោះ ភាពស្និទ្ធស្នាល និងការ ប្រកបរបស់គាត់ (Koinonia) ជាមួយព្រះជាម្ចាស់គឺមានទំនាក់ទំនងលក្ខណៈផ្ទាល់ខ្លួន។ ជារៀងរាល់

ថ្ងៃគាត់និយាយជាមួយព្រះជាម្ចាស់ និងចែកចាយជាមួយព្រះជាម្ចាស់ទៅវិញទៅមក។ ហេតុដូច្នេះហើយ ទើបយើងអាចនិយាយបានថាព្រះជាម្ចាស់ និង លោកអដាំជា*សហគមន៍*មួយ។

នៅក្នុងរយៈពេលដ៏ខ្លីមួយព្រះជាម្ចាស់បានប្រទានភរិយាម្នាក់ឱ្យអដាំ ហើយអដាំបានហៅនាងថាជា*ស្ត្រី* (លោកុប្បត្តិ ២:២៣)។ ឥឡូវនេះ សហគន៍អាចកើតមានទៅបានតាមរយៈបុគ្គលពីរនាក់។ លោកអដាំ និងនាងអេវ៉ារស់នៅយ៉ាងចុះសម្រុងជាមួយគ្នា។ ពួកគាត់រស់នៅប្រកបគ្នាយ៉ាងស្និទ្ធស្នាលជាមួយព្រះជាម្ចាស់និងអ្វីៗដែលព្រះជាម្ចាស់បង្កើតមក។ របៀបបីយ៉ាងនៅក្នុងសហគមន៍មានអត្ថិភាពឡើង។ នេះគឺទឹកដីនៃ សហគមន៍ដ៏គ្រប់លក្ខណ៍!

ប៉ុន្តែ ទឹកដីនៃសហគមន៍នេះមិនបានបន្តគ្រប់លក្ខណ៍រហូតឡើយពីព្រោះអំពើបាបបានចូលមកក្នុងសហគមន៍ភាពគ្រប់លក្ខណ៍របស់សហគមន៍ត្រូវបានបាក់បែកដោយសារលោកអដាំនិងនាងអេវ៉ាមិនបានគោរពស្តាប់បង្គាប់ព្រះជាម្ចាស់ (លោកុប្បត្តិ៣)។ ជាលទ្ធផលនៃអំពើបាបរបស់ពួកគេអាដាំនិងនាងអេវ៉ាត្រូវបានបណ្តេញចេញពីសហគមន៍ដ៏គ្រប់លក្ខណ៍ និង ត្រូវបានញែកចេញពីព្រះជាម្ចាស់។

ដំណើរកូនចៅអ៊ីស្រាអែលវង្វេងនៅវាលរហោស្ថាន ជាឧទាហរណ៍ផ្សេងទៀតអំពីសហគមន៍។ វាមានកត់ត្រានៅក្នុងព្រះគម្ពីរចាប់ផ្តើមនៅក្នុងជំពូក៣នៃកណ្ឌគម្ពីរនិក្ខមនំ។ អស់រយៈពេល៤០ឆ្នាំដែលជនជាតិអ៊ីស្រាអែលធ្វើដំណើរពីទឹកដីអេស៊ីបដែលពួកគេបានជាប់ជាឈ្លើយ ហើយមានសេរីភាពនៅក្នុងទឹកដីសន្យា។ នៅក្នុងអំឡុងពេលនេះ គេមានការត្រាច់ចរដោយគ្មានផ្ទះពិតប្រាកដស្នាក់នៅឡើយ។ នៅពេលដែលគេធ្វើដំណើរពីកន្លែងមួយទៅកន្លែងមួយគេរស់នៅក្នុងដួងចិត្តជាសហគមន៍។ និក្ខមនំ១៧បានសរសេរថា «សហគមន៍អ៊ីស្រាអែលទាំងមូលចាកចេញពីវាលរហោស្ថាននៃអំពើបាប» អ៊ីស្រាអែលជាសហគមន៍ប្រជាជាតិពីព្រោះសហគមន៍គឺនិយាយអំពីការចែលរំលែកសេចក្តីស្រឡាញ់ និងទំនាក់ទំនងដែលមានរវាងមនុស្សនិងមនុស្ស។  នៅពេលដែលអានរឿងរ៉ាវនៅក្នុងកណ្ឌគម្ពីរនិក្ខមនំចប់អ្នកនឹងឃើញថាជនជាតិអ៊ីស្រាអែលចែករំលែកទាំងស្ថានការណ៍លំបាក និងជ័យជម្នះជាមួយគ្នា។

យើងបានអាននៅក្នុងនិក្ខមនំជំពូក២០ដឹងថាព្រះជាម្ចាស់បានប្រទានបទបញ្ញត្តិចំនួន១០ប្រកាដល់ជនជាតិអ៊ីស្រាអែល។ បញ្ញាត្តិទាំងនេះគឺបង្ហាញដល់ពួកគេឱ្យចេះរស់នៅក្នុងសហគមន៍។បទបញ្ញត្តិទាំង១០ប្រការជាបទបញ្ញត្តិរបស់ព្រះជាម្ចាស់ដែលមិនអាចឱ្យនរណាម្នាក់បំពានបានឡើយ។ បទបញ្ញត្តិបានបង្រៀនដល់យើងថាយើងត្រូវស្រឡាញ់ដល់ព្រះជាម្ចាស់ជាទីមួយ បន្ទាប់មកត្រូវស្រឡាញ់ដល់អ្នកឯទៀត។ នេះគឺជាបញ្ញាត្តិក្នុងចំណោមច្បាប់ជាច្រើនដែលបានបង្រៀនយើងតាំងពីមុនមកទាក់ទងនឹងការរស់នៅជាសហគមន៍។ ព្រះជាម្ចាស់បានមានព្រះបន្ទូលថា «ការគោរពតាមបទបញ្ញត្តិទាំងនេះនឹងធ្វើឱ្យ អ្នករស់នៅក្នុងសហគមន៍មួយដែលគ្រប់លក្ខណ៍»។

បន្ថែមទៅលើបទបញ្ញត្តិទាំងដប់ប្រការ ព្រះជាម្ចាស់បានប្រទាននូវសេចក្តីបង្រៀនជាច្រើនទៀតដែលអាចជួយដល់ប្រជាជាតិអ៊ីស្រាអែលឱ្យចេះរស់នៅក្នុងសហគមន៍។ មានបញ្ញាត្តិអំពី អាសនៈ ការថ្វាយយញ្ញបូជា ពិធីបុណ្យ ទំលាប់នៃការបរិភោគអាហារ និងអាកប្បកិរិយាប្រព្រឹត្តចំពោះអ្នកដំទៃ។ បទបញ្ញត្តិទាំងនេះបានប្រទានមកមនុស្សឱ្យចេះរស់នៅដើម្បី

លះបង់ថ្វាយព្រះជាម្ចាស់និងមានដួចចិត្តជាសហគមន៍-ការប្រកបជាមួយគ្នាសេចក្តីស្រឡាញ់និងការយកចិត្តទុកដាក់គ្នាទៅវិញទៅមក។

ឥឡូវនេះចូរក្រឡេកមើលគំរូនៃសហគមន៍នៅគម្ពីរសញ្ញាថ្មី។ នៅក្នុងក្រុមជំនុំដំបូងបន្ទាប់ពីព្រះវិញ្ញាណរបស់ព្រះជាម្ចាស់បានចាក់បង្ហូរព្រះវិញ្ញាណនៅថ្ងៃបុណ្យទីហាសិបមកការរួបរួមដ៏រឹងមាំខាងវិញ្ញាណនិងសហគមន៍បានកើតមានឡើង។ សូមអាននៅក្នុងកណ្ឌគម្ពីរកិច្ចការ ២:៤៣-៤៧។ ខទី៤៤បានសរសេរថាប្រជាជនទាំងនេះ«មានការប្រកបគ្នាយ៉ាងស្និទ្ធស្នាល» និង «ចែករំលែកអ្វីដែលគេមាន»។ ឥឡូវនេះ ចូរគិតត្រឡប់ទៅវិញអំពីនិយមន័យរបស់សហគមន៍។ ពាក្យទាំងនេះបង្ហាញយើងថា «ស្រឡាញ់និងយកចិត្តទុកដាក់» និង «មានការប្រកបគ្នាយ៉ាងស្និទ្ធស្នាល» មានបង្ហាញនៅក្នុងក្រុមជំនុំដំបូងក្រុមជំនុំនៅក្នុងកណ្ឌគម្ពីរសម្ពន្ធមេត្រីថ្មី ជាក្រុមជំនុំសហគមន៍ពីព្រោះគេរស់នៅដោយយកចិត្តទុកដាក់ ព្រមទាំងថែរក្សាគ្នា  សូមឱ្យយើងធ្វើកិច្ចការទាំងនេះផងដែរ។

## លំហាត់អនុវត្តន៍

៥ ចូរគូសរង្វង់នៅខាងមុខប្រយោគដែលត្រឹមត្រូវ។

ក) បទបញ្ញត្តិដប់ប្រការ គឺជាច្បាប់ដំបូង១ក្នុងចំណោមច្បាប់ជាច្រើនដែលកំណត់សម្រាប់ការរស់នៅក្នុងសហគមន៍

ខ) ប្រជាជនអ៊ីស្រាអែលមិនអាចរស់នៅដោយមានដួងចិត្តតែមួយជាសហគមន៍ឡើយ នៅពេលដែលរស់នៅក្នុងវាលរហោស្ថាននោះ ពីព្រោះពួកគេមិនទាន់មានផ្ទះពិតប្រាកដ។

គ) លោកអដាំ និង នាងអេវ៉ា រស់នៅជាសហគមន៍ដ៏គ្រប់លក្ខណ៍ជាមួយព្រះជាម្ចាស់ជាមួយគ្នាទៅវិញទៅមក និង ជាមួយអ្វីៗដែលព្រះជាម្ចាស់បង្កើតរហូតដល់គេធ្លាក់ចូលក្នុងអំពើបាប។

ឃ)  យើងដឹងថាសហគមន៍មានតាំងពីក្រុមជំនុំដំបូងដោយសារ គ្រិស្តបរិស័ទមានក្តីស្រឡាញ់ និង យកចិត្តទុកដាក់គ្នាទៅវិញទៅមក។

៦ ចូរសរសេរពីទឹកចិត្តរស់នៅជាសហគមន៍តាមបួនយ៉ាង ដែលឃើញនៅក្នុងឧទាហរណ៍ដែលយើងបានសិក្សានៅក្នុងផ្នែកនេះ។

……………………………………………………………………………………………………

……………………………………………………………………………………………………

៧ តើមេរៀននេះប្រាប់អ្នកយ៉ាងដូចម្តេចខ្លះអំពី របៀបដែលអ្នកអាចរស់នៅដោយមានទឹកចិត្តជាសហគមន៍?

……………………………………………………………………………………………………

……………………………………………………………………………………………………

ប្រសិនបើអ្នកជាគ្រិស្តបរិស័ទ អ្នកគឺជាផ្នែកមួយនៃសហគមន៍អ្នកជឿដ៏អស្ចារ្យរបស់ព្រះជាម្ចាស់។ តើអ្នកត្រូវយកចិត្តទុកដាក់ដល់សមាជិកដទៃទៀតនៅក្នុងសហគមន៍ ដែរឬទេ? តើអ្នកត្រូវចែកចាយជាមួយអ្នកដែលខ្វះខាតដែរឬទេ? នេះគឺជាអត្ថន័យពិតប្រាកដនៃសហគមន៍។

# សូមផ្ទៀងចម្លើយរបស់អ្នក

ចម្លើយសម្រាប់លំហាត់នៃការសិក្សារបស់អ្នកមិនបានផ្តល់ជូនតាមលំដាប់លំដោយទេ ដើម្បីមិនឱ្យអ្នកងាយស្រួលមើលចម្លើយនៃសំណួរបន្ទាប់របស់អ្នក។ សូមមើល តែចម្លើយដែលអ្នកត្រូវការ កុំមើលរំលងឡើយ។

៤ ក) នៅក្នុងទីក្រុងដ៏ធំ
ខ) នៅភូមិដាច់ស្រយាល
គ) នៅក្នុងក្រុមតូចមួយ
ង) រវាងមនុស្សពីរនាក់

១ ក) ការដាក់ប្រាក់ដង្វាយ
គ) ដៃគូ
ឃ) ការប្រកបគ្នា
ច) ចែកចាយ

៥ ប្រយោគ ក គ និង ឃ ជាប្រយោគត្រឹមត្រូវ

២ ខ) រឿង សាសន៍សាម៉ារីចិត្តល្អ។

៦ ចំណុចទាំងនេះមួយណាក៏បាន៖ ការចែករំលែកឬការចែកចាយ ការប្រកបគ្នា ការបង្ហាញ សេចក្តីស្រឡាញ់ និង ការយកចិត្តទុកដាក់  ការបង្ហាញការឱ្យតម្លៃ ការថែរក្សា។

៣ សេចក្តីស្រឡាញ់ ឬ ការយកចិត្តទុកដាក់

៧ ចម្លើយរបស់អ្នក។

# មេរៀនទី ២

# សហគមន៍គ្រិស្តបរិស័ទ

## The Christian's Community

មេភូមិ គឺជាអ្នកដឹកនាំនៅភូមិមួយ។ មេឃុំគឺជាអ្នកដឹកនាំនៅក្នុងឃុំមួយ។ ប៉ូលីសធ្វើការតាមច្បាប់និងនៅតាមតំបន់នីមួយៗ។ មេភូមិ និង មេឃុំ មិនអាចនិយាយអំពីកិច្ចការរបស់ភូមិ ឬ ឃុំដទៃឡើយ។ ប៉ូលីសមិនអាចអនុវត្តច្បាប់ក្រៅពីតំបន់របស់គាត់គ្រប់គ្រងដែរ។ គ្រប់កិច្ចការទាំងអស់នេះ មានព្រំដែនកំណត់។ ពួកគេមិនមានសិទ្ធអំណាចក្រៅពីតំបន់របស់គេឡើយ។

វាមានភាពខុសប្លែកគ្នាសម្រាប់គ្រិស្តបរិស័ទ។ នៅក្នុងកណ្ឌគម្ពីរម៉ាថាយ ២៨:១៩-២០ ព្រះយេស៊ូមានព្រះបន្ទូលទៅកាន់ សាវ័ករបស់ព្រះអង្គ «ដូច្នេះចូរចេញទៅនាំមនុស្សគ្រប់ជាតិសាសន៍ឱ្យធ្វើជាសិស្ស» បទបញ្ជានេះគឺសម្រាប់ពួកយើងទាំងអស់គ្នាផងដែរ។ ការងាររបស់ពួកយើងមិនមានដែនកំណត់នោះឡើយ។ ព្រះយេស៊ូចាត់ឱ្យយើងចេញទៅគ្រប់ទីកន្លែង ដែលរាប់បញ្ចូលមនុស្សគ្រប់ទីកន្លែងទាំងអស់!

នៅក្នុងមេរៀនទីមួយ យើងបានសិក្សាអំពីដួងចិត្តរបស់មនុស្សនៅក្នុងសហគមន៍។ នៅក្នុងមេរៀននេះ អ្នកនឹងសិក្សាថាតើអ្នកត្រូវបង្ហាញដួងចិត្តសហគមន៍នេះយ៉ាងដូចម្ដេច? ប៉ុន្តែនៅខណៈពេលដែលអ្នកសិក្សា សហគមន៍គឺជា *ក្រុមនៃមនុស្ស* មិនមែនមានន័យថាជា *ទីកន្លែងឡើយ*។ មិនថាកន្លែងណាដែលអ្នកទៅនោះទេអ្នក ជាផ្នែកមួយនៃសហគមន៍ក្នុងការចែកចាយពីព្រះគ្រិស្តជាមួយអ្នកដទៃ។

## គម្រោង

សហគមន៍ចំនួនបួនក្នុងកណ្ឌគម្ពីរកិច្ចការ ១:៨

## គោលដៅ

កំណត់ និងពិពណ៌នាពីសហគមន៍ចំនួនបួនក្នុងកណ្ឌគម្ពីរកិច្ចការ ១:៨

# សហគមន៍បួនក្នុងកណ្ឌគម្ពីរកិច្ចការ ១:៨ The Four Communities of Acts 1:8

**គោលដៅទី១. កំណត់ និងពិពណ៌នាពីសហគមន៍បួននៅក្នុងកណ្ឌគម្ពីរកិច្ចការ ១:៨។**

> ប៉ុន្តែ អ្នករាល់គ្នានឹងទទួលឫទ្ធានុភាពមួយ គឺឫទ្ធានុភាពនៃព្រះវិញ្ញាណដ៏វិសុទ្ធមកសណ្ឋិតលើអ្នករាល់គ្នា។ អ្នករាល់គ្នានឹងធ្វើជាបន្ទាល់របស់ខ្ញុំ នៅក្នុងក្រុងយេរូសាឡឹម ក្នុងស្រុកយូដាទាំងមូល ក្នុងស្រុកសាម៉ារី និង រហូតដល់ស្រុកដាច់ស្រយាលនៃផែនដី» (កិច្ចការ ១:៨)។

ខគម្ពីរដែលបានដកស្រង់ខាងលើ ព្រះយេស៊ូមានព្រះបន្ទូលអំពីអ្នកដើរតាមព្រះអង្គ។ ទ្រង់ប្រាប់ពួកគេឱ្យរង់ចាំនៅក្រុងយេរូសាឡឹមដើម្បីទទួលឫទ្ធានុភាពរបស់ព្រះវិញ្ញាណដ៏វិសុទ្ធ។ ទ្រង់មានព្រះបន្ទូលថាបន្ទាប់ពីពួកគេទទួលឫទ្ធានុភាពនេះ ពួកគេនឹងក្លាយទៅជាស្មរបន្ទាល់។

ស្មរបន្ទាល់ជាអ្នកដែលបានឃើញពីព្រឹត្តិការណ៍និងព្រមទាំងប្រាប់ពីអ្វីដែលគេបានឃើញ។ ព្រះយេស៊ូសព្វព្រះហឫទ័យឱ្យអស់អ្នកដើរតាមព្រះអង្គប្រាប់មនុស្សដទៃទៀតអំពីកិច្ចការដ៏អស្ចារ្យដែលពួកគេបានឃើញព្រះអង្គធ្វើដូចជាទ្រង់ព្យាបាលអ្នកជំងឺ ប្រោសមនុស្សស្លាប់ឱ្យរស់ឡើងវិញ សុគតសម្រាប់អ្នកមានបាបនៅផែនដីនេះ រស់ពីការសោយទិវង្គតឡើងវិញនិង ជាចុងក្រោយព្រះអង្គបានយាងទៅស្ថានបរមសុខវិញ។ សាវ័កជាស្មរបន្ទាល់សាក្សីអំពីកិច្ចការទាំងអស់នេះ ជាដំបូងគេត្រូវចាប់ផ្តើមនៅក្រុងយេរូសាឡឹម បន្ទាប់មកចាប់ពីស្រុកយូដា ដល់សាម៉ារី និង កន្លែងផ្សេងទៀត រហូតទាល់តែគេបានប្រាប់មនុស្សទាំងអស់ទូទាំងពិភពលោក។ព្រះយេស៊ូមិនបានដាក់ដែនកំណត់សម្រាប់ការធ្វើស្មរបន្ទាល់របស់ពួកគេនោះទេ។

### លំហាត់អនុវត្តន៍

១ សេចក្តីបង្រៀនរបស់ព្រះយេស៊ូនៅក្នុងកណ្ឌគម្ពីរម៉ាថាយ ២៨:១៩-២០។ គឺធំជាងអ្វីដែលបានប្រគល់ដល់មេភូមិ មេឃុំ និង ប៉ូលីស ពីព្រោះ

ក) មានព្រំដែនកំណត់

ខ) មិនមានព្រំដែនកំណត់

២ ដួងចិត្តរស់នៅជាសហគមន៍ល្អដែលសិក្សានៅក្នុងមេរៀនទីមួយ អាចរកឃើញបាននៅ

ក) គ្រប់ទីកន្លែង

ខ) មានតែនៅកន្លែងជាក់លាក់ណាមួយប៉ុណ្ណោះ។

៣ សូមអានកិច្ចការ ១:៨ ម្តងទៀត បន្ទាប់មកកត់ត្រាពីទីកន្លែងដែលព្រះយេស៊ូចាត់ឱ្យពួកសាវ័កចេញទៅធ្វើជាបន្ទាល់

..................................................................................................................................

..................................................................................................................................

## ក្រុងយេរូសាឡឹម ជាពិភពផ្ទាល់ខ្លួនរបស់អ្នក Jerusalem—Your Personal World

វាពិតជាមានសារសំខាន់ណាស់ក្នុងការយល់ខគម្ពីរកិច្ចការ ១:៨។ ព្រះយេស៊ូនៅជាមួយសិស្សរបស់ព្រះអង្គក្នុងក្រុងយេរូសាឡឹមហើយនឹងអ្នកដើរតាមព្រះអង្គប្រមាណ៥០០នាក់ទៀត។ ទ្រង់មានព្រះបន្ទូលប្រាប់ដល់ពួកគេទាំងអស់គ្នាអំពីរឿងរ៉ាងដ៏រំភើបដែលនឹងកើតឡើងនៅថ្ងៃបុណ្យថ្ងៃទីហាសិប។ អ្នកដើរតាមព្រះអង្គមិនបានយល់ពេញលេញថាព័ន្ធកិច្ចរបស់គេត្រូវបន្តពីព័ន្ធកិច្ចដែលព្រះយេស៊ូបានចាប់ផ្តើមនោះទេ។ គេក៏មិនបានយល់ច្បាស់ថាព្រះជាម្ចាស់ចាកចេញពីពួកគេដែរតែភ្លាមៗនោះបន្ទាប់ពីគេបានទទួលសេចក្តីសន្យាដែលពួកគេនឹងទទួលឫទ្ធានុភាពនៃព្រះវិញ្ញាណដ៏វិសុទ្ធសណ្ឋិតលើពួកគេព្រះយេស៊ូក៏យាងឡើងទៅស្ថានបរមសុខវិញ ហើយគេលែងបានឃើញព្រះអង្គទៀត។

ដំណើររឿងដែលកើតឡើងបន្តបន្ទាប់ថ្ងៃបុណ្យទី៥០បានកត់ត្រានៅក្នុងកិច្ចការ ២:១-៦។ សូមអានខទាំងនេះនោះអ្នកនឹងឃើញថាអ្នកជឿបានទទួលព្រះវិញ្ញាណដ៏វិសុទ្ធដូចដែលព្រះយេស៊ូបានសន្យាមែន។ មនុស្សដែលបានឃើញ និង ឮគេមានការភ្ញាក់ផ្អើល និងអស្ចារ្យអំពីការនេះ។

ក្រោយមកលោកពេត្រុសមានឱកាសដើម្បីពន្យល់ទៅកាន់មនុស្សអំពីអ្វីដែលបានកើតឡើង (កិច្ចការ២:១៤-៣២)។ លោករំលឹកពួកគេអំពីការមានព្រះជន្មរស់ឡើងវិញរបស់ព្រះយេស៊ូហើយលោកបានមានប្រសាសន៍ថា «ព្រះជាម្ចាស់បានប្រោសលោកយេស៊ូនេះអោយរស់ឡើងវិញ យើងខ្ញុំទាំងអស់គ្នាជាសាក្សី» (កិច្ចការ ២:៣២)។ មានមនុស្សប្រមាណ៣០០០នាក់បានទទួលការឆ្លើយតបទៅនឹងសាររបស់ និង ជឿព្រះគ្រិស្ត។

នៅក្នុងជំពូកទី៣ នៃកណ្ឌគម្ពីរកិច្ចការមានការកត់ត្រាអំពីការអស្ចារ្យយ៉ាងច្រើន។ ពួកសាវ័កបានធ្វើសក្ខីភាពថាការអស្ចារ្យបានកើតឡើងដោយសារ «យើងជឿលើព្រះនាមព្រះយេស៊ូ» (កិច្ចការ ៣:១៦)។ ជំពូកទី៤ ប្រាប់យើងអំពីលោកពេត្រុស និង លោកយ៉ូហានអធិប្បាយទៅកាន់មនុស្ស និង ចំនួនអ្នកជឿបានកើនឡើងប្រហែលប្រាំពាន់នាក់។ ការចែកចាយរាជ្យសារអំពីការសុគត និង ការរស់ឡើងវិញរបស់ព្រះយេស៊ូ។ នៅក្នុងកិច្ចការ ៣:១៥ និង ៥:៣២ លោកពេត្រុសបានលើកឡើងម្តងទៀតថា «យើងធ្វើជាសាក្សីពីកិច្ចការទាំងអស់នេះ»។ គេក៏បានធ្វើសាក្សីនៅក្នុងក្រុងយេរូសាឡឹមដូចអ្វីដែលព្រះយេស៊ូមានព្រះបន្ទូល។

គ្រិស្តបរិស័ទគ្រប់រូប ត្រូវទទួលខុសត្រូវក្នុងការប្រាប់ដល់អ្នកដទៃអំពីជីវិតថ្មីរបស់គេក្នុងព្រះយេស៊ូ។ ដំណឹងល្អនឹងកាន់តែរីកសុសសាយដល់ចុងបំផុតនៃផែនដីតាមរយៈគ្រិស្តបរិស័ទ *ដទៃទៀត* ហើយមិនមែនគ្រាន់តែតាមរយៈពួកសាវ័កប៉ុណ្ណោះទេ (កិច្ចការ ៨:១-៤)។ គ្រិស្តបរិស័ទទាំងអស់បានបំពេញដោយព្រះវិញ្ញាណដ៏វិសុទ្ធ និងចង់បង្ហាញពីសហគមន៍គ្រិស្តបរិស័ទទៅកាន់ពិភពលោក។ ពួកគេចាប់ផ្ដើមអធិប្បាយ និងប្រាប់ពីដំណឹងល្អទៅកាន់មនុស្សគ្រប់ទីកន្លែង។

ដើម្បី បំពេញតាមសេចក្ដីបង្គាប់របស់ព្រះយេស៊ូក្នុងការបង្កើតសិស្សគ្រប់ទាំងសាសន៍ តើយើងត្រូវចាប់ផ្ដើមនៅទីណា? យើងត្រូវចាប់ផ្ដើមនៅកន្លែងដែលគ្រិស្តបរិស័ទនៅទីក្រុងយេរូសាឡឹមចាប់ផ្ដើម គឺនៅផ្ទះ នៅក្នុងសហគមន៍របស់យើង នៅក្នុងចំណោមគ្រួសារ និង អ្នកជិតខាងរបស់យើង ជាកន្លែងដែលយើងមានទំនាក់ទំនងជារៀងរាល់ថ្ងៃ។ នៅក្នុងពិភពលោករបស់អ្នក នៅទីកន្លែងដែលអ្នករស់នៅ នៅកន្លែងធ្វើការរបស់អ្នក នៅកន្លែងដែលអ្នកតែងតែចំណាយពេលជាមួយ នេះគឺជាការចែករំលែកនូវក្ដីស្រឡាញ់ និង ការយកចិត្តទុកដាក់ ដែលត្រូវចាប់ផ្ដើមឡើង។ សូមឱ្យពិភពលោកផ្ទាល់ខ្លួនដែលអ្នករស់នៅ ទីក្រុងយេរូសាឡឹម អ្នកដែលអ្នកស្គាល់ អ្នកដែលអ្នករស់នៅជាមួយ មើលឃើញពីដួងចិត្តនៃការរស់នៅជាសហគមន៍គ្រិស្តបរិស័ទដែលមាននៅក្នុងអ្នក។

**លំហាត់អនុវត្តន៍**

---

៤ សូមអានកណ្ឌគម្ពីរកិច្ចការ ១:៨, ៨:១-៤, ៣:១២-១៦ និង ៥:៣០-៣២។ តើខទាំងនេះនិយាយអំពីអ្វី?

..........................................................................................................................................

៥ ចូរគូសរង្វង់នៅខាងមុខប្រយោគដែលត្រឹមត្រូវ

ក) មានតែអ្នកដែលព្រះជាម្ចាស់ត្រាស់ហៅឱ្យធ្វើជាគ្រូគង្វាល និង អ្នកអធិប្បាយប៉ុណ្ណោះ ទើបមានទំនួលខុសត្រូវប្រកាសពីដំណឹងល្អ។

ខ) តាមរយៈមេរៀននេះ ទំនួលខុសត្រូវរបស់ខ្ញុំដំបូងបំផុតគឺ ធ្វើជាគ្រិស្តបរិស័ទដែលប្រកាសអំពីព្រះគ្រិស្តទៅកាន់អ្នកដែលខ្ញុំរស់នៅជាមួយរាល់ថ្ងៃ។

៦ ទីក្រុងយេរូសាឡឹមរបស់អ្នក មានន័យថា ជាទីកន្លែងដែលអ្នករស់នៅ និង ចំណាយពេលដ៏ច្រើនរបស់អ្នក។ ចូរសរសេរនៅក្នុងសៀវភៅសរសេររបស់អ្នកអំពីឈ្មោះរបស់មនុស្សដែលអ្នកមានទំនាក់ទំនងជាមួយរៀងរាល់ថ្ងៃ។ បន្ទាប់មកសូមសរសេរពីវិធីដែលអ្នកអាចទំនាក់ទំនងទៅកាន់ពួកគេបាន និងបង្ហាញពីដួងចិត្តនៃការរស់នៅក្នុងសហគមន៍ទោះកាន់គេ។ សូមអធិស្ឋាន ឱ្យអ្នកក្លាយជាសាក្សីដ៏មានប្រសិទ្ធភាពទៅកាន់មនុស្សជុំវិញអ្នក។

## ស្រុកយូដា ជាប្រទេសរបស់អ្នក Judea—Your Country

ក្នុងនាមជាអ្នកដើរតាមព្រះយេស៊ូ ដែលធ្វើសក្ខីភាពដោយស្មោះត្រង់នៅក្នុងក្រុងយេរូសាឡឹម មេដឹកនាំសាសនាបានច្រណែន និងចាប់ផ្ដើមបៀតបៀន (ដាក់ទណ្ឌកម្មនិងបញ្ហា) គ្រិស្តបរិស័ទ។ កិច្ចការ ៨:១ ប្រាប់យើងថា គ្រប់អ្នកជឿនៅទីក្រុងយេរូសាឡឹមទទួលការបៀតបៀនយ៉ាងខ្លាំង។ ដោយហេតុនេះហើយ ពួកគេទាំងអស់គ្នាលើកលែងតែពួកសាវ័កបានចាកចេញពីក្រុងយេរូសាឡឹម និង ចេញទៅពាសពេញទាំងស្រុកយូដា និង ស្រុកសាម៉ារី។ (ខេត្តត្រូវបានបែងចែកទឹកដីនៅក្រោមការគ្រប់គ្រងរបស់ចក្រភពរ៉ូម៉ាំង)។ កិច្ចការ ៨:៤ ប្រាប់យើងថា «អ្នកជឿបានធ្វើដំណើរពីកន្លែងមួយទៅកន្លែងមួយ ទាំងផ្សព្វផ្សាយដំណឹងល្អអំពីព្រះបន្ទូល»។

ដោយសារគ្រិស្តបរិស័ទត្រូវគេបង្ខំឱ្យចាកចេញពីទីក្រុងយេរូសាឡឹម ពួកគេបានធ្វើតាមបទបញ្ញត្តិផ្នែកទីពីររបស់ព្រះយេស៊ូ គឺចេញទៅស្រុកយូដាដើម្បីធ្វើជាសាក្សី។ យូដាគឺជាខេត្តមួយរបស់ចក្រភពរូម៉ាំងរ៉ូមដែលក្រុងយេរូសាឡឹមមានទីតាំងនៅទីនោះ។ ប្រជាជនរស់នៅទីនោះ ជាពួកយូដាដែលត្រូវការឮអំពីព្រះយេស៊ូ។

ជាច្រើនឆ្នាំកន្លងទៅដែលព្រះជាម្ចាស់ត្រាស់បុរសម្នាក់ឈ្មោះលោកម៉ូសេឱ្យចេញទៅជួយរំដោះប្រជារាស្ត្ររបស់គាត់ចេញពីទាសកររបស់ជនជាតិអេស៊ីប។ លោកម៉ូសេគិតថាគាត់គ្មានសមត្ថភាពឡើយ។ ប៉ុន្តែ ព្រះជាម្ចាស់សន្យាជាមួយលោកម៉ូសេថា ព្រះអង្គនឹងទៅជាមួយលោកម៉ូសេ ព្រមទាំងប្រទានពាក្យសម្ដីដល់គាត់ (និក្ខមនំ ៣-៤)។ ប្រហែលជាវាជារឿងរ៉ាវល្អ ដែលលោកម៉ូសេលែងមានអារម្មណ៍ថាគាត់ធ្វើការម្នាក់ឯងទៀតហើយ។ ចំណុចនេះគឺធ្វើឱ្យគាត់ទុកចិត្តព្រះអង្គទាំងស្រុង។

ប្រហែលជាអ្នកមានអារម្មណ៍ដូចជាលោកម៉ូសេដែរ។ ចម្លើយដែលផ្ដល់មកអ្នក គឺដូចទៅនឹងចម្លើយរបស់លោកម៉ូសេដែរ។ ព្រះជាម្ចាស់នឹងគង់នៅជាមួយអ្នក។ ទ្រង់នឹងជួយអ្នក។ «កុំពឹងលើការចេះដឹងរបស់ខ្លួនឡើយ តែត្រូវទុកចិត្តលើព្រះជាម្ចាស់ទាំងស្រុង» (សុភាសិត ៣:៥)។

បន្ទាប់ពីអ្នកបានបម្រើដោយស្មោះត្រង់នៅក្នុងព័ន្ធកិច្ចទៅកាន់ក្រុងយេរូសាឡឹម អ្នកចាំបាច់ត្រូវអនុញ្ញាតឱ្យព្រះជាម្ចាស់បញ្ជូនអ្នកទៅកាន់ស្រុកយូដា ជាខេត្ត ឬ ប្រទេស តំបន់ ផ្ទាល់របស់អ្នក។ អ្នកនិយាយថា «តើអាចឱ្យខ្ញុំនាំប្រជាជននៅក្នុងប្រទេសរបស់ខ្ញុំយ៉ាងដូចម្ដេចទៅ?» យើងអាចរកឃើញនៅក្នុងគន្លឹះនៅក្នុងសំណួរនេះ៖ «តើអ្នកញ៉ាំនំប៉ុងទាំងមូលក្នុងពេលម្ដងឬ?» ចម្លើយគឺ «អ្នកញ៉ាំបន្តិចម្ដង»។

នៅក្នុងជីវិតជាគ្រិស្តបរិស័ទ ប្រសិនបើអ្នកស្មោះត្រង់ចំពោះការតូចនោះ ព្រះជាម្ចាស់នឹងបើកទ្វារនៃឱកាស។ មានរបៀបជាច្រើនក្នុងការឈោងចាប់ដល់មនុស្សដទៃទៀតនោះ។ ជាឧទាហរណ៍ អ្នកអាចចាប់ផ្ដើមតាមរយៈការបង្រៀនថ្នាក់ថ្ងៃអាទិត្យពិសេសនៅក្នុងក្រុមជំនុំរបស់អ្នក។ អ្នកជួយគ្រូគង្វាលរបស់អ្នកទៅសួរសុខទុកអ្នកជំងឺ ឬ អ្នកដែលជាប់ឃុំឃាំង អ្នកអាចចែក ទានអាហារដល់ចាស់ជរា ឬក៏អ្នកដែលកំពុងតែត្រូវការអាហារ។ ប្រសិនបើអ្នកធ្វើដំណើរឆ្ងាយចាកចេញពីផ្ទះ អ្នកអាចរកមើលរបៀបដើម្បីបង្ហាញសេចក្ដីស្រឡាញ់ ឬ ប្រាប់ដល់អ្នកដទៃអំពីព្រះយេស៊ូ។ ចូរទុកចិត្តព្រះវិញ្ញាណដ៏វិសុទ្ធ

នោះព្រះអង្គនឹងជួយអ្នករកឃើញពីរបៀបដែលត្រូវបង្ហាញដួងចិត្តនៃការរស់នៅក្នុងសហគមន៍នៅក្នុងស្រុកយូដារបស់អ្នក គឺប្រទេសរបស់អ្នក។

## លំហាត់អនុវត្តន៍

៧ ចូរគូសរង្វង់នៅពីមុខប្រយោគដែលត្រឹមត្រូវ។

ក) វិធីសាស្ត្រល្អបំផុតដែលអ្នកអាចបង្ហាញពីសហគមន៍ ទៅដល់ប្រទេសរបស់អ្នកបាន គឺការរៀបចំគម្រោងការដ៏ធំ និង អធិប្បាយទៅកាន់ហ្វូងមនុស្សដ៏ធំដែរ។

ខ) យូដារបស់អ្នក គឺជាខេត្ត ឬ ប្រទេស ឬ តំបន់របស់អ្នក។

គ) អ្នកត្រូវស្មោះត្រង់នឹងកិច្ចការតូចសិន មុននឹងព្រះជាម្ចាស់ប្រើប្រាស់អ្នកសម្រាប់ធ្វើកិច្ចការធំ។

៨ សូមអធិស្ឋានសម្រាប់ប្រជាជននៅក្នុងប្រទេសរបស់អ្នក។ សូមអធិស្ឋានដើម្បីឱ្យព្រះជាម្ចាស់ប្រើប្រាស់អ្នកទៅកាន់អ្នកដទៃតាមរយៈដួងចិត្តនៃការរស់នៅក្នុងសហគមន៍ល្អ។ សូមសរសេរពីរបៀបដែលអ្នកអាចបង្ហាញដួចចិត្តនេះទៅកាន់អ្នកដែលមិនរស់នៅក្នុងតំបន់របស់អ្នក។ (សូមសរសេរ)

៩ តើគំរូនៃការទុកចិត្តព្រះជាម្ចាស់របស់លោកម៉ូសេ បង្រៀនអ្វីខ្លះដល់យើង?

……………………………………………………………………………………………………………….

## ស្រុកសាម៉ារី ជាប្រទេសនៅជុំវិញអ្នក Samaria—Your Surrounding Countries

ស្រុកសាម៉ារី ហាក់បីដូចជានៅឆ្ងាយពីក្រុងយេរូសាឡឹម! ជាការពិត សាសន៍ យូដា បានចាត់ទុកសាសន៍សាម៉ារីថាជាជនបរទេស។ ពួកយូដាមិនមានទំនាក់ទំនងជាមួយពួកសាម៉ារីទេ ទោះបីជាគេមានការជាប់ទាក់ទងគ្នាក៏ដោយ។ ប៉ុន្តែយើងបានអាននៅក្នុងកិច្ចការ៨បានប្រាប់យើងថាបន្ទាប់ពីលោកភីលីពបានពេញដោយព្រះវិញ្ញាណដ៏វិសុទ្ធគាត់បានទៅស្រុកសាម៉ារីដើម្បីអធិប្បាយ និង ធ្វើបន្ទាល់អំពីព្រះយេស៊ូទៅកាន់មនុស្ស។ លោកពេត្រុស មិនចង់ទៅទេ ប៉ុន្តែ ព្រះជាម្ចាស់បង្ហាញគាត់ថា គាត់ត្រូវធ្វើបន្ទាល់ទៅកាន់សាសន៍ដទៃ ក៏ដូចជាទៅកាន់សាសន៍យូដាដែរ។

មានឧទាហរណ៍ផ្សេងទៀតដូចគ្នានេះដែរ នៅក្នុងកណ្ឌគម្ពីរសម្ពន្ធមេត្រីចាស់ គឺនៅក្នុងគម្ពីរយ៉ូណាស។ ព្យាការី យ៉ូណាស ជាមនុស្សដែលមានអំណួត និង ធ្វើអ្វីៗតាមចិត្តរបស់ខ្លួនឯង។ គាត់ទទួលព្រះរាជ្យសារមកពីព្រះអម្ចាស់ ដើម្បីឱ្យទៅប្រកាសពីព្រះបន្ទូលនៅទីក្រុងនីនីវេ ដែលស្ថិតនៅឯប្រទេសអាស្ស៊ីរី។ លោកយ៉ូណាសមិនចង់ទៅទីក្រុងនីនីវេទេ ពីព្រោះមនុស្សនៅទីនោះចាត់ទុកគាត់ដូចជាជនបរទេស។

ដោយព្រោះតែលោកយ៉ូណាសមិនបានយកចិត្តទុកដាក់នឹងមនុស្សទាំងនេះ លោកបដិសេធមិនទៅ។ លើសពីនេះទៅទៀត លោកបានធ្វើដំណើរជាមួយនឹងតាមនាវាទៅទីក្រុងផ្សេងវិញ។ ព្រះអម្ចាស់បានធ្វើឱ្យមានព្យុះយ៉ាងធំ ហើយនាវាស្ទើរតែនឹងលេចបាត់ទៅក្នុងទឹក។ លោកយ៉ូណាស បានប្រាប់មនុស្សដែលនៅលើទូកថា ព្យុះទាំងនេះកើតឡើងដោយសារលោកមិនស្ដាប់បង្គាប់ព្រះជាម្ចាស់។ លោកបានប្រាប់គេថា «សូមលើកខ្ញុំបោះទៅក្នុងសមុទ្រទៅ ទើបសមុទ្រស្ងប់» (យ៉ូណាស ១:១២)។ ការនេះក៏បានសម្រេច ហើយសមុទ្រក៏បានស្ងប់ទៅវិញ។

បន្ទាប់មកព្រះជាម្ចាស់បានឱ្យត្រីមកលេបលោកយ៉ូណាស។ លោកយ៉ូណាសបានអធិស្ឋាននៅក្នុងពោះត្រី ហើយទូលអង្វរសុំការលើកលែងទោសពីព្រះជាម្ចាស់។ ហេតុដូច្នេះហើយទើបព្រះជាម្ចាស់បានឱ្យត្រីខ្ជាក់លោកយ៉ូណាសចេញមកដីស្ងួតវិញ។ ហើយលោកយ៉ូណាសត្រៀមខ្លួនជាស្រេចក្នុងការស្ដាប់បង្គាប់ព្រះជាម្ចាស់។ លោកក៏បានដើរទៅក្រុងនីនីវេដ៏កំណាច ហើយប្រកាសពីព្រះបន្ទូលរបស់ព្រះជាម្ចាស់។ មានមនុស្សជាច្រើនបានទទួលការកែប្រែចិត្តចេញពីអំពើបាបរបស់គេ និង ទទួលជឿព្រះជាម្ចាស់។ ព្រះជាម្ចាស់បានទុកជីវិតសម្រាប់មនុស្សក្នុងក្រុងនេះ និង បង្រៀនដល់ក្រុងនេះអំពីមេរៀននៃការស្ដាប់បង្គាប់ដល់លោកយ៉ូណាស។

ព្រះជាម្ចាស់ ស្រឡាញ់មនុស្សគ្រប់គ្នា។ ព្រះអម្ចាស់មានព្រះឫទ័យមេត្តាករុណាដល់ប្រជាជននៅក្នុងក្រុងនីនីវេ ហើយព្រះអង្គក៏នៅតែមានព្រះហឫទ័យមេត្តាករុណាដល់មនុស្សគ្រប់គ្នាដែរ។ ប្រសិនបើយើងស្ដាប់បង្គាប់ដល់ព្រះអង្គ ទ្រង់នឹងជួយយើងក្នុងការឈោងចាប់មនុស្ស ដែលរស់នៅជិតៗយើងក្នុងប្រទេសរបស់យើង។ ព្រះជាម្ចាស់មិនបានស្រឡាញ់តែមនុស្សម្នាក់ឡើយ។ ទ្រង់នឹងលែកលែងទោសដល់អស់អ្នកណាដែលស្រែករកព្រះអង្គ។

តើអ្នកអាចចែកចាយពីសហគមន៍គ្រិស្តបរិស័ទទៅកាន់មនុស្សដែលរស់នៅជិតអ្នកក្នុងប្រទេសរបស់អ្នកយ៉ាងដូចម្ដេច? ជាដំបូងអ្នកត្រូវអធិស្ឋានសម្រាប់គេ។ អ្នកអាចដាក់ដង្វាយជាប្រាក់ឱ្យគេ ឬ ក៏ឱ្យរបស់របរទៅគេ និង ប្រាប់គេអំពីដំណឹងល្អតាមរយៈដំណើររឿង។ បងប្អូនមួយចំនួនអាចនឹងចូលទៅនិយាយលេងជាមួយពួកគាត់។ កុំធ្វើឱ្យព្រះជាម្ចាស់មានដែនកំណត់ឡើយ។ ចូរអនុញ្ញាតឱ្យព្រះអង្គរៀបចំផែនការនៅក្នុងជីវិតរបស់អ្នក។ អ្នកមិនត្រូវការប្រាក់ច្រើនដើម្បីផ្សាយដំណឹងល្អឱ្យគេទទួលជឿលើព្រះគ្រិស្តឡើយ។ ប្រសិនបើគ្រិស្តបរិស័ទទាំងអស់គោរពតាមបទបញ្ញត្តិរបស់ព្រះយេស៊ូ អ្នកខ្វះខាតនឹងបានបំពេញតម្រូវការ ហើយដំណឹងល្អនឹងរីកសុះសាយរហូតដល់ចុងបំផុតនៃផែនដី!

១០ ចូរគូសរង្វង់នៅពីមុខប្រយោគដែលត្រឹមត្រូវ។

ក) ខ្ញុំអាចចែកចាយសហគមន៍គ្រិស្តបរិស័ទទៅកាន់មនុស្សនៅក្នុងប្រទេសដទៃទៀតបានតាមរយៈការអធិស្ឋាន និង ថ្វាយដង្វាយដើម្បីប្រកាសពីដំណឹងល្អ។

ខ) ព្រះជាម្ចាស់មិនបានយកចិត្តទុកដាក់ពីទីក្រុងនីនីវេទេពីព្រោះប្រជាជននៅទីនោះមិនបម្រើព្រះអង្គ។

គ) ព្រះជាម្ចាស់មិនរំពឹងឱ្យខ្ញុំយកចិត្តទុកដាក់ដល់អ្នកដទៃឡើយបើខ្ញុំមិនចេះភាសារបស់គេទេនោះ។

ឃ) លោកយ៉ូណាសបានរៀនមេរៀនអំពីការស្តាប់បង្គាប់។

១១ តើអ្នកមានចាត់ទុកក្រុមណាថាជាជនបរទេស ឬ ជនចម្លែកដែរឬទេ? តើពួកគេជានរណា? តើអ្នកអាចជួយពួកគេបានយ៉ាងដូចម្តេច?

……………………………………………………………………………………………………………………

សូមអធិស្ឋានឱ្យមនុស្សទាំងនេះបានស្គាល់ព្រះជាម្ចាស់។ ចូរទូលសូមដល់ព្រះជាម្ចាស់ពីរបៀបដែលអ្នកអាចឈោងចាប់ពួកគេថ្វាយព្រះជាម្ចាស់។

## ស្រុកដាច់ស្រយាលនៃផែនដី ជាពិភពលោករបស់អ្នក Ends of the Earth—Your World

លោកសាវ័កប៉ូលជាបេសកជនដ៏អស្ចារ្យបំផុតដែលពិភពលោកបានស្គាល់។ លោកបានធ្វើដំណើរទូទាំងក្រុងយេរូសាឡឹម ស្រុកយូដា និង ស្រុកសាម៉ារី និងរហូតដល់ស្រុកដាច់ស្រយាលនៃផែនដី។ នៅក្នុងដំណើរបេសកកម្មរបស់លោកជារៀងរាល់លើក លោកតែងឈោងចាប់ពិភពលោកដែលគេស្គាល់។ ដំណើរទីមួយរបស់គាត់គឺទៅកាន់អាស៊ីមីន័រ ដែលស្ថិតនៅជិតផ្ទះរបស់លោកនៅប៉ាលេស្ទីន។ ដំណើររបស់គាត់លើកទីពីរ និង ទីបី គឺទៅកាន់ទីដែលឆ្ងាយគឺ កោះក្រិកនៅដំណើរចុងក្រោយរបស់គាត់គឺគាត់បានធ្វើដំណើរដ៏ឆ្ងាយទៅកាន់ទីក្រុងរ៉ូម និងប្រហែលជាទៅដល់អេស្ប៉ាញ។ ជាការពិតលោកសាវ័កប៉ូលមានការយកចិត្តទុកដាក់ផ្សាយដំណឹងល្អដល់ចុងបំផុតនៃផែនដី គឺទៅដល់មនុស្សគ្រប់គ្នា គ្រប់ទីកន្លែងអំពីព្រះយេស៊ូគ្រិស្ត។

ព្រះយេស៊ូមានព្រះបន្ទូលថា «ដូច្នេះចូរចេញទៅនាំមនុស្សគ្រប់ជាតិសាសន៍អោយធ្វើជាសិស្ស ហើយធ្វើពីធីជ្រមុជទឹកអោយគេក្នុងព្រះនាមព្រះបិតា ព្រះបុត្រា និង ព្រះវិញ្ញាណដ៏វិសុទ្ធ» (ម៉ាថាយ ២៨:១៩)។ ព្រំដែនរបស់សហគមន៍គឺវិសេសវិសាលមែនទែន។ ព្រំដែនរបស់សហគមន៍ គ្មានដែនកំណត់ឡើយ។ ពួកគេផ្សាយដំណឹងល្អតាំងពីពិភពលោកផ្ទាល់ខ្លួនរបស់គេរហូតដល់ ចុងបំផុតនៃផែនដី។ គេបានធ្វើឱ្យមនុស្សនៅគ្រប់ទីកន្លែងទទួលការប៉ះពាល់ចិត្ត។ តើនៅពេលនេះអ្នកយល់ពីរបៀបដែលអាចយកចិត្តទុកដាក់ស្របតាមព្រះគម្ពីរ ក្នុងការបង្ហាញដួងចិត្តរស់នៅក្នុងសហគមន៍ហើយឬ

នៅ? ចូរយើងបានចេញទៅឈោងចាប់មនុស្សដោយសេចក្តីស្រឡាញ់ និងបង្ហាញដួងចិត្តនៃសហគមន៍គ្រិស្តបរិស័ទទៅកាន់ពិភពលោកទាំងមូល។

ខ្ញុំចង់ប្រាប់អ្នកអំពីនារីម្នាក់មកពីប្រទេសអង់គ្លេសដែលមានគំនិតអំពីសហគមន៍ដែលនាងមិនដែលស្គាល់នៅស្រុកដាច់ស្រយាលនៃផែនដី។ នាងឈ្មោះថា ហ្គ្លេដឌីស៍ អ៊ីលវឺដ (Gladys Aylward)។ នៅក្នុងឆ្នាំ១៩២០ នាងជាអ្នកបម្រើនៅក្នុងគ្រួសារអ្នកមានមួយនៅក្នុងទីក្រុងឡុង។ ប៉ុន្តែ នាងមានបំណងចង់ទៅប្រាប់ប្រជាជនចិនអំពីព្រះយេស៊ូ។ ប៉ុន្តែ នាងមិនដឹងថា ប្រទេសចិននៅទីណាឡើយ។

ជាទីបញ្ចប់ នាងបានដឹងថានាងអាចធ្វើដំណើរទៅប្រទេសចិនបានតាមរយៈរថភ្លើង។ នាងបានទិញសំបុត្ររថភ្លើងមួយ និងធ្វើដំណើរឆ្លងកាត់អឺរ៉ុប បន្ទាប់មក នាងធ្វើដំណើរតាមរថភ្លើងមួយទៀតឆ្លងកាត់តាមតំបន់ស៊ីបេរី។ នាងបានធ្វើដំណើរមកដល់ប្រទេសចិនបន្ទាប់ពីធ្វើដំណើរអស់ជាច្រើនថ្ងៃមក។

នាងហ្គ្លេដឌីស៍ អ៊ីលវឺដ បានធ្វើការនៅប្រទេសចិនអស់រយៈពេល៤០ឆ្នាំដើម្បីប្រាប់មនុស្សអំពីព្រះយេស៊ូ។ នាងធ្លាប់ជាប់ពន្ធនាគារ។ នាងបានជួយមនុស្សជាច្រើនឱ្យស្គាល់ព្រះយេស៊ូជាព្រះសង្គ្រោះ។ នាងបានថែរក្សាក្មេងកំព្រាជាច្រើនរយនាក់។ នៅក្នុងអំឡុងសម័យសង្គ្រាមលោកលើកទីពីរ នាងបានដឹកនាំក្មេងកំព្រាប្រមាណ១០០នាក់ ដើម្បីគេចចេញពីកន្លែងគ្រោះថ្នាក់ទៅរកទីទួលមានសុវត្ថិភាពនៅលើភ្នំ។ ស្ត្រីវ័យក្មេងម្នាក់នេះបង្ហាញទឹកចិត្តនៃការរស់នៅជាសហគមន៍ដែលឈោងចាប់មនុស្សដែលនៅទីឆ្ងាយពីទីក្រុង ឬ ប្រទេសរបស់ខ្លួនឯង។ ការចាប់ផ្តើមរបស់នាង គឺដោយការបន្ទាបខ្លួន។ នាងមានសេចក្តីស្រឡាញ់ដែលឆ្លុះបញ្ចាំងពីព្រះជាម្ចាស់។ នាងបានឈោងចាប់មនុស្សតាំងពីប្រទេសអង់គ្លេសរហូតដល់ប្រទេសចិននៅទីឆ្ងាយបំផុត។

**លំហាត់អនុវត្តន៍**

---

ចូរបំពេញប្រយោគខាងក្រោម។

១២ នាងហ្គ្លេដឌីស៍ អ៊ីលវឺដ បានទៅប្រទេស.........................................................

១៣ ខ្ញុំមានគំនិតគិតអំពីសហគមន៍ដោយ.........................................................
.........................................................
.........................................................

១៤ នៅក្នុងចន្លោះនៅខាងមុខសហគមន៍នីមួយៗដែលមានសរសេរនៅខាងឆ្វេង សូមសរសេរលេខរៀងដែលមាននៅខាងស្តាំដែលបង្ហាញពីក្រុមមនុស្សរស់នៅក្នុងក្រុមនៃតំបន់នោះ។

| | |
|---|---|
| …….. .ក ស្រុកសាម៉ារី | ១) ជនរួមជាតិរបស់ខ្ញុំ |
| …….. ខ ស្រុកយូដា | ២) ប្រជាជនដែលនៅប្រទេសជិតខាង |
| …….. គ ចុងបញ្ចប់នៃផែនដី | ៣) គ្រួសារ និង អ្នកជិតខាងខ្ញុំ |
| ……. ឃ ស្រុកយេរូសាឡឹម | ៤) ប្រជាជនដែលរស់នៅទីដ៏សែនឆ្ងាយ។ |

១៥ ឥឡូវនេះ សូមបែរទៅរកការបង្ហាញពីខាងដើមនៃមេរៀននេះ។ សូមសរសេរក្រុមមនុស្សដែល តំណាងឱ្យក្រុមនីមួយៗនៅលើចន្លោះដែលផ្តល់ឱ្យ។

## សូមផ្ទៀងចម្លើយរបស់អ្នក

---

៨ ចម្លើយរបស់អ្នក។ នៅពេលដែលអ្នកអធិស្ឋាន ព្រះជាម្ចាស់នឹងបង្ហាញផ្លូវដល់អ្នកក្នុងការផ្សាយដំណឹងល្អទៅកាន់មនុស្ស។

១ ខ) មិនមានព្រំដែនកំណត់

៩ នៅពេលដែលព្រះជាម្ចាស់ប្រទានឱ្យយើងធ្វើអ្វីមួយ យើងត្រូវទុកចិត្តដល់ព្រះអង្គក្នុងការជួយដល់យើង។

២ ក) គ្រប់ទីកន្លែង

១០ ប្រយោគ ក និង ឃ ត្រឹមត្រូវ។

៣ យេរូសាឡឹម យូដា សាម៉ារី និង ស្រុកដាច់ស្រយាលនៃផែនដី។

១១ ចម្លើយរបស់អ្នក។ អ្នកអាចអធិស្ឋានសម្រាប់គេ និង ទូលសូមដល់ព្រះជាម្ចាស់បង្ហាញពីរបៀបជួយពួកគេដើម្បីទទួលបានដំណឹងល្អ។

៤ របៀបដែលអ្នកជឿធ្វើសាក្សីអំពីព្រះគ្រិស្ត។

១២ ប្រទេសចិន

៥ ប្រយោគ ខ ជាប្រយោគត្រឹមត្រូវ

១៣ បង្ហាញសេចក្តីស្រឡាញ់ និង ការយកចិត្តទុកដាក់ សម្រាប់គ្រប់មនុស្សទាំងអស់គ្រប់ទីកន្លែង។

៦ ចម្លើយរបស់អ្នក។ ខ្ញុំសង្ឃឹមថា អ្នកនឹងកាន់តែដឹងថែមទៀតអំពីរបៀបដើម្បីបង្ហាញទៅដល់សហគមន៍ និងសេចក្តីគ្រិស្តបរិស័ទនូវរាល់ទង្វើរបស់អ្នកជាមួយអ្នកដទៃទៀត។

១៤ ក ២)

ខ ១)

គ ៤)

ឃ ៣)

៧ ប្រយោគខ និង គ ជាប្រយោគត្រឹមត្រូវ

១៥ ក *យេរូសាឡឹម:* គ្រួសារ និង អ្នកជិតខាងខ្ញុំ

ខ *យូដា:* ជនរួមជាតិរបស់ខ្ញុំ

គ *សាម៉ារី*: ប្រជាជនដែលរស់នៅប្រទេសជិតខាងខ្ញុំ

ឃ *ស្រុកដាច់ស្រយាលនៃផែនដី:* មនុស្សដែលរស់នៅតំបន់ដ៏សែនឆ្ងាយ។

## មេរៀនទី ៣

# ការរីកចម្រើននៅក្នុងសហគមន៍

## Growing in Community

ទារកចាប់ផ្ដើមជីវិតទាំងយំផង និង ញ៉ាំផង។ វាគឺជាការអស្ចារ្យណាស់ដែលយើងចំណាយពេលយកចិត្តទុកដាក់អំពីការនេះ។ ទារកធំលូតលាស់ ពីព្រោះគេញ៉ាំ និងរៀនពីអ្នកដែលថែរក្សាពួកគេ ដែលបានបង្រៀនកិច្ចការជាច្រើនដល់ពួកគេ។ រូបកាយ និង ស្មារតីរបស់គេបន្តរីកលូតលាស់រហូតដល់គេក្លាយទៅជាមនុស្សពេញវ័យ។ នៅពេលដែលគេក្លាយជាមនុស្សពេញវ័យហើយ យើងនិយាយថាគេក្លាយទៅជាមនុស្សធំហើយ។

នៅក្នុងមេរៀនទី២ យើងបានរៀនអំពីសេចក្ដីបង្គាប់របស់ព្រះយេស៊ូក្នុងការធ្វើជាសាក្សី។ ដើម្បីធ្វើជាសាក្សីដ៏មានប្រសិទ្ធភាពយើងត្រូវតែអភិវឌ្ឍវិញ្ញាណរបស់យើង។ នៅក្នុងមេរៀននេះអ្នកនឹងសិក្សាអំពីរបៀបដែលធ្វើឱ្យវិញ្ញាណរបស់យើងរីកចម្រើនឡើង។ មានមនុស្សមួយចំនួននៅតែជាគ្រិស្តបរិស័ទក្មេងខ្ចីដដែល ទោះបីជាគេទទួលជឿព្រះជាម្ចាស់យូរហើយក៏ដោយ។ នេះមិនមែនជាគម្រោងផែនការរបស់ព្រះជាម្ចាស់ទេ។ ព្រះជាម្ចាស់ចង់ឱ្យយើងធំពេញវ័យឡើង។ ព្រះជាម្ចាស់ចង់ឱ្យវិញ្ញាណរបស់យើងរីកចម្រើន «ទៅជាមនុស្សពេញវ័យឡើងដល់កំពស់របស់ព្រះគ្រិស្តដែលបំពេញអ្វីៗទាំងអស់» (អេភេសូ ៤:១៣)។ បន្ទាប់មក យើងនឹងរីកចម្រើននៅក្នុងសហគមន៍ជាមួយអ្នកដទៃទៀត។

## គម្រោង

ក. របៀបដើម្បីរីកចម្រើន Ways to Grow

ខ. គោលការណ៍នៃការរីកចម្រើន Principles for Growth

## គោលដៅ

១. ពន្យល់ពីរបៀបដែលអ្នកអាចរីកចម្រើនក្នុងព្រះអម្ចាស់។

២. ពន្យល់អំពីគោលការណ៍នៃការញែកថ្វាយព្រះជាម្ចាស់ និង ការញែកចេញពីលោកិយ៍។

## ក. របៀបដើម្បីរីកចម្រើន Ways to Grow

### ស្គាល់ពីព្រះបន្ទូល Know the Scriptures

**គោលដៅទី១. ពន្យល់ពីរបៀបដែលអ្នកអាចរីកចម្រើនក្នុងព្រះអម្ចាស់។**

ពួកខាងគណៈសាឌូស៊ី បាននិយាយជាមួយព្រះយេស៊ូអំពីរឿងប្រឌិតដែលពួកគេបានបង្កើតឡើង គេបាននិយាយថា មានស្ត្រីម្នាក់បានរៀបការជាមួយបុរសម្នាក់ បុរសនោះក៏ស្លាប់ទៅ។ បន្ទាប់មក នាងក៏រៀបការជាមួយប្អូនប្រុសរបស់ប្ដី ហើយបុរសនោះក៏ស្លាប់ទៀតដែរ។ ការនេះកើតឡើងដល់ទៅ៧ដង។ ពួកខាងគណៈសាឌូស៊ីសួរសំណួរនេះទៅព្រះយេស៊ូថា តើស្ត្រីម្នាក់នេះនឹងបានក្លាយទៅជាប្រពន្ធរបស់បុរសណាមួយនៅឯស្ថានបរមសុខ? (ម៉ាថាយ ២២:២៨)។

ពួកខាងគណៈសាឌូស៊ីប្រឌិតរឿងនេះឡើងដើម្បីសាកល្បងព្រះយេស៊ូ។ ពួកគេមិនបានជឿលើការរស់ឡើងវិញឡើយ។ ពួកគេចង់ឱ្យព្រះយេស៊ូមានព្រះបន្ទូលមកដែលប្រឆាំងទៅនឹងជំនឿរបស់គេបន្ទាប់មកគេបដិសេធការបង្រៀនរបស់ព្រះអង្គ។ ប៉ុន្តែ លើសពីការឆ្លើយសំណួរនេះ ព្រះយេស៊ូបានបង្ហាញពីឫសគល់នៃបញ្ហានេះ។ ព្រះអង្គបើកសម្ដែងឱ្យគេបានឃើញពីកង្វះនៃការយល់ដឹងខាងព្រះបន្ទូលរបស់ពួកគេ។ «អ្នករាល់គ្នាយល់ខុសហើយ! ដ្បិតអ្នករាល់គ្នាមិនយល់គម្ពីរទាំងមិនស្គាល់ឫទ្ធានុភាពរបស់ព្រះជាម្ចាស់ផង» (ម៉ាថាយ ២២:២៩)។ ចូរគូសចំណាំពីសេចក្ដីបង្គាប់បញ្ហាដែលព្រះយេស៊ូបានប្រើ។ ទ្រង់បានដាក់ចំណេះដឹងខាងព្រះបន្ទូលជាទីមួយហើយអំណាចព្រះចេស្ដារបស់ព្រះជាម្ចាស់ជាទីពីរវិញ។

មានចំណុចជាច្រើនដែលយើងរៀនបាននៅទីនេះ។ មនុស្សជាច្រើនហាក់បីដូចជាចង់បានឫទ្ធានុភាពរបស់ព្រះជាម្ចាស់ខ្លាំងបំផុត ប៉ុន្តែ គេមិនសូវចង់ដឹងអំពីព្រះបន្ទូលរបស់ព្រះជាម្ចាស់ឱ្យបានច្រើនឡើយ។ តើអ្នកចង់បានឫទ្ធានុភាពរបស់ព្រះជាម្ចាស់ដែរឬទេ? បន្ទាប់មក អ្នកត្រូវតែដឹង និងរស់នៅតាមការបង្រៀនស្របតាមព្រះបន្ទូលរបស់ព្រះជាម្ចាស់។ លោកសាវ័កពេត្រុសមានប្រសាសន៍ថា «ចូរប្រាថ្នាចង់បានព្រះបន្ទូលដូចទារកដែលទើបនឹងកើតប្រថ្នាចង់បានទឹកដោះសុទ្ធ ដើម្បីអោយបងប្អូនបានចម្រើនឡើងតាមរយៈព្រះបន្ទូលនេះ និង ទទួលការសង្គ្រោះ» (១ពេត្រុស ២:២)។

ទំនុកតម្កើង ១១៩ មានចំនួន ១៧៦ខ។ គ្រប់ទាំងខទាំងអស់នេះ ព្រះបន្ទូលលើកឡើង អំពីរបៀបមួយ ឬ របៀបផ្សេងទៀត។ នៅក្នុងចំណោមកិច្ចការដទៃទៀត ខគម្ពីរនេះបង្ហាញពីព្រះបន្ទូលរបស់ព្រះជាម្ចាស់ជាមគ្គុទេសន៍របស់យើង ជាប្រាជ្ញា ជាអំណរ និងជារបងការពារពួកយើងពីអំពើបាប។

ប្រសិនបើការអានព្រះបន្ទូលព្រះជាម្ចាស់មិនបានជាផ្នែកមួយនៃជីវិតរបស់អ្នកទេ អ្នកអាចទូលសូមដល់ព្រះជាម្ចាស់ដើម្បីជួយដល់អ្នកឱ្យមានគំនិតប្រាជ្ញា ដើម្បីអាន និង យល់អំពីព្រះបន្ទូល។ មានពេលខ្លះ យើងធ្វើនូវអ្វីដែលយើងមិនគួរធ្វើដោយសារកង្វះនូវវិន័យផ្ទាល់ខ្លួន។ មានរឿងខ្លះមានតែព្រះជាម្ចាស់ប៉ុណ្ណោះដែលអាចធ្វើសម្រាប់ខ្ញុំបាន។ មានរឿងខ្លះទៀតដែលខ្ញុំត្រូវធ្វើសម្រាប់ខ្លួនឯង។ ការនេះគឺខ្ញុំធ្វើតាមចំណង់របស់ខ្ញុំ។ គ្មាននរណាម្នាក់បង្ខំខ្ញុំឱ្យធ្វើកិច្ចការអ្វីមួយបានឡើយ ខ្ញុំត្រូវឱ្យខ្លួនខ្ញុំធ្វើកិច្ចការដោយខ្លួនឯង។ នៅពេលដែលខ្ញុំចាប់ផ្ដើមអានព្រះបន្ទូលជារៀងរាល់ថ្ងៃ ខ្ញុំឆ្លងកាត់បទពិសោធន៍នៃសេចក្ដីអំណរ និង សេចក្ដីសប្បាយរីករាយ ព្រមទាំងការរីកចម្រើន។

កុមារនឹងអាចរីកចម្រើនលូតលាស់បាននៅពេលដែលគេញ៉ាំទឹកដោះគោ និង អាហារពីមាតាបិតារបស់គេ។ វាដូចគ្នាដែរនៅក្នុងជីវិតរបស់អ្នកជឿ។ ប្រសិនបើអ្នកចង់រីកចម្រើនក្នុងព្រះអម្ចាស់អ្នកត្រូវឱ្យព្រះអង្គប្រទានអាហារសម្រាប់ជីវិតអ្នក។ ព្រះអង្គប្រទានអាហារដល់អ្នកជាព្រះបន្ទូល។ ចូររៀបចំកាលវិភាគទៀងទាត់សម្រាប់គោលបំណងនេះដូចដែលអ្នកមានពេលរាល់ថ្ងៃក្នុងកាលដែលអ្នកញ៉ាំអាហារដែរ។ ព្រះវិញ្ញាណដ៏វិសុទ្ធនឹងជួយអ្នកយល់ពីអ្វីដែលអ្នកអានហើយអ្នកនឹងរីកចម្រើនក្នុងព្រះអម្ចាស់។

**លំហាត់អនុវត្តន៍**

---

១ ចូរគូសពីមុខប្រយោគដែលត្រឹមត្រូវ

ក) ព្រះយេស៊ូបើកសម្ដែងដល់ពួកខាងគណៈសាឌូស៊ី ពីព្រោះពួកគេមិនយល់ពី ព្រះបន្ទូលរបស់ព្រះជាម្ចាស់។

ខ) ព្រះយេស៊ូប្រទានអាហារខាងវិញ្ញាណដល់យើងនៅពេលដែលយើងអានព្រះគម្ពីរ។

គ) ព្រះយេស៊ូមានព្រះបន្ទូលថាការដឹងអំពីឫទ្ធានុភាពរបស់ព្រះជាម្ចាស់នោះមានសារៈសំខាន់ជាងការដឹងអំពីព្រះបន្ទូល។

២ តើអ្វីទៅជាលទ្ធផលនៃការអានព្រះបន្ទូលបានទៀងទាត់?

……………………………………………………………………………………………………………….

## គិតអំពីព្រះអម្ចាស់ Think About the Lord

បន្ថែមពីលើចំណុចនេះទៀតសម្រាប់ការរីកចម្រើនក្នុងជាគ្រិស្តបរិស័ទ គឺការអធិស្ឋាន និង ការសញ្ជឹងគិត ឬ ការគិតអំពីព្រះអម្ចាស់។ យើងត្រូវការហ្វឹកហាត់ខ្លួនយើងឱ្យគិតអំពីព្រះជាម្ចាស់។ យើងត្រូវការគិតអំពីព្រះបន្ទូលរបស់ព្រះអង្គ អំពីព្រះបន្ទូលកាលពីម្សិលមិញនិងអំពីអ្វីដែលព្រះអង្គបានធ្វើសម្រាប់យើង។ លោកប៉ុលប្រាប់យើងនៅក្នុងភីលីព ៤:៨ ថា

«សូមបងប្អូនគិតតែអ្វីៗដែលពិត ថ្លៃថ្នូរ សុចរិត បរិសុទ្ធ គួរអោយស្រឡាញ់គួរអោយគោរពនិងគំនិតណាដែលល្អឥតខ្ចោះ គួរឱ្យកោតសរសើរ»។ យើងមានសេចក្តីសន្យាមួយនៅកណ្តាគម្ពីរអេសាយថាព្រះអង្គប្រទានសេចក្តីសុខសាន្តជានិរន្តរ៍ដល់ប្រជាជាតិនេះ ព្រោះគេមានជំហររឹងប៉ឹងហើយផ្ញើជីវិតលើព្រះអង្គ (អេសាយ ២៦:៣)។ សូមគិតអំពីព្រះអម្ចាស់ដែលធ្វើឱ្យជំនឿរបស់យើងកាន់តែរីកចម្រើនជាមួយព្រះអង្គជារៀងរាល់ថ្ងៃ។

យើងក៏ត្រូវអធិស្ឋានផងដែរទូលសូមដល់ព្រះជាម្ចាស់បង្រៀនដល់យើងតាមរបៀបរបស់ព្រះអង្គ និងតម្រង់ផ្លូវរបស់យើង។ ទ្រង់ចង់ឱ្យយើងអធិស្ឋានដើម្បីឱ្យយើងកាន់តែយល់ព្រះបន្ទូលព្រះអង្គថែមទៀត។ យើងបានទទួលសេចក្តីបង្រៀននៅក្នុងភីលីពជំពូក ៤:៦ ថា ចូរទូលសូមព្រះជាម្ចាស់នៅអ្វីដែលជាតម្រូវការរបស់យើង។ យើងក៏បានអាននៅក្នុងគម្ពីរអេភេសូ ៦:១៨ «ចូរអធិស្ឋានគ្រប់ពេលវេលាសម្រាប់ប្រជារាស្រ្តរបស់ព្រះជាម្ចាស់»។ នៅពេលដែលយើងអធិស្ឋានសម្រាប់គ្រិស្តបរិស័ទដទៃទៀត យើងកំពុងបង្ហាញអំពីដួងចិត្តនៃការរស់នៅជាសហគមន៍ល្អដល់គេ។ យើងក៏ត្រូវអធិស្ឋានសម្រាប់អស់អ្នកដែលមិនទាន់ស្គាល់ព្រះគ្រិស្តដែរ និងអស់អ្នកដែលបានបែកចេញពីព្រះអង្គដែរ។ នៅពេលដែលយើងអធិស្ឋានសម្រាប់អ្នកមិនជឿ យើងមានដួងចិត្តនៃការរស់នៅជាសហគមន៍ល្អជាមួយគ្នា។

### លំហាត់អនុវត្តន៍

---

៣ ហេតុអ្វីបានជាអធិស្ឋាន និង ការសញ្ជឹងគិតមានសារៈសំខាន់?

……………………………………………………………………………………………………………

……………………………………………………………………………………………………………

៤ ចូរសេរសេពីចំណុចដែលព្រះគម្ពីរប្រាប់យើងឱ្យអធិស្ឋានឱ្យ។

……………………………………………………………………………………………………………

……………………………………………………………………………………………………………

## គ្រប់គ្រងដោយសេចក្តីស្រឡាញ់បែបគ្រិស្តបរិស័ទ Be Ruled by Christian Love

ព្រះជាម្ចាស់បានប្រទានបទបញ្ញត្តិ១០ ប្រការទៅដល់ជនជាតិអ៊ីស្រាអែលដែលជាច្បាប់ដំបូងបំផុតសម្រាប់ឱ្យសហគមន៍ចេះរស់នៅដោយប្រព្រឹត្តត្រឹមត្រូវ (និក្ខមនំ ២០)។ បទបញ្ញត្តិចំនួន១០ ប្រការប្រាប់យើងអំពីទំនាក់ទំនងជាមួយព្រះជាម្ចាស់ និង ប្រជាជនទំនាក់ទងជាមួយប្រជាជន។ អ្វីៗដែលជនជាតិអ៊ីស្រាអែលធ្វើត្រូវតែសមស្របជាមួយនឹងបញ្ញត្តិទាំងនេះ។ មិនមាននរណាម្នាក់ដែលមិនស្តាប់បង្គាប់ឡើយ។ ប៉ុន្តែ ជនជាតិអ៊ីស្រាអែលមានការពិបាកក្នុងការគោរពតាមបទបញ្ញាត្តិទាំងនេះ។

ព្រះជាម្ចាស់ទតឃើញថាប្រជាជនដែលបានទទួលបញ្ញត្តិទាំងនេះពិបាកក្នុងការគោរពតាមបញ្ញត្តិដែលបានប្រទានមក។ ដូច្នេះហើយ ទើបព្រះអង្គចាត់ព្រះយេស៊ូគ្រិស្តឱ្យមក ដើម្បីស្តារឡើងវិញនូវទំនាក់ទំនងរវាងព្រះជាម្ចាស់និងមនុស្សជាតិ។ សូមអាននៅក្នុងរ៉ូម ៨:៣ និង កាឡាទី ៤:៤-៥។ ខគម្ពីរទាំងនេះ បង្ហាញពីព្រះគុណរបស់ព្រះជាម្ចាស់ និងអំពី

បំណងព្រះហឫទ័យរបស់ព្រះអង្គដែលចង់មានទំនាក់ទំនងដែលឥតខ្ចោះ (សហគមន៍) ជាមួយមនុស្សជាតិ។ ទំនាក់ទំនងរបស់មនុស្សជាមួយអ្នកដទៃរីកចម្រើនទៅបាននៅពេលដែលគេមានទំនាក់ទំនងត្រូវជាមួយព្រះជាម្ចាស់។

កាលពីខ្ញុំនៅក្មេង ខ្ញុំត្រូវបានគេចាត់ចែងឱ្យខ្ញុំធ្វើការជាមួយមនុស្សចាស់ ដែលគាត់មានជំនាញជាមួយនឹងការងាររបស់គាត់។ ប៉ុន្តែ គាត់មិនមែនស្រួលឱ្យខ្ញុំធ្វើការជាមួយគាត់ឡើយ។ ខ្ញុំបានសម្រេចចិត្តបង្ហាញសេចក្ដីស្រឡាញ់ទៅកាន់គាត់ទោះបីគាត់ធ្វើមិនល្អមកកាន់ខ្ញុំក៏ដោយ។ នៅពេលដែលគាត់ដឹងថាអ្វីដែលគាត់បានធ្វើឥតមានឥទ្ធិពលដល់ខ្ញុំ គាត់បានផ្លាស់ប្ដូរចរិតលក្ខណៈរបស់គាត់ចំពោះខ្ញុំ។ គាត់បានឆ្លើយតបចំពោះសេចក្ដីស្រឡាញ់របស់ខ្ញុំ។ តាមរយៈគាត់ខ្ញុំបានរៀនមេរៀនដ៏មានតម្លៃជាច្រើន ដែលអាចនៅតែជួយខ្ញុំដល់ពេលបច្ចុប្បន្ននេះ។ ចំណុចដ៏សំខាន់មួយដែលខ្ញុំរៀនបាននោះគឺមិនមាននរណាម្នាក់អាចតទល់ជាមួយឥរិយាបទនៃសេចក្ដីស្រឡាញ់ និងការយកចិត្តទុកដាក់ឡើយ។

នៅពេលដែលយើងបានទទួលព្រះគ្រិស្ដជាព្រះអម្ចាស់សង្គ្រោះរបស់យើង យើងទទួលបានរូបភាពផ្សេងៗគ្នាអំពីព្រះជាម្ចាស់ ព្រះគម្ពីរ និងមនុស្សដទៃទៀត។ ព្រះយេស៊ូបានធ្វើជំនួសយើង ដែលបញ្ញត្តិទាំងដប់ប្រការ ច្បាប់មិនអាចធ្វើបាន។ យើងក្លាយជាមនុស្សថ្មី នៅពេលដែលយើងបានចូលមកក្នុងសហគមន៍របស់ព្រះអង្គ (២កូរិនថូស ៥:១៧)។ ទ្រង់សរសេរច្បាប់នៃសេចក្ដីស្រឡាញ់ថ្មីនៅលើដួងចិត្តរបស់មនុស្ស (២កូរិនថូស ៣:៣)។ មានន័យថាច្បាប់នៃសេចក្ដីស្រឡាញ់បានជម្រុញយើងឱ្យស្ដាប់បង្គាប់ព្រះជាម្ចាស់ដោយព្រោះយើងស្រឡាញ់ព្រះអង្គ។ ច្បាប់នៃសេចក្ដីស្រឡាញ់របស់ព្រះអង្គគ្រប់គ្រងទំនាក់ទំនងរបស់យើងជាមួយអ្នកដទៃ។ មនសិការរបស់យើងត្រូវបានសំអាត និងគំនិតយើងត្រូវបានធ្វើឱ្យថ្មីឡើង។ ឥឡូវនេះ យើងធ្វើអ្វីតាមធម្មជាតិដែលបញ្ញត្តិធ្វើទៅតាមច្បាប់។

តើនៅពេលដែលអ្នកក្លាយជាគ្រិស្ដបរិស័ទមាននរណាម្នាក់ធ្វើអាក្រក់ដល់អ្នកដែរឬទេ? តើអ្នកខឹងដែរឬទេ? ប្រសិនបើអ្នកអនុញ្ញាតឱ្យក្ដីស្រឡាញ់ព្រះជាម្ចាស់ចាក់បំពេញក្នុងជីវិតរបស់អ្នក អ្នកនឹងអាចលើកលែងទោសដល់អ្នកដែលធ្វើអាក្រក់មកលើអ្នក។ ប្រសិនបើអ្នកជាគ្រិស្ដបរិស័ទ ឫទ្ធានុភាពរបស់ព្រះជាម្ចាស់បានផ្លាស់ប្ដូរនិស្ស័យរបស់អ្នក។ ច្បាប់នៃសេចក្ដីស្រឡាញ់របស់ព្រះអង្គបានគ្រប់គ្រងលើជីវិតរបស់អ្នកនិងអាកប្បកិរិយារបស់អ្នក។ នេះគឺជារបៀបនៃការរស់នៅនៃដួងចិត្តសហគមន៍ល្អ!

៥ ចូរបំពេញប្រយោគខាងក្រោមជាមួយនឹងពាក្យដែលត្រឹមត្រូវ

ក) ព្រះជាម្ចាស់បានប្រទានបញ្ញត្តិដែលហៅថា

……………………………………………………………………………………………………

ខ) ព្រះយេស៊ូបង្រៀនពីច្បាប់នៃ

……………………………………………………………………………………………………

គ) វាជាការងាយស្រួលក្នុងការគោរពតាមបញ្ញត្តិរបស់ព្រះជាម្ចាស់ពីព្រោះយើង

……………………………………………………………………………………………………

ឃ) ព្រះគ្រិស្តបានសរសេរច្បាប់របស់ព្រះអង្គក្នុងរបស់យើង

……………………………………………………………………………………………………

៦ ឥឡូវនេះដោយសារខ្ញុំជាគ្រិស្តបរិស័ទ ខ្ញុំងាយស្រួលក្នុងការលើកលែងទោសឱ្យដែលធ្វើខុសជាមួយខ្ញុំដោយសារ

ក) ច្បាប់ប្រាប់ខ្ញុំថា ខ្ញុំត្រូវតែលើកលែងទោស។

ខ) នៅពេលដែលខ្ញុំក្លាយជាគ្រិស្តបរិស័ទ និស្ស័យរបស់ខ្ញុំត្រូវផ្លាស់ប្តូរ។

## ការថ្វាយបង្គំជាមួយអ្នកដទៃទៀត Worship With Others

ការថ្វាយបង្គំជាមួយគ្រិស្តបរិស័ទដទៃទៀតនឹងជួយឱ្យយើងរីកចម្រើន។ យើងត្រូវការជួបជុំគ្នាជាមួយគ្នាដើម្បីសិក្សាព្រះបន្ទូលរបស់ព្រះជាម្ចាស់។ ការចូលរួមថ្វាយបង្គំទៀងទាត់នៅព្រះវិហារនិងការបង្រៀនជួយស្អាងគ្នានៅក្នុងព្រះអម្ចាស់។ ការចែកចាយទាំងអំណរនិងបញ្ហាជាមួយគ្នាគឺជួយគ្នាទៅវិញទៅមក។ មូលដ្ឋានគ្រឹះសំខាន់បំផុតសម្រាប់សហគមន៍គឺយើងត្រូវការគ្នាទៅវិញទៅមក។ យើងត្រូវការចំណាយពេលជាមួយអ្នកដែលស្គាល់និងស្រលាញ់ព្រះអម្ចាស់ដូចយើងដែរ។ តើអ្នកជួបជុំជាមួយគ្រិស្តបរិស័ទដទៃទៀតដែរឬទេ? តើអ្នកចែកចាយអំណរជាមួយគ្នាដែរឬទេ? តើអ្នកលើកទឹកចិត្តគ្នានៅពេលដែលជួបទុក្ខលំបាកដែរឬទេ? ប្រសិនបើអ្នកបានធ្វើដូច្នេះមានន័យថាអ្នកបានបង្ហាញដួងចិត្តនៃការរស់នៅជាសហគមន៍ល្អ និងរស់នៅដោយក្តីស្រឡាញ់។

៧ តើប្រយោគខាងក្រោមមួយណាដែលពន្យល់អ្នកអំពីការថ្វាយបង្គំជាមួយព្រះជាម្ចាស់ជាមួយអ្នកដទៃទៀតធ្វើឱ្យអ្នករីកចម្រើនខាងវិញ្ញាណ?

ក) នៅពេលដែលយើងចែកចាយពីក្ដីអំណរ និងទុក្ខលំបាកជាមួយគ្នា យើងចាប់ផ្ដើមដឹងថាគេត្រូវការយើង។

ខ) ការថ្វាយបង្គំ និង ការចែកចាយជាមួយគ្រិស្តបរិស័ទដទៃទៀតធ្វើឱ្យយើងមានកម្លាំង និងស្អាងគ្នាឡើងក្នុងព្រះអម្ចាស់។

## ខ. គោលការណ៍នៃការរីកចម្រើន Principles For Growth

**គោលដៅទី២. ពន្យល់អំពីគោលការណ៍នៃការញែកថ្វាយព្រះជាម្ចាស់ និង ការញែកចេញពីលោកិយ៍។**

នៅពេលដែលយើងរីកចម្រើនជាគ្រិស្តបរិស័ទដែលចេះព្រះបន្ទូលរបស់ព្រះជាម្ចាស់ អធិស្ឋាន សញ្ជឹងគិតអំពីព្រះជាម្ចាស់ ថ្វាយបង្គំព្រះអង្គ និងស្រឡាញ់ដល់អ្នកដទៃ ព្រះជាម្ចាស់ដឹកនាំយើងទៅកាន់ជីវិត*ដ៏វិសុទ្ធ*។ ពេលខ្លះព្រះគម្ពីរនិយាយអំពីការនេះការញែកចេញ។ សម្ពន្ធមេត្រីថ្មីនិយាយអំពីការញែកចេញចំនួនពីរប្រភេទ។ ទីមួយគឺ*ការញែកចេញសម្រាប់ថ្វាយព្រះជាម្ចាស់*។ ទីពីរគឺ *ការញែកពីលោកិយ*។ ចំណុចទាំងពីរសុទ្ធតែសំខាន់។

### ការញែកចេញសម្រាប់ថ្វាយព្រះជាម្ចាស់ Separation Unto God

ព្រះជាម្ចាស់បានត្រាស់ហៅអ្នកឱ្យញែកទុកសម្រាប់ព្រះអង្គ។ ទ្រង់ចង់ឱ្យអ្នកថ្វាយខ្លួន របស់អ្នកដល់ព្រះអង្គទាំងស្រុង ដើម្បីញែកឱ្យព្រះអង្គប្រើប្រាស់អ្នក។ រ៉ូម ១២:១ មានចែងថា

> ហេតុនេះ បងប្អូនអើយ ខ្ញុំសូមដាស់តឿនបងប្អូនថា ដោយព្រះជាម្ចាស់មានព្រះហឫទ័យអាណិតអាសូរ បងប្អូនចូរថ្វាយខ្លួនទៅព្រះអង្គទុកជាយញ្ញបូជាដ៏មានជីវិតដ៏វិសុទ្ធហើយជាទីគាប់ព្រះហឫទ័យរបស់ព្រះជាម្ចាស់ នេះគឺជាការថ្វាយបង្គំផ្នែកខាងវិញ្ញាណរបស់អ្នក។

នេះគឺជាការញែកថ្វាយដោយវិជ្ជមាន។ ចូរមើលក្នុងកិច្ចការ ១៣:២ «ចូរញែកបារណាបាសនិងសូលចេញដោយឡែកដ្បិតយើងបានហៅអ្នកទាំងពីរមកអោយបំពេញកិច្ចការដែលយើងនឹងដាក់អោយធ្វើ»។ សូមអានរ៉ូម ១:១ «ខ្ញុំប៉ូលជាអ្នកបំរើរបស់ព្រះគ្រិស្តយេស៊ូព្រះជាម្ចាស់បានត្រាស់ហៅខ្ញុំអោយធ្វើជាសាវ័ក និងជ្រើសរើសខ្ញុំអោយប្រកាសដំណឹងល្អរបស់ព្រះអង្គ»។ ជាថ្មីម្ដងទៀតយើងកត់ចំណាំថាជាការញែកទុក*ថ្វាយព្រះជាម្ចាស់*។ ការញែកថ្វាយព្រះជាម្ចាស់ត្រូវបានហៅថាការថ្វាយខ្លួនទាំងស្រុង ឬ ការប្ដេជ្ញាចិត្តថ្វាយព្រះជាម្ចាស់ ដើម្បីឱ្យទ្រង់អាចជួយយើងរស់នៅក្នុងជីវិតមួយដែលវិសុទ្ធ។

## ការញែកដាច់ចេញពីលោកិយ Separation From the World

នៅក្នុង ២កូរិនថូស ៦:១៤ «សូមកុំសេពគប់ជាមួយអ្នក មិនជឿឡើយ។ តើសេចក្តីសុចរិត និងសេចក្តីទុច្ចរិតចូលរួមជាមួយគ្នាកើតឬទេ? តើពន្លឺនិងភាពងងឹតចូលរួមជាមួយគ្នាកើតឬទេ?»។ ព្រះបន្ទូលនេះគឺនិយាយអំពីដៃគូដ៏ពិតប្រាកដ (សហគមន៍) មិនអាចមានអ្នកជឿនិងអ្នកមិនជឿផងឡើយ។ មានចំណុចតិចតួចប៉ុណ្ណោះដែលកើតឡើងនៅក្នុងចំណោមអ្នកជឿ និង មិនជឿ។ សូមសង្កត់ធ្ងន់ទៅលើពាក្យ «សេពគប់» «រួមជាមួយគ្នា» និង «រស់នៅជាមួយគ្នា» ពាក្យទាំងនេះប្រើនៅក្នុងសហគមន៍ក្នុងមេរៀនទីមួយ។  ខនេះប្រាប់យើងអំពីការចូលទៅក្នុងប្រភេទនៃទំនាក់ទំនងទាំងនេះជាមួយអ្នកមិនជឿ។ គឺវានិយាយអំពីទំនាក់ទំនងដែលស្និទ្ធស្នាលដូចជា ការរៀបអាពាហ៍ពិពាហ៍ ឬ ការរកស៊ីជាមួយគ្នា។ គឺមិនមែននិយាយអំពីទំនាក់ទំនងប្រចាំថ្ងៃជាមួយគ្នានៅលើផែនដីឡើយ។

យើងតែងតែនៅជាមួយនឹងមនុស្សដែលមិនមានជំនឿលើព្រះជាម្ចាស់។ មនុស្សទាំងអស់នេះគឺជាអ្នកដែលយើងត្រូវផ្សាយដំណឹងល្អឱ្យគេទទួលជឿព្រះ។ អាថ៌កំបាំងនៃការក្លាយជាកូនរបស់ព្រះជាម្ចាស់នៅក្នុងផែនដីដែលពេញដោយការអាក្រក់នេះគឺការស្គាល់ព្រះជាម្ចាស់។ អ្នកត្រូវតែអនុញ្ញាឱ្យព្រះវិញ្ញាណដ៏វិសុទ្ធគ្រប់គ្រងលើជីវិតរបស់អ្នក។ អ្នករស់នៅលើផែនដីនេះ ប៉ុន្តែ អ្នកជាប្រជាជននៃនគរស្ថានសួគ៌។ អ្នកអាចនៅជាមួយ*អ្នកមិនជឿបាន* ប៉ុន្តែ កុំធ្វើដូចអ្នក*មិនជឿ* ឡើយ!

**លំហាត់អនុវត្តន៍**

---

៨ ចូរសរសេរពាក្យថា **បាទ/ចាស** ពីមុខប្រយោគដែលបង្ហាញពីគោលការណ៍នៃការញែកទុកសម្រាប់ថ្វាយព្រះជាម្ចាស់ ឬ ការញែកចេញពីលោកិយ

……… ក ការអានព្រះគម្ពីររាល់ថ្ងៃ

……… ខ ជ្រើសរើសមានការប្រកបគ្នាជាមួយមិត្តភក្តិគ្រិស្តបរិស័ទ

……… គ ចូររួមជាមួយសកម្មភាពណាដែលអ្នកគិតថាព្រះជាម្ចាស់មិនសព្វព្រះហឫទ័យ

……… ឃ រៀបការជាមួយអ្នកមិនមែនជាគ្រិស្តបរិស័ទ

……… ង ខិតខំអធិស្ឋានទៀងទាត់

……… ច ទូលសូមការដឹកនាំពីព្រះជាម្ចាស់

……… ឆ បង្ហាញសេចក្តីស្រឡាញ់ និង ការយកចិត្តទុកដាក់ដល់អ្នកដែលខ្វះខាត

## ការចេះអត់អោន និង កុំជ្រុលហួសហេតុ Tolerance and Moderation

ពេលខ្លះគ្រិស្តបរិស័ទពិបាកក្នុងការស្គាល់ពីឥរិយាបទនៃការប្រព្រឹត្តរបស់ខ្លួន។ យើងគួរតែអនុញ្ញាតឱ្យព្រះគម្ពីរធ្វើជាអ្នកដឹកនាំយើងក្នុងវិស័យជាក់លាក់ណាមួយ និង ទូលសូមព្រះវិញ្ញាណដ៏វិសុទ្ធដឹកនាំយើងក្នុងវិស័យដទៃទៀត។

គ្រិស្តបរិស័ទមួយចំនួននិយាយថាយើងមិនស្ថិតក្រោមវិន័យទេ ដូច្នេះយើងមានសេរីភាពរស់នៅតាមខ្នាតគំរូរបស់ខ្លួនឯង។ ហេតុនេះហើយ ពួកគេព្យាយាមរស់នៅដោយផ្គាប់ព្រះហឫទ័យព្រះជាម្ចាស់នូវអ្វីដែលពួកគេធ្វើ ឬ មិនធ្វើ។ ពួកគេព្យាយាមធ្វើឱ្យព្រះជាម្ចាស់ទទួលយកពួកគេតាមរយៈការធ្វើតាមក្បួនច្បាប់ជាជាងជំនឿរបស់គេលើព្រះអម្ចាស់ព្រះយេស៊ូគ្រិស្ត។ ជំនឿគ្រិស្តបរិស័ទមិនមែនជាច្បាប់ដែលត្រូវតែដើរតាមទេ។ ជំនឿគ្រិស្តបរិស័ទជាការទទួលយកព្រះយេស៊ូគ្រិស្តជាព្រះអង្គសង្គ្រោះនិងអនុញ្ញាតឱ្យព្រះអង្គធ្វើជាព្រះអម្ចាស់គង់នៅក្នុងជីវិតយើង។ ព្រះយេស៊ូមានព្រះបន្ទូលថា៖ សុំកុំនឹកស្មានថាខ្ញុំមកលុបបំបាត់គម្ពីរវិន័យ ឬ គម្ពីរព្យាការីចោលឡើយ។ ខ្ញុំមិនមែនមកលុបបំបាត់ទេគឺខ្ញុំមកធ្វើអោយគម្ពីរមានអត្ថន័យពេញលក្ខណៈទៅវិញ (ម៉ាថាយ ៥:១៧)។

នៅពេលដែលព្រះយេស៊ូគ្រិស្តជាព្រះអម្ចាស់គ្រប់គ្រងលើជីវិតរបស់យើង យើងចង់ធ្វើអ្វីៗ ដើម្បីផ្គាប់ព្រះហឫទ័យព្រះអង្គ។ យើងមិនចង់ធ្វើរឿងណាជារឿងដែលបំផ្លាញដល់ទីបន្ទាល់ជាគ្រិស្តបរិស័ទរបស់យើងឡើយ។ យើងមិនបានជាប់ចំណងនៃការប្រព្រឹត្តដោយនិយមទៅលើក្រិត្យវិន័យ ឬ ច្បាប់ទេ ក៏មិនមែនធ្វើតាមតែចិត្តនឹកឃើញរបស់យើងដែរ។ ច្បាប់នៃសេចក្តីស្រឡាញ់របស់ព្រះគ្រិស្តជួយយើងក្នុងការអនុវត្តនូវ*ការចេះទប់ចិត្ត* ឬ មានតុល្យភាពនៃកម្រិតស្តង់ដារនៃអាកប្បកិរិយារបស់យើង។ ព្រះជាម្ចាស់មានដំណោះស្រាយជាមួយយើងផ្ទាល់ខ្លួន។ ទ្រង់ស្គាល់ពីតម្រូវការរបស់យើង។ ទ្រង់នឹងជួយយើងឱ្យមានតុល្យភាពក្នុងឥរិយាបថដែលត្រឹមត្រូវជាគ្រិស្តបរិស័ទ។

ដោយសារព្រះជាម្ចាស់មានដំណោះស្រាយសម្រាប់យើងម្នាក់ៗ យើងត្រូវតែប្រុងប្រយ័ត្នដោយមិនត្រូវថ្កោលទោសនរណាម្នាក់ទៅតាមរបៀបផ្ទាល់ខ្លួនឡើយ។ ការពន្យល់ត្រូវបានរកឃើញរ៉ូម ១៤ និង ១៥ ទាក់ទងទៅនឹងអាហារនិងការគោរពទៅតាមថ្ងៃនីមួយៗ។ ទោះបីជាគោលការណ៍នៃការបង្រៀននៅក្នុងជំពូកនេះឆ្លើយតបជាមួយនឹងចម្ងល់នៃជីវិតរស់នៅប្រចាំថ្ងៃរបស់យើងក៏ដោយ។ ខាងក្រោមនេះជាគោលការណ៍មួយចំនួន៖

1. «ហេតុនេះហើយ បានជាយើងត្រូវតែឈប់ថ្កោលទោសគ្នាទៅវិញទៅមក តែត្រូវប្ដេជ្ញាចិត្តថា មិនត្រូវធ្វើអ្វីដែលនាំអោយបងប្អូនជំពប់ដួល ឬវាតចិត្តបាត់ជំនឿនោះឡើយ» (រ៉ូម ១៤:១៣)។

2. «ដូច្នេះ យើងត្រូវស្វែងរកអ្វីដែលនាំអោយមានសេចក្ដីសុខ និងអោយមានការអប់រំគ្នាទៅវិញទៅមក» (រ៉ូម ១៤:១៩)។

3. «ប្រសិនបើយើងមិនបរិភោគសាច់ មិនពិសាស្រា និងមិនប៉ះពាល់របស់ណាដែលធ្វើអោយបងប្អូនជំពប់ចិត្តបាត់ជំនឿនោះ ជាការល្អប្រពៃហើយ។ អ្វីៗដែលអ្នកជឿថា ត្រឹមត្រូវ ចូររក្សាទុកតែម្នាក់ឯងនៅចំពោះព្រះភក្ត្រព្រះជាម្ចាស់ទៅ។ អ្នកណាមិនដាក់ទោសខ្លួនឯង ចំពោះការយល់ឃើញរបស់ខ្លួន អ្នកនោះមានសុភមង្គលហើយ!» (រ៉ូម ១៤:២១-២២)។

4. «ដូច្នេះ ត្រូវទទួលគ្នាទៅវិញទៅមកដោយរាក់ទាក់ អោយបានដូចព្រះគ្រិស្តទទួលបងប្អូនដែរ ដើម្បីលើកតម្កើងសិរីរុងរឿងរបស់ព្រះជាម្ចាស់» (រ៉ូម ១៥:៧)។

ខគម្ពីរទាំងនេះបានបង្ហាញកាន់តែច្បាស់ថាយើងត្រូវតែចេះអត់អោន ចំពោះអ្នកដទៃដែលមានខ្នាតគំរូអាកប្បកិរិយាខុសពីយើង។ ការអត់ធ្មត់មានន័យថា ការអត់ធ្មត់ និងការទទួលយកគ្នា ទោះបីជាយើងមិនស្ថិតនៅក្រោមការព្រមព្រៀងគ្នាក៏ដោយ។

ព្រះជាម្ចាស់ស្គាល់របៀបដែលព្រះអង្គត្រូវមានដំណោះស្រាយជាមួយបុគ្គលម្នាក់ៗ។ ទ្រង់ដោះស្រាយជាមួយយើងទៅតាមរបៀបមនុស្សម្នាក់ៗ។ ទ្រង់ធ្វើកិច្ចការទាំងអស់នេះ ពីព្រោះទ្រង់កំពុងនាំយើងទៅកាន់ទំនាក់ទំនងដែលស្និទ្ធស្នាលជាមួយព្រះអង្គ។ ទ្រង់ស្គាល់ពីអ្វីដែលជាសេចក្តីត្រូវការរបស់យើង។ ទ្រង់អាចត្រូវការរឿងមួយពីអ្នកគឺជាអ្វីដែលខុសពីអ្នកដទៃ។ ទ្រង់អាចធ្វើឱ្យយើងធ្វើអ្វីមួយបានហើយទ្រង់ក៏អាចមិនឱ្យយើងធ្វើអ្វីមួយបានដែរ។ យើងមិនគួរព្យាយាមធ្វើឱ្យនរណាម្នាក់ធ្វើដូចយើងឡើយនៅពេលដែលព្រះជាម្ចាស់មានព្រះបន្ទូលមកកាន់យើងទេ។ យើងទទួលគ្រិស្តបរិស័ទដទៃទៀតទៅតាមលក្ខណៈរបស់ពួកគេ និងជឿថាព្រះជាម្ចាស់នឹងដឹកនាំពួកគេ។ យើងត្រូវតែអត់ធ្មត់។

ព្រះយេស៊ូមានព្រះបន្ទូលថា «បើអ្នករាល់គ្នាថ្កោលទោស គេយ៉ាងណា ព្រះជាម្ចាស់ក៏នឹងថ្កោលទោសអ្នករាល់គ្នាយ៉ាងនោះដែរ។ ព្រះអង្គនឹងវាល់អោយអ្នករាល់គ្នា តាមរង្វាល់ដែលអ្នករាល់គ្នាវាល់អោយអ្នកដទៃ» (ម៉ាថាយ ៧:២)។ យ៉ាងណាមិញ វាមិនមែនជារឿងល្អទេ ក្នុងការដែលយើងប្រើពាក្យសម្តីមិនសមរម្យ ឬ រិះគន់ ថ្កោលទោសអ្នកដទៃនោះ។ ភាពអត់ធ្មត់ចំពោះអ្នកដទៃ គឺជាគំរូនៃច្បាប់នៃក្តីស្រឡាញ់ និងបង្ហាញនៅក្នុងការរស់នៅក្នុងដួងចិត្តជាសហគមន៍ល្អ។

**លំហាត់អនុវត្តន៍**

---

៩ តើចំណុចពីរយ៉ាងអ្វីខ្លះដែលព្រះគម្ពីរ រ៉ូម ១៤:១៩ និង ១៥:៧ ប្រាប់យើង?

………………………………………………………………………………………………….......

……………………………………………………………………………………………………

១០ ចូរគូសរង្វង់នៅខាងមុខប្រយោគត្រឹមត្រូវ

ក) ព្រះគម្ពីរប្រាប់យើងពីចរឹតលក្ខណៈដែលយើងគួរប្រព្រឹត្តនៅគ្រប់កាលៈទេសៈទាំងអស់។

ខ) ព្រះវិញ្ញាណដ៏វិសុទ្ធ អាចបង្ហាញយើងពីអ្វីដែលត្រូវ និង អ្វីដែលខុស។

គ) គ្រិស្តបរិស័ទគួរតែញែកចេញពីគ្រិស្តបរិស័ទដទៃទៀតដែលមានខ្នាតគំរូខុសពីយើង។

ឃ) ប្រសិនបើយើងថ្កោលទោសអ្នកដទៃដោយឃោរឃៅព្រះជាម្ចាស់ក៏នឹងថ្កោលទោសយើងដោយឃោរឃៅវិញដែរ។

ង) យើងគួរតែព្យាយាមធ្វើឱ្យគ្រិស្តបរិស័ទដទៃទៀត រស់នៅតាមខ្នាតគំរូរបស់យើង។

១១ តើគោលការណ៍អ្វីដែលអ្នករៀននៅក្នុងមេរៀននេះ?

ក) ចរឹតលក្ខណៈគ្រិស្តបរិស័ទ

……………………………………………………………………………………………………………………

ខ) ការនិយមលើច្បាប់

………………………………………………………………………………………………………………………

គ) ភាពអត់ធ្មត់

……………………………………………………………………………………………………………………

## សូមផ្ទៀងចម្លើយរបស់អ្នក

៧ ខ) ការថ្វាយបង្គំ និង ការចែកចាយជាមួយគ្រិស្តបរិស័ទដទៃទៀតធ្វើឱ្យយើងមានកម្លាំង និង ស្អាងគ្នាឡើងក្នុងព្រះអម្ចាស់។

១ ប្រយោគ ក និង ខ ត្រឹមត្រូវ

៨ គោលការណ៍នៃការញែកចេញចម្លើយដែលត្រឹមត្រូវគឺ ក) ខ) ង) និង ច)

២ យើងរីកចម្រើនខាងវិញ្ញាណ។

៣ គឺការធ្វើដូច្នេះជួយយើងឱ្យរីកចម្រើនខាងវិញ្ញាណ ហើយយើងមានដួងចិត្តនៃការរស់នៅជាសហគមន៍ដ៏អស្ចារ្យ។

៩ ធ្វើកិច្ចការដែលនាំមកនូវសន្តិភាព ទទួលយកគ្នាទៅវិញទៅមក។

៤ ចម្លើយរបស់អ្នក។ អាចមានដូចជា៖ សម្រាប់ការតម្រង់ទិសរបស់ព្រះជាម្ចាស់ ដើម្បីយល់ពីព្រះបន្ទូលរបស់ព្រះជាម្ចាស់សម្រាប់សេចក្តីត្រូវការរបស់យើង សម្រាប់គ្រិស្តបរិស័ទដទៃទៀតសម្រាប់អ្នកមិនជឿ។

១០ ប្រយោគ ខ) និង ឃ)។

៥ ក) បទបញ្ញត្តិ១០ប្រការ
ខ) សេចក្តីស្រឡាញ់
គ) ស្រឡាញ់ព្រះអង្គ និង ចង់ស្តាប់បង្គាប់ព្រះអង្គ
ឃ) ដួងចិត្ត

១១ ចម្លើយរបស់អ្នក។ អាចជាចម្លើយដូចខាងក្រោម៖

ក) យើងគួរតែឱ្យព្រះគម្ពីរជាអ្នកដឹកនាំយើងកែតម្រង់យើងនៅក្នុងវិស័យជាក់លាក់ណាមួយ និង ទូលសូមដល់ព្រះវិញ្ញាណដ៏វិសុទ្ធដឹកនាំយើងនៅក្នុងវិស័យដទៃទៀត។

ខ) យើងគួរតែអនុញ្ញាតឱ្យច្បាប់នៃសេចក្តីស្រឡាញ់របស់ព្រះគ្រិស្ត ដឹកនាំរាល់ទង្វើរបស់យើងជាជាងការដែលយើងគ្រាន់តែធ្វើទៅតាមបញ្ជីច្បាប់។

គ) យើងគួរតែទទួលយកអ្នកដទៃដែលគំនិតរបស់គេអាចខុសពីយើង និង ទូលសូមដល់ព្រះវិញ្ញាណដ៏វិសុទ្ធឱ្យដឹកនាំពួកគេ។

៦ ខ) នៅពេលដែលខ្ញុំក្លាយជាគ្រិស្តបរិស័ទ និស្ស័យរបស់ខ្ញុំត្រូវផ្លាស់ប្តូរ។

# មេរៀនទី ៤ ការប្រកាន់គោលជំហរនៅក្នុងសហគមន៍

## Standing in Community

«សូមអរគុណនេះ គឺជាការផ្លាស់ប្តូររបស់អ្នក»។

«ប៉ុន្តែ លោកបានធ្វើឱ្យខ្ញុំមានការផ្លាស់ប្តូរជាច្រើន។ នេះគឺជារបស់លោក»។

«អ្នកត្រឹមត្រូវណាស់។ អ្នកគឺជាមនុស្សដ៏ស្មោះត្រង់ម្នាក់! មិនមានមនុស្សច្រើនអាចធ្វើការទាំងអស់នេះបានឡើយ

«ប៉ុន្តែ ខ្ញុំជាគ្រិស្តបរិស័ទហើយព្រះគម្ពីរបង្រៀនខ្ញុំឱ្យថា យើងត្រូវតែមានភាពស្មោះត្រង់!»

អ្នកប្រហែលជាមានបទពិសោធន៍ដូចខាងលើ។ តើម្ចាស់ហាងបង្ហាញការភ្ញាក់ផ្អើលចំពោះអ្នកទេនៅពេលដែលអ្នកគាត់អាប់លុយឱ្យអ្នកលើស? ឬអ្នកមានវិធីណាផ្សេងទៀតដែលអ្នកបង្ហាញពីគោលការជាគ្រិស្តបរិស័ទរបស់អ្នកដែរឬទេ? នេះគឺជាឧទាហរណ៍នៃការបង្ហាញពីដួងចិត្តនៃសហគមន៍ល្អ។ អ្នកត្រូវប្រកាន់គោលជំហរដោយស្មោះត្រង់។ នៅក្នុងមេរៀននេះយើងនឹងស្វែងយល់ពីអត្ថន័យនៃពាក្យថាប្រកាន់គោលជំហរ។ នៅដែលយើងប្រកាន់យកជំហរអ្វីដែលត្រឹមត្រូវមិនថាទោះបីជាអ្វីកើតឡើងក៏ដោយគឺយើងកំពុងតែប្រកាន់ជំហរនៅក្នុងសហគមន៍។

## គម្រោង

ក. ការប្រកាន់យកគោលជំហរ និង ព្រះបន្ទូលរបស់ព្រះជាម្ចាស់ Standing and the Word of God

ខ. ការប្រកាន់យកគោលជំហរ និង ប្រពៃណី Standing and Tradition

គ. ការប្រកាន់យកគោលជំហរ និង ច្បាប់សហគមន៍ Standing and Regulations

## គោលដៅ

១. ពន្យល់ពីសារៈសំខាន់នៃការប្រកាន់សម្រាប់សេចក្ដីសុចរិត។

២. ពិពណ៌នាពីមធ្យោបាយដែលអ្នកអាចលើកតម្កើងព្រះជាម្ចាស់តាមរយៈប្រពៃណីនៅក្នុងសហគមន៍របស់អ្នក។

៣. ស្គាល់ពីរបៀបបង្ហាញឥរិយាបថគ្រិស្តបរិស័ទទៅកាន់សហគមន៍។

# ក. ការប្រកាន់យកគោលជំហរ និង ព្រះបន្ទូលរបស់ព្រះជាម្ចាស់

Standing and the Word of God

**គោលដៅទី១. ពន្យល់ពីសារៈសំខាន់នៃការប្រកាន់យកគោលជំហរសេចក្ដីសុចរិត**

សាវ័កប៉ូលបានជំរុញថា «ចូរបងប្អូនប្រដាប់ខ្លួនដោយគ្រឿងសស្ត្រាវុធទាំងប៉ុន្មានរបស់ព្រះជាម្ចាស់ដើម្បីអាចតតាំងនឹងកលល្បិចរបស់មារ» (អេភេសូ ៦:១១)។ ព្រះគម្ពីរបានបង្ហាញយើងនូវការឈរយ៉ាងរឹងមាំប្រឆាំងជាមួយនឹងសត្រូវរបស់យើងដោយបំពាក់នូវគ្រឿងសាស្ត្រាវុធដែលព្រះជាម្ចាស់ប្រទានមក។ តើពាក្យថាប្រកាន់ជំហរមានន័យយ៉ាងដូចម្ដេច? វាមានន័យថាប្រឆាំងនឹងអ្វីមួយ ឬ ក៏វាមានន័យថាសម្រាប់អ្វីមួយ។ នៅក្នុងករណីជាច្រើនព្រះគម្ពីរប្រាប់យើងឱ្យប្រកាន់ជំហរប្រឆាំងនឹងអ្វីមួយដែលគួរប្រឆាំង។ ជាការពិតក្នុងនាមយើងជាគ្រិស្តបរិស័ទ យើងត្រូវពេញចិត្តនឹងអ្វីដែលជារបស់ព្រះជាម្ចាស់។ ការប្រកាន់គោលជំហររឹងមាំមានន័យថាគោរពតាមបំណងព្រះហឫទ័យព្រះជាម្ចាស់នូវអ្វីដែលអ្នករៀនបានពីព្រះបន្ទូលរបស់ព្រះអង្គ។

តាមរយៈខព្រះគម្ពីរដែលបានលើកឡើងខាងលើ យើងត្រូវតែបំពាក់នូវគ្រឿងសាស្ត្រាវុធរបស់ព្រះជាម្ចាស់។ សាស្ត្រាវុធ គឺជាគ្រឿងដែកសម្រាប់បំពាក់ការពារខ្លួន។ ចូរចងចាំថាហេតុអ្វីបានជាយើងត្រូវបំពាក់គ្រឿងសាស្ត្រាវុធរបស់ព្រះជាម្ចាស់ ដូច្នេះអ្នកនឹងឈរយ៉ាងរឹងមាំប្រឆាំងនឹងល្បិចវិញ្ញាណអាក្រក់។

គ្រឿងសាស្ត្រាវុធរបស់ព្រះជាម្ចាស់បានប្រទាននូវការការពារដល់យើង។ លោកសាវ័កប៉ូលប្រាប់យើងពីផ្នែកនីមួយៗនៃគ្រឿងសាស្ត្រាវុធរបស់ព្រះជាម្ចាស់ដែលបង្ហាញយើងពីរបៀបរៀបចំខ្លួនរួចជាស្រេចដើម្បីតយុទ្ធជាមួយនឹងខ្មាំងសត្រូវ។ សាស្ត្រាវុធគឺជាងគ្រឿងសម្រាប់ការពារខ្លួនដើម្បីឱ្យយើងមានជំហររឹងមាំ។ ការនេះមានន័យថាអ្នកនឹងមិនបដិសេធនូវអ្វីដែលអ្នកជឿឡើយ។

ការប្រកាន់គោលជំហរដ៏រឹងមាំ គឺការឥតងាករេ។ ទោះបីជាមានសកម្មភាពអាក្រក់ ឬ ការបង្រៀនខុសឆ្គងអ្វីក៏ដោយ ក៏មិនប៉ះពាល់ដល់អ្នកដែរ។ ជីវិតជាគ្រិស្តបរិស័ទរបស់អ្នកនឹងបានរឹងមាំឡើងតាមរយៈការអនុវត្តន៍នូវការប្រព្រឹត្តត្រឹមត្រូវ និងតាមការបង្រៀនត្រូវ។

យើងគួរតែបង្ហាញសកម្មភាពប្រភេទនេះតាមរយៈទម្លាប់ជាគ្រិស្តបរិស័ទល្អ ដោយការទៅព្រះវិហារជាប្រចាំ។ នៅពេលដែលអ្នកដឹងថាដល់ពេលត្រូវទៅព្រះវិហារថ្វាយបង្គំព្រះអម្ចាស់អ្នកនឹងទៅ។ អ្នកមិនត្រូវស្ទាក់ស្ទើរក្នុងការសម្រេចចិត្តឡើយ។ វាគឺជាខ្នាតគំរូសម្រាប់ជីវិតរបស់អ្នក។ សម្រាប់អ្នកវាគឺជារឿងសាមញ្ញដែលអ្នកត្រូវធ្វើ។ ប៉ុន្តែ នៅក្នុងស្ថានការណ៍មួយចំនួននៅក្នុងជីវិតរបស់មនុស្សមានជំហរប្រឆាំងទៅនឹងអ្វីមួយ។ លោកប៉ូលបានផ្តល់ដំបូន្មានថា «ហេតុនេះចូរបងប្អូនប្រើគ្រឿងសស្ត្រាវុធទាំងប៉ុន្មានរបស់ព្រះជាម្ចាស់ទៅដើម្បីអោយបងប្អូនអាចតទល់នៅថ្ងៃអពមង្គល ហើយមានជំហររឹងប៉ឹងដដែល ដោយបានប្រើគ្រប់មធ្យោបាយ។ដូច្នេះ ចូរមានជំហររឹងប៉ឹងឡើង ចូរយកសេចក្តីពិតមកក្រវាត់ចង្កេះ យកសេចក្តីសុចរិតធ្វើជាអាវក្រោះ» (អេភេសូ ៦:១៣-១៤)។

នៅក្នុងកណ្ឌគម្ពីរដានីយ៉ែល៣យើងបានដឹងថាស្តេចសាងសង់រូបសំណាកនិងប្រាប់ទៅប្រជាជនឱ្យថ្វាយបង្គំរូបសំណាងនេះ។ បុរសវ័យក្មេងទាំងបីនាក់បានបដិសេធ។ ទោះបីជាគេដឹងថាទណ្ឌកម្មរបស់គេត្រូវបោះចូលទៅក្នុងចង្ក្រាន ឬ ឡភ្លើងក៏ដោយគឺគេមិនផ្លាស់ប្តូរសកម្មភាពរបស់គេឡើយ។ ស្តេចខ្ញាល់យ៉ាងខ្លាំង។ ព្រះអង្គបានឱ្យគេដុតភ្លើងដែលមានកំដៅយ៉ាងក្តៅជាងមុន។ យុវជនជំទង់ទាំងបីនាក់បានបដិសេធព្រមទាំងប្រកាន់ជំហរមិនផ្លាស់ប្តូរចិត្តឡើយ។ គេត្រូវបានបោះចូលទៅក្នុងភ្លើងដែលកំពុងតែឆេះ។ សេចក្តីស្លាប់ហាក់ដូចជាមកដល់ពួកគេ។

ប៉ុន្តែ ព្រះជាម្ចាស់មិនបានឱ្យគេស្លាប់ឡើយ។ ពួកស្តេច និង នាម៉ឺនរបស់ព្រះអង្គមានការភ្ញាក់ផ្អើលយ៉ាងខ្លាំង។ ព្រះអង្គបានហៅយុវជនទាំងបីឱ្យចេញមកខាងក្រៅ និង មានបន្ទូលទៅកាន់ពួកគេថា «ដ្បិតគ្មានព្រះណាអាចរំដោះមនុស្សដូចព្រះអង្គទេ» (ដានីញ៉ែល ៣:១៦)។ យុវជនទាំងបីនាក់បានប្រកាន់គោលជំហរមិនគោរព និងថ្វាយបង្គំព្រះក្លែងក្លាយទាំងនោះទេ។ ដោយសារតែសេចក្តីជំនឿ និងលទ្ធផលចុងក្រោយរបស់បុរសវ័យក្មេងទាំងបីនាក់បានធ្វើឱ្យស្តេច និងប្រជារាស្ត្ររបស់ព្រះអង្គបានឃើញពីឫទ្ធានុភាពដ៏អស្ចារ្យរបស់ព្រះជាម្ចាស់។

ជំនឿរបស់អ្នកត្រូវតែចេញពីចិត្ត។ នៅពេលដែលមិត្តភក្តិរបស់អ្នកមើលឃើញពីដួងចិត្តរស់នៅជាសហគមន៍របស់អ្នកនិងការឈរដោយឥតងាករេចំពោះរឿងអ្វីដែលត្រឹមត្រូវគេនឹងឱ្យតម្លៃអ្នក ហើយគេនឹងមើលឃើញពីឫទ្ធានុភាពរបស់ព្រះជាម្ចាស់នៅក្នុងជីវិតរបស់អ្នក។ នៅពេលដែលការរស់នៅជាក់ស្តែងមានអ្វីមួយជម្រុញឱ្យអ្នកបដិសេធផ្នែកណាមួយក្នុងភាពជាគ្រិស្តបរិស័ទរបស់អ្នក ចូរសម្រេចចិត្តដោយឈរលើគោលការណ៍ប្រកាន់ជំហរឥតងាករេចំពោះអ្វីដែលត្រឹមត្រូវ។

១ ការប្រកាន់ជំហរមានន័យថាការប្រឆាំងទៅនឹងអ្វីដែល
ក) មិនមែនចាប់ផ្តើមនៅក្នុងក្រុមជំនុំឡើយ។
ខ) ប្រឆាំងទៅនឹងអ្វីដែលព្រះគម្ពីរបង្រៀន។

២ ការប្រកាន់គោលជំហរទាមទារឱ្យយើង
ក) តែងតែប្រឆាំងជាមួយនឹងអ្វីមួយ។
ខ) ជារឿយៗធ្វើតម្រូវទៅតាមអ្វីមួយ។

៣ រឿងរ៉ាវអំពីយុវជនទាំងបីនាក់នៅក្នុងគម្ពីរដានីយ៉ែល បង្រៀនយើងថាយើងត្រូវតែ
ក) គោរពព្រះជាម្ចាស់ជាជាងមនុស្ស។
ខ) គោរពតាមច្បាប់របស់ខ្លួនយើងទោះបីជាគេទាមទារអ្វីក៏ដោយ។

៤ យើងត្រូវប្រកាន់ជំហរឥតងាករេ នៅពេលដែលយើង
ក) គោរពតាមព្រះបន្ទូលព្រះជាម្ចាស់ទោះបីជាពេលខ្លះវាមិនស្រួលក៏ដោយ។
ខ) ធ្វើអ្វីដែលនឹងនាំមកនូវបញ្ហាតិចតួច។

## ខ. ការប្រកាន់យកគោលជំហរ និង ប្រពៃណី Standing and Tradition

គោលដៅទី២. ពិពណ៌នាពីមធ្យោបាយដែលអ្នកអាចលើកតម្កើងព្រះជាម្ចាស់តាមរយៈប្រពៃណីនៅក្នុងសហគមន៍របស់អ្នក។

ប្រពៃណីគឺជាជំនឿ ឬ ជាទំលៀមទម្លាប់ពីជំនាន់មួយទៅជំនាន់មួយទៀត។ ទោះបីជាគេមិនបានសរសេរវាទុក ប៉ុន្តែវាពិតជាមានសារៈសំខាន់សម្រាប់ប្រជាជននៅក្នុងសហគមន៍។ ប្រពៃណីមួយចំនួនគឺល្អ និងជួយដល់មនុស្សឱ្យចងចាំពីអតីតកាលរបស់គេ។ ប្រពៃណីមួយចំនួនទៀតមិនល្អសម្រាប់គ្រិស្តបរិស័ទឡើយ។ ប្រពៃណីមួយចំនួនអាចដឹកនាំយើងឱ្យធ្វើអ្វីដែលប្រឆាំងទៅនឹងសេចក្តីបង្រៀនក្នុងព្រះគម្ពីរ។ នៅក្នុងស្ថានការណ៍បែបដូច្នេះយើងត្រូវតែមានជំហរឱ្យរឹងមាំ និងប្រកាន់យកអ្វីដែលត្រឹមត្រូវ។

ជាឧទាហរណ៍ នៅប្រទេសមួយចំនួននៅលើពិភពលោក ដែលមានសាច់ញាតិស្លាប់ជាច្រើនឆ្នាំមកហើយ មានការគោរពយ៉ាងខ្ពង់ខ្ពស់បំផុត។ ចំណុចនេះមិនមែនមានន័យថាអាក្រក់នោះទេ។ យើងត្រូវចងចាំដោយសេចក្តីគោរពចំពោះសាច់ញាតិដែលបានស្លាប់។ ប៉ុន្តែ យើងមិនមែនសម្តែងការគោរពរហូតដល់ថ្វាយបង្គំសាកសពទាំងអស់នោះទេ។ នៅពេលដែលយើងថ្វាយបង្គំដូនតារបស់យើង យើងមិនបានធ្វើតាមព្រះបន្ទូលរបស់ព្រះជាម្ចាស់ឡើយ។ នៅក្នុងនិក្ខមនំ ២០:៣ ព្រះជាម្ចាស់មានព្រះបន្ទូលថា «មិនត្រូវគោរពព្រះណាផ្សេង ក្រៅពីយើងឡើយ»។ អស់អ្នកដែលស្លាប់ទៅគឺលែង

មានទៀតហើយ។ យើងត្រូវតែចាកចេញពីគេដោយមានព្រះជាម្ចាស់។ ឥឡូវនេះយើងគួរតែរស់នៅដោយយើងដឹងប្រាកដថាវិញ្ញាណរបស់យើងនឹងទៅណានៅពេលដែលយើងស្លាប់ទៅ។

**លំហាត់អនុវត្តន៍**

---

៥ ប្រពៃណីគឺជា

ក) ជំនឿ ឬ ទំនាមទម្លាប់ គឺមានពីជំនាន់មួយទៅជំនាន់មួយទៀត។

ខ) គឺជាច្បាប់ជាលាយលក្ខណ៍អក្សររបស់គ្រួសារដែលត្រូវតែគោរព។

៦ គ្រិស្តបរិស័ទគួរតែ

ក) ព្យាយាមរកមកវិធីដែលប្រើប្រាស់ប្រពៃណីឱ្យបានល្អ សម្រាប់ជាទីបន្ទាល់របស់គ្រិស្តបរិស័ទ។

ខ) មិនមានអ្វីសម្រាប់ធ្វើជាមួយនឹងប្រពៃណីនៅក្នុងសហគមន៍ឡើយ។

៧ ចូរឆ្លើយសំណួរខាងក្រោម

ក) តើប្រពៃណីចំនួនមួយដែលបានអនុវត្តន៍នៅក្នុងប្រទេសរបស់អ្នកគឺជាអ្វី?

……………………………………………………………………………………………………………

ខ) តើមានវិធីណាទៀតដែលអាចសង្កេតឃើញថាវាមិនបានបំផ្លាញដល់បន្ទាល់អំពីគ្រិស្តបរិស័ទ? ចូរពន្យល់។

……………………………………………………………………………………………………………

គ) តើមានប្រពៃណីដែលអនុវត្តន៍នៅក្នុងសហគមន៍របស់អ្នក ដែលមិនសមរម្យសម្រាប់គ្រិស្តបរិស័ទដែរឬទេ? តើអ្នកត្រូវធ្វើយ៉ាងដូចម្តេចអំពីប្រពៃណីទាំងអស់នេះ?

……………………………………………………………………………………………………………

## គ. ការប្រកាន់យកគោលជំហរ និង ច្បាប់សហគមន៍ Standing and Regulations

**គោលដៅទី ៣. ស្គាល់ពីរបៀបបង្ហាញឥរិយាបថគ្រិស្តបរិស័ទទៅកាន់សហគមន៍។**

ព្រះជាម្ចាស់បានប្រទានរដ្ឋាភិបាល អ្នកគ្រប់គ្រង និង អាជ្ញាធរមកឱ្យយើង។ នៅក្នុង ១ធីម៉ូថេ ២:១-២ យើងត្រូវបានណែនាំឱ្យទូលអង្វរសម្រាប់អ្នកដែលជាអាជ្ញាធរគ្រប់គ្រងលើយើង។ នៅពេលដែលយើងអធិស្ឋានសម្រាប់ពួកគព្រះជាម្ចាស់នឹងប្រើប្រាស់គេដើម្បីជាអ្នកប្រទានពរ។

ព្រះគម្ពីរប្រាប់ក៏បានបង្រៀនយើងដែរថាឱ្យចុះចូលនិងគោរពចំពោះច្បាប់ដែលអ្នកគ្រប់គ្រងបានបង្កើត។ នៅក្នុងកណ្ឌគម្ពីរទីតុស ៣:១ «ចូររំលឹកដាស់តឿនបងប្អូនអោយគោរពចុះចូលនឹងអាជ្ញាធរចុះចូលនឹងរដ្ឋអំណាចអោយគេចេះស្ដាប់បង្គាប់និងប្រុងប្រៀបប្រព្រឹត្តអំពើល្អគ្រប់យ៉ាង»។ ជាគ្រិស្តបរិស័ទត្រូវតែគោរពចុះចូលជាមួយច្បាប់របស់រដ្ឋាភិបាល លើកលែងតែច្បាប់នោះផ្ទុយពីព្រះបន្ទូលរបស់ព្រះជាម្ចាស់។

រដ្ឋាភិបាលត្រូវសម្រេចចិត្តថាថ្ងៃណាជាថ្ងៃឈប់សម្រាកប្រចាំថ្ងៃ។ មានថ្ងៃសម្រាកជាច្រើនដែលជាប់ទំនាក់ទំនងជាមួយនឹងសាសនានៅក្នុងប្រទេស។ ពេលខ្លះ ថ្ងៃប្រារព្ធពិធី ជាថ្ងៃដែលមិនសំខាន់សម្រាប់គ្រិស្តបរិស័ទ។ កុំអនុញ្ញាតឱ្យការនេះរំខានអ្នកឡើយ។ អ្នកអាចថ្វាយបង្គំព្រះជាម្ចាស់ពេញមួយឆ្នាំជារៀងរាល់ថ្ងៃ។ នៅពេលដែលថ្ងៃសម្រាកបានមកដល់ចូរចំណាយពេលសម្រាក និង អរព្រះគុណជាអម្ចាស់ ដែលបំភ្លឺភ្លើងរបស់ព្រះអង្គក្នុងជីវិតរបស់អ្នក។

នៅក្នុងតំបន់មួយចំនួនថ្ងៃឈប់សម្រាកជាឱកាសដ៏ពិសេសសម្រាប់គ្រិស្តបរិស័ទ។ មនុស្សនៅតាមដងផ្លូវនឹងបានអានខិតបណ្ណំដំណឹងល្អ។ ប្រសិនបើអ្នកចង់ធ្វើកិច្ចការទាំងនេះនៅតំបន់របស់អ្នកប្រើថ្ងៃឈប់សម្រាករបស់អ្នកដើម្បីចែកចាយខិតបណ្ណំនិងធ្វើស្មរបន្ទាល់ទៅកាន់មនុស្សដែលត្រូវការព្រះគ្រិស្ត។ វាប្រហែលជាអាចទៅរួចក្នុងការអធិប្បាយព្រះបន្ទូលនៅតាមកន្លែងសាធារណៈប្រសិនបើអ្នកប្តេជ្ញាចិត្តក្នុងការធ្វើវា។ ត្រឡប់ថ្ងៃឈប់សម្រាករបស់គ្រិស្តបរិស័ទទៅជាថ្ងៃធ្វើការសម្រាប់ព្រះជាម្ចាស់។

ពេលខ្លះយើងត្រូវការកែតម្រូវគម្រោង ឬ កាលវិភាគរបស់យើងដើម្បីស្របតាមការតម្រូវរបស់រដ្ឋាភិបាល។ ជាឧទាហរណ៍នៅក្នុងប្រទេសមួយរដ្ឋាភិបាលបង្កើតច្បាប់មួយដោយធ្វើការជួបជុំខាងពិភាក្សាខាងនយោបាយនៅព្រឹកថ្ងៃអាទិត្យ។ គ្រប់គ្នាតម្រូវឱ្យចូលរួម។ ក្រុមជំនុំត្រូវតែសហការណ៍។ តើក្រុមជំនុំត្រូវធ្វើយ៉ាងដូចម្តេចក្នុងករណីបែបនេះ? ព្រះជាម្ចាស់មិនមែនមានដែនកំណត់សម្រាប់ឱ្យយើងថ្វាយបង្គំតែថ្ងៃអាទិត្យឡើយ។ ក្រុមជំនុំភាគច្រើនមានកម្មវិធីថ្វាយបង្គំរៀងរាល់ល្ងាចថ្ងៃសៅរ៍។ តាមរយៈវិធីនេះ គ្រិស្តបរិស័ទដែលគោរពច្បាប់និង នៅតែមានពេលសម្រាប់ថ្វាយបង្គំព្រះអម្ចាស់។

**លំហាត់អនុវត្តន៍**

---

៨ បទបញ្ញាត្តិគួរតែត្រូវបានគោរព

ក) ក្នុងគ្រប់សកម្មភាព។

ខ) លើកលែងតែខុសជាមួយព្រះបន្ទូលព្រះជាម្ចាស់។

៩ ថ្ងៃឈប់សម្រាកដ៏ស្របច្បាប់គួរតែ

ក) ត្រូវបានសង្កេតមើលនៅពេលដែលមានហេតុផលសាសនាសម្រាប់ពួកគេ។

ខ) ត្រូវបានរកមើលនៅពេលដែលមានឱកាសដើម្បីធ្វើជាបន្ទាល់។

១០ នៅពេលដែលមុខងាររដ្ឋាភិបាលជះឥទ្ធិពលទៅលើមុខងាររបស់ក្រុមជំនុំ គ្រិស្តបរិស័ទគួរតែ

ក) សហប្រតិបត្តិការណ៍ជាមួយ ឱ្យបានកាន់តែច្រើនកាន់តែល្អ។

ខ) មិនយកចិត្តទុកដាក់នឹងការទាមទាររបស់រដ្ឋាភិបាល។

ប្រសិនបើយើងចង់ឱ្យទីបន្ទាល់គ្រិស្តបរិស័ទរបស់យើងមានការជះឥទ្ធិពលទៅដល់សហគមន៍ យើងត្រូវប្រកាន់ជំហរដោយឥតងាករេចំពោះអ្វីដែលត្រឹមត្រូវ។ យើងគួរតែធ្វើជាប្រជាពលរដ្ឋដែលស្មោះត្រង់ឱ្យបានកាន់តែច្រើន និងបង្ហាញការគោរពដល់រដ្ឋាភិបាលនិងអ្នកដឹកនាំរបស់យើង។ នៅពេលដែលបទបញ្ញត្តិបង្កើតឡើយផ្ទុយពីគោលការណ៍ជាគ្រិស្តបរិស័ទរបស់យើង យើងត្រូវតែអធិស្ឋាននិងទូលសូមដល់ព្រះជាម្ចាស់សម្រាប់ប្រាជ្ញាដើម្បីដឹងពីរបៀបដោះស្រាយ និងជួយឱ្យយើងមានឆន្ទៈក្នុងការប្រកាន់ជំហរចំពោះព្រះជាម្ចាស់។

## សូមផ្ទៀងចម្លើយរបស់អ្នក

៦ ក) ព្យាយាមរកវិធីក្នុងការប្រើប្រាស់ប្រពៃណីសម្រាប់ជាបន្ទាល់របស់គ្រិស្តបរិស័ទ។

១ ខ) គឺប្រឆាំងទៅនឹងអ្វីដែលព្រះគម្ពីរបង្រៀន។

៧ ក) ខ) គ) ចម្លើយរបស់អ្នក។ តើអ្នកយល់ ពីមូលហេតុដែលយើងត្រូវតែប្រកាន់ជំហរប្រឆាំងទៅនឹងប្រពៃណីទាំងឡាយដែលមិនមកពីព្រះជាម្ចាស់ទេ?

២ ខ) ជារឿយៗធ្វើតម្រូវទៅតាមអ្វីមួយ។

៨ ខ) លើកលែងតែខុសជាមួយព្រះបន្ទូលព្រះជាម្ចាស់។

៣ ក) គោរពព្រះជាម្ចាស់ជាជាងមនុស្ស។

៩ ខ) ត្រូវបានរកមើលនៅពេលដែលមានឱកាសដើម្បីធ្វើជាបន្ទាល់។

៤ ក) គោរពតាមព្រះបន្ទូលព្រះជាម្ចាស់ទោះបីជាពេលខ្លះវាមិនស្រួលក៏ដោយ។

១០ ក) សហប្រតិបត្តិការណ៍ជាមួយ ឱ្យបានកាន់តែច្រើនកាន់តែល្អ។

៥ ក) ជំនឿ ឬ ទំនាមទម្លាប់ មានពីជំនាន់មួយទៅជំនាន់មួយទៀត។

## មេរៀនទី ៥

# ការសាងសង់នៅក្នុងសហគមន៍

Building in Community

មនុស្សពីរនាក់កំពុងជីករណ្ដៅ។ បុរសទីបីដើរកាត់ និង សួរសំណួរថា៖

«តើអ្នកកំពុងជីកអ្វី?»

«អូ! ខ្ញុំកំពុងជីករណ្ដៅ»។

«ចុះចំណែកលោកវិញ?»

បាទ ខ្ញុំកំពុងសាងសង់សាលារៀនដ៏ស្រស់ស្អាតមួយ។

តើអ្នកឃើញពីភាពខុសប្លែកគ្នានៃអត្តចរិក ឬ អាកប្បកិរិយារបស់អ្នកទាំងពីរដែរឬទេ? បុរសទីមួយមើលទៅការងាររបស់គាត់ថាជាការងារដ៏លំបាក។ គាត់មិនបានមើលឃើញអ្វីដែលហួសពីការងាររបស់គាត់ទេក្នុងពេលភ្លាមៗនោះ។ បុរសម្នាក់ទៀតសម្លឹងមើលទៅវែងឆ្ងាយ។ គាត់មើលឃើញសាលារៀនដ៏ស្រស់ស្អាតដែលនឹងឈរនៅកន្លែងនោះ។

តើអ្នកដូចជាបុរសទីមួយដែរឬទេ ឬ ដូចជាបុរសទីពីរ? តើអ្នកមើលឃើញអាគារដ៏ស្រស់ស្អាត ឬ ក៏មើលឃើញតែកំទេចដី? នៅក្នុងមេរៀននេះ យើងនឹងពិចារណាពីមូលដ្ឋានគ្រឹះ ដែលយើងត្រូវចាក់គ្រឹះពីលើ។ ចូរក្លាយជាអ្នកសាងសង់សម្រាប់សហគមន៍របស់យើង!

## គម្រោង

ក. ការសាងសង់នៅលើគ្រឹះដ៏ត្រឹមត្រូវ Building on Proper Foundation

ខ. ការសាងសង់ជាមួយគ្នា Building Together

គ. ការសាងសង់ស្ពាន Building Bridges

## គោលដៅ

១. ចូរពិពណ៌នាពីគ្រឹះដ៏ត្រឹមត្រូវ ដែលអ្នកត្រូវសាងសង់នៅពីលលើ។

២. ពន្យល់ពីសារៈសំខាន់នៃការសាងសង់ជាមួយអ្នកជឿដទៃទៀត។

៣. ពន្យល់លពីភាពខុសគ្នារវាងការសាងសង់ «ស្ពាន» និង ការសាងសង់ «ជញ្ជាំង»។

## ក. ការសាងសង់នៅលើគ្រឹះដ៏ត្រឹមត្រូវ Building on Proper Foundation

**គោលដៅទី១. ចូរពិពណ៌នាពីគ្រឹះដ៏ត្រឹមត្រូវ ដែលអ្នកត្រូវសាងសង់នៅពីលើ។**

ជីវិតជាគ្រិស្តបរិស័ទ ដូចគ្នាទៅនឹងអាគារមួយដែរ។ នៅខាងក្រោមគ្រឹះតែងតែមានគ្រឹះដ៏រឹងមាំ។ គ្រឹះនោះជាធម្មតាលាយពីថ្ម និង ស៊ីម៉ង់។ គ្រឹះជាអ្នកទ្រអាគារទាំងមូល។ ប្រសិនបើមិនមានគ្រឹះទេ អាគារទាំងមូលនឹងរលំ។ ដូចគ្នាផងដែរ ដួងចិត្តជាសហគមន៍របស់អ្នកត្រូវតែសាងសង់នៅលើថ្មដ៏រឹងមាំ គឺព្រះយេស៊ូគ្រិស្ត។ ព្រះអង្គជាគ្រឹះរបស់អ្នក។ លោកប៉ូលបានសរសេរថា «ដ្បិតគ្មាននរណាអាចចាក់គ្រឹះមួយផ្សេងទៀត ក្រៅពីគ្រឹះដែលបានចាក់រួចមកហើយនោះទេ ពោលគឺព្រះយេស៊ូគ្រិស្ត» (១កូរិនថូស ៣:១១)។

មូលដ្ឋានគ្រឹះព្រះគម្ពីរមានសារៈសំខាន់សម្រាប់ការរីកចម្រើនខាងវិញ្ញាណ។ នៅក្នុងម៉ាថាយ ៧:២៤-២៧ ព្រះយេស៊ូមានព្រះបន្ទូលអំពីអ្នកសាងសង់ពីរនាក់ ម្នាក់សាងសង់ផ្ទះរបស់គាត់នៅលើថ្ម និងបុរសម្នាក់ទៀតសាងសង់ផ្ទះរបស់គាត់នៅដីខ្សាច់ ដែលគ្មានគ្រឹះរឹងមាំឡើយ។ នៅពេលដែលមានព្យុះ និងទឹកជំនន់មកដល់ ផ្ទះដែលសាងសង់នៅលើដីខ្សាច់បានដួលចុះ។ ប៉ុន្តែ ផ្ទះដែលសាងសង់នៅលើថ្មនឹងមិនរលំនោះឡើយ។

នៅក្នុងរឿងនេះព្រះយេស៊ូបានមានព្រះបន្ទូលអំពីបុរសឆ្លាតដែលផ្ទះនៅលើថ្ម ប្រៀបដូចជាបុរសម្នាក់ដែលគោរពតាមព្រះបន្ទូលរបស់ព្រះគ្រិស្ត។ ថ្មដែលគាត់សាងសង់នៅលើ គឺជាការគោរពទៅនឹងការបង្រៀនរបស់ព្រះគ្រិស្ត។ បុរសដែលសាងសង់ផ្ទះរបស់គាត់នៅលើដីខ្សាច់ ប្រៀបដូចទៅនឹងមនុស្សដែលមិនបានស្ដាប់បង្គាប់តាមព្រះបន្ទូលរបស់ព្រះគ្រិស្ត។ ដីខ្សាច់ដែលគាត់សាងសង់នៅពីលើ ប្រៀបដូចជាការមិនធ្វើតាមការបង្រៀនរបស់ព្រះគ្រិស្ត។

វាគឺជារឿងមួយដែលត្រូវនិយាយថា យើងជឿលើព្រះគ្រិស្ត និងដើរដោយមិនស្ដាប់បង្គាប់ព្រះបន្ទូលរបស់ព្រះអង្គ។ ព្រះយេស៊ូមានព្រះបន្ទូលថា «អ្នកដែលចូលទៅក្នុងព្រះរាជ្យនៃស្ថានបរមសុខ មិនមែនជាអ្នកដែលគ្រាន់តែហៅខ្ញុំថា

"ព្រះអម្ចាស់! ព្រះអម្ចាស់!" ប៉ុណ្ណោះទេ គឺជាអ្នកដែលធ្វើតាមព្រះហឫទ័យព្រះបិតាខ្ញុំ ដែលគង់នៅស្ថានបរមសុខនោះវិញ។ (ម៉ាថាយ ៧:២១)។

អ្នកត្រូវការគ្រឹះដ៏រឹងមាំនៅក្នុងជីវិតរបស់អ្នកដើម្បីការពារអ្នកនៅពេលដែលមានព្យុះមកដល់។ ព្យុះនោះមកតាមរបៀបផ្សេងៗ៖ សេចក្តីស្លាប់នៃអ្នកជាទីស្រឡាញ់ ជំងឺ ការបាត់បង់តំណែង ឬ ការល្បួងល។ នៅពេលដែលយើងចាក់គ្រឹះរឹងមាំដោយស្តាប់បង្គាប់តាមព្រះជាម្ចាស់យើងមានមនសិកាច្បាស់លាស់ ហើយយើងអាចមានទំនុកចិត្តថាព្រះជាម្ចាស់នឹងជួយយើងនៅពេលដែលមានព្យុះកើតឡើង។ នៅក្នុង១យ៉ូហាន ៣:២១-២២ «យើងអានខគម្ពីរទាំងនេះ៖ ប្រសិនបើចិត្តគំនិតរបស់យើងមិនដាក់ទោសយើងទេនោះយើងនឹងមានចិត្តរឹងប៉ឹងនៅចំពោះព្រះភក្ត្រព្រះអង្គ។ អ្វីៗក៏ដោយអោយតែយើងទូលសូម យើងមុខជាទទួលពីព្រះអង្គមិនខានព្រោះយើងកាន់តាមបទបញ្ជារបស់ព្រះអង្គ និងប្រព្រឹត្តអំពើណាដែលគាប់ព្រះហឫទ័យព្រះអង្គ»។

មានតែជំនឿរបស់យើង និងគ្រឹះរបស់យើងនៅក្នុងព្រះអម្ចាស់ និង ព្រះបន្ទូលរបស់ព្រះជាម្ចាស់ តែប៉ុណ្ណោះ ដែលនឹងថែរក្សាយើងនៅពេលដែលយើងជួបទុកលំបាក។ តើព្រះអង្គជាគ្រឹះរបស់អ្នកឬ? តើអ្នកស្តាប់បង្គាប់ព្រះបន្ទូលរបស់ព្រះអង្គទេ?

## លំហាត់អនុវត្តន៍

---

១ ចូរបំពេញប្រយោគខាងក្រោមជាមួយនឹងពាក្យដែលត្រឹមត្រូវបំផុត៖

ក) ប្រសិនបើមិនមានថ្ម……………………………….ទេ អាគារនឹងដួលចុះ។

ខ) អស់អ្នកដែលសាងសង់នៅលើថ្ម…………………………………….ការបង្រៀនរបស់ព្រះគ្រិស្ត។

គ) ផ្ទះដែលសាងសង់នៅលើដីខ្សាច់នឹង……………………………….អំឡុងពេលព្យុះ។

ឃ) គ្រឹះដែលយើងគួរតែសាងសង់ជីវិតរបស់យើងនៅលើគឺ…………………… ……………………។

២ ចូរគិតអំពីជីវិតរបស់អ្នកនៅពេលដែលអ្នកបានទទួលព្រះយេស៊ូគ្រិស្តជាព្រះសង្គ្រោះរបស់អ្នក។ តើអ្នកអាចនិយាយដោយខ្លួនឯងថា អ្នកកំពុងដើរដោយស្តាប់បង្គាប់ព្រះគ្រិស្ត? …………………………………………………
ប្រសិនបើចម្លើយរបស់អ្នកទៅនឹងសំណួរនេះថា *បាទ/ចាស* អ្នកកំពុងតែពឹងផ្អែកលើគ្រឹះដ៏រឹងមាំ។ ប្រសិនបើមិនមែនទេ ចូរទូលសូមដល់ព្រះជាម្ចាស់ឱ្យជួយដល់អ្នកស្តាប់បង្គាប់ព្រះអង្គ។

## ខ. ការសាងសង់ជាមួយគ្នា Building Together

**គោលដៅទី២. ចូរពន្យល់ពីសារៈសំខាន់នៃការសាងសង់ជាមួយអ្នកជឿដទៃទៀត។**

យើងមិនគ្រាន់តែសាងសង់តែម្នាក់ឯងទេ។ ប៉ុន្តែ យើងក៏ជាផ្នែកមួយនៃក្រុមជំនុំសាកល របស់ព្រះយេស៊ូគ្រិស្ត។ អ្នកជឿទាំងអស់រួមគ្នាជារចនាសម្ព័ន្ធពេញលេញ ជាមួយអង្គព្រះគ្រិស្ត ដែលជាមូលដ្ឋានគ្រឹះ។ លោកពេត្រុស បានសរសេរថា «រីឯបងប្អូនវិញបងប្អូនប្រៀបបាននឹងថ្មដ៏មានជីវិតដែរ ដូច្នេះ ចូរផ្គុំគ្នាឡើង កសាងជាព្រះដំណាក់របស់ព្រះវិញ្ញាណធ្វើជាក្រុមបូជាចារ្យដ៏វិសុទ្ធដើម្បីថ្វាយយញ្ញបូជាខាងវិញ្ញាណជាទីគាប់ព្រះហឫទ័យព្រះជាម្ចាស់តាមរយៈព្រះយេស៊ូគ្រិស្ត» (១ពេត្រុស ២:៥)។ នៅក្នុងអេភេសូ ២:២០-២២ លោកប៉ូលមានប្រសាសន៍ថាៈ

> ព្រះអង្គបានកសាងបងប្អូនឡើងជាសំណង់ ដោយមានក្រុមសាវ័ក និងព្យាការីជាគ្រឹះ និងមានព្រះគ្រិស្តយេស៊ូផ្ទាល់ជាថ្មដ៏សំខាន់។ គឺព្រះគ្រិស្តហើយ ដែលធ្វើអោយសំណង់ទាំងមូលភ្ជាប់គ្នាយ៉ាងមាំនិងធ្វើអោយចំរើនឡើង ទៅជាព្រះវិហារដ៏វិសុទ្ធមួយ រួមជាមួយព្រះអម្ចាស់។ រីឯបងប្អូនក៏ដូច្នោះដែរ ដោយបងប្អូនរួមជាមួយព្រះអង្គ បងប្អូនបានផ្គុំគ្នាឡើង ធ្វើជាព្រះដំណាក់របស់ព្រះជាម្ចាស់ក្នុងព្រះវិញ្ញាណ។

យើងទាំងអស់គ្នាសុទ្ធតែជាថ្មនៃសំណង់ដូចគ្នា។ បទគម្ពីរបានណែនាំយើងយ៉ាងច្រើនអំពីទំនាក់ទំនងរបស់យើងជាមួយគ្នាទៅវិញទៅមក។ ទាំងនេះជា ពាក្យសំដីជាស់តឿនរបស់សាវ័កប៉ូលទៅកាន់ក្រុមជំនុំៈ

> ចូរបន្ទាបខ្លួន មានចិត្តស្លូតបូត និងចេះអត់ធ្មត់ ព្រមទាំងទ្រាំទ្រគ្នាទៅវិញទៅមកដោយសេចក្ដីស្រឡាញ់។ ចូរយកចិត្តទុកដាក់រក្សាឯកភាពដែលមកពីព្រះវិញ្ញាណ ដោយយកសេចក្ដីសុខសាន្តធ្វើជាចំណងប្រាស្រ័យទាក់ទងគ្នា។ (អេភេសូរ ៤: ២-៣)

> កុំអោយមានពាក្យអាស្រូវណាមួយចេញពីមាត់បងប្អូនឡើយផ្ទុយទៅវិញត្រូវនិយាយតែពាក្យល្អដែលជួយកសាងជំនឿអ្នកដទៃ ប្រសិនបើគេត្រូវការ ព្រមទាំងនាំព្រះពរមកអោយអ្នកស្ដាប់ផងដែរ។ (អេភេសូរ ៤: ២៩)

> ត្រូវមានចិត្តសប្បុរស និងចេះអាណិតមេត្តាដល់គ្នាទៅវិញទៅមក។ ត្រូវប្រណីសន្ដោសគ្នាទៅវិញទៅមកដូចព្រះជាម្ចាស់បានប្រណីសន្ដោសបងប្អូន ដោយសារព្រះគ្រិស្តដែរ។ (អេភេសូរ ៤: ៣២)

> ត្រូវជួយរំលែកទុក្ខធុរៈគ្នាទៅវិញទៅមក ធ្វើយ៉ាងនេះ ទើបបងប្អូនបំពេញតាមក្រឹត្យវិន័យរបស់ព្រះគ្រិស្តទាំងស្រុង។ (កាឡាទី ៦:២)

ហេតុនេះ ពេលយើងមានឱកាសនៅឡើយ យើងត្រូវប្រព្រឹត្តអំពើល្អចំពោះមនុស្សទាំងអស់ជាពិសេសចំពោះបងប្អូនរួមជំនឿ។ (កាឡាទី ៦:១០)

លើសពីនេះទៅទៀត ត្រូវមានចិត្តស្រឡាញ់ដ្បិតសេចក្តីស្រឡាញ់ធ្វើអោយបងប្អូនរួបរួមគ្នាពេញលក្ខណៈ។ (កូឡុស ៣:១៤)

ខគម្ពីរទាំងនេះបានបង្ហាញយ៉ាងច្បាស់ពីសហគមន៍អ្នកជឿថាមានទំនួលខុសត្រូវចំពោះគ្នាទៅវិញទៅមក។ នៅក្នុងចំណោមអ្នកជឿច្រើនជាជាងកន្លែងដទៃទៀតដួងចិត្តនៃការរស់នៅជាសហគមន៍គួរតែមាននៅក្នុងការប្រកបគ្នាពិធីជប់លៀងព្រះអម្ចាស់ ការទំនាក់ទំនង ការស្រឡាញ់ ការយកចិត្តទុកដាក់ ការឱ្យ និង ការទទួល។ ក្រុមជំនុំដើមបានអនុវត្តនូវដួងចិត្តបែបនេះជាមួយគ្នា (កិច្ចការ ២:៤៣-៤៧)។

នៅពេលដែលយើងកសាងសហគមន៍ជាមួយគ្នា យើងត្រូវតែផ្សាំឱ្យបាន។ ខ្ញុំមិននិយាយអំពីការផ្លាស់ប្តូរទេមនុស្សដែលងាយក្នុងការផ្សុំជាម្នាក់ដែលងាយក្នុងការចុះចូលគ្រប់ស្ថានការណ៍តាមរបៀបណាមួយដែលអាចបំពេញតម្រូវការដល់អ្នកដទៃជាមួយនឹងគោលដៅរួម។ ជាឧទាហរណ៍ មិត្តដែលអ្នកបានធ្វើទីបន្ទាល់ទៅកាន់នោះបានសុំអ្នកទៅលេងសួនសត្វនៅថ្ងៃអាទិត្យ ពេលល្ងាច។ ប៉ុន្តែ ជាធម្មតាអ្នកមានទំលាប់មួយទៅព្រះវិហារថ្ងៃអាទិត្យពេលល្ងាច។ ដូច្នេះអ្នកប្រាប់ទៅមិត្តអ្នកថាអ្នកនឹងទៅសួនសត្វមុនម៉ោងនៅថ្ងៃអាទិត្យ ហើយបន្ទាប់មកអ្នកអាចនាំមិត្តរបស់អ្នកទៅព្រះវិហារជាមួយអ្នក។ នៅក្នុងរបៀបនេះអ្នកបានធ្វើឱ្យមិត្តរបស់អ្នកពេញចិត្តតាមរយៈការប្រកបគ្នាដោយរីករាយហើយអ្នកក៏មានឧកាសក្នុងការនាំមិត្តរបស់អ្នកថ្វាយព្រះអម្ចាស់។

ប្រសិនបើយើងចង់នាំសហគមន៍របស់យើងថ្វាយព្រះគ្រិស្តពួកយើងត្រូវការមានផែនការ។ ប៉ុន្តែ ត្រូវតែអនុញ្ញាតឱ្យព្រះវិញ្ញាណដ៏វិសុទ្ធជាអ្នកដឹកនាំផែនការរបស់យើង។ ប្រសិនបើទ្រង់ចង់ផ្លាស់ប្តូរសហគមន៍សូមអនុញ្ញាតឱ្យព្រះអង្គធ្វើកិច្ចការនេះ។

ទីក្រុងសេអ៊ូល ប្រទេសកូរ៉េដែលមានប្រជាជនសរុបច្រើនជាងដប់លាននាក់។ ក្រុមជំនុំនៅសេអ៊ូដែលមានព័ន្ធការីរាប់ពាន់អ្នកដែលបម្រើព្រះអង្គក្នុងមួយសប្តាហ៍។ ប៉ុន្តែ អាគារក្រុមជំនុំរបស់គេមិនមានកន្លែងគ្រប់គ្រាន់ក្នុងការដាក់មនុស្សដ៏ច្រើនយ៉ាងនេះនោះទេ ដូច្នេះពួកគេរៀនក្នុងការផ្សុំខ្លួនដើម្បីបំពេញតម្រូវការមនុស្សទាំងនេះ។

នៅក្នុងសេអ៊ូលវាជារឿងធម្មតាសម្រាប់មនុស្សដែលមានតំបន់ផ្សេងៗពីគ្នាក្នុងទីក្រុងប្រមូលផ្តុំគ្នាសម្រាប់ការប្រជុំជាសាធារណៈនៅក្រុងកន្លែងតូចមួយ (ទីស្តីការអភិបាលក្រុង)។ នៅក្នុងតំបន់នីមួយៗមានអ្នកដឹកនាំផ្ទាល់ខ្លួនដែលជាអ្នកជួបជាមួយប្រជាជនរបស់គេផ្ទាល់។ គ្រូគង្វាលក្នុងក្រុមជំនុំត្រូវអនុវត្តន៍តាមរបៀបនេះផងដែរក្នុងការធ្វើព័ន្ធកិច្ចជាមួយមនុស្ស។ ពួកគេមិនអាចទៅព្រះវិហារទាំងអស់គ្នានោះទេ ដូច្នេះគាត់អាចនាំក្រុមជំនុំទៅកាន់កន្លែងរបស់ពួកគេត្រូវការសម្របសម្រួលដើម្បីបំពេញតម្រូវការរបស់ពួកគេ។

ប្រសិនបើមានមនុស្សបីនាក់រស់នៅក្នុងតំបន់ដូចគ្នានៅក្នុងទីក្រុងមួយ ម្នាក់ក្នុងចំណោមពួកគេបានអនុញ្ញាតឱ្យមានការជួបជុំគ្នាពេលយប់ក្នុងផ្ទះរបស់គាត់ឬនាង។ ពួកគេអញ្ជើញមិត្តភក្តិនិងអ្នកជិតខាងរបស់ពួកគេ។ ក្រុមនេះនឹងមានការរីកចម្រើនបើមានមនុស្សដែលស្វែងរកព្រះជាម្ចាស់អស់ពីចិត្ត។ នៅពេលដែលក្រុមមានមនុស្ស១២នាក់ក្រុមអាចបែកចែកបាន។ ឥឡូវមានរាប់រយក្រុមតូចនៅក្នុងទីក្រុងដែលអាចឈោងចាប់មនុស្សបាន៤៥០០០ជារៀងរាល់សប្តាហ៍។

ជាញឹកញាប់យើងតែងតែភ្លេចថាក្រុមជំនុំមិនមែនជាអាគារនោះទេក្រុមជំនុំគឺជាមនុស្ស។ ក្នុងការដែលយើងថ្វាយបង្គំរួមគ្នាជាការសំខាន់ ប៉ុន្តែ យើងត្រូវមានឆន្ទះក្នុងការសម្របសម្រួល នៅពេលដែលចាំបាច់ដើម្បីឈោងចាប់មនុស្សគ្រប់ទីកន្លែងដោយដំណឹងល្អ។

**លំហាត់អនុវត្តន៍**

---

៣ ចូរសរសេរចរិកលក្ខណៈចំនួនប្រាំមួយដែលយើងគួរតែមានចំពោះមនុស្សដទៃ។

៤ ចូរគូសរង្វង់ជុំវិញចរិកលក្ខណៈណាដែលអ្នកត្រូវការអភិវឌ្ឍន៍ក្នុងជីវិតរបស់អ្នក។

៥ ការសម្របសម្រួល មានន័យថាជាការផ្លាស់ប្តូរសម្ភារៈ ឬ វិធីសាស្ត្រក្នុងការធ្វើអ្វីមួយ

ក) ផ្លាស់ប្តូរគោលបំណងចំបងរបស់អ្នក

ខ) តាមរយៈការផ្លាស់ប្តូរគោលបំណងចំបងរបស់អ្នក

៦ ប្រសិនបើអ្នកចង់នាំមនុស្សថ្វាយព្រះអម្ចាស់ អ្នកត្រូវ

ក) រង់ចាំរហូតដល់ពួកគេទៅក្រុមជំនុំរបស់អ្នក

ខ) បង្កើតឱកាសដើម្បីធ្វើបន្ទាល់ទៅកាន់ពួកគេនៅកន្លែងដែលពួកគេរស់នៅ

៧ ដួងចិត្តនៃការសម្របសម្រួលគឺ

ក) អាត្មានិយម

ខ) មិនអាត្មានិយម

## គ. ការកសាងស្ពាន Building Bridges

**គោលដៅទី៣. ពន្យល់លពីភាពខុសគ្នា រវាងការសាងសង់ «ស្ពាន» នឹង ការសាងសង់ «ជញ្ជាំង»។**

ជាច្រើនឆ្នាំមកហើយដែលគេប្រើឥដ្ឋនិងថ្មជាគ្រឿងក្នុងការសាងសង់។ ឥដ្ឋនិងថ្មដូចគ្នាត្រូវបានប្រើក្នុង ដើម្បីសាងសង់ក្រុមជំនុំមន្ទីរពេទ្យនិងគុកផងដែរ។ គ្រឿងសំណង់ដែលគេប្រើសម្រាប់សាងសង់ស្ពានអាចប្រើសម្រាប់សង់ធ្វើជញ្ជាំងផងដែរ។ អ្វីដែលជាភាពខុសគ្នាគឺផែនការរបស់អ្នកសាងសង់ប៉ុណ្ណោះ។

ស្ពានអាចជួយមនុស្សឱ្យឆ្លងកាត់ព្រំប្រទល់ក្នុងទិសដៅពីរបាន។ ពួកគេមានន័យថាមានសហគមន៍មានទំនាក់ទំនងគ្នា។ យើងចងចាំនៅក្នុងមេរៀនទីមួយរបស់យើងដែលបានលើកឡើងអំពីអត្ថន័យគ្រឹះនៃពាក្យកូណូនា (Koinonia) បានបង្ហាញអំពីទំនាក់ទំនងពីរទំនាក់ទំនងនៃការឱ្យនិងការទទួល។ ពួកយើងកសាងស្ពានតាមរយៈ មិត្តភាព ការជួយគ្នា និងធ្វើជាមនុស្សដែលគេអាចពឹកពាក់បាននៅពេលដែលគេត្រូវការ។ ឬយើងកសាងជញ្ជាំងតាមរយៈការមិនរាប់អានគ្នា និងការពារខ្លួនយើងមិនឱ្យមានទំនាក់ទំនងជាមួយមនុស្សដទៃ។

គ្រិស្តបរិស័ទត្រូវព្យាយាមមានទំនាក់ទំនងឬមិត្តភាពជាមនុស្សគ្រប់វណ្ណៈទាំងអស់ក្នុងសង្គម។ យើងកសាងជញ្ជាំងនៅពេលដែលយើងគិតថាយើងប្រសើរជាងមនុស្សផ្សេងទៀត។ យើងក៏កសាងជញ្ជាំងផងដែរនៅពេលដែលយើងបដិសេធមិនឈោងចាប់មនុស្សដែលយើងគិតថាពួកគេមានឋានៈខ្ពង់ខ្ពស់ជាងយើង។ ទោះបីអ្នកជា កសិករ អ្នកពិសោធ អ្នកជំនួញ ឬ ក៏អ្នកធ្វើការនៅជួររាជរដ្ឋាភិបាលអ្នកអាចមានមិត្តភាពជាមួយមនុស្សដែលមានឋានៈឬ វណ្ណៈខុសពីអ្នកបាន។ បន្ទាប់មកអ្នកត្រូវព្យាយាមនាំពួកគេថ្វាយព្រះអម្ចាស់។ ខ្ញុំមិនអាចនាំនរណាម្នាក់ថ្វាយព្រះអម្ចាស់ដោយមិនបង្កើតមិត្តភាពជាមួយគាត់ជាមុននោះឡើយ។

ជញ្ជាំងបែងចែកនិងញែកមនុស្សចេញពីគ្នា។ ប្រហែលជាអ្នកធ្លាប់បានអានអំពីជញ្ជាំងដ៏អស្ចារ្យបំផុតនៅក្នុងប្រទេសចិនដែលបានកសាងអស់រយៈពេលរាប់រយឆ្នាំមកហើយ ប៉ុន្តែ នៅតែមានភាពរឹងមាំ។ ជញ្ជាំងត្រូវបានកសាងឡើងដើម្បីការពារមនុស្សមួយចំនួនពីខាងក្រៅនិងដើម្បការពារមនុស្សដទៃទៀតនៅខាងក្នុងជញ្ជាំងផងដែរ។ នៅក្នុងការប្រៀបធៀបមួយគឺការកសាងជញ្ជាំងមានសុវត្ថិភាពជាងការកសាងស្ពាន។ នៅពេលដែលយើងកសាងស្ពានយើងកំពុងតែផ្សងជាមួយការឈឺចាប់ និងការបដិសេធ។ ប៉ុន្តែ ព្រះយេស៊ូបានធានាអះអាងជាមួយយើងថា «អ្នករាល់គ្នាជួបនឹងទុក្ខវេទនានៅក្នុងលោក ប៉ុន្តែ ចូរមានសង្ឃឹមឡើង! ខ្ញុំបានឈ្នះលោកនេះហើយ» (យ៉ូហាន ១៦:៣៣)។ ព្រះយេស៊ូមិនបានអធិស្ឋានថាសូមឱ្យព្រះជាម្ចាស់ដកយកយើងចេញពីផែនដីនេះឡើយ ប៉ុន្តែ ទ្រង់បានអធិស្ឋានថាសូមឱ្យព្រះជាម្ចាស់ថែរក្សាការពារយើងចេញពីមារកំណាចនៅលើផែនដីនេះវិញ (យ៉ូហាន ១៧:១៥)។

នៅពេលដែលយើងឈោងចាប់មនុស្សដទៃមានពេលខ្លះជញ្ជាំងត្រូវតែដួលចុះ។ មានជញ្ជាំង សង្គម ក្រមសីលធម៌ វប្បធម៌ និងសាសនាតម្រូវឱ្យយើង កំទេច ឬ បំផ្លាញដើម្បីកសាងសហគមន៍មួយបាន។ ព្រះយេស៊ូផ្ទាល់បានរលំ ឬ បំផ្លាញជញ្ជាំងនៅពេលដែលទ្រង់មានព្រះបន្ទូលទៅកាន់ស្ត្រីសាសន៍សាម៉ារីនៅឯអណ្តូងទឹក (យ៉ូហាន ៤:៧-៩)។

យើងត្រូវតែបន្តជ្រើសរើសរវាងការកសាងជញ្ជាំងឬស្ពាននៅក្នុងសហគមន៍គ្រិស្តបរិស័ទរបស់ពួកយើងនិងនៅក្នុងសហគមន៍ដ៏ធំនៅក្នុងពិភពលោករបស់យើងនេះ។ តើអ្នកបានបង្ហាញដួងចិត្តនៃសេចក្តីស្រឡាញ់ដ៏ពិតទៅកាន់សហគមន៍របស់អ្នកដែរឬទេ? តើអ្នកបាននាំព្រលឹងមនុស្សបាត់បង់មកថ្វាយព្រះគ្រិស្តតាមរយៈការនាំជីវិតរបស់ពួកគេទៅកាន់ជីវិតរបស់អ្នកដែរឬទេ? សហគមន៍របស់អ្នកនឹងស្គាល់ពីអត្ថន័យដ៏ពិតនៃពាក្យថាដួងចិត្តនៃសហគមន៍នៅពេលដែលអ្នកជាព័ន្ធការីនៃក្តីស្រឡាញ់។

### លំហាត់អនុវត្តន៍

---

៨ ចូរសរសេរអក្សរ W ប្រសិនបើសកម្មភាពបង្កើតជាជញ្ជាំងនិងចូរអក្សរ B ប្រសិនបើសកម្មភាពបង្កើតជាស្ពាននៅពីមុខប្រយោគនីមួយៗ។

..........ក មើលថែអ្នកដែលមានជំងឺ

..........ខ នាំនរណាម្នាក់ទៅព្រះវិហារ

..........គ បដិសេធចំពោះមនុស្សដែលមានលក្ខណៈខុសពីអ្នកនៅពេលដែលពួកគេសូមអ្នកចូលរួមក្នុងកម្មវិធីនៅក្នុងសហគមន៍

.........ឃ សម្អាតផ្ទះឱ្យមនុស្សដែលមានជំងឺ

.........ង រើសអើងចំពោះមនុស្សដែលមានឋានៈខុសពីអ្នក

.........ច សួរសុខទុក្ខមនុស្សដែលនៅមន្ទីរពេទ្យ ឬ នៅក្នុងគុក

.........ឆ អញ្ជើញនរណាម្នាក់ទៅផ្ទះរបស់អ្នកសម្រាប់ការប្រកបគ្នា

.........ជ និយាយអំពីមនុស្សដែលធ្វើឱ្យអ្នកមានការឈឺចាប់

ឥឡូវនេះអ្នកបានបញ្ចប់ជំពូកទីមួយរួចរាល់ហើយអ្នកត្រៀមខ្លួនដើម្បីឆ្លើយសំណួរនៅក្នុងជំពូកវាយតម្លៃទីមួយ។ រលឹកមេរៀនមុនបន្ទាប់មកធ្វើតាមការណែនាំដែលមាននៅក្នុងសន្លឹកចម្លើយ។ សូមផ្ញើរសន្លឹកសម្លើយរបស់អ្នកទៅកាន់អាស័យដ្ឋានចុះឈ្មោះរបស់អ្នក។

## សូមផ្ទៀងផ្ទាត់ចម្លើយរបស់អ្នក

៥ ក) ដោយគ្មានការផ្លាស់ប្តូរគោលបំណងចំបងរបស់អ្នក

១ ក) គ្រឹះ
ខ) ការស្តាប់បង្គាប់
គ) ការដួលចុះ
ឃ) ព្រះយេស៊ូគ្រិស្ត

៦ ខ) បង្កើតឱកាសដើម្បីធ្វើបន្ទាល់ទៅកាន់ពួកគេនៅកន្លែងដែលពួកគេរស់នៅ

២ ចម្លើយរបស់អ្នក

៧ ខ) មិនអាត្មានិយម

៣ ចម្លើយដែលអាចទៅរួច ស្លូតបូត អត់ធ្មត់ បន្ទាបខ្លួន អត់ឱន សប្បុរស អត់ទោស មេត្តាករុណា ក្តីស្រឡាញ់ ដួងចិត្តដែលទន់ភ្លន់។

៨ ក) ស្ពាន
ខ) ស្ពាន
គ) ជញ្ជាំង
ឃ) ស្ពាន
ង) ស្ពាន
ច) ជញ្ជាំង
ជ) ស្ពាន
ឈ) ជញ្ជាំង

៤ ចម្លើយរបស់អ្នក។ ព្រះវិញ្ញាណដ៏វិសុទ្ធនឹងជួយអ្នកដើម្បីអភិវឌ្ឍឥរិយាបថដែលត្រឹមត្រូវ។

# ជំពូក

# ៣

## មេរៀន


៦ ការរៀនពីព្រះយេស៊ូ Learning from Jesus

៧ ការជះពន្លឺក្នុងសហគមន៍របស់អ្នក Shining in Your Community

៨ សមាជិកភាពនៅក្នុងក្រុមជំនុំសហគមន៍
Belonging in the Church Community

៩ ការបរិច្ចាគនៅក្នុងសហគមន៍ Contributing to Your Community

១០ ការបន្តនៅក្នុងសហគមន៍ Continuing in Community

មេរៀនទី

៦

# ការរៀនអំពីព្រះយេស៊ូ

## Learning from Jesus

ម្ដាយនិងកូនប្រុសតូចកំពុងនិយាយគ្នា។

"អ្នកម៉ែ តើម៉ែនៅទីណានៅពេលដែលព្រះយេស៊ូនៅជាកុមារ?"

"ហេតុអ្វី? ម៉ែកើតមិនទាន់ទេកូនប្រុស។ ព្រះយេស៊ូបានគង់នៅតាំងពីយូ ប្រហែលជាជាង២០០០ឆ្នាំមុន។

"អូរ! កូនស្មានថាព្រះអង្គមានព្រះជន្មគង់នៅពេលដែលម៉ែនៅជាតូចនៅឡើយ។ ដោយសារតែកូនឃើញម៉ាក់ហាក់បីដូចជាចូលចិត្តនិយាយអំពីព្រះអង្គ។

វាពិតជារឿងមួយដ៏អស្ចារ្យនៅពេលដែលយើងស្គាល់នរណាម្នាក់ដែលតែងតែនិយាយអំពីព្រះយេស៊ូ។ វាជាការពិតណាស់ថាគ្រប់រឿងរ៉ាងដែលយើងនិយាយស្ទើរតែទាំងអស់ចេញពីចិត្តរបស់យើង។

នៅក្នុងមេរៀននេះ អ្នកនឹងសិក្សាពីកុមារភាពព័ន្ធកិច្ចនិងឥទ្ធិពលរបស់ព្រះយេស៊ូនៅពេលដែលទ្រង់មានព្រះជន្មនៅលើផែនដី និងឥទ្ធិពលរបស់ទ្រង់នៅតែបន្តនៅលើផែនដី។ ទ្រង់ជាគ្រូបង្រៀនដ៏អស្ចារ្យដែលមានព្រះជន្មរស់។ ការនៅជាប់ជាមួយព្រះអង្គនឹងជួយយើងឱ្យរស់នៅកាន់តែដូចព្រះអង្គ។

## គម្រោង

ក. កុមារភាពរបស់ព្រះយេស៊ូ The Childhood of Jesus

ខ. ទំនាក់ទំនងរបស់ព្រះយេស៊ូទៅកាន់សហគមន៍របស់ព្រះអង្គ Jesus' Relationship to His Community

គ. ឥទ្ធិពលរបស់ព្រះយេស៊ូ The Influence of Jesus

## គោលដៅ

១. ពិពណ៌នាពីរបៀបដែលព្រះយេស៊ូមានការពាក់ព័ន្ធជាមួយសហគមន៍នៅអំឡុងពេលកុមារភាពរបស់ព្រះអង្គ។

២. ពិពណ៌នាអំពីការពាក់ព័ន្ធរបស់ព្រះយេស៊ូនៅក្នុងសហគមន៍នៅពេលដែលព្រះអង្គពេញវ័យ។

៣. ពិពណ៌នាពីឥទ្ធិពលរបស់ព្រះយេស៊ូនៅក្នុងពិភពលោក។

## **ក. កុមារភាពរបស់ព្រះយេស៊ូ** The Childhood of Jesus

**គោលដៅទី១. ពិពណ៌នាពីរបៀបដែលព្រះយេស៊ូមានការពាក់ព័ន្ធជាមួយសហគមន៍នៅអំឡុងពេលកុមារភាពរបស់ព្រះអង្គ។**

ទោះបីជាស្ថិតនៅក្នុងវ័យកុមារភាពព្រះយេស៊ូមានការទំនាក់ទំនងជាមួយសកម្មភាពជាច្រើននៅក្នុងសហគមន៍របស់ព្រះអង្គ។ ឪពុកម្ដាយរបស់ព្រះអង្គជាសាសន៍យូដាដែលគោរពតាមទំនៀមទំលាប់យូដា។ នៅក្នុងលូកា ២:២១ បានប្រាប់ថា ពួកគេបាននាំព្រះយេស៊ូទៅធ្វើពិធីកាត់ស្បែក និងថ្វាយព្រះនាមឱ្យព្រះអង្គនៅពេលដែលទ្រង់ប្រសូតបានមួយសប្តាហ៍។ តាមរយៈការធ្វើកិច្ចការទាំងអស់នេះ ពួកគេអនុលោមតាមសេចក្ដីបង្រៀននៅក្នុងសម្ពន្ធមេត្រីចាស់។ ការកាត់ស្បែកជាប្រពៃណីដ៏មានសារសំខាន់មួយនៅក្នុងសហគមន៍យូដា។ នេះគឺជាសញ្ញាសម្គាល់ខាងផ្នែករាងកាយនៃសម្ពន្ធមេត្រីរបស់ព្រះជាម្ចាស់ (កិច្ចព្រមព្រៀង) ជាមួយប្រជាជាតិអ៊ីស្រាអែល (លោកុប្បត្តិ ១៧:៩-១៤)។

នៅក្នុងពិធីថ្វាយព្រះយេស៊ូគឺជាពេលវេលាមួយដែលសប្បាយរីករាយរបស់ឪពុកម្ដាយព្រះអង្គ ម៉ារី និងយ៉ូសែប។ ពួកគេបានធ្វើដំណើរទៅកាន់ក្រុងយេរូសាឡឹមដើម្បីថ្វាយព្រះយេស៊ូទៅកាន់ព្រះអម្ចាស់។ (សូមអានអំពីប្រវត្តិអំពីពិធីបុណ្យនេះនៅក្នុង(និក្ខមនំ ១៣:១-២ និងលេវីវិន័យ ១២:៣,៨) នៅក្រុងយេរូសាឡឹម ឪពុកម្តាយព្រះយេស៊ូបានយកសត្វព្រាប ឬសត្វស្លាបចំនួនពីរមកថ្វាយជាយញ្ញបូជាដោយអនុវត្តតាមក្រឹត្យវិន័យរបស់លោកម៉ូសេ (លូកា ២:២២-២៤)។ ជាថ្មីម្តងទៀត យើងឃើញថាឪពុកម្តាយរបស់ព្រះអង្គបានធ្វើនូវអ្វីដែលមានកំណត់ទុកនៅក្នុងសាសនាយូដា។ ពួកគេទទួលស្គាល់ជាមួយសហគមន៍របស់ពួកគេ។

នៅក្នុងពិធីថ្វាយព្រះយេស៊ូមានបុរសចំណាស់ម្នាក់ឈ្មោះស៊ីម្មានបានរង់ចាំជួបជាមួយព្រះមេស្ស៊ីដែលព្រះអម្ចាស់បញ្ជូនមក។ នៅក្នុងលូកា ២:២៧-២៨៖

> ព្រះវិញ្ញាណនាំលោកស៊ីម្មានចូលក្នុងព្រះវិហារ។ ពេលមាតាបិតានាំព្រះឱរសយេស៊ូមកថ្វាយព្រះជាម្ចាស់ដូចមានចែងទុកក្នុងក្រឹត្យវិន័យលោកស៊ីម្មានក៏យកព្រះឱរសមកបី រួចសរសើរតម្កើងព្រះជាម្ចាស់។

លោកស៊ីម្មានបានប្រទានពរព្រះយេស៊ូ ដោយនិយាយថាព្រះយេស៊ូគឺជាព្រះមេស្ស៊ី និងជាពន្លឺរបស់សាសន៍ដទៃ។ លោកក៏បានថ្លែងទំនាយអំពីព័ន្ធកិច្ចរបស់ព្រះយេស៊ូផងដែរ។

បន្ទាប់មកមានស្ត្រីម្នាក់ទៀតឈ្មោះអាណាបានមកព្រះវិហារហើយនាងក៏បានសរសើរតម្កើងព្រះជាម្ចាស់ដែលបានបញ្ជូនព្រះបុត្រាមកបង្ហាញពីផ្លូវដើម្បីទទួលសេរីភាព។ ការបង្ហាញពីអារម្មណ៍អំណរសាទរនៅពេលដែលបានឃើញព្រះយេស៊ូទាំងនេះបង្ហាញថាព្រះហឫទ័យរបស់ព្រះជាម្ចាស់នឹងសម្រេច។ ព្រះជាម្ចាស់សព្វព្រះហឫទ័យជាមួយការអនុវត្តតាមវប្បធ៌ម និងប្រពៃណីសាសនា។

លោកយ៉ូសែប និងនាងម៉ារីគឺជាមនុស្សសាមញ្ញដែលព្រះជាម្ចាស់បានជ្រើសរើស ដើម្បីធ្វើជាឪពុកម្ដាយរបស់ព្រះយេស៊ូនៅលើផែនដី។ សាច់រឿងដែលនិយាយអំពីកុមារភាពរបស់ព្រះយេស៊ូគឺខ្លីបំផុត។ វាបានបង្ហាញថាទ្រង់ប្រសូតមកតាមរបៀបធម្មតា។ ព្រះគម្ពីរមិនបានប្រាប់យើងពីអ្វីផ្សេងទៀតលំអិតអំពីព្រះយេស៊ូរហូតដល់ទ្រង់មានព្រះជន្ម១២ព្រះវស្សា។ នៅសម័យកាលនោះពួកគេធ្វើជារៀងរាល់ឆ្នាំគ្រួសារព្រះយេស៊ូបានធ្វើដំណើរពីទីឆ្ងាយទៅកាន់ក្រុងយេរូសាឡឹមដើម្បីពិធីបុណ្យចម្លង ជាថ្ងៃដ៏ពិសិដ្ឋរបស់សាសន៍យូដា។

(សូមអានដំណើររឿងអំពីព្រះយេស៊ូនៅក្នុងព្រះវិហារនៅបទគម្ពីរលូកា ២:៤១-៥១)។ នៅពេលពិធីបុណ្យបញ្ចប់គ្រួសាររបស់ព្រះយេស៊ូបានត្រឡប់មកផ្ទះវិញជាមួយមនុស្សដទៃទៀតនៅក្នុងសហគមន៍របស់ពួកគេ។ បន្ទាប់ពីធ្វើដំណើរអស់រយៈពេលមួយថ្ងៃពួកគេដឹងថាព្រះយេស៊ូមិនបានមកជាមួយពួកគេទេ។ នាងម៉ារី និង លោកយ៉ូសែបខិតខំរកព្រះយេស៊ូហើយភ័យនិងបារម្ភជាខ្លាំង។ នៅពេលដែលពួកគេរកព្រះអង្គឃើញ ពួកគេនៅតែមិនយល់ពីហេតុផលដែលទ្រង់គង់នៅក្រុងយេរូសាឡឹម។ ប៉ុន្តែ ព្រះកុមារមានព្រះបន្ទូលតបថា៖ «តើលោកឪពុកអ្នកម្ដាយមិនជ្រាបថា កូនត្រូវនៅក្នុងដំណាក់ព្រះបិតារបស់កូនទេឬ?» (លូកា ២:៤៩)។ ទោះបីជាមានព្រះជន្មវ័យក្មេងក៏ដោយ ព្រះយេស៊ូបានប្រកាសពីបេសកម្មរបស់ព្រះអង្គទៅកាន់សហគមន៍របស់ព្រះអង្គនិងពិភពលោក។

ព្រះយេស៊ូបានត្រឡប់ទៅភូមិណាសារ៉ែតជាមួយមាតាបិតាវិញ ហើយធ្វើតាមឱវាទរបស់ពួកគាត់ទាំងពីរនាក់ (លូកា ២:៥១)។ ព្រះយេស៊ូបានផ្ដល់អំណាចកំពូលទៅកាន់ឪពុកម្ដាយរបស់ព្រះអង្គ ព្រះអទិករបានផ្ដល់អំណាចមួយផ្នែកទៅកាន់អ្វីដែលព្រះអង្គបានបង្កើត។ សេចក្ដីពិតនេះជាការសារសំខាន់ណាស់ នៅក្នុងលូកា ២:៥២ ជាខគន្លឹះដែលធ្វើឱ្យយើងយល់ពីព្រះយេស៊ូនៅក្នុងសហគមន៍របស់ព្រះអង្គ «ព្រះយេស៊ូមានវ័យចំរើនឡើងហើយមានប្រាជ្ញាកាន់តែវាងវៃជាទីគាប់ព្រះហឫទ័យព្រះជាម្ចាស់និងជាទីគាប់ចិត្តមនុស្សផងទាំងពួង»។ ព្រះយេស៊ូមានទំនាក់ទំនងជាមួយព្រះជាម្ចាស់ និងជាមួយសហគមន៍របស់ព្រះអង្គ។

១ ព្រះយេស៊ូត្រូវបាននាំទៅព្រះវិហារពីព្រោះទ្រង់គឺ

ក) មានលក្ខណៈខុសពីក្មេងៗសាសន៍យូដាដទៃទៀត។

ខ) បង្ហាញចំពោះព្រះជាម្ចាស់ដូចជាក្មេងៗ កុមារនៃសាសន៍យូដាដទៃទៀត។

២ យ៉ូសែប និងនាងម៉ារីនាំព្រះយេស៊ូទៅកាន់ក្រុងយេរូសាឡឹមជារៀងរាល់ឆ្នាំពីព្រោះ៖

ក) វាគឺជាប្រពៃណីដែលត្រូវចូលរួមពិធីបុណ្យនៅទីនោះ។

ខ) ពួកគេចូលចិត្តទៅសួរសុខទុក្ខសាច់ញាតិនៅទីនោះ។

៣ ព្រះគម្ពីរបានបង្ហាញថា ពេលទ្រង់ចម្រើនវ័យឡើង ព្រះយេស៊ូគឺ

ក) មានការទទួលស្វាគមន៍ល្អបំផុតពីសហគមន៍របស់ព្រះអង្គ

ខ) មិនស្ថិតនៅក្នុងផ្នែកណាមួយនៃសហគមន៍នោះទេ

៤ យើងដឹងថាព្រះយស៊ូ

ក) មិនដែលអនុញ្ញាតឱ្យមនុស្សប្រាប់ព្រះអង្គពីអ្វីដែលត្រូវធ្វើនោះទេ

ខ) ស្តាប់បង្គាប់ដល់អស់អ្នកដែលមានឋានៈលើព្រះអង្គ

## ខ. ទំនាក់ទំនងរបស់ព្រះយេស៊ូទៅកាន់សហគមន៍របស់ព្រះអង្គ

Jesus' Relationship to His Community

**បំពេញតាមតម្រូវការ** Ministering to Needs

**គោលដៅទី២. ពិពណ៌នាអំពីការពាក់ព័ន្ធរបស់ព្រះយេស៊ូនៅក្នុងសហគមន៍នៅពេលដែលព្រះអង្គពេញវ័យ ។**

ព្រះយេស៊ូចាប់ផ្តើមព័ន្ធកិច្ចនៅពេលដែលទ្រង់មានព្រះជន្មប្រហែល៣០ព្រះវស្សា។ អំឡុងរយៈពេលបីឆ្នាំនៃការបម្រើព័ន្ធកិច្ច ទ្រង់តែងតែមានទំនាក់ទំនងជាមួយមនុស្សផ្សេងទៀតនៅក្នុងសហគមន៍របស់ព្រះអង្គ។ ព្រះយេស៊ូមានទំនាក់ទំនងយ៉ាងជិតស្និទ្ធជាមួយសាវ័កទាំង១២នាក់ និងបានចំណាយជាច្រើនដើម្បីហ្វឹកហ្វឺនពួកគេ។ ព្រះយេស៊ូនិងសាវ័ករស់នៅជាហគមន៍ដែលមានទំនាក់ទំនងយ៉ាងជិតស្និតទ្ធជាមួយគ្នាក្នុងអំឡុងពេលបីឆ្នាំនៃព័ន្ធកិច្ចរបស់ព្រះអង្គនិងពួកគេប្រើថង់ដង្វាយឬថវិការួមគ្នា (យ៉ូហាន ១:២៦)។ ពួកគេមានបទពិសោធជាមួយការរស់នៅជាក់ស្តែងក្នុងសហគមន៍។

ព្រះយេស៊ូក៏មានអ្នកដើរតាមផ្សេងទៀតដែលរស់នៅក្នុងសហគមន៍ជាមួយព្រះអង្គ។ នាងម៉ារី នាងម៉ាថា និងលោកឡាសារ គឺជាមិត្តភក្តិជិតស្និទ្ធរបស់ព្រះអង្គ។ នៅក្នុងពេលមួយព្រះយេស៊ូបានបញ្ជូនសិស្ស៧០នាក់ឱ្យចេញទៅតាមភូមិ

តាមស្រុក ដើម្បីរៀបចំមនុស្សសម្រាប់ការយាងមករបស់ព្រះអង្គ (លូកា ១០:១-១២)។ តាមការលើកឡើងនៅក្នុងអត្ថបទគម្ពីរមានមនុស្សដទៃទៀតជាច្រើនដែលស្រឡាញ់ព្រះអង្គនិងមានទំនាក់ទំនងជាមួយព្រះអង្គ។

ព្រះយេស៊ូចាប់ផ្តើមព័ន្ធកិច្ចជាសាធារណៈរបស់ព្រះអង្គនៅក្នុងស្រុកកាលីឡេដែលជាស្រុកកំណើតរបស់ព្រះអង្គផ្ទាល់។ ព្រះអង្គបានបំពេញតម្រូវការមនុស្សនៅទីនោះ។ មនុស្សពិការភ្នែក ខ្វិន ថ្លង់ អារក្សចូល និងអស់អ្នកដែលមានជំងឺទទួលបានការប្រោសឱ្យជាទាំងស្រុង។ លោកម៉ាថាយបានសរសេរអំពីព្រះយេស៊ូថា «កាលព្រះអង្គទតឃើញមហាជនទ្រង់មានព្រះហឫទ័យអាណិតអាសូរគេពន់ពេកណាស់ ព្រោះអ្នកទាំងនោះអស់កម្លាំងល្ហើយ ធ្លាក់ទឹកចិត្ត ប្រៀបបីដូចជាចៀមដែលគ្មានគង្វាលថែទាំ» (ម៉ាថាយ ៩:៣៦)។

ជាច្រើនដងព្រះយេស៊ូមានព្រះបន្ទូលទៅកាន់អ្នកកើតឃ្លង់ដែលព្រះអង្គបានប្រោសឱ្យជាឱ្យទៅបង្ហាញខ្លួនរបស់ពួកគេនៅមុខមហាបូជាចារ្យ និងថ្វាយយញ្ញបូជាទៅតាមក្រឹត្យវិន័យ។ ទ្រង់មានព្រះបន្ទូលបញ្ជាក់ថា «សុំកុំនឹកស្មានថាខ្ញុំមកលុបបំបាត់គម្ពីរវិន័យ ឬគម្ពីរព្យាការីចោលឡើយ។ ខ្ញុំមិនមែនមកលុបបំបាត់ទេ គឺខ្ញុំមកធ្វើអោយគម្ពីរមានអត្ថន័យពេញលក្ខណៈទៅវិញ។» (ម៉ាថាយ ៥:១៧)។

ព្រះយេស៊ូមានទំនាក់ទំនងល្អជាមួយមនុស្សគ្រប់ស្រទាប់វណ្ណៈទាំងអស់ក្នុងសង្គម។ ទ្រង់បានចូលរួមក្នុងពិធីមង្គលការមួយនៅក្នុងភូមិកាណាស្រុកកាលីឡេជាមួយមាតានិងសាវ័ករបស់ព្រះអង្គ។ នៅទីនោះទ្រង់បានបង្ហាញការយកចិត្តទុកដាក់លើបញ្ហាមនុស្សដទៃទៀតនិងទ្រង់បានសម្តែងការអស្ចារ្យដើម្បីជួយដល់ពួកគេ (យ៉ូហាន ២:១-១១)។ នៅក្នុងម៉ាថាយ ៩:៩-១១ បានកត់ត្រាថាព្រះយេស៊ូបានបរិភោគអាហារជាមួយអ្នកទារពន្ធនិងមនុស្សមានបាប។ នៅពេលមួយទៀតទ្រង់បានអង្គុយជាមួយពួកខណៈផារីស៊ី (លូកា ៧:៣៦,១១:៣៧)។ ដំណឹងល្អលោកយ៉ូហានបានប្រាប់យើងអំពីស្ត្រីសាសន៍សាម៉ារីដែលបានព្រះយេស៊ូបាននិយាយជាមួយ (យ៉ូហាន ៤:១-៣០)។

ព្រះយេស៊ូផ្ទាល់បានបង្ហាញពីព័ន្ធកិច្ចរបស់ព្រះអង្គនៅក្នុងព្រះបន្ទូល ដែលយើងអាចឃើញនៅក្នុងកណ្ឌគម្ពីរអេសាយ (អេសាយ ៦១:១-២)៖

> ព្រះវិញ្ញាណរបស់ព្រះអម្ចាស់សណ្ឋិតលើខ្ញុំ។ ព្រះអង្គបានចាក់ប្រេងអភិសេកខ្ញុំអោយនាំដំណឹងល្អទៅប្រាប់ជនក្រីក្រ។ ព្រះអង្គបានចាត់ខ្ញុំអោយមកប្រកាសប្រាប់ជនជាប់ជាឈ្លើយថា គេនឹងមានសេរីភាពហើយប្រាប់មនុស្សខ្វាក់ថាគេនឹងមើលឃើញវិញ។ ព្រះអង្គបានចាត់ខ្ញុំអោយមករំដោះអស់អ្នកដែលត្រូវគេសង្កត់សង្កិនព្រមទាំងប្រកាសអំពីឆ្នាំដែលព្រះអម្ចាស់សំដែងព្រះហឫទ័យមេត្តាករុណា)។ (លូកា ៤:១៨-១៩

ព្រះយស៊ូបានចម្អែតអាហារពីរដង ដល់ហ្វូងមនុស្សយ៉ាងច្រើនតាមដែលអាចធ្វើបាន (សូមមើល គម្ពីរម៉ាថាយជំពូក១៤ និង ១៥)។ ទ្រង់យកព្រះហឫទ័យទុកដាក់ជាមួយស្ថានភាពរបស់មនុស្សនៅលើផែនដី។ នៅក្នុងម៉ាថាយ

២៥:៣១៤០ ព្រះយេស៊ូមានព្រះបន្ទូលអំពីការវិនិច្ឆ័យទោសចុងក្រោយ។ ទ្រង់មានព្រះបន្ទូលថាគ្រប់ពេលដែលអ្នកជួយមនុស្សក្រីក្រ សួរសុខទុក្ខអ្នកជំងឺ និងអ្នកជាប់ឃុំឃាំង អ្នកធ្វើកិច្ចការទាំងអស់នេះសម្រាប់ព្រះអង្គ។ ប្រសិនបើអ្នកមិនបានធ្វើកិច្ចការទាំងអស់នេះ អ្នកនឹងក្លាយជាព័ន្ធការីដែលបរាជ័យចំពោះព្រះអង្គ។ ព្រះហឫទ័យរបស់ព្រះអង្គ មិនមែនដើម្បីបំពេញគ្រប់ទាំងក្រឹត្យវិន័យទាំងអស់នោះទេ ប៉ុន្តែ ដើម្បីសរសេរក្រឹត្យវិន័យខាងឯព្រលឹងវិញ្ញាណនៅក្នុងដួងចិត្ត និងគំនិតរបស់មនុស្សវិញ។ ការសុគត និងការមានព្រះជន្មរស់ឡើងវិញរបស់ព្រះអង្គបំពេញគ្រប់ទាំងកិច្ចការទាំងអស់នេះ។ តើព័ន្ធកិច្ចរបស់ព្រះយេស៊ូមានការប៉ះពាល់ដល់ជីវិតរបស់អ្នកដែរឬទេ? តើអ្នកមានការប្រកបជាមួយព្រះអង្គដែរឬទេ? សូមព្រះជាម្ចាស់យកជីវិតរបស់អ្នកដាក់នៅក្រោមការគ្រប់គ្រងរបស់ព្រះអង្គ។ ទ្រង់នឹងជួយអ្នកឱ្យធ្វើជាព័ន្ធការីនៅក្នុងសហគមន៍របស់អ្នកដូចជាអ្វីដែលទ្រង់បានធ្វើនៅក្នុងសហគមន៍របស់ព្រះអង្គដែរ។

លំហាត់អនុវត្តន៍

---

៥ គូរវង្វង់ជុំវិញប្រយោគដែលត្រឹមត្រូវ។

ក) ព្រះយេស៊ូបម្រើព័ន្ធកិច្ចតែនៅក្នុងភូមិណាសារ៉ែតដែលជាស្រុកកំណើតរបស់ព្រះអង្គប៉ុណ្ណោះ។

ខ) ព្រះយេស៊ូបម្រើព័ន្ធកិច្ចទៅកាន់មនុស្សគ្រប់ស្រទាប់វណ្ណៈទាំងអស់នៅក្នុងសង្គម។

គ) ព្រះយេស៊ូប្រត្តិបត្តតាមក្រឹត្យវិន័យនៃសហគមន៍របស់ព្រះអង្គ។

ឃ) ព្រះយេស៊ូមិនមានទំនាក់ទំនងជាមួយមនុស្សដែលមិនគោរពកោតខ្លាចព្រះនោះឡើយ។

ង) នៅពេលដែលយើងបំពេញតម្រូវការរបស់មនុស្សដទៃ គឺវាដូចគ្នាដែលយើងធ្វើសម្រាប់ព្រះគ្រិស្ត។

៦ ចូរសរសេររបៀបបីដែលព្រះយេស៊ូបង្ហាញពីព្រះហឫទ័យនៃសហគមន៍។

……………………………………………………………………………………………………..

…………………………………………………………………………………………………….

……………………………………………………………………………………………………..

## ការចុះចូលជាមួយនឹងអាជ្ញាធរ Submitting to Authority

ទោះបីជាព្រះយេស៊ូជាព្រះបុត្រារបស់ព្រះជាម្ចាស់ ប៉ុន្តែ ទ្រង់គោរព និងចុះចូលជាមួយសិទ្ធិអំណាចនៅក្នុងសហគមន៍របស់ព្រះអង្គ។ ជាឧទាហរណ៍ យើងអាននៅក្នុងម៉ាថាយ ១៧:២៤-២៧ ទ្រង់បានចុះចូលជាមួយសិទ្ធិអំណាចដោយបង់ពន្ធសម្រាប់ព្រះវិហារ។ ដើម្បីកុំអោយអ្នកទាំងនោះទាស់ចិត្ត ព្រះយេស៊ូមានព្រះបន្ទូលទៅលោកពេត្រុសឱ្យទៅស្ទូចត្រី ហើយយកត្រីដែលស្ទូចបានមុនគេមកបើកមាត់ អ្នកនឹងឃើញកាក់មួយ ចូរយកកាក់នោះទៅបង់ពន្ធចុះ។

នៅពេលមួយទៀត ព្រះយេស៊ូមិនទទួលប្រពៃណីដែលទាស់ប្រឆាំងជាមួយព្រះហឫទ័យរបស់ព្រះជាម្ចាស់នោះទេ។ អ្នកប្តូរប្រាក់បានយកព្រះវិហារធ្វើជាកន្លែងជំនួញប្តូរប្រាក់ឱ្យសាសន៍ដទៃ (ម៉ាថាយ ២១:១២)។ ព្រះវិហារគឺជាន្លែងតែមួយគត់សម្រាប់សាសន៍ដទៃដែលមានបំណងចិត្តស្វែងរកព្រះអង្គអាចថ្វាយបង្គំព្រះជាម្ចាស់បាន។ នៅពេលដែលអ្នកលក់ និង

អ្នកទិញធ្វើឱ្យមានសំលេងរំខានខ្លាំង តើឱ្យពួកគេអធិស្ឋានដោយរបៀបណា? អ្នកដូរប្រាក់បានកេញចំណេញពីអ្នកក្រដោយយកការប្រាក់ខ្ពស់នៅពេលដែលពួកគេដូរប្រាក់សម្រាប់ប្រើប្រាស់ក្នុងព្រះវិហារ។ ពួកគេក៏បានរារាំងអ្នកដែលស្វែងរកព្រះជាម្ចាស់អស់ពីចិត្តផងដែរ។ ពួកគេបានបំពានទៅលើព្រះបន្ទូលដែលមានចែងក្នុងគម្ពីរអេសាយ ៥៦:៧ «ដ្បិតគេនឹងហៅដំណាក់របស់យើងថាជា កន្លែងសម្រាប់ជាតិសាសន៍ទាំងអស់អធិស្ឋាន»។ នៅក្នុងស្ថានភាពនេះព្រះយេស៊ូយកព្រះហឫទ័យទុកដាក់កាន់តែខ្លាំងទៅលើការសម្រេចតាមព្រះហឫទ័យរបស់ព្រះបិតារបស់ព្រះអង្គ។ ទ្រង់ប្រឆាំងជាមួយប្រពៃណីរបស់មនុស្សពីព្រោះទ្រង់ស្តាប់បង្គាប់ដល់ព្រះវរបិតាដែលគង់នៅស្ថានដ៏ខ្ពស់បំផុត។

ព្រះយេស៊ូគឺជាគម្រូដ៏គ្រប់លក្ខណ៍ដែលបង្ហាញអំពីព្រះហឫទ័យនៃសហគមន៍? ទ្រង់មិនអនុញ្ញាតឱ្យប្រពៃណីរបស់មនុស្សរារាំងព្រះហឫទ័យរបស់ព្រះជាម្ចាស់។

**លំហាត់អនុវត្តន៍**

---

៧ គូសរង្វង់ជុំវិញប្រយោគដែលត្រឹមត្រូវ

ក) ព្រះយេស៊ូមិនត្រូវបង់ពន្ធសម្រាប់ព្រះវិហារនោះទេ ប៉ុន្តែ ទ្រង់ធ្វើកិច្ចការនេះដើម្បីកុំអោយអ្នកទាំងនោះទាស់ចិត្ត។

ខ) ព្រះយេស៊ូបរិភោគអាហារជាមួយអ្នកទារពន្ធពីព្រោះទ្រង់ស្រឡាញ់ពួកគេ និងចង់អត់ទោសពួកគេពីបាប។

គ) ព្រះយេស៊ូផ្តួលតុ និងដេញអ្នកដូរប្រាក់ចេញពីព្រះវិហារពីព្រោះ ពួកគេមិនបានបង់ពន្ធសម្រាប់ព្រះវិហារ។

ឃ) ព្រះយេស៊ូមិនដែលចុះចូលជាមួយអាជ្ញាធរនៅក្នុងសហគមន៍របស់ព្រះអង្គទេ ពីព្រោះទ្រង់គឺជាបុត្រារបស់ព្រះជាម្ចាស់។

៨ សូមសរសេរពីកាលៈទេសៈមួយដែលព្រះយេស៊ូចុះចូលជាមួយអ្នកកាន់អំណាច។

……………………………………………………………………………………………………

……………………………………………………………………………………………………

## គ. ឥទ្ធិពលរបស់ព្រះយេស៊ូ The Influence of Jesus

**គោលដៅទី៣. ពិពណ៌នាពីឥទ្ធិពលរបស់ព្រះយេស៊ូនៅក្នុងពិភពលោក។**

ជំនឿដ៏ពិតរបស់គ្រិស្តបរិស័ទនាំឱ្យមានសេរីភាព។ ព្រះយេស៊ូបានបង្រៀនថា «ប្រសិនបើអ្នករាល់គ្នាស្ថិតនៅជាប់នឹងពាក្យរបស់ខ្ញុំ អ្នករាល់គ្នាពិតជាសិស្សរបស់ខ្ញុំមែន។ អ្នករាល់គ្នានឹងស្គាល់សេចក្តីពិត ហើយសេចក្តីពិតនឹងរំដោះអ្នករាល់គ្នាអោយមានសេរីភាព» (យ៉ូហាន ៨:៣១-៣២)។ បន្ទាប់មកទ្រង់មានព្រះបន្ទូលថា «ប្រសិនបើព្រះបុត្រារំដោះអ្នករាល់គ្នា អ្នករាល់គ្នាពិតជាមានសេរីភាព»។ ជំនឿលើព្រះគ្រិស្តរំដោះមនុស្សឱ្យមានសេរីភាពពីជំនឿខុសឆ្គង និងទាសករនៃអំពើបាប។ សេចក្តីបង្រៀននេះចារឹកនៅក្នុងដួងចិត្តរបស់ពួកគេ និងធ្វើឱ្យពួកគេមានសមត្ថភាពរស់នៅឈ្នះលើអំពើបាប។

ព័ន្ធកិច្ចរបស់ព្រះយេស៊ូនៅតែបន្តមានឥទ្ធិពលនៅលើពិភពលោករបស់យើងនេះ។ ព្រះយេស៊ូបានលើកកំពស់ស្ត្រីឱ្យមានការគោរពថ្មីមួយ។ ទ្រង់បានលើកកិត្តិយសដល់មាតារបស់ព្រះអង្គ។ ទោះបីជានៅលើឈើឆ្កាង ទ្រង់យកព្រះហឫទ័យទុកដាក់អំពីសុខុមាភាពរបស់នាងម៉ារី និងឱ្យលោកយ៉ូហានជាអ្នកថែរក្សានាង (សូមមើលយ៉ូហាន ១៩:២៦-២៧)

លូកា ៧:៣៦-៣៩ រៀបរាប់អំពីស្ត្រីម្នាក់ដែលបានចាក់ប្រេងក្រអូបទៅលើព្រះបាទារបស់ព្រះយេស៊ូ។ ទ្រង់មិនបានបណ្តេញនាងចេញទេ ទោះបីជានាងពេញដោយអំពើបាបក៏ដោយ ព្រះយេស៊ូបានអត់ទោសអំបាបរបស់នាង និងផ្លាស់ប្រែជីវិតរបស់នាង។ ទ្រង់បានលើកកិត្តិយសនាងចំពោះកិច្ចការដែលនាងបានធ្វើចំពោះព្រះអង្គ។ នៅពេលមួយទៀតនៅក្នុងស្រុកសាម៉ារី ទ្រង់បានធ្វើព័ន្ធកិច្ចចំពោះស្ត្រីម្នាក់ដែលសង្គមមិនឱ្យតម្លៃ ហើយជីវិតរបស់នាងត្រូវបានផ្លាស់ប្រែ។ សព្វថ្ងៃនេះនៅកន្លែងជាច្រើនដែលដំណឹងល្អរបស់ព្រះយេស៊ូគ្រិស្តបានអធិប្បាយ ស្ត្រីទទួលបានក្តីស្រឡាញ់ ការគោរព និងការផ្តល់កិត្តិយសដ៏ធំ។

ព្រះជន្ម និងព័ន្ធកិច្ចរបស់ព្រះយេស៊ូមានឥទ្ធិពលយ៉ាងខ្លាំងបំផុតទៅលើពិភពលោកទាំងមូល។ គិតអំពីរបៀបដែលលោកខាងលិចរាប់អំពីពេលវេលា។ ឆ្នាំដែលគិតពីចំនួនរាប់មុនគ្រិស្តសករាជ (មុន គ.ស) និង គ.ស (បន្ទាប់ពីព្រះគ្រិស្ត)។

ព្រះជាម្ចាស់បានចាប់ផ្តើមប្រាំពីរថ្ងៃក្នុងមួយសប្តាហ៍។ ក្នុងការបង្កើតផែនដី ទ្រង់សម្រាកក្នុងថ្ងៃទីប្រាំពីរ ព្រមទាំងបង្គាប់ឱ្យរក្សាទុកជាថ្ងៃបរិសុទ្ធ និងប្រើថ្ងៃនេះជាថ្ងៃឈប់សម្រាក។ ថ្ងៃនៃការឈប់សម្រាកបានផ្លាស់ប្តូរបន្ទាប់ពីព្រះយេស៊ូយាងមកផែនដី។ ទ្រង់មានព្រះជន្មរស់ឡើងវិញក្នុងថ្ងៃទីមួយនៃសប្តាហ៍។ សព្វថ្ងៃនេះ មនុស្សជាច្រើននៅលើពិភពលោកបានយកថ្ងៃអាទិត្យ ជាថ្ងៃឈប់សម្រាក និងការថ្វាយបង្គំ។

មានការរស់នៅបែបស្តង់ដារខ្ពស់ជាច្រើននៅក្នុងពិភពលោកគឺរីករាយនៅកន្លែងដែលដំណឹងល្អអាចប្រកាសដោយសេរី។ ប្រព័ន្ធដ៏ទំនើបនៃក្រឹត្យវិន័យរបស់ពួកយើងវាមានមូលដ្ឋានគ្រឹះនៅក្នុងព្រះគម្ពីរ។ បំណងចិត្តដែលជំរុញឱ្យមនុស្សជាច្រើនធ្វើកិច្ចការយ៉ាងនឿយហត់គឺយោងទៅតាមគោលការណ៍បង្រៀននៅក្នុងព្រះគម្ពីរ។

ការយកចិត្តទុកដាក់មួយដ៏សំខាន់ចំពោះអ្នកជឿលើព្រះគម្ពីរ គ្រិស្តបរិស័ទបានបង្រៀនមនុស្សឱ្យចេះអាន ដើម្បីឱ្យគេអាចអានព្រះបន្ទូលដោយខ្លួនឯងបាន។ បេសកជនគ្រិស្តបរិស័ទបានប្រើភាសាជាច្រើននៅក្នុងការសរសេរសម្រាប់ពេលដំបូងរបស់ពួកគេ។ បេសកជននៅក្នុងប្រទេសជាច្រើនលើពិភពលោក បានចូលសាលាដើម្បីរៀន ដើម្បីឱ្យ បុរស និងស្ត្រីអាចរៀនក្នុងការអានបាន។ សាលារៀនទាំងនេះជាព្រះពរដល់សហគមន៍ជាច្រើនទៅកាន់ពិភពលោក។

ឥទ្ធិពលនៃជំនឿលើព្រះគ្រិស្តបានស្ថិតនៅក្នុងដួងចិត្តមរបស់នុស្សសម័យទំនើប និងពិភពលោករបស់ពួកគេ។ សារធ្វើឱ្យជាទាសករ ប៉ុន្តែ ជំនឿលើព្រះគ្រិស្តរំដោះពួកគេឱ្យមានសេរីភាព។ នៅពេលដែលព្រះគ្រិស្តសុគត ការបង្រៀនរបស់ព្រះអង្គមិនត្រូវបញ្ចប់ឡើយ។ អ្នកគឺជាអ្នកបន្តព័ន្ធកិច្ចរបស់ព្រះអង្គ អ្នកជាអ្នកតំណាងព្រះគ្រិស្តទៅកាន់ពិភពលោក។ នៅ

ពេលដែលអ្នកបង្ហាញជំនឿដ៏ពិតទៅលើព្រះគ្រិស្តទៅកាន់សហគមន៍របស់អ្នក ពិភពលោកកាន់តែប្រសើរ។ នៅក្នុងមេរៀនបន្ទាប់ យើងនឹងពិភាក្សាអំពីរបៀបខ្លះៗដែលអ្នកអាចពង្រីកព័ន្ធកិច្ចរបស់ព្រះគ្រិស្តទៅកាន់សហគមន៍របស់អ្នក។

**លំហាត់អនុវត្តន៍**

---

៩ សរសេរពីរបៀបពីរដែលពិភពលោកអាចមានលក្ខណៈខុសប្លែក ប្រសិនបើព្រះគ្រិស្តមិនបានយាងមក។

……………………………………………………………………………………………………

……………………………………………………………………………………………………

១០ សរសេរឥទ្ធិពលពីរដែលជំនឿលើព្រះគ្រិស្តមានលើស្ត្រី។

……………………………………………………………………………………………………

……………………………………………………………………………………………………

១១ សរសេររបៀបមួយដែលជំនឿលើព្រះគ្រិស្តបានផ្លាស់ប្តូរអ្នកជាលក្ខណៈបុគ្គល។

……………………………………………………………………………………………………

……………………………………………………………………………………………………

……………………………………………………………………………………………………

……………………………………………………………………………………………………

## សូមផ្ទៀងផ្ទាត់ចម្លើយរបស់អ្នក

៦ ទ្រង់ប្រើដង្វាយជាមួយសាវ័ករបស់ព្រះអង្គ ទ្រង់បរិភោគជាមួយមនុស្សមានបាប ទ្រង់ប្រោសអ្នកជំងឺឱ្យជា ទ្រង់ផ្គត់ផ្គង់ដល់ហ្វូងមនុស្ស ទ្រង់ចូលរួមក្នុងកម្មវិធីសប្បាយផ្សេងដូចជាពិធីមង្គលការ។
ខ) ត្រូវថ្វាយទៅព្រះជាម្ចាស់ដូចជាក្មេងៗសាសន៍យូដាដទៃទៀត។

៧ ប្រយោគ ក) និង ខ) ត្រឹមត្រូវ។

២ ក) វាគឺជាប្រពៃណីដែលត្រូវចូលរួមពិធីបុណ្យនៅទីនោះ។

៨ នៅពេលដែលទ្រង់បង់ពន្ធសម្រាប់ព្រះវិហារ

៣ ក) មានការទទួលស្វាគមន៍ល្អបំផុតពីសហគមន៍របស់ព្រះអង្គ។

៩ ចម្លើយរបស់អ្នក។ មានរបៀបជាច្រើនដែលបានលើកឡើងនៅក្នុងមេរៀននេះ និងមានរបៀបផ្សេងៗទៀតជាច្រើន។ តើអ្នកអាចឃើញពីរបៀបដែលពិភពលោករបស់អ្នកអាចមានភាពខុសប្លែកប្រសិនបើព្រះគ្រិស្តមិនយាងមកដែលឬទេ?

៤ ខ) ស្តាប់បង្គាប់ដល់អស់អ្នកដែលមានឋានៈលើព្រះអង្គ។

១០ ចម្លើយណាដែលអាចទៅរួច។ ស្ត្រីគឺទទួលបានក្តីស្រឡាញ់ដ៏ធំ ការគោរព និងការកិត្តិយសនៅកន្លែងដែលដំណឹងល្អបានប្រកាស។ ពួកគេត្រូវបានរំដោះឱ្យមានសេរីភាពចេញពីអំពើបាប និងជំនឿដែលខុសឆ្គង។ ពួកគេទទួលបានឱកាសកាន់តែប្រសើរសម្រាប់ការរៀនសូត្រ។

៥ ប្រយោគ ខ) គ) និង ង)ត្រឹមត្រូវ

១១ ចម្លើយរបស់អ្នក។

មេរៀនទី ៧

# ការរះពន្លឺក្នុងសហគមន៍របស់អ្នក

## Shining in Your Community

នៅសារមន្ទីបាណាម៉ា ខានល (Panama Canal Museum) មានភ្លើងសញ្ញាចាស់មួយ។  វាត្រូវបានបង្កើតឡើងនៅប្រទេសបារាំងក្នុងទសវត្សរ៍ឆ្នាំ១៨០០ និងត្រូវបានយកទៅកាន់ បាណាម៉ា (Panama) នៅអំឡុងពេលដែលបារាំងព្យាយាមសាងសង់ស្ពានឆ្លងដែសមុទ្រ។ ពួកគេមិនមានសមត្ថភាពសាងសង់ស្ពានឆ្លងដែសមុទ្រនេះបានដោយសារតែបញ្ហាសុខភាព និងខ្វះខាតថវិកា។ ប៉ុន្តែ ភ្លើងសញ្ញាចាស់នៅតែមាន។ វាជួយធ្វើជាសញ្ញាសម្រាប់កាប៉ាល់នៅក្នុងសមុទ្រអស់រយៈជាច្រើនឆ្នាំ។

នៅកណ្តាលភ្លើងសញ្ញាមានកន្លែងសម្រាប់កូនអំពូលតូចមួយ។ នៅជុំវិញកូនអំពូល គឺមានកញ្ចក់នៅខាងក្នុងខ្សែភ្លើងតូចដែលជួយបញ្ចេញពន្លឺ។ មានប្រដាប់បញ្ចេញពន្លឺប្រហែលជា៨០០នៅជុំវិញអំពូល។ ពួកវាមិនអាចមានពន្លឺដោយខ្លួនពួកវានោះទេ ប៉ុន្តែ ពួកវាជះ និងបញ្ជូនពន្លឺទៅអំពូល។

នៅក្នុងរបៀបដូចគ្នា យើងបញ្ចាំងពន្លឺព្រះយេស៊ូគ្រិស្តទៅកាន់ពិភពលោក។ ព្រះគម្ពីរប្រៀបធៀបគ្រិស្តបរិស័ទដូចជាពន្លឺ និងអំបិល។ នៅក្នុងមេរៀននេះអ្នកនឹងឃើញពីរបៀបដែលអ្នកអាចធ្វើជាពន្លឺ និងអំបិលនៅក្នុងសហគមន៍របស់អ្នក។ អនុញ្ញាតឱ្យព្រះគ្រិស្តមានឥទ្ធិពលក្នុងគំនិតរបស់អ្នកនឹងជួយអ្នកក្នុងការឆ្លុះបញ្ចាំងក្តីស្រឡាញ់របស់ព្រះអង្គទៅកាន់ពិភពលោក។

## គម្រោង

ក. ជាពន្លឺនៅក្នុងសហគមន៍របស់អ្នក A Light to Your Community

ខ. ជាអំបិលនៅក្នុងសហគមន៍របស់អ្នក Salt in Your Community

គ. ចិត្តគំនិតថ្មី A Renewed Mind

## គោលដៅ

១. ពិពណ៌នាពីរបៀបដែលគ្រិស្តបរិស័ទអាចចាំងជះពន្លឺរបសព្រះយេស៊ូ។

២. បង្ហាញពីរបៀបដែលគ្រិស្តបរិស័ទអាចដូចជាអំបិលនៅក្នុងសហគមន៍របស់គាត់។

៣. កត់សម្គាល់ពីឥរិយាបថនៃការមានចិត្តគំនិតថ្មី។

## ក. ជាពន្លឺនៅក្នុងសហគមន៍របស់អ្នក A Light to Your Community

**គោលដៅទី១. ពិពណ៌នាពីរបៀបដែលគ្រិស្តបរិស័ទអាចពន្លឺរបសព្រះយេស៊ូ។**

ព្រះយេស៊ូមានព្រះបន្ទូលថា «ខ្ញុំជាពន្លឺបំភ្លឺពិភពលោក» (យ៉ូហាន ៨:១២)។ ទ្រង់ក៏មានព្រះបន្ទូលផងដែរ «អ្នករាល់គ្នាជាពន្លឺ សំរាប់បំភ្លឺមនុស្សលោក......ចូរអោយពន្លឺរបស់អ្នករាល់គ្នា បំភ្លឺមនុស្សទាំងឡាយដូច្នោះដែរ គេនឹងឃើញអំពើល្អ ដែលអ្នករាល់គ្នាប្រព្រឹត្ត ហើយលើកតម្កើងសិរីរុងរឿងព្រះបិតារបស់អ្នករាល់គ្នា ដែលគង់នៅស្ថានបរមសុខ (ម៉ាថាយ ៥:១៤, ១៦)។ យើងមិនមានពន្លឺដោយខ្លួនឯងនោះទេ ប៉ុន្តែ យើងទទួលបានពន្លឺពីព្រះយេស៊ូ ប្រសើរជាងឧបករណ៍ជះពន្លឺនៅក្នុងភ្លើងសញ្ញានៅប៉ាណាម៉ា (Panama) ដែលទទួលបានពន្លឺពីអំពូល។

គោលបំណងមួយក្នុងចំណោមគោលបំណងផ្សេងទៀតរបស់ពន្លឺដើម្បីបំភ្លឺដែលជួយឱ្យមនុស្សធ្វើដំណើរដោយសុវត្ថិភាព។ អ្នកនិពន្ធទំនុកតម្កើងបានសរសេរថា «ព្រះបន្ទូលរបស់ព្រះអង្គជាចង្កៀងបំភ្លឺជំហាន ទូលបង្គំ និងជាពន្លឺបំភ្លឺផ្លូវរបស់ទូលបង្គំ» (ទំនុកតម្កើង១១៩:១០៥)។ មនុស្សប្រហែលជាមិនបានអានព្រះបន្ទូលព្រះជាម្ចាស់ ប៉ុន្តែ ពួកគេមើលជីវិតរស់នៅរបស់អ្នក។ ក្នុងនាមយើងជាអ្នកសិក្សាព្រះបន្ទូល និងដើរនៅក្នុងពន្លឺ មនុស្សដទៃទៀតនឹងអាចមានសមត្ថភាពកាន់តែប្រសើរក្នុងការមើលឃើញផ្លូវដែលត្រឹមត្រូវ។ យើងនឹងបម្រើដូចជាឧបករណ៍បញ្ចេញពន្លឺរបស់ព្រះគ្រិស្ត និងជួយមនុស្សដទៃទៀតក្នុងការស្វែងរកផ្លូវទៅកាន់ព្រះគ្រិស្ត។

គោលបំណងមួយទៀតនៃពន្លឺគឺដើម្បីប្រមានពីភាពគ្រោះថ្នាក់។ បង្គោលភ្លើងដែលគេបានសាងសង់ឡើងដើម្បីជាសញ្ញាសម្រាប់ទូកដែលឆ្លងកាត់ថាជាកន្លែងមានថ្មធំៗ ឬ បណ្តុំនៃថ្មដែលស្ថិតនៅពីក្រោមទឹក។ គ្រិស្តបរិស័ទដូចជាពន្លឺដែលប្រមានមនុស្សអំពីគ្រោះថ្នាក់នៃអំពើបាប។ មិនគ្រាន់តែព្រះបន្ទូលរបស់ព្រះជាម្ចាស់ដែលជួយយើងឱ្យជៀសវៀងពីអំពើបាបប៉ុណ្ណោះទេ ប៉ុន្តែ ព្រះបន្ទូលរបស់ព្រះអង្គជះពន្លឺពីជីវិតរបស់យើងដើម្បីប្រមានដល់មនុស្សដទៃទៀតផងដែរ។ ជាញឹកញាប់វាពិតជាចាំបាច់ណាស់សម្រាប់យើងដែលផ្តល់ការប្រមានប្រឆាំងនឹងអំពើបាប។

ពន្លឺក៏ជួយមនុស្សឱ្យស្គាល់នូវអ្វីដែលគេមើលឃើញផងដែរ។ ហេប្រឺ ៤:១២-១៣ បានចែងថា៖

ដ្បិតព្រះបន្ទូលរបស់ព្រះជាម្ចាស់ ជាព្រះបន្ទូលដ៏មានជីវិត និងមានមហិទ្ធិឫទ្ធិមុតជាងដាវមុខពីរទៅទៀត។ ព្រះបន្ទូលនេះចាក់ទម្លុះចូលទៅកាត់ព្រលឹង និងវិញ្ញាណដាច់ចេញពីគ្នា កាត់សន្លាក់ឆ្អឹង និងខួរឆ្អឹងចេញពីគ្នា។ ព្រះបន្ទូលវិនិច្ឆ័យឆន្ទៈ និងគំនិតនៅក្នុងជំរៅចិត្តមនុស្ស។គ្មានសត្វលោកណាមួយដែលព្រះបន្ទូលមើលមិនឃើញឡើយ ចំពោះព្រះនេត្ររបស់ព្រះអង្គ អ្វីៗទាំងអស់នៅទទេ ឥតបិទបាំងទាល់តែសោះ។ យើងត្រូវទូលរៀបរាប់ថ្វាយព្រះបន្ទូលពីគ្រប់កិច្ចការទាំងអស់។

នៅពេលដែលដួងចិត្តរបស់យើងបើកចំហចំពោះព្រះបន្ទូល ជាហេតុដែលនាំឱ្យយើងអាចមើលឃើញខ្លួនរបស់យើងផ្ទាល់ដូចជារបៀបដែលព្រះជាម្ចាស់ទតមកកាន់ជីវិតរបស់យើង។ មួយវិញទៀត នៅពេលដែលមនុស្សដែលមិនមែនជាគ្រិស្តបរិស័ទមើលមកកាន់ជីវិតរបស់យើង វាអាចជួយពួកគេឱ្យស្គាល់អំពើបាប និងសេចក្តីត្រូវការរបស់ពួកគេសម្រាប់ការផ្លាស់ប្រែដោយអំណាចចេស្តរបស់ព្រះយេស៊ូ។ លោកប៉ូបានសរសេរថាអ្នកជឿគួតែរស់នៅដូចជា «ដើម្បីអោយបងប្អូនបានល្អឥតខ្ចោះ ឥតសៅហ្មង ជាបុត្ររបស់ព្រះជាម្ចាស់ដែលឥតមានកំហុស ក្នុងចំណោមមនុស្សវៀចវេរ និងខិលខូចនៅជំនាន់នេះ។ បងប្អូនភ្លឺក្នុងចំណោមពួកគេ ដូចពន្លឺដែលបំភ្លឺពិភពលោក» (ភីលីពី ២:១៥-១៦)។

លំហាត់អនុវត្តន៍

---

១ សរសេរពីគោលបំណងបីនៃពន្លឺដែលបានផ្តល់ជូនក្នុងមេរៀននេះ។

…………………………………………………………………………………………………………

…………………………………………………………………………………………………………

…………………………………………………………………………………………………………

២ សរសេរពីការអនុវត្តគោលបំណងទាំងនេះទៅកាន់ទំនួលខុសត្រូវរបស់យើងក្នុងនាមជាគ្រិស្តបរិស័ទ។

…………………………………………………………………………………………………………

…………………………………………………………………………………………………………

…………………………………………………………………………………………………………

## ខ. ជាអំបិលនៅក្នុងសហគមន៍របស់អ្នក Salt in Your Community

**គោលដៅទី២. បង្ហាញពីរបៀបដែលគ្រិស្តបរិស័ទអាចដូចជាអំបិលនៅក្នុងសហគមន៍របស់គាត់ៗ**

ព្រះយេស៊ូមានព្រះបន្ទូលថា «អ្នករាល់គ្នាជាអំបិល សំរាប់មនុស្សលោក ប៉ុន្តែ បើអំបិលបាត់ជាតិប្រៃហើយ តើគេនឹងយកអ្វីមកធ្វើអោយប្រៃឡើងវិញបាន? អំបិលនោះគ្មានប្រយោជន៍អ្វីទៀតទេ គឺមានតែបោះចោលទៅខាងក្រៅអោយមនុស្សដើរជាន់ប៉ុណ្ណោះ» (ម៉ាថាយ ៥:១៣)។ តួនាទី ឬ គោលបំណងមួយនៃអំបិលគឺធ្វើបន្សុទ្ធ។ នៅពេលដែលប្រើអំបិលដើម្បីបន្សុទ្ធអ្វីមួយ អំបិលវាបំផ្លាញសារធាតុទាំងឡាយណាដែលមិនល្អចោល។

ភាពបរិសុទ្ធគឺជាគុណធម៌ ឬ ជាគុណសម្បត្តិដែលគ្រិស្តបរិស័ទត្រូវតែបង្ហាញទៅកាន់សហគមន៍របស់ពួក។ ដើម្បីបានបរិសុទ្ធគឺត្រូវតែរស់នៅក្នុងភាពបរិសុទ្ធ។ ចាប់ផ្ដើមជាមួយភាពបរិសុទ្ធពីខ្លួនយើងផ្ទាល់ យើងអាចមានឥទ្ធិពលទៅកាន់សហគមន៍របស់យើងដោយសារភាពបរិសុទ្ធ។ ខណៈពេលដែលវិញ្ញាណគ្រប់គ្រងពិភពលោកនេះកំពុងតែព្យាយាមលុបបំបាត់ភាពស្មោះត្រង់ និងសីលធម៌ដែលត្រឹមត្រូវ គ្រិស្តបរិស័ទទទួលបានបេសកកម្មពីព្រះជាម្ចាស់ក្នុងការការពារភាពបរិសុទ្ធឱ្យស្ថិតក្នុងមាត្រាដ្ឋានដែលត្រឹមត្រូវទាំងឥរិយាបថ និងការគិត។ អំពើបាបដូចជាជំងឺឆ្លង ហើយពួកយើងត្រូវទទួលការព្យាបាលដើម្បីបំផ្លាញវា និងការពារកុំឱ្យមានការឆ្លងរាលដាល។ នៅពេលដែលយើងនិយាយប្រឆាំងនឹងអំពើបាប យើងដូចជាអំបិលនៅក្នុងសហគមន៍របស់យើង។

អំបិលក៏ប្រើដើម្បីការពារកុំឱ្យស្អុយផងដែរ។ ជាឧទាហរណ៍ យើងប្រើអំបិលដើម្បីប្រឡាក់ត្រី និងសាច់។ ខ្ញុំកើតនៅកោះមួយនៃញូហ្វោនលែន (Newfoundland) ជាកន្លែង(អាហារពេលល្ងាចប្រឡាក់សាច់) បណ្ដុំនៃអាហារជាច្រើន។ គេប្រើឈ្មោះនេះដោយសារតែគេប្រើអំបិលដើម្បីប្រឡាក់សាច់គោនៅទីនោះ។ ញូហ្វោនលែនគឺជាប្រទេសនេសាទត្រីដ៏ធំមួយ។ ខ្ញុំចាំបានថាពេលមួយខ្ញុំបានទៅទស្សនានៅផែនេសាទត្រីដែលជាកន្លែងមានឃ្លាំងប្រឡាក់ត្រីវាប់តោន។ បន្ទាប់ពីប្រឡាក់ត្រីជាមួយអំបិលអស់រយៈពេលជាយូ ក្រោយមកត្រីទាំងអស់នោះត្រូវបានលក់ចេញ។

មូលហេតុចំនួនពីរក្នុងចំណោមមូលហេតុទាំងនេះ អំបិលធ្វើឱ្យសាច់មិនឱ្យស្អុយ ដូច្នេះអាចទុកវាបរិភោគពេលក្រោយបាន។ សាច់អាចរក្សាគុណភាពធម្មជាតិរបស់វាបាន វាមិនបាត់បង់រស់ជាតិនោះទេ។ ដូចគ្នានេះដែល គ្រិស្តបរិស័ទគឺជាអំបិលនៅក្នុងពិភពលោក ជាភ្នាក់ងារការពារផែនដី។ គ្រិស្តបរិស័ទត្រូវតែមានឥទ្ធិពលវិជ្ជមានទៅកាន់មនុស្សដទៃ។

គុណភាពចម្បងបំផុតនៃអំបិលគឺវាធ្វើឱ្យមានរសជាតិ។ អំបិលវាមានរសជាតិដោយខ្លួនវាផ្ទាល់ ប៉ុន្តែ អំបិលត្រូវបានគេប្រើជាពិសេសដើម្បីធ្វើឱ្យម្ហូបមានរសជាតិ។ ជំនឿគ្រិស្តបរិស័ទគឺមានការប៉ះពាល់ទៅកាន់ជីវិតដូចជាអំបិលដែលមានការប៉ះពាល់ទៅកាន់ម្ហូប។ ជីវិតរបស់អ្នកនឹងអាប់អួ គ្មានន័យ គ្មានគោលបំណង ប្រសិនបើអ្នកយកជំនឿគ្រិស្តបរិស័ទ ឬឥទ្ធិពលរបស់វាចេញពីជីវិតរបស់អ្នក។

ជាគ្រិស្តបរិស័ទយើងត្រូវតែមានភាពវិសុទ្ធ និងធ្វើឱ្យអ្នកដទៃមានភាពវិសុទ្ធដូចគ្នា។ យើងគួរតែធ្វើឱ្យអស់ពីសមត្ថភាពរបស់យើងដើម្បីការពារអ្វីដែលល្អ និងត្រឹមត្រូវ។ ជីវិតរបស់យើងផ្ទាល់ត្រូវតែបង្ហាញទៅអ្នកដទៃថាជំនឿលើព្រះគ្រិស្តនឹងផ្ដល់ក្ដីសង្ឃឹមទៅកាន់ជីវិត។ បន្ទាប់មកយើងត្រូវបម្រើក្នុងលក្ខណៈជាអំបិលដូចដែលព្រះយេស៊ូបានមានព្រះបន្ទូល។

**លំហាត់អនុវត្តន៍**

---

៣ បំពេញចន្លោះខាងក្រោម។

ក) នៅក្នុងពិភពលោកដែលពេញដោយអំពើបាប គ្រិស្តបរិស័ទត្រូវតែដូចជា.........................................

ខ) គ្រិស្តបរិស័ទដែលវិសុទ្ធដូ ជា...........................................................................................

គ) ពីព្រោះគាត់ ឬ នាងជួយធ្វើសហគមន៍កាន់តែវិសុទ្ធ។

៤ ចូរសរសេរតួនាទីចំនួនបីនៃអំបិល។

……………………………………………………………………………………………………

……………………………………………………………………………………………………

…………………………………………………………………………………………………..

៥ សូមសរសេរការអនុវត្តន៍នៃតួនាទីទាំងនេះទៅកាន់ទំនួលខុសត្រូវរបស់យើងក្នុងនាមយើងជាគ្រិស្តបរិស័ទ។

……………………………………………………………………………………………………

……………………………………………………………………………………………………

……………………………………………………………………………………………………

## គ. ចិត្តគំនិតថ្មី A Renewed Mind

**គោលដៅទី៣. កំណត់សម្គាល់ពីឥរិយាបថនៃការមានចិត្តគំនិតថ្មី។**

យើងទើបតែបានសិក្សារួចរាល់ហើយថាយើងមិនមានពន្លឺដោយខ្លួនឯងនោះទេ យើងគ្រាន់តែបញ្ចាំងពន្លឺរបស់ព្រះគ្រិស្តតែប៉ុណ្ណោះ។ ទោះបីជាអំណាចដែលយើងមានក្នុងការការពារ បន្សុទ្ធ ឬ ធ្វើឱ្យមានរស់ជាតិនៅក្នុងពិភពលោករបស់យើងក៏ដោយ។ អំណាចទាំងអស់គឺមកពីព្រះជាម្ចាស់ ដែលប្រទានឱ្យយើងមានប្រាជ្ញាក្នុងការប្រើប្រាស់ឫទ្ធានុភាពទាំងនេះសម្រាប់ជាការល្អទៅកាន់មនុស្សដទៃ។

វាគឺដូចគ្នាជាមួយគំនិតរបស់អ្នក។ អ្នកមិនអាចយល់ពីរបៀបដែលវាធ្វើដំណើរការនោះទេ មានតែព្រះជាម្ចាស់ប៉ុណ្ណោះដែលយល់អំពីវា។ ដូច្នេះគ្រប់អ្វីដែលស្ថិតក្នុងគំនិតរបស់អ្នក ឬ អ្វីដែលអ្នកគិតថ្វាយទៅព្រះជាម្ចាស់ច្រើនយ៉ាងណា នោះទ្រង់ក៏មានឥទ្ធិពលលើគំនិតរបស់អ្នកច្រើនយ៉ាងនោះដែរ។ កណ្ឌគម្ពីររ៉ូម ១២:២បានចែងថា «មិនត្រូវយកតំរាប់តាមនិស្ស័យលោកីយ៍នេះឡើយ ត្រូវទុកអោយព្រះជាម្ចាស់កែប្រែចិត្តគំនិតបងប្អូន អោយទៅជាថ្មីទាំងស្រុងវិញ»។

ការផ្លាស់ប្តូរ ឬ ការកែប្រែទាំងស្រុងកើតឡើងនៅក្នុងជីវិតរបស់យើងនៅពេលដែលយើងស្វែងរកព្រះអម្ចាស់អស់ពីចិត្ត។ អ្វីៗទាំងអស់ចាប់ផ្តើមនៅក្នុងជីវិតថ្មី។ យើងឃើញមានអ្វីដែលប្លែកៗបានកើតមានឡើង យើងគិតខុសពីមុននិងគំនិតរបស់យើងគឺថ្មី។ ឥឡូវនេះព្រះជាម្ចាស់គឺគ្រប់គ្រងការគិត និងគំនិតរបស់យើង។ យើងត្រូវការរស់នៅក្នុងទម្លាប់មួយដែលអនុញ្ញាតឱ្យព្រះជាម្ចាស់មានឥទ្ធិពលមកកាន់គំនិតរបស់យើងតាមរយៈគំនិតរបស់យើង។ អនុញ្ញាតឱ្យព្រះជាម្ចាស់ដាក់ព្រះតម្រិះរបស់ព្រះអង្គនៅក្នុងគំនិតរបស់យើង។ នៅពេលដែលអ្នកអធិស្ឋាន អ្នកនឹងមានការប៉ះពាល់ជាមួយការដឹកនាំរបស់ព្រះវិញ្ញាណដ៏វិសុទ្ធ។ ទ្រង់នឹងប្រទានប្រាជ្ញាដល់អ្នកនៅក្នុងទំនាក់ទំនងរបស់អ្នកជាមួយអ្នកដទៃ។ នៅពេលដែលអ្នកដើរតាមការដឹកនាំរបស់ព្រះអង្គ គំនិតរបស់អ្នកនឹងផ្លាស់ប្តូរ និងប្រែមកជាថ្មី ហើយអ្នកនឹងក្លាយជាពន្លឺ និងអំបិលទៅកាន់សហគមន៍របស់អ្នក។

នៅក្នុង ១កូរិនថូស ២:១៦ លោកសាវ័កប៉ូលបានមានប្រសាសន៍ថា «រីឯយើងវិញ យើងមានគំនិតរបស់ព្រះគ្រិស្តហើយ»។ លោកក៏បានមានប្រសាសន៍នៅក្នុងភីលីព ២:៥ ផងដែរថា «ព្រះគ្រិស្តយេស៊ូមានចិត្តគំនិតយ៉ាងណា បងប្អូនត្រូវមានចិត្តគំនិតយ៉ាងនោះដែរ»។ បន្ទាប់មកគាត់បន្តចែកចាយអំពីឥរិយាបថដែលព្រះគ្រិស្តមាន។ សូមអានភីលីព ២:៥-១១

បន្ទាប់មកសិក្សាតាមតារាងខាងក្រោមរហូតទាល់តែអ្នកយល់ពីឥរិយាបថរបស់ព្រះគ្រិស្ត និងទំនួយខុសត្រូវរបស់ព្រះអង្គជាមួយទំនួលខុសត្រូវទាំងនោះ។

| សកម្មភាពរបស់ព្រះយេស៊ូ | ឥរិយាបថគំនិតរបស់ព្រះអង្គ | ការឆ្លើយតបរបស់ព្រះជាម្ចាស់ |
| --- | --- | --- |
| ទ្រង់បានលះបង់អ្វីៗទាំងអស់ដែលទ្រង់មាន (ខ.៧)។ | ចុះចូល | ព្រះជាម្ចាស់ លើកតម្កើងព្រះអង្គឡើងយ៉ាងខ្ពង់ខ្ពស់បំផុត(ខ.៩) |
| ទ្រង់យកឋានៈជាទាសករ (ខ.៧) | បន្ទាបខ្លួន | ព្រមទាំងប្រោសប្រទានអោយព្រះអង្គមានព្រះនាមប្រសើរលើសអ្វីៗទាំងអស់ (ខ.៩) |
| ព្រះអង្គបានដាក់ខ្លួន ធ្វើតាមព្រះបញ្ជា (ខ.៨) | ស្តាប់បង្គាប់ | ព្រះជាម្ចាស់ប្រទានកិត្តិយសដល់ព្រះអង្គ (ខ.១០ ខ.១១) |

តើអ្នកមានប្រភេទនៃគំនិតណាមួយដូចដែលព្រះគ្រិស្តមានដែលឬទេ? តើអ្នកចុះចូល បន្ទាបខ្លួន និងស្តាប់បង្គាប់ដែលឬទេ? សូមព្រះអម្ចាស់ជួយអ្នកឱ្យមានគំនិតថ្មី គំនិតរបស់ព្រះគ្រិស្ត។ ការមានព្រះតម្រិះរបស់ព្រះអង្គនឹងជួយអ្នកឱ្យមានទំនាក់ទំនងជាមួយក្តីស្រឡាញ់របស់ព្រះអង្គ និងព្រះហឫទ័យទុកដាក់របស់ព្រះអង្គនៅក្នុងសហគមន៍របស់អ្នក។

**លំហាត់អនុវត្តន៍**

---

៦ សូមសរសេរពីឧទាហរណ៍ពីរបៀបដែលអ្នកអាច

ក) ចុះចូល

......................................................................................................................................

ខ) បន្ទាបខ្លួន

......................................................................................................................................

គ) ស្តាប់បង្គាប់

......................................................................................................................................

៧ តើគំនិតថ្មីអាចធ្វើឱ្យយើងកាន់តែមានឥទ្ធិពលដោយរបៀបណា?

......................................................................................................................................

......................................................................................................................................

## សូមផ្ទៀងចម្លើយរបស់អ្នក

៥ ក្នុងនាមជាគ្រិស្តបរិស័ទគួរតែធ្វើជាភ្នាក់ងារនៃការប្រោសឱ្យជាទៅកាន់មនុស្សដែលនៅជុំវិញគាត់ ឬ នាង។ គាត់ ឬ នាងគួរតែរក្សាកិច្ចការនេះជាមួយអ្វីដែលត្រឹមត្រូវ និងបង្ហាញពីរបៀបដែលព្រះគ្រិស្តប្រទានអត្ថន័យទៅកាន់ជីវិត។

១ ដើម្បីជួយពួកយើងឱ្យឃើញនូវផ្នែករបស់ពួកយើង ដើម្បីព្រមានពីគ្រោះថ្នាក់ ដើម្បីជួយពួកយើងឱ្យមើលឃើញអ្វីមួយជាក់ច្បាស់។

៦០ ចម្លើយរបស់អ្នក។ តើអ្នកអាចគិតពីឧទាហរណ៍សម្រាប់ចំណុចទាំងបីនេះ?

២ ពួកយើងឆ្លុះបញ្ចាំងពន្លឺរបស់ព្រះគ្រិស្តដើម្បីជួយមនុស្សដទៃឱ្យរកឃើញផ្លូវទៅកាន់ព្រះអង្គ ដើម្បីព្រមានពួកគេពីគ្រោះថ្នាក់នៃអំពើបាប និងជួយពួកគេឱ្យស្គាល់ជាក់ច្បាស់ថាអំពើបាបជាអ្វី។

៣ ក) បរិសុទ្ធ
ខ) អំបិល

៧ នៅពេលគំនិតរបស់ខ្ញុំប្រែមកជាថ្មី ខ្ញុំមានឥរិយាបថរបស់ព្រះគ្រិស្ត និងខ្ញុំអាចមានការប៉ះពាល់ដល់មនុស្សដទៃទៀតក្នុងការដើរតាមព្រះអង្គ។

៤ ដើម្បីបន្សុទ្ធ ការពារកុំឱ្យស្អុយ និងធ្វើឱ្យមានរស់ជាតិ។

# មេរៀនទី ៨

# សមាជិកភាពនៅក្នុងសហគមន៍ក្រុមជំនុំ

## Belonging in the Church Community

ឈេ គីម (Chee Kim) គឺជាក្មេងកំព្រាម្នាក់។ ទោះបីគាត់មានអាយុប្រាំមួយឆ្នាំ គាត់រស់នៅតាមផ្លូវនៅក្រុងហុងកុង (Hong Kong)។ គាត់មិនមែនជាកម្មសិទ្ធិរបស់នរណាម្នាក់នោះទេ។

ថ្ងៃមួយមានបុរសចិត្តល្អម្នាក់បានជួបជាមួយឈេ គីម និងបាននាំគាត់ទៅផ្ទះជាកន្លែងដែលមានក្មេងប្រុស និងក្មេងស្រីជាច្រើនរស់នៅ។ នៅទីនោះគាត់ទទួលបានការយកចិត្តទុកដាក់យ៉ាងល្អ និងគាត់ទទួលការបង្រៀនអំពីព្រះយេស៊ូ។ ក្នុងពេលយ៉ាងខ្លីឈេរៀនអាន និងសរសេរឈ្មោះរបស់គាត់ផ្ទាល់។

បន្ទាប់ពីពីរ ឬ បីខែកន្លងមកឈេ គីមត្រូវបានគេនាំយកទៅកាន់ក្រុមគ្រួសារជនជាតិចិនដែលពេញដោយក្តីស្រឡាញ់មួយ។ គាត់ត្រូវបានគ្រួសារមួយនេះយកទៅចិញ្ចឹម និងថែរក្សាដូចជាកូនបង្កើត។ ឥឡូវនេះគាត់ពិតជាមានអំណរខ្លាំងណាស់ ពីព្រោះគាត់ក្លាយទៅជាសមាជិកភាពរបស់ក្រុមគ្រួសារមួយ។

តម្រូវការមួយនៃតម្រូវការគ្រឹះរបស់ពួកយើងគឺភាពជាកម្មសិទ្ធ។ ភាពជាកម្មសិទ្ធរបស់ក្រុមគ្រួសារមួយធ្វើឱ្យយើងទទួលបានការថ្នាក់ថ្នម និងសុវត្ថិភាព។ នៅពេលដែលអ្នកក្លាយជាគ្រិស្តបរិស័ទ អ្នកក្លាយទៅជាផ្នែកមួយនៃក្រុមគ្រួសាររបស់ព្រះជាម្ចាស់។ នៅក្នុងមេរៀននេះអ្នកនឹងសិក្សាអំពីអត្ថន័យភាពជាកម្មសិទ្ធក្នុងក្រុមគ្រួសារព្រះជាម្ចាស់។ សហគមន៍នៃអ្នកជឿជាអ្នកបង្កើតក្រុមជំនុំរបស់ព្រះអង្គ។

## គម្រោង

ក. ការថ្វាយបង្គំរួមគ្នា Worshipping Together

ខ. ការប្រកបគ្នា Fellowship

គ. ការបម្រើព័ន្ធកិច្ចជាមួយគ្នា Ministering Together

## គោលដៅ

១. ស្គាល់ពីតម្លៃនៃការថ្វាយបង្គំជាមួយអ្នកជឿដទៃទៀត។

២. ពិណ៌នាពីលទ្ធផលនៃព័ន្ធកិច្ចរួមរបស់អ្នកជឿនៅក្នុងក្រុមជំនុំ។

៣. បង្ហាញពីលទ្ធផលនៃការចូលរួមជាមួយអ្នកផ្សេងទៀតនៅក្នុងព័ន្ធកិច្ច។

## ក. ការថ្វាយបង្គំរួមគ្នា Worshipping Together

**គោលដៅ១. ស្គាល់ពីតម្លៃនៃការថ្វាយបង្គំជាមួយជឿដទៃទៀត។**

នៅក្នុងមេរៀនដំបូងពួកយើងបាននិយាយថាក្រុមជំនុំមិនមែនជាអាគារនោះទេ__គឺជារូបកាយរបស់អ្នកជឿដែលរួមគ្នាធ្វើកិច្ចការបម្រើព្រះអម្ចាស់។ នៅពេលដែលយើងក្លាយជាគ្រិស្តបរិស័ទពួកយើងក្លាយជាផ្នែកមួយនៃព្រះកាយរបស់ព្រះគ្រិស្ត។ ពួកយើងគឺជាផ្នែកមួយនៃក្រុមជំនុំសកលរបស់ព្រះអង្គ។ មនុស្សដែលជាព្រះកាយរបស់ព្រះគ្រិស្តប្រួបរួមគ្នា ដើម្បីធ្វើកិច្ចការបម្រើព្រះអម្ចាស់ និងដើម្បីថ្វាយបង្គំព្រះអង្គ។ ពួកគេបង្កើតក្រុមជំនុំជាក្រុមនៅក្នុងសហគមន៍របស់ពួកគេ។ នៅក្នុងកណ្ឌគម្ពីរកិច្ចការយើងបានអានអំពីក្រុមជំនុំដំបូង និងអំពីរបៀបដែលគ្រិស្តបរិស័ទធ្វើដំណើរពីសហគមន៍មួយទៅសហគមន៍មួយទៀត ជួយដើម្បីដាំក្រុមជំនុំថ្មី។ អ្នកជឿដំបូងទាំងនេះមានបំណងចិត្តយ៉ាងមុតមាំក្នុងការថ្វាយបង្គំព្រះអម្ចាស់រួមគ្នា។

ការថ្វាយបង្គំព្រះជាម្ចាស់មានន័យថាការថ្វាយពេលវេលាផ្ទាល់ខ្លួនរបស់អ្នកទៅកាន់ព្រះអង្គ។ អ្នកថ្វាយការលើកតម្កើង និងការសរសើរទៅកាន់ព្រះអង្គ។ អ្នកលើកតម្កើងព្រះអង្គលើសជាងអ្វីៗផ្សេងទៀត។ ព្រះជាម្ចាស់បានបង្កើតមនុស្សដូចច្នេះហើយបានជាពួកគេចូលចិត្តរស់នៅជាមនុស្សផ្សេងទៀត។ វាជាធម្មជាតិសម្រាប់អ្នកជឿក្នុងការមានបំណងចិត្តចូលរួមជាមួយគ្នាក្នុងការថ្វាយបង្គំ។ យើងផ្តល់ឱ្យ និងទទួលការលើកទឹកចិត្តនៅពេលដែលយើងថ្វាយបង្គំជាមួយគ្នា។

មានរបៀបជាច្រើនក្នុងការបង្ហាញការថ្វាយបង្គំទៅកាន់ព្រះជាម្ចាស់។ នៅក្នុងកណ្ឌគម្ពីរទំនុកតម្កើងយើងទទួលបានការណែនាំពីការថ្វាយបង្គំព្រះជាម្ចាស់នៅក្នុងរបៀបផ្សេងៗជាច្រើន-តាមរយៈការទះដៃ ការច្រៀង សរសើរព្រះអង្គជាមួយសម្លេងរបស់យើងតាមរយៈការអធិស្ឋាន តាមរយៈឧបករណ៍ភ្លេង និងនៅក្នុងរបៀបផ្សេងទៀត។ នៅពេលដែលយើងចូលរួមជាមួយអ្នកជឿដទៃទៀតក្នុងការថ្វាយបង្គំតាមរបៀបទាំងនេះ យើងរកឃើញរបៀបងាយស្រួលក្នុងការបង្ហាញពី

ក្តីស្រឡាញ់ និងការលើកតម្កើងរបស់ពួកយើងទៅកាន់ព្រះជាម្ចាស់។ ការថ្វាយបង្គំជាមួយអ្នកជឿដទៃទៀតនឹងផ្តល់ឱ្យយើងនូវកម្លាំងដ៏ខ្លាំងក្លាក្នុងការបម្រើព្រះជាម្ចាស់។

របៀបផ្សេងទៀតដើម្បីបង្ហាញការថ្វាយបង្គំទៅកាន់ព្រះជាម្ចាស់គឺតាមរយៈការបម្រើដល់អ្នកដទៃទៀត។ ការថ្វាយបង្គំដ៏ពិត ជាការបង្ហាញក្តីស្រឡាញ់ និងការលើកតម្កើងទៅកាន់ព្រះជាម្ចាស់ ជាធម្មតាលទ្ធផល គឺការបង្ហាញក្តីស្រឡាញ់ និងសប្បុរសដល់មនុស្សដទៃទៀត។ បានបង្ហាញនៅក្នុងព្រះបន្ទូលរបស់ព្រះយេស៊ូក្នុងម៉ាថាយ ២៣:៣១-៤០ និងដូចជាអ្វីដែលយើងបានឃើញនៅក្នុងមេរៀនដទៃទៀត។ នៅពេលដែលពួកយើងបម្រើដល់មនុស្សដទៃទៀត យើងធ្វើកិច្ចការទាំងអស់នេះដូចជាធ្វើថ្វាយព្រះអម្ចាស់។

**លំហាត់អនុវត្តន៍**

---

១ គូសរង្វង់ជុំវិញអក្សរនៅពីមុខប្រយោគដែលពិពណ៌នាពីតម្លៃនៃការថ្វាយបង្គំជាមួយអ្នកជឿឯទៀត។

ក) យើងបានទទួលបានកម្លាំង។

ខ) យើងក្លាយទៅជាអ្នកដែលយកចិត្តទុកដាក់ខ្លាំងទៅលើខ្លួនរបស់យើងផ្ទាល់។

គ) យើងឱ្យ និងទទួលការលើកទឹកចិត្ត។

ឃ) តាមរយៈការបម្រើមនុស្សផ្សេងទៀត យើងលើកតម្កើងព្រះជាម្ចាស់។

ង) វាធ្វើឱ្យយើងកាន់តែងាយស្រួលក្នុងការបង្ហាញអារម្មណ៍ក្នុងពេលថ្វាយបង្គំរបស់យើង។

ច) វាធ្វើឱ្យយើងកាន់តែលំបាកក្នុងការគិតអំពីព្រះជាម្ចាស់។

២ ធ្វើបញ្ជីអំពីរបៀបមួយចំនួនក្នុងការថ្វាយបង្គំព្រះជាម្ចាស់។

……………………………………………………………………………………………………

……………………………………………………………………………………………………

## ខ. ការប្រកបគ្នា Fellowship

**គោលដៅទី២. ពិពណ៌នាពីលទ្ធផលនៃព័ន្ធកិច្ចរួមរបស់អ្នកជឿនៅក្នុងក្រុមជំនុំ។**

នៅក្នុងមេរៀនដំបូងរបស់យើង យើងឃើញថាអត្ថន័យមួយរបស់សហគមន៍ក្នុងចំណោមអត្ថន័យផ្សេងទៀតគឺ «ការប្រកបគ្នា» ភាពខ្ពង់ខ្ពស់បំផុតនៃការប្រកបគ្នាអាចរកឃើញនៅក្នុងចំណោមគ្រិស្តបរិស័ទ។ ក្រុមជំនុំតាមតំបន់គឺ ជាកន្លែងដ៏ល្អប្រសើរមួយក្នុងការស្វែងរកការប្រកបជាមួយអ្នកជឿដទៃទៀត។ យុវជនរីករាយក្នុងការនៅជាមួយមនុស្សផ្សេងទៀត និងចំណាយពេលកំសាន្ត និងធ្វើកិច្ចការរួមគ្នា។ មនុស្សពេញវ័យដូចគ្នាផងដែរ ត្រូវការស្គាល់មនុស្សដទៃទៀត និងចំណាយពេលធ្វើសកម្មភាពរួមគ្នា។

តាមរយៈសកម្មភាពប្រកបគ្នាក្នុងក្រុមជំនុំ យើងអាចឈោងចាប់សហគមន៍ទាំងមូលបាន។ សកម្មភាពពិសេសសម្រាប់កុមារអាចមានន័យថាជាការនាំកុមារដទៃទៀត។ ការធ្វើដំណើរកំសាន្តរួមគ្នា ឬធ្វើការក្នុងគម្រោងអ្វីមួយជាមួយគ្នា ឬ គ្រាន់តែចំណាយពេលវេលាជជែកកំសាន្ត និងចែកចាយជាមួយគ្នាទាំងនេះគឺជារបៀបដែលធ្វើឱ្យយើងស្គាល់មនុស្សបានកាន់តែប្រសើរ។ នៅពេលដែលយើងស្គាល់គ្នា យើងងាយស្រួលក្នុងការបម្រើគ្នាទៅវិញទៅមក នៅពេលនរណាម្នាក់មានតម្រូវការ។

នៅក្នុងកណ្ឌដំណឹងល្អមានកន្លែងជាច្រើនដែលនិយាយពីការដែលព្រះយេស៊ូបរិភោគជាមួយមនុស្ស។ ទ្រង់បានប្រើពេលវេលាធម្មតានៃការប្រកបគ្នាដើម្បីចែកចាយសេចក្តីពិតកាន់តែស៊ីជំរៅអំពីព្រះរាជរបស់ព្រះជាម្ចាស់ ឬ ធ្វើព័ន្ធកិច្ចដើម្បីបំពេញតម្រូវការជាលក្ខណៈបុគ្គល។ យើងទាំងអស់គ្នាត្រូវការពេលវេលាដើម្បីសម្រាក រីករាយជាមួយមនុស្សផ្សេងទៀត និងដើម្បីស្គាល់គ្នាកាន់តែច្បាស់។ នៅក្នុងរបៀបនេះជាញឹកញាប់ ប្រជាជនដែលរស់នៅក្នុងសហគមន៍មិនមែនជាផ្នែកនៅក្នុងក្រុមជំនុំតាមតំបន់ដែលនាំឱ្យមានការប្រេបកជាមួយព្រះអម្ចាស់ និងក្រុមជំនុំ។ ការចែកចាយ ការយកចិត្តទុកដាក់ និងក្តីស្រឡាញ់ត្រូវបានបង្ហាញជាសកម្មភាពរបស់សហគមន៍។

**លំហាត់អនុវត្តន៍**

---

៣ គ្រិស្តបរិស័ទអាចមានការប្រកបយ៉ាងជិតស្និតជាមួយ

ក) មនុស្សដែលគេធ្វើការជាមួយ។

ខ) អ្នកជិតខាងរបស់ពួកគេ។

គ) អ្នកជឿដទៃទៀតនៅក្នុងក្រុមជំនុំ។

៤ អត្ថប្រយោជន៍ដ៏ធំបំផុតនៃការប្រកបគ្នាគឺយើង

ក) រៀនពីរបៀបក្នុងការសិក្សារួមគ្នា។

ខ) អាចស្គាល់គ្នាទៅវិញទៅមកកាន់តែប្រសើរ។

គ) អាចបំភ្លេចបញ្ហាផ្ទាល់ខ្លួនរបស់យើង។

៥ ពិពណ៌នាពីរបៀបមួយចំនួនក្នុងការប្រកបជាមួយអ្នកជឿដទៃទៀត។

..................................................................................................................................

..................................................................................................................................

## គ. ការបម្រើព័ន្ធកិច្ចជាមួយគ្នា Ministering Together

**គោលដៅទី៣. បង្ហាញពីលទ្ធផលនៃការចូលរួមជាមួយអ្នកផ្សេងទៀតនៅក្នុងព័ន្ធកិច្ច។**

គុណសម្បត្តិមួយក្នុងចំណោមគុណសម្បត្តិដ៏វិសេសនៃការចូលរួមទៀតទាត់នៅក្នុងក្រុមជំនុំ គឺអភ័យឯកសិទ្ធិនៃការសិក្សាជាមួយគ្រិស្តបរិស័ទដទៃទៀត។ នៅក្នុងក្រុមជំនុំជាច្រើនគឺមានថ្នាក់ថ្ងៃអាទិត្យ និងវគ្គហ្វឹកហ្វឺនព្រះគម្ពីរ។ ការសិក្សាព្រះគម្ពីរ ជាទៀងទាត់ផ្តល់ឱ្យបុគ្គលម្នាក់ស្គាល់ច្បាស់ពីសាវតាប្រវត្តិសាស្ត្រ និងយល់ដឹងកាន់តែប្រសើរទៅលើព្រះបន្ទូល។ លោកគ្រូគង្វាលរៀបចំមេរៀនអធិប្បាយដើម្បីជួយយើងឱ្យមានការរីកចម្រើន និងក្លាយទៅជាមនុស្សពេញវ័យ។ ខណៈពេលយើងព័ន្ធកិច្ចក្នុងរបៀបនេះ យើងអាចបម្រើព័ន្ធកិច្ចទៅកាន់អ្នកដទៃទៀត។

នៅក្នុងជំពូកទី២ និងទី៣ នៃកណ្ឌគម្ពីរទីតុសមានកន្លែងជាច្រើនដែលនិយាយអំពីកិរិយាមាយាទ និងទំនួលខុសត្រូវរបស់គ្រិស្តបរិស័ទ។ នៅក្នុងខគម្ពីរទាំងនេះលោកសាវ័កប៉ូលបាននិយាយពីកិច្ចការមួយចំនួនដែលយល់ស្របជាមួយគោលលទ្ធិ និងការបង្រៀន។ ជួយស្ត្រីមេម៉ាយ សេចក្តីបង្រៀនដល់យុវជន និងសេចក្តីបង្រៀនដល់អ្នកបម្រើព័ន្ធកិច្ចដើម្បីស្តាប់បង្គាប់គ្រប់ចំណុចទាំងអស់ដែលបានលើកឡើងនៅទីនេះ។ គ្រប់ទាំងអស់នៃចំណុចទាំងនេះជាផ្នែកនៃព័ន្ធកិច្ចនៃក្រុមជំនុំ។

មនុស្សនៅពេលប្រមូលផ្តុំគ្នាអាចធ្វើកិច្ចការដែលពួកគេមិនអាចធ្វើបានពេលនៅម្នាក់ឯង។ ពេលប្រពន្ធរបស់ខ្ញុំនៅក្មេងគាត់បានរស់នៅក្នុងកសិដ្ឋានមួយនៅក្នុងប្រទេសកាណាដា កសិករតែងតែជួយគ្នាទៅវិញទៅមកនៅពេលប្រមូលផលដំណាំ ពីព្រោះពួកគេមិនមានម៉ាស៊ីនក្នុងការធ្វើកិច្ចការទាំងអស់នេះ។ កសិករមួយចំនួនបានទុកការងាររបស់ខ្លួនចោលដើម្បីទៅជួយកសិករផ្សេងទៀតក្នុងការប្រមូលផលពោត និងស្រូវសាលី។ នៅពេលកសិករទាំងអស់ធ្វើការរួមគ្នា ដំណាំទាំងអស់ គឺត្រូវបានច្រូតកាត់។ ពួកគេមិនអាចធ្វើកិច្ចការទាំងនេះតែម្នាក់ឯងបានទេ។

គោលការណ៍ដូចគ្នាដែលមានដំណើរការនៅក្នុងក្រុមជំនុំ។ ឧទាហរណ៍ ព្រះគម្ពីរត្រូវការបកប្រែជាភាសារបស់មនុស្សនៅក្នុងប្រទេសភូមា (Burma)។ គម្រោងមួយនេះធំខ្លាំងណាស់សម្រាប់មនុស្សម្នាក់ ឬ ក្រុមជំនុំមួយ។ ដូច្នេះយើងត្រូវការចំនួនមនុស្សដ៏ច្រើនដែលមកពីក្រុមជំនុំផ្សេងៗ ដាក់ដង្វាយរួមគ្នា និងការចំណាយដើម្បីបានការបកប្រែព្រះគម្ពីរ។

នៅពេលដែលអ្នកក្លាយជាមនុស្សពេញវ័យក្នុងព្រះអម្ចាស់ អ្នកមានបំណងចិត្តមុតមាំក្នុងការបម្រើទៅកាន់អ្នកដទៃ។ ពិភពលោករបស់អ្នកកាន់តែធំ ហើយអ្នកក្លាយជាមនុស្សម្នាក់ដែលយកចិត្តទុកដាក់ទៅលើតម្រូវការរបស់មនុស្សដទៃ។

នៅពេលមនុស្សមួយចំនួនបានឮសម្រែកនៃការស្រេកឃ្លានរបស់មនុស្សដទៃទៀតដែលមិនមែនជាបងប្អូនរបស់ពួកគេ។ ពួកគេគ្រាន់តែគិតថាមនុស្សទាំងនោះគួរតែខិតខំធ្វើការដូច្នេះពួកគេនឹងមានលុយដើម្បីទិញម្ហូបអាហារ។ ប៉ុន្តែ នៅពេលដែលគ្រិស្តបរិស័ទឮសម្រែកនៃការរងទុក្ខរបស់មនុស្សដែលអត់អាហារបរិភោគ ពួកគេតែងតែជួយ និងយល់ចិត្តអ្នកទាំងនោះ។ ព្រះយេស៊ូមានព្រះបន្ទូលថា «បើគេអោយអ្វីច្រើនទៅអ្នកណា គេនឹងទារពីអ្នកនោះវិញច្រើនដែរ។ បើគេផ្ទុកផ្ដាក់

កិច្ចការច្រើនដល់អ្នកណា គេនឹងទារពីអ្នកនោះវិញរឹងរឹតតែច្រើនថែមទៀត»។ (លូកា ១២:៤៨) នៅក្នុងន័យមួយទៀត បើព្រះជាម្ចាស់ប្រទានពរអ្នកកាន់តែច្រើន អ្នកនឹងមានទំនួលខុសត្រូវសម្រាប់របៀបដែលអ្នកប្រើប្រាស់ព្រះពរទាំងនេះ និងរបៀបដែលអ្នកមានទំនួលខុសត្រូវទៅកាន់តម្រូវការរបស់មនុស្សដទៃទៀត។

នៅពេលដែលអ្នកឮសម្រែករបស់មនុស្សនៅជ្រុងម្ខាងទៀតនៃផែនដីឈឺចាប់ដោយការអត់អាហារ ឬ ខ្យល់ព្យុះ ឬ រញ្ជួលផែនដី តើបញ្ហាទាំងអស់នេះប៉ះពាល់ដល់ជីវិតរបស់អ្នកដែរឬទេ? សញ្ញានៃភាពពេញវ័យរបស់អ្នកគឺរបៀបដែលបញ្ហាទាំងអស់នេះប៉ះពាល់ដល់ជីវិតរបស់អ្នក។ សួរខ្លួនឯងនូវសំណួរទាំងនេះ តើខ្ញុំយកចិត្តទុកដាក់ចំពោះអ្នកជិតខាងរបស់ខ្ញុំដែលឬទេ? តើវាពិតជាមានសារសំខាន់សម្រាប់ខ្ញុំដែរឬទេ ប្រសិនបើមានមនុស្សមួយពាន់អ្នកស្លាប់នៅកន្លែងដ៏សែនឆ្ងាយមួយ? តើខ្ញុំពិតជាយកចិត្តទុកដាក់ចំពោះការជាប់ពាក់ព័ន្ធក្នុងព័ន្ធកិច្ចក្នុងពិភពលោកទាំងមូលដែរឬទេ? តើខ្ញុំជួយក្រុមជំនុំរបស់ខ្ញុំដើម្បីបម្រើដល់អស់អ្នកដែលមានតម្រូវការដែរឬទេ?

**លំហាត់អនុវត្តន៏**

---

៦ ព្រះជាម្ចាស់រំពឹងយើងឱ្យទៅកាន់អ្នកដទៃ

ក) នូវអ្វីគ្រប់យ៉ាងដែលយើងមាន។

ខ) ទៅតាមព្រះពរដែលយើងទទួលបានពីព្រះអង្គ។

គ) តែពេលណាដែលយើងចង់តែប៉ុណ្ណោះ។

៧ គូររង្វង់ជុំវិញប្រយោគដែលត្រឹមត្រូវនីមួយៗ

ក) សញ្ញាសម្គាល់ពិតប្រាកដមួយក្នុងចំណោមសញ្ញាសម្គាល់ផ្សេងទៀតនៃគ្រិស្តបរិស័ទគឺពួកគេយកចិត្តទុកដាក់សម្រាប់មនុស្សដទៃទៀត។

ខ) នៅពេលគ្រិស្តបរិស័ទឮសម្រែករងទុក្ខ និងវិនាសកម្ម ពួកគេមានអារម្មណ៍ឈឺចាប់ចំពោះមនុស្សដែលមានការពាក់ព័ន្ធ។

គ) មានតម្រូវការជាច្រើនទៀតសម្រាប់អ្នកដែលទទួលបានតិចតួច។

ឃ) នៅពេលព្រះជាម្ចាស់ប្រទានពរមកអ្នកកាន់តែច្រើន វាមិនមែនមានន័យថាអ្នកមានតម្រូវការច្រើននោះទេ។

ង) មនុស្សធ្វើការរួមគ្នាអាចបំពេញកិច្ចការបានច្រើនជាងធ្វើការតែម្នាក់ឯង។

៨ ពិនិត្យមើលខ្លួនអ្នកផ្ទាល់តាមរយៈការឆ្លើយតាមសំណួរខាងក្រោម។

| | ចាស/បាទ | ទេ |
|---|---|---|
| ក) តើអ្នកជាសមាជិកនៅក្នុងក្រុមជំនុំតាមតំបន់? | …………. | ……… |
| ខ) តើអ្នកមានភាពស្មោះត្រង់ក្នុងការចូលរួមដែរឬទេ? | …………. | ……… |
| គ) តើអ្នករីករាយក្នុងការប្រកបជាមួយគ្រិស្តបរិស័ទដទៃទៀតដែរឬទេ? | ………… | ……… |
| ឃ) តើអ្នកជួយផ្គត់ផ្គង់ក្រុមជំនុំតាមរយៈថវិការបស់អ្នក ឬតាមរបៀបផ្សេងទៀតដែរឬទេ? | ………… | ……… |
| ង) តើក្រុមជំនុំរបស់អ្នកមានសកម្មភាពដើម្បីបម្រើទៅកាន់សហគមន៍ដែរឬទេ? | ……….. | ……… |
| ច) តើអ្នកត្រូវការធ្វើអ្វីបន្ថែមទៀតដើម្បីមានការពាក់ព័ន្ធនៅក្នុងសកម្មភាពផ្សេងៗក្នុងចំណោមសកម្មភាពទាំងនេះនៅក្នុងក្រុមជំនុំរបស់អ្នកដែរឬទេ? | ……….. | ……… |

## សូមផ្ទៀងផ្ទាត់ចម្លើយរបស់អ្នក

៤ ក) ស្គាល់មនុស្សផ្សេងទៀតកាន់តែប្រសើរ

១ ប្រយោគ ក) គ) ឃ) និង ង) គឺត្រឹមត្រូវ។

៧ ប្រយោគ ក) ខ) គ) និង ច) គឺត្រឹមត្រូវ។

៥ ចម្លើយរបស់អ្នក។ ចម្លើយមួយចំនួនគឺៈ ការបរិភោគអាហាររួមគ្នា ការជជែក ឬ ចែកចាយជាមួយគ្នា ការប្រើឧបករណ៍តន្ត្រី ទះដៃ អធិស្ឋាន ឬបម្រើអ្នកដទៃ។

៦ ខ) ទៅតាមព្រះពរដែលយើងទទួលបានពីព្រះអង្គ។

៣ គ) ជាមួយអ្នកជឿដទៃទៀតក្នុងក្រុមជំនុំ។

៨ ចម្លើយរបស់អ្នក។ ប្រសិនបើចម្លើយរបស់អ្នក *ទេ* ទៅកាន់សំណួរមួយចំនួនក្នុងចំណោមសំនួរទាំងនេះ គិតអំពីរបៀបដែលអ្នកអាចបង្កើនទំនាក់ទំនងរបស់អ្នកជាមួយព្រះជាម្ចាស់តាមរយៈក្រុមជំនុំតាមតំបន់របស់អ្នក។

# មេរៀនទី ៦

# ការបរិច្ចាគនៅក្នុងសហគមន៍របស់អ្នក

## Contributing to Your Community

សមាគមកាកបាទក្រហមធ្វើការស្ទើរតែគ្រប់ទ្វីប និងគ្រប់ប្រទេសទាំងអស់បម្រើមនុស្សជាតិ។ ពួកគេជួយមនុស្សនៅពេលដែលមានគ្រោះមហន្តរាយដូចជាគ្រោះទុរ្ភិក្ស ឬ ខ្យល់ព្យុះ ឬ រញ្ជួយផែនដី។ សមាគមកាកបាទក្រហមផ្គត់ផ្គង់តាមរយៈការចែករំលែក ឬ អំណោយ។ មនុស្សឱ្យជាថវិកា សម្ភារៈផ្សេងៗ និងឈាមដូច្នេះកាកបាទក្រហមបានរៀបចំខ្លួនរួចជាស្រេចដើម្បីជួយនៅពេលណាដែលគ្រោះមហន្តរាយកើតឡើង។ មនុស្សចែករំលែកមិនមែនដោយសារពួកគេទទួលបានអ្វីមួយត្រឡប់មកវិញនោះទេ ប៉ុន្តែ ពួកគេមានបំណងចិត្តក្នុងការជួយមនុស្សផ្សេងទៀតនៅក្នុងពេលមានអាសន្ន និងបញ្ហា។

ឮដូចគ្នាជាមួយការចែករំលែករបស់ពួកយើងទៅកាន់សហគមន៍របស់ពួកយើងដែរ។ យើងមិនជួយដោយរំពឹងថានឹងបានអំណោយដ៏ល្អត្រឡប់មកវិញនោះទេ។ ដូចគ្នាផងដែរ យើងចែករំលែកពេលវេលារបស់ពួកយើង ថវិកា និងអំណោយទានទៅកាន់តម្រូវការរបស់សហគមន៍ពីព្រោះវាជាកិច្ចការដ៏ល្អ និងត្រឹមត្រូវដែលយើងគួរតែធ្វើ។  នៅក្នុងមេរៀននេះយើងនឹងឃើញពីរបៀបដែលយើងអាចរៀបចំខ្លួនរបស់យើងផ្ទាល់ដើម្បីបម្រើសហគមន៍របស់យើងកាន់តែប្រសើរ។

## គម្រោង

ក. ការរៀបចំក្នុងការបម្រើ Preparing to Serve

ខ. ការជាប់ពាក់ព័ន្ធ Becoming Involved

គ. ការបរិច្ចាគជំនាញ Contributing Skills

## គោលដៅ

១. ស្គាល់ពីរបៀបដើម្បីរៀបចំខ្លួនជាទីបន្ទាល់គ្រិស្តបរិស័ទនៅក្នុងសហគមន៍របស់អ្នក។

២. បង្ហាញពីរបៀបដែលមានឥទ្ធិពលទៅកាន់សហគមន៍របស់អ្នកសម្រាប់ព្រះជាម្ចាស់។

៣. បង្ហាញពីរបៀបដែលជំនាញរបស់អ្នកអាចប្រើដើម្បីជួយទៅកាន់សហគមន៍របស់អ្នក។

## ក. ការរៀបចំក្នុងការបម្រើ Preparing to Serve

**គោលដៅទី១. ស្គាល់ពីរបៀបដើម្បីរៀបចំខ្លួនជាទីបន្ទាល់គ្រិស្តបរិស័ទនៅក្នុងសហគមន៍របស់អ្នក។**

មុនពេលដែលយើងអាចបម្រើនរណាម្នាក់បាន ពួកយើងត្រូវការរៀបចំសម្រាប់ការបម្រើដែលយើងនឹងធ្វើ។ ការបម្រើដ៏ល្អបំផុតរបស់គ្រិស្តបរិស័ទដែលអាចឱ្យទៅកាន់សហគមន៍របស់គេគឺនាំព្រលឹងមនុស្ស។ មានរបៀបចំនួនបីក្នុងការរៀបចំខ្លួនរបស់អ្នកផ្ទាល់ក្លាយទៅជាស្មរបន្ទាល់នៅក្នុងសហគមន៍របស់អ្នក៖

*១. មានការធានាអះអាងផ្ទាល់ខ្លួននៃការសង្គ្រោះ។* តើអ្នកអាចដឹងប្រាកដអំពីការសង្គ្រោះរបស់អ្នកបានដោយរបៀបណា? តាមរយៈការមានទំនាក់ទំនងជិតស្និទ្ធជាមួយព្រះអម្ចាស់។ អ្នកអាចមានទំនាក់ទំនងនេះតាមរយៈ ការអធិស្ឋាន និងការសិក្សាព្រះបន្ទូលព្រះជាម្ចាស់។ នៅពេលដែលអ្នកស្គាល់អ្នកនិពន្ធនៃកណ្ឌគម្ពីរអ្នកនឹងមានបំណងចិត្តដ៏ខ្លាំងក្នុងការអានកណ្ឌគម្ពីរនោះ។ នៅពេលដែលអ្នកស្គាល់ព្រះជាម្ចាស់កាន់តែប្រសើរ អ្នកនឹងមានបំណងចិត្តដ៏ខ្លាំងក្នុងការអានព្រះបន្ទូលរបស់ព្រះអង្គ-ព្រះគម្ពីរ។

ត្រូវទុកចិត្តលើព្រះជាម្ចាស់ដោយផ្អែកលើអ្វីដែលព្រះគម្ពីរបានចែង និងមិនអាស្រ័យលើអារម្មណ៍ដែលអ្នកមាន។ ប្រសិនបើអ្នកមានអារម្មណ៍ថាបរាជ័យ ចូរមានកម្លាំងឡើង។ ព្រះជាម្ចាស់ស្រឡាញ់អ្នក! សូមទទួលយកសេចក្ដីស្រឡាញ់របស់ព្រះអង្គ និងដាក់ជំនឿរបស់អ្នកនៅលើព្រះបន្ទូលរបស់ព្រះអង្គជាងអារម្មណ៍របស់អ្នក។ ប្រសិនបើមានហេតុផលមួយចំនួនដែលធ្វើឱ្យអ្នកមានការយល់ច្រឡំទំនាក់ទំនងរបស់អ្នកជាមួយព្រះអង្គ សូមចងចាំខគម្ពីរនៅក្នុងអេភេសូ ២:៤-៥៖

ក៏ប៉ុន្តែ ព្រះជាម្ចាស់ដែលតែងតែមានព្រះហឫទ័យអាណិតមេត្តាដ៏ច្រើនពន់ប្រមាណនោះព្រះអង្គមានព្រះហឫទ័យស្រឡាញ់យើងខ្លាំងបំផុត គឺទោះបីយើងស្លាប់ដោយសារអំពើបាបរបស់យើងហើយក៏ដោយ ក៏ព្រះអង្គបានប្រោសប្រទានអោយយើងមានជីវិតរស់ រួមជាមួយព្រះគ្រិស្តវិញដែរ។ ព្រះជាម្ចាស់បានសង្គ្រោះបងប្អូន ដោយសារព្រះគុណ។

គ្មាននរណាម្នាក់ក្នុងចំណោមយើងអាចសន្សំគ្លីស្រឡាញ់របស់ព្រះជាម្ចាស់បាននោះទេ ដូច្នេះហើយពួកយើងត្រូវតែទទួលយកអំណោយដោយឥតគិតថ្លៃពីព្រះអង្គ និងរស់នៅក្នុងជីវិតដែលបង្ហាញពីការដឹងគុណចំពោះព្រះជាម្ចាស់។ លោកប៉ូលបានសួរថា៖

តើនរណាអាចបំបែកយើងចេញពីព្រះហឫទ័យស្រឡាញ់របស់ព្រះគ្រិស្តបាន? ទុក្ខវេទនា ឬការតប់ប្រមល់អន្ទះអន្ទែងការបៀតបៀន ការស្រេកឃ្លាន ខ្វះសម្លៀកបំពាក់ គ្រោះថ្នាក់ ឬ មួយត្រូវគេសម្លាប់?......ក៏ប៉ុន្តែក្នុងការទាំងនោះ យើងមានជ័យជំនះលើសពីអ្នកមានជ័យជំនះទៅទៀត ដោយព្រះអម្ចាស់ដែលបានស្រឡាញ់យើង។

នៅពេលយើងទទួលយកព្រះគ្រិស្តជាព្រះសង្គ្រោះរបស់យើង យើងអាចមានសុវត្ថិភាពពេញលេញនៅក្នុងការសង្គ្រោះរបស់យើងដោយសារព្រះគុណរបស់ព្រះអង្គ ហើយមិនដោយសារអារម្មណ៍របស់យើងនោះទេ។

*២. ដឹងពីរបៀបដឹកនាំមនុស្សទៅស្គាល់ព្រះជាម្ចាស់។* តើអ្នកធ្លាប់មាននរណាម្នាក់និយាយមកកាន់អ្នកថា «មកតាមខ្ញុំ ខ្ញុំស្គាល់ផ្លូវ» ហើយបន្ទាប់មកអ្នកក៏វង្វេង? វាមិនមែនជារឿងដែលគួរឱ្យពេញចិត្តនោះទេ។ យើងចូលចិត្តដើរតាមមនុស្សដែលពិតជាស្គាល់ផ្លូវច្បាស់។

ប្រសិនបើយើងចង់ដឹកនាំមនុស្សដទៃទៀតទៅកាន់ព្រះជាម្ចាស់ យើងត្រូវតែស្គាល់ផ្លូវ។ មានខគម្ពីរជាច្រើននៅក្នុងព្រះគម្ពីរដែលជួយយើងដើម្បីដឹកនាំមនុស្សទៅកាន់ព្រះគ្រិស្ត។ នៅក្នុងតារាងខាងក្រោមមានខគម្ពីរមួយចំនួនដែលអ្នកត្រូវតែចងចាំដើម្បីការចាប់ផ្តើមរបស់អ្នក៖

| | |
|---|---|
| រ៉ូម ៣:២៣ | មនុស្សគ្រប់គ្នាសុទ្ធតែមានបាប និងត្រូវការព្រះសង្គ្រោះ។ |
| រ៉ូម ៦:២៣ | មនុស្សសក្តិសមនឹងស្លាប់ ប៉ុន្តែព្រះជាម្ចាស់ប្រទានជីវិត។ |
| យ៉ូហាន ៣:១៦ | ព្រះជាម្ចាស់បានប្រទានយញ្ញបូជាសម្រាប់អំពើបាបរបស់យើង។ |
| ១យ៉ូហាន ១:៩ | ប្រសិនបើយើងសារភាពបាប ព្រះជាម្ចាស់នឹងអត់ទោសឱ្យយើង។ |
| ១យ៉ូហាន ៥:១៣ | យើងអាចដឹងថាយើងមានជីវិតអស់កល្បជានិច្ច។ |

ប្រសិនបើអ្នកចង់ប្រើខគម្ពីរទាំងនេះដើម្បីបង្ហាញនរណាម្នាក់ពីរបៀបរកព្រះគ្រិស្ត ចូរទន្ទេញខទាំងនេះ។ ចូរសរសេរខដំបូងដាក់ទំព័រខាងមុខ បន្ទាប់ខបន្ទាប់ដាក់ក្នុងទំព័របន្ទាប់។ ធ្វើដូច្នេះរហូតដល់សរសេរអស់ទាំង៥ខ។ បន្ទាប់មកអ្នកងាយស្រួល និងមានប្រសិទ្ធភាពក្នុងការប្រើព្រះគម្ពីរដឹកនាំនរណាម្នាក់ថ្វាយព្រះគ្រិស្ត។ អ្នករៀបចំខ្លួនរបស់អ្នកដើម្បីបម្រើ។ ខណៈពេលដែលអ្នកស្វែងរកខគម្ពីរដទៃទៀតដែលនឹងជួយអ្នកក្នុងការធ្វើស្មរបន្ទាល់ សូមរៀបចំខគម្ពីរនោះតាមរបៀបដូចគ្នា។

*៣. ពឹងផ្អែកលើព្រះវិញ្ញាណដ៏វិសុទ្ធ។* មិនសំខាន់ថាអ្នកចេះព្រះគម្ពីរច្រើនប៉ុណ្ណានោះទេ អ្នកត្រូវតែពឹងផ្អែកលើព្រះវិញ្ញាណបរិសុទ្ធដើម្បីជួយអ្នក។ព្រះអង្គនឹងប្រទានការណែនាំ នឹងពាក្យសំដីដែលត្រឹមត្រូវទៅក្នុងគំនិតរបស់អ្នកខណៈពេលដែលអ្នកធ្វើស្មរបន្ទាល់។

ព្រះវិញ្ញាណបរិសុទ្ធជាអ្នកនាំមនុស្សទៅកាន់ព្រះជាម្ចាស់ និងធ្វើឱ្យពួកគេមានការសោកស្តាយចំពោះអំពើបាបរបស់ពួកគេ។ ទ្រង់ជ្រាបពីស្ថានភាពនៃដួងចិត្តរបស់បុគ្គលម្នាក់ៗ។ នៅពេលដែលអ្នកអធិស្ឋានសម្រាប់ការណែនាំរបស់ព្រះអង្គទ្រង់នឹងជួយអ្នកដើម្បីបម្រើសហគមន៍របស់អ្នកតាមរយៈស្មរបន្ទាល់ផ្ទាល់ខ្លួនរបស់អ្នក។

**លំហាត់អនុវត្តន៍**

---

១ កុំមើលចម្លើយខាងលើ សូមសរសេរចុះនូវរបៀបបីដែលអ្នកអាចរៀបចំខ្លួនដើម្បីបម្រើសហគមន៍របស់អ្នកក្នុងនាមជាអ្នកនាំព្រលឹងវិញ្ញាណថ្វាយព្រះ។

ក)…………………………………………………………………………………………………

ខ)…………………………………………………………………………………………………

គ)…………………………………………………………………………………………………

២ សូមសរសេរពាក្យដែលត្រឹមត្រូវដើម្បីបំពេញប្រយោគខាងក្រោម។

ក) ខ្ញុំនឹងមានបំណងចិត្តដ៏អស្ចារ្យដើម្បីអានសៀវភៅ ប្រសិនបើខ្ញុំមានការយល់ដឹងផ្ទាល់ខ្លួនអំពី……...............

ខ) ទំនាក់ទំនងខ្ញុំជាមួយព្រះជាម្ចាស់មិនអាស្រ័យលើរបៀបដែលខ្ញុំ……………………………………….....

គ) តាមរយៈព្រះគុណរបស់ព្រះជាម្ចាស់ខ្ញុំ……………………………………………………………….

ឃ) ដើម្បីដឹកនាំនរណាម្នាក់ឱ្យមានបទពិសោធផ្ទាល់ខ្លួនជាមួយការសង្គ្រោះ ខ្ញុំត្រូវដឹង………………………..

ង) ខ្ញុំនឹងទទួលជំនួយនៅក្នុងការដឹកនាំមនុស្សដទៃទៀតថ្វាយព្រះជាម្ចាស់មកពី………………………………..

## ខ. ការជាប់ពាក់ព័ន្ធ Becoming Involved

គោលដៅទី២. បង្ហាញពីរបៀបដែលមានឥទ្ធិពលទៅកាន់សហគមន៍របស់អ្នកសម្រាប់ព្រះជាម្ចាស់។

គ្រិស្តបរិស័ទអាចបម្រើ និងមានឥទ្ធិពលទៅកាន់សហគមន៍របស់ពួកគេតាមរបៀបជាច្រើន។ ពួកយើងគួរតែធ្វើជាប្រជាពលរដ្ឋដែលល្អ អ្នកជិតខាង និងមិត្តភក្ដិ ពីព្រោះពួកយើងគឺជាគ្រិស្តបរិស័ទ។ សហគមន៍របស់ពួកយើងគួរតែប្រសើរ ពីព្រោះពួកយើងរស់នៅទីនោះ។ ប្រសិនបើយើងសង្ឃឹមចង់មានឥទ្ធិពលទៅកាន់សហគមន៍របស់យើងសម្រាប់ព្រះជាម្ចាស់ ពួកយើងត្រូវតែចូលរួមសកម្មភាពនៅក្នុងសហគមន៍។ ប៉ុន្តែយើងត្រូវតែសម្រេចចិត្តថាសកម្មភាពមួយណាដែលត្រឹមត្រូវ និងសកម្មភាពមួយណាដែលប៉ះពាល់ដល់បន្ទាល់ជាគ្រិស្តបរិស័ទរបស់យើង។ តើយើងធ្វើការសម្រេច ចិត្តដោយរបៀបណា?

ជាបឋម នៅពេលដែលអ្នកសម្រេចចិត្តជាប់ពាក់ព័ន្ធនៅក្នុងសកម្មភាពផ្សេងៗ សូមសួរសំណួរមកកាន់ខ្លួនឯងថា "តើវាប្រឆាំងជាមួយមូលដ្ឋានគ្រឹះនៃការបង្រៀនរបស់គ្រិស្តបរិស័ទដោយផ្អែកលើព្រះគម្ពីរដែលឬទេ? ប្រសិនបើចម្លើយ ទេ បន្ទាប់មកសួរសំណួរនេះមកកាន់ខ្លួនរបស់អ្នក" តើខ្ញុំអាចធ្វើជាស្មរបន្ទាល់របស់ព្រះជាម្ចាស់ រីករាយជាមួយសកម្មភាពទាំងនោះ ហើយមិនប៉ះពាល់ដល់អ្នកដទៃដែលឬទេ? ប្រសិនបើចម្លើយចាស/បាទ ហើយប្រសិនបើអ្នកធ្វើការសម្រេចចិត្តដោយការអធិស្ឋាន បន្ទាប់មកសូមចូលរួមសកម្មភាពនោះចុះ។

ប្រសិនបើអ្នកចូលរួមក្នុងសកម្មភាពនោះ ហើយឃើញថាសកម្មភាពទាំងនោះមិនបំពេញដល់ស្តង់ដាដែលបានផ្តល់ជូនខាងលើ បន្ទាប់មកសូមចាកចេញពីសកម្មភាពនោះទៅ ហើយអរគុណព្រះជាម្ចាស់សម្រាប់ការបង្រៀនមេរៀនមួយនេះមកកាន់អ្នក។ ព្រះវិញ្ញាណបរិសុទ្ធនឹងប្រទានប្រាជ្ញាមកកាន់អ្នកនៅក្នុងការសម្រេចចិត្តដូចជាចំណុចមួយនេះផងដែរ។

គ្រិស្តបរិស័ទខ្លួនរបស់ពួកគេផ្ទាល់អាចមានការពាក់ព័ន្ធនៅក្នុងសហគមន៍របស់ពួកគេ និងចាំងជះពន្លឺរបស់ពួកគេនៅក្នុងរបៀបជាច្រើន។ ឧទាហរណ៍ ពួកគេអាចធ្វើជាប្រជាពលរដ្ឋគំរូ តាមរយៈការផ្តល់ព័ត៌មានទៅប៉ូលីសប្រសិនបើពួកគេឃើញមានចោរកម្មកើតឡើង។ ពួកគេអាចចូលរួមឧបត្ថម្ភដល់សកម្មភាពដែលទាក់ទងជាមួយសុខភាពសម្រាប់យុវជន ឬមនុស្សចាស់នៅក្នុងសហគមន៍។

ឪពុកម្តាយដែលគ្រិស្តបរិស័ទ និងគ្រិស្តបរិស័ទដទៃទៀតអាចទាញយកចំណាប់អារម្មណ៍នៅក្នុងសាលាតាមតំបន់ ព្រមទាំងជួយគ្រូ និងអ្នកដឹកនាំនៅក្នុងរបៀបផ្សេងៗដែលអាចធ្វើទៅបាន។ អ្នកអាចជួយនាំគ្រូដែលជាគ្រិស្តបរិស័ទសម្រាប់សាលារបស់អ្នក។បង្ហាញការចាប់អារម្មណ៍កាន់តែប្រសើរតាមរយៈការសាងសង់អាគារសាលា សៀវភៅ និងបណ្ណាល័យ ប្រសិនបើពួកគេត្រូវការ។

របៀបដ៏ល្អផ្សេងទៀតដើម្បីមានឥទ្ធិពលទៅកាន់សហគមន៍របស់អ្នកគឺការមានទំនាក់ទំនងមិត្តភាពជាមួយអ្នកដឹកនាំនៅក្នុងសហគមន៍ដូចជា ប៉ូលីស គ្រូបង្រៀន គ្រូពេទ្យ និងអ្នកធ្វើជំនួញ។ ស្វែងរកឱកាសដើម្បីធ្វើស្មរបន្ទាល់ទៅកាន់ពួកគេអំពីអ្វីដែលព្រះយេស៊ូបានធ្វើនៅក្នុងជីវិតរបស់អ្នក។ ព្យាយាមស្គាល់អភិបាលក្រុងរបស់អ្នក និងអ្នកតំណាងរាជរដ្ឋាភិបាលនៅក្នុងតំបន់របស់អ្នកត្រូវចាំថា ពួកគេក៏ត្រូវការព្រះអម្ចាស់ផងដែរ។

វាពិតជាមិនអាចទៅរួចទេក្នុងការដែលសរសេរគ្រប់របៀបទាំងអស់ដែលយើងអាចបម្រើទៅកាន់សហគមន៍របស់យើង។ នៅពេលដែលយើងមានឱកាសក្នុងការបោះឆ្នោតសម្រាប់អ្នកដឹកនាំ ឬ ច្បាប់ដែលលើកទឹកចិត្តរស់នៅក្នុងភាពសុចរិត គឺជាទំនួលខុសត្រូវរបស់គ្រិស្តបរិស័ទក្នុងការធ្វើវាផងដែរ។ ប្រសិនបើសហគមន៍ព្យាយាមក្នុងការស្វែងរកប្រាក់ឧបត្ថម្ភសម្រាប់គម្រោងដ៏សំខាន់ដូចជា មន្ទីរពេទ្យ ឬ មណ្ឌលកុមារកំព្រា គ្រិស្តបរិស័ទគួរតែជួយជាមួយគម្រោងទាំងនេះ។

នៅគ្រប់ទំនាក់ទំនងរបស់យើង ការសារសំខាន់ណាស់ដែលពួកយើងធ្វើជាគំរូនៃជំនឿគ្រិស្តបរិស័ទ។ ការនេះគឺ ជាសេចក្ដីពិតដ៏ពិសេសមួយនៅក្នុងជំនួញរបស់យើង។ ព្រះគម្ពីរបានប្រាប់យើងថាយើងគួរតែ «ផ្ទុយទៅវិញក្នុងការនិយាយស្ដីក្ដី កិរិយាមារយាទក្ដី ចិត្តស្រឡាញ់ក្ដី ជំនឿក្ដី និងចិត្តបរិសុទ្ធក្ដី ត្រូវធ្វើជាគំរូដល់អស់អ្នកជឿ» (១ធីម៉ូថេ ៤:១២)។

**លំហាត់អនុវត្តន៍**

---

៣ គូសរង្វង់ជុំវិញអក្សរនៅពីមុខប្រយោគដែលត្រឹមត្រូវ។

ក) គ្រិស្តបរិស័ទអាចចូលរួមគ្រប់សកម្មភាពទាំងអស់ដរាបណាពួកគេធ្វើស្មរបន្ទាល់អំពីព្រះគ្រិស្តនៅទីនោះ។

ខ) ប្រសិនបើគ្រិស្តបរិស័ទចូលរួមនៅក្នុងសកម្មភាពណាមួយ ហើយរកឃើញថាវាមិនសមស្របដោយយោងទៅលើការបង្រៀននៅក្នុងព្រះគម្ពីរអំពីអ្វីដែលគ្រិស្តបរិស័ទគួរតែធ្វើ ពួកគេគួរតែចាកចេញ។

គ) វាគឺអាចទៅរួចក្នុងការចូលរួមគ្រប់សកម្មភាពទាំងអស់ ដរាបណាអ្នកមិនអនុញ្ញាតឱ្យមនុស្សដែលនៅទីនោះដឹងថាអ្នកគឺជាគ្រិស្តបរិស័ទ។

ឃ) ក្នុងនាមជាគ្រិស្តបរិស័ទម្នាក់អ្នកត្រូវជាប្រជាពលរដ្ឋ អ្នកជិតខាង និងមិត្តភក្ដិដ៏ល្អ។

៤ គូសរង្វង់ជុំវិញអក្សរនៅពីមុខគំរូដែលត្រឹមត្រូវនៃសហគមន៍ខាងព្រលឹងវិញ្ញាណរបស់គ្រិស្តបរិស័ទ។

ក) ចន (John) បានសម្រេចចិត្តមិនទៅធ្វើការបោះឆ្នោតពីព្រោះគាត់មិនខ្វល់ខ្វាយពីតំណាងរាស្ត្រដែលត្រូវបានជ្រើសរើសដើម្បីគ្រប់គ្រងសហគមន៍។

ខ) ជេម (James) រៀបចំសកម្មភាពយុវជននៅសាលាបន្ទាប់ពីលេងបាល់ទាត់

គ) រស់ (Ruth) ទៅមន្ទីពេទ្យពីរដងក្នុងមួយសប្តាហ៍ដើម្បីជួយមនុស្សដែលមានជំងឺតាមរយៈការអានឱ្យពួកគេស្តាប់ សរសេរសំបុត្រសម្រាប់ពួកគេ ឬការសួរសុខទុក្ខពួកគេ។

ឃ) ម៉ារី (Mary) និងមិនចូលរួមសកម្មភាពនៅក្នុងសាលាពីព្រោះនាងមិនមានការអប់រំល្អដូចជាគ្រូបង្រៀនដទៃទៀត។

ង) រ៉ូបឺត (Robert) បានឃើញបុរសវ័យក្មេងម្នាក់ប្លន់អ្នកថែរក្សាហាង ប៉ុន្តែ គាត់មិនបានរាយការហេតុការណ៍នេះពីព្រោះគាត់មិនចង់មានការពាក់ព័ន្ធ។

ច) ភីលីព (Philip) ញញឹម និងស្វាគមន៍មនុស្សនៅតាមផ្លូវ ដូចជាអ្នករត់សំបុត្រ ប៉ូលីស ឬ អ្នកជិតខាង។

៥ ព្យាយាមក្នុងការមានទំនាក់ទនងជាមួយអ្នកដឹកនាំនៅក្នុងសហគមន៍របស់អ្នកយ៉ាងហោចណាស់ឱ្យបានពីនាក់នៅក្នុងខែនេះ។ សរសេរឈ្មោះមនុស្សដែលអ្នកព្យាយាមស្គាល់នៅទីនេះ។

…………………………………………………………………………………………………………

…………………………………………………………………………………………………………

## គ. ការបរិច្ចាគជំនាញ Contributing Skills

### គោលដៅទី៣. បង្ហាញពីរបៀបដែលជំនាញរបស់អ្នកអាចប្រើដើម្បីជួយទៅកាន់សហគមន៍របស់អ្នក។

ចន ប្រោន (John Brown) គឺជាគ្រិស្តបរិស័ទម្នាក់ដែលបានថ្វាយជីវិតរបស់គាត់ទៅព្រះគ្រិស្តអស់រយៈពេលច្រើនឆ្នាំមកហើយ។ មនុស្សគ្រប់គ្នានៅក្នុងសហគមន៍របស់គាត់គោរពគាត់ដូចជាអ្នកបម្រើព័ន្ធកិច្ចគំរូ និងជាមនុស្សដែលគួរឱ្យគោរព។ លោកប្រោនជាម្នាក់ដែលនៅក្នុងសហគមន៍របស់គាត់ទទួលស្គាល់ផងដែរថាជាអ្នកសាងសង់ដ៏ជំនាញ។ នៅពេលដែលអភិបាលក្រុងសុំអ្នកស្ម័គ្រចិត្តដើម្បីជួយកសាងសំណង់អគារទីក្រុង លោកប្រោនបានស្ម័គ្រចិត្តធ្វើជាអ្នកដឹកនាំនៅក្នុងគម្រោងកសាងអគារថ្មី។

សូមកត់សំគាល់ពីទិដ្ឋភាពសំខាន់ៗនៃរឿងទាំងនេះ:

១. ចន ប្រោនគឺជាអ្នកកសាងយ៉ាងអស្ចារ្យរួមទាំងមានកេរ្តិ៍ឈ្មោះល្បីល្បាញ។

២. គាត់បានប្រើអំណោយទានរបស់គាត់ដើម្បីជួយគម្រោងនៅក្នុងសហគមន៍ដែលធ្វើឱ្យមនុស្សជាច្រើនមានអំណរ។

សហគមន៍ចាប់អារម្មណ៍ទៅលើចំណុចទាំងពីរនេះ។ ប្រហែលមនុស្សជាច្រើនមិនដឹងថាលោកប្រោនក៏ជាគ្រិស្តបរិស័ទផងដែរ។ ប៉ុន្តែ មនុស្សដែលមានការពាក់ព័ន្ធនៅក្នុងគម្រោងនឹងស្គាល់ថាគាត់ជាគ្រិស្តបរិស័ទខណៈពេលដែលពួកគេធ្វើការជាមួយគាត់។ គាត់ស្រឡាញ់ព្រះជាម្ចាស់ ហើយគោលការណ៍គ្រិស្តបរិស័ទនឹងបញ្ចេញពន្លឺពីជីវិតរបស់គាត់។

ប្រហែលអ្នកមានជំនាញដែលសហគមន៍របស់អ្នកត្រូវការ។ តើអ្នកអាចប្រើជំនាញរបស់អ្នកទុកដូចជាការចែករំលែកទៅកាន់មនុស្សគ្រប់គ្នាដែរឬទេ? ប្រសិនបើអ្នកអាច អ្នកនឹងក្លាយជាព្រះពរទៅកាន់មនុស្សផ្សេងទៀត ហើយអ្នកនឹងមានឱកាសចែកចាយពីទីបន្ទាល់គ្រិស្តបរិស័ទរបស់អ្នកតាមរយៈការប្រើជំនាញរបស់អ្នកដើម្បីជួយអ្នកដទៃទៀត។ សហគមន៍ត្រូវការជំនាញជាច្រើន កសិករ សំណង់ គិលានុបដ្ឋាយិកា អ្នកថែរក្សាក្មេងតូចៗ និងជួយក្នុងការប្រោសសំអាត ឬធ្វើឱ្យសហគមន៍មានភាពស្រស់ស្អាតគឺមានតែរបៀបពីរបីប៉ុណ្ណោះដើម្បីមានការជាប់ព័ន្ធ។ តើអ្វីដែលជាសមត្ថភាពពិសេសរបស់អ្នក? តើអ្នកបានថ្វាយវាទៅកាន់ព្រះជាម្ចាស់ និងសហគមន៍របស់អ្នកដែរឬទេ?

**លំហាត់អនុវត្តន៍**

---

៦ សូមពិភាក្សាអំពីរបៀបពីរដែលអ្នកអាចប្រើជំនាញធ្វើជាស្មរបន្ទាល់ទៅកាន់សហគមន៍របស់អ្នក។

………………………………………………………………………………………………………

…………………………………………………………………………………………………….....

៧ គិតអំពីរបៀបមួយចំនួនដែលអ្នកបានប្រើដើម្បីមានការជាប់ពាក់ព័ន្ធនៅក្នុងសហគមន៍របស់អ្នក តាមរយៈការប្រើជំនាញរបស់អ្នក? សរសេរវានៅក្នុងសៀវភៅសរសេររបស់អ្នក។

៨ សូមសរសេរចុះនូវរបៀបមួយដែលអ្នកអាចមានការជាប់ពាក់ព័ន្ធថែមទៀតនៅក្នុងសហគមន៍របស់អ្នក។

………………………………………………………………………………………………………

## សូមផ្ទៀងចម្លើយរបស់អ្នក

៥ ចម្លើយរបស់អ្នក

១ ក)មានការធានាអះអាងផ្ទាល់ខ្លួននៃការសង្គ្រោះ។
ខ) ដឹងពីរបៀបក្នុងការដឹកនាំមនុស្សទៅកាន់ព្រះជាម្ចាស់។
គ) ពឹងផ្អែកលើព្រះវិញ្ញាណដ៏វិសុទ្ធ។

៦ ចម្លើយរបស់អ្នក។ ខណៈពេលដែលអ្នកចែករំលែកជំនាញរបស់អ្នក មនុស្សនឹងឃើញពីស្មារបន្ទាល់គ្រិស្តបរិស័ទរបស់អ្នក ហើយអ្នកអាចនាំពួកគេទៅកាន់ព្រះគ្រិស្ត។ អ្នកនឹងក្លាយជាព្រះពរទៅកាន់សហគមន៍របស់អ្នកតាមរយៈឥរិយាបថនឹងការជាប់ពាក់ព័ន្ធរបស់អ្នក។

២ ក) អ្នកនិពន្ធ
ខ) អារម្មណ៍
គ) សង្គ្រោះ
ឃ) ព្រះបន្ទូលព្រះជាម្ចាស់
ង) ព្រះវិញ្ញាណដ៏វិសុទ្ធ

៧ ចម្លើយរបស់អ្នក។ តើអ្នកអាចស្វែងរកឃើញរបៀបដែលអ្នកអាចធ្វើបន្ថែមទៀតដែរឬទេ?

៣ ប្រយោគ ខ) និង ឃ)គឺត្រឹមត្រូវ។

៨ ចម្លើយរបស់អ្នក។ ព្រះជាម្ចាស់នឹងប្រទានពរអ្នកនៅពេលដែលអ្នកឱ្យទៅកាន់អ្នកដទៃដោយឥតគិតថ្លៃ នូវអ្វីដែលព្រះជាម្ចាស់បានប្រទានដល់អ្នក។

៤ ខ) គ) និង ច)គឺជាគំរូដ៏ល្អនៃសហគមន៍គ្រិស្តបរិស័ទ។

មេរៀនទី ១០

# ការបន្តនៅក្នុងសហគមន៍

## Continuing in Community

នៅសម័យសង្គ្រាមលោកលើកទីមួយ សាស្ត្រាចារ្យម្នាក់នៅសហគមន៍អ៊ីរ៉ុបកំពុងបង្រៀនសិស្សរបស់គាត់ ស្រាប់តែមានបញ្ហាមកឱ្យគាត់ផ្អាកការបង្រៀនភ្លាមព្រោះមានសង្គ្រាម។ នៅពេលសិស្សមិនបានជួបគ្នាជាច្រើនឆ្នាំ។ រហូតក្រោមមក សាលាក៏ចាប់ផ្តើមឡើងវិញ លោកសាស្ត្រាចារ្យក៏ចាប់ផ្តើមបង្រៀនមេរៀនដំបូង ព្រមទាំងនិយាយថា «ដូចខ្ញុំបាននិយាយ…»

គាត់បន្តមេរៀននៅកន្លែងដែលគាត់បានបញ្ចប់មុនពេលដែលថ្នាក់រៀនត្រូវបានបញ្ឈប់។ ឥរិយាបថនៃការបន្តបង្ហាញពីការប្តេជ្ញាចិត្តច្បាស់លាស់។ ពួកយើងត្រូវការការប្តេជ្ញាចិត្តបែបនេះដើម្បីរក្សាទំនាក់ទំនងជាមួយសហគមន៍របស់យើង។

នៅក្នុងមេរៀននេះអ្នកនឹងសិក្សាពីរបៀបជាច្រើនដែលអ្នកអាចបន្តអនុវត្តគោលការណ៍បង្រៀននៅក្នុងមេរៀននេះ។ របៀបដ៏មានសារសំខាន់បំផុតគឺការពឹងផ្អែកលើព្រះវិញ្ញាណដ៏វិសុទ្ធ។

## គម្រោង

ក. ធ្វើជាខ្លួនឯង Be Yourself

ខ. ធ្វើឱ្យទីបន្ទាល់មានលក្ខណៈផ្ទាល់ខ្លួន Make Your Witness Personal

គ. ពឹងផ្អែកលើព្រះវិញ្ញាណដ៏វិសុទ្ធ Depend on the Holy Spirit

## គោលដៅ

១. ពន្យល់ពីសារសំខាន់នៃការមានស្មរបន្ទាល់គ្រិស្តបរិស័ទផ្ទាល់ខ្លួនដែលអាចទុកចិត្តបាន។

២. ផ្តល់ឧទាហរ៍ពីរបៀបផ្សេងៗក្នុងការបង្ហាទីបន្ទាល់ផ្ទាល់ខ្លួនបែបវិជ្ជមាន។

៣. សរសេរចុះពីហេតុផលដែលព្រះយេស៊ូចាត់បញ្ជូនព្រះវិញ្ញាណដ៏វិសុទ្ធមកកាន់យើង។

## ក. ធ្វើជាខ្លួនឯង Be Yourself

**គោលដៅ១. ពន្យល់ពីសារសំខាន់នៃការមានស្មរបន្ទាល់គ្រិស្តបរិស័ទផ្ទាល់ខ្លួនដែលអាចទុកចិត្តបាន។**

មាននារីវ័យក្មេងម្នាក់ទៅធ្វើការបម្រើព្រះជាម្ចាស់នៅក្រៅប្រទេសក្នុងនាមជាបេសកជន។ នៅក្នុងកម្មវិធីវិទ្យុមួយបានសួរនាងថា "តើនាងនឹងធ្វើអ្វីនៅទីនោះ?" នាងបានឆ្លើយថា "ខ្ញុំនឹងធ្វើជាមនុស្សដូចដែលខ្ញុំបាននិយាយ។"

តើអ្នកធ្លាប់និយាយថាអ្នកជានរណាដែរឬទេ? អ្នកពិតជាប្រសើរបំផុតនៅពេលដែលអ្នកធ្វើជាខ្លួនរបស់អ្នកផ្ទាល់។ របៀបដ៏ល្អបំផុតដើម្បីមានឥទ្ធិពលទៅកាន់សហគមន៍របស់អ្នកអំពីព្រះយេស៊ូផ្តល់នូវរូបភាពពិតប្រាកដគ្រប់ពេលវេលា។ ប្រសិនបើរូបភាពរបស់អ្នកមួយចំនួនធ្វើឱ្យអ្នកមិនសប្បាយចិត្ត សូមព្រះវិញ្ញាណដ៏វិសុទ្ធប្រទានរូបភាពថ្មីមកកាន់អ្នក។ ធ្វើជាមនុស្សដែលមានប្រយោជន៍ និងមានតម្លៃ ជាម្នាក់ដែលមនុស្សដទៃទៀតអាចពឹងពាក់បានគ្រប់ពេលវេលា។ សូមព្រះជាម្ចាស់ដើម្បីកែច្នៃអ្នកឱ្យក្លាយដូចជាមនុស្សដែលអ្នកគួរតែដូចជា និងអ្វីដែលទ្រង់ចង់ឱ្យដូចជាផងដែរ។

តើមានមនុស្សដែលឃើញអ្នកថ្ងៃមួយអ្នកសប្បាយចិត្ត រីករាយ ហើយថ្ងៃបន្ទាប់អ្នកក្លាយជាមនុស្សដែលអន់ចិត្តមិនសប្បាយចិត្តដែលឬទេ? តើអ្នកជាមនុស្សដែលមិនប្រែប្រួល ជាស្មរបន្ទាល់ដែលគួរឱ្យទុកចិត្តគ្រប់ពេលវេលា ជាមនុស្សដែលមិនងាយបាក់ទឹកចិត្តជាមួយរឿងរ៉ាវផ្សេងៗដែលកើតឡើងពីមួយថ្ងៃទៅមួយថ្ងៃដែលឬទេ?

មនុស្សដែលរក្សាឥរិយាបថត្រឹមត្រូវគ្រប់ពេលវេលាផ្តល់ស្មរបន្ទាល់ដែលល្អបំផុត។ ព្រះវិញ្ញាណដ៏វិសុទ្ធជាភ្នាក់ងារដ៏ល្អបំផុតសម្រាប់ផ្លាស់ប្តូរចរិតលក្ខណរបស់បុគ្គលម្នាក់។ ប្រសិនបើអ្នកជាមនុស្សម្នាក់ដែលមិនសូវរីករាយ សូមព្រះជាម្ចាស់ផ្លាស់ប្តូរចរិតលក្ខណរបស់អ្នក។ បន្ទាប់មកចាប់ផ្តើមធ្វើសកម្មភាពណាដែលអ្នកដឹងថាព្រះជាម្ចាស់សព្វព្រះហឫទ័យឱ្យអ្នកធ្វើ។

មិត្តភក្តិរបស់ខ្ញុំ ចន (John) ជាមនុស្សម្នាក់ដែលឆាប់អន់ចិត្ត រអ៊ូរទាំ។ ទោះបីគាត់ជាគ្រិស្តបរិស័ទហើយក៏ដោយ គាត់ដោះសារចំពោះឥរិយាបថរបស់គាត់ ហើយគាត់និយាយថាគាត់មិនអាចកែប្រែឥរិយាបថរបស់គាត់បានទេ។ នៅពេលដែលគាត់ទទួលស្គាល់ពិតប្រាកដថាព្រះជាម្ចាស់អាចជួយគាត់ឱ្យក្លាយទៅជាមនុស្សម្នាក់ផ្សេងទៀតបាន គាត់ក្លាយជាមនុស្សដែលរីករាយ សប្បុរស ហើយចេះគិតដល់អ្នកដទៃរហូតដល់វាក្លាយជាធម្មតា។

ជីវិតរបស់អ្នកត្រូវតែផ្តល់រូបភាពពិតប្រាកដនៃអ្វីដែលគ្រិស្តបរិស័ទគួរតែមាន។ ប្រសិនបើមនុស្សមិនប្រាកដថាអ្នករស់នៅជាជីវិតគ្រិស្តបរិស័ទ អ្នកនឹងមិនអាចក្លាយជាស្មរបន្ទាល់ដែលមានប្រសិទ្ធិភាពសម្រាប់ព្រះគ្រិស្តនោះទេ។ សូមធ្វើឱ្យការត្រាស់ហៅរបស់អ្នកមានការច្បាស់លាស់  បន្ទាប់មកមនុស្សដទៃទៀតនឹងតាមអ្នក។

លំហាត់អនុវត្តន៍

---

១ តើមនុស្សអាចផ្លាស់ប្តូរបុគ្គលិកលក្ខណផ្ទាល់ខ្លួនរបស់ពួកគេដោយរបៀបណា ប្រសិនបើពួកគេមិនពេញចិត្តលក្ខណៈរបស់ពួកគេ?

..........................................................................................................................................

..........................................................................................................................................

២ ហេតុអ្វីបានជាវាមានសារសំខាន់ក្នុងការអភិវឌ្ឍរូបភាពត្រឹមត្រូវដើម្បីតំណាងព្រះគ្រិស្តទៅកាន់ក្រុមជំនុំរបស់អ្នក?

………………………………………………………………………………………………………

……………………………………………………………………………………………………….

៣ ស្មរបន្ទាល់ដ៏ល្អបំផុតគឺផ្តល់ឱ្យតាមរយៈគ្រិស្តបរិស័ទដែល

ក) សិក្សាពីរបៀបដ៏ពិសេសក្នុងការនិយាយទៅកាន់មនុស្ស។

ខ) យកព្រះគម្ពីររបស់ពួកគេទៅគ្រប់ទីកន្លែងដែលពួកគេទៅ។

គ) រក្សាឥរិយាបថត្រឹមត្រូវគ្រប់ពេលវេលា។

## ខ. ធ្វើឱ្យស្មរបន្ទាល់ក្លាយជាលក្ខណៈផ្ទាល់ខ្លួន Make Your Witness Personal

**គោលដៅទី២. ផ្តល់ឧទាហរណ៍ពីរបៀបផ្សេងៗក្នុងការបង្ហាញស្មរបន្ទាល់ផ្ទាល់ខ្លួនបែបអវិជ្ជមាន។**

នៅពេលដែលខ្ញុំមានអាយុ១៧ឆ្នាំ ខ្ញុំបានបញ្ចប់ការសិក្សានៅអនុវិទ្យាល័យ ហើយបានធ្វើការជាមួយក្រុមហ៊ុនដ៏ធំមួយនៅក្នុងស្រុកកំណើតរបស់ខ្ញុំ។ នៅព្រឹកថ្ងៃដំបូង ខណៈពេលដែលខ្ញុំចេញទៅធ្វើការ ម្តាយរបស់ខ្ញុំបានហៅខ្ញុំពីខាង

ក្រោយ ហើយនិយាយថា "កូនប្រុស ត្រូវចាំថា ត្រីដែលងាប់វាអាចទៅតាមទឹកបាន។ វាត្រូវការត្រីរស់មួយដែលហែលបញ្ច្រាសទឹកនោះ"។

ខ្ញុំមិនដែលភ្លេចពាក្យសំដីរបស់ម្ដាយខ្ញុំនោះទេ។ តាំងពីពេលនោះមក ខ្ញុំព្យាយាមដើម្បីឱ្យប្រាកដថា ខ្ញុំមិនគ្រាន់តែរសាត់តាមទឹកនោះទេ។ វាមិនងាយស្រួលនោះទេដើម្បីធ្វើឱ្យមានខុសប្លែកពីមនុស្សដទៃ។ ពេលខ្លះកន្លែងការងាររបស់យើង ឬ សកម្មភាពផ្សេងៗប្រហែលមានតែយើងម្នាក់ឯងទេដែលជាគ្រិស្តបរិស័ទ។ ប្រសិនបើយើងចង់មានស្នាមបន្ទាល់ផ្ទាល់ខ្លួន ពួកយើងត្រូវតែមានឆន្ទៈឈរលើគោលការណ៍គ្រិស្តបរិស័ទរបស់ពួកយើងទោះបីជាវាងាយស្រួល បណ្ដោយទៅតាមមនុស្សផ្សេងទៀតក៏ដោយ។

នៅក្នុង១ពេត្រុស ៣:១៥ បានផ្ដល់ដំបូន្មានដល់យើងថា «ត្រូវប្រុងប្រៀបខ្លួនឆ្លើយតទល់នឹងអស់អ្នកដែលសាកសួរ អំពីសេចក្ដីសង្ឃឹមរបស់បងប្អូននោះជានិច្ច»។ ក្ដីសង្ឃឹមរបស់យើងស្ថិតនៅលើព្រះគ្រិស្តយេស៊ូ ដែលព្រះអង្គបានសុគត និងមានព្រះជន្មរស់ឡើងវិញដែលនាំឱ្យយើងមានជីវិតអស់កល្បជានិច្ច។ ពួកយើងត្រូវតែរក្សាបន្ទាល់ល្អផ្ទាល់ខ្លួនគ្រប់ពេលវេលា ប្រសិនបើយើងចង់នាំមនុស្សផ្សេងទៀតស្វែងរកព្រះគ្រិស្ត។

តើអ្នកទទួលស្គាល់ថាព្រះជាម្ចាស់ស្គាល់អ្នកជាងអ្នកស្គាល់ខ្លួនឯងផ្ទាល់ដែរឬទេ? ពិចារណាពីអត្ថបទខគម្ពីរនេះ៖

> គ្មានសត្វលោកណាមួយដែលព្រះបន្ទូលមើលមិនឃើញឡើយ ចំពោះព្រះនេត្ររបស់ព្រះអង្គ អ្វីៗទាំងអស់នៅទទេ ឥតបិទបាំងទាល់តែសោះ។ យើងត្រូវទូលរៀបរាប់ថ្វាយព្រះបន្ទូលពីគ្រប់កិច្ចការទាំងអស់។ (ហេប្រឺ ៤:១៣)

ព្រះជាម្ចាស់ចង់ឱ្យយើងបង្ហាញពិភពលោកនូវលក្ខណរបស់ព្រះអង្គ។ ធ្វើឱ្យស្នាមបន្ទាល់របស់អ្នកសម្រាប់ព្រះគ្រិស្តជារឿងផ្ទាល់ខ្លួន។ អនុញ្ញាតឱ្យមនុស្សដទៃទៀតឃើញពីលទ្ធផលពីព្រះគុណរបស់ព្រះជាម្ចាស់នៅក្នុងជីវិតរបស់យើង។ ព្រះជាម្ចាស់ប្រទានព្រះវិញ្ញាណដ៏វិសុទ្ធជួយយើងដើម្បីធ្វើកិច្ចការទាំងនេះ។ ប្រសិនបើអ្នកឈោងចាប់សហគមន៍របស់អ្នកសម្រាប់ព្រះជាម្ចាស់ អ្នកត្រូវតែមានតម្លាភាពនៅចំពោះមនុស្សទាំងអស់។ ពួកគេនឹងឃើញថាអ្នកជានរណាពិតប្រាកដ។ លោកសាវ័កប៉ូលបាននិយាយថា «សូមយកគំរាប់តាមខ្ញុំ ដូចខ្លួនខ្ញុំផ្ទាល់បានយកគំរាប់តាមព្រះគ្រិស្តដែរ។» (១កូរិនថូស ១១:១)។ តើអ្នកអាចនិយាយអ្វីដដែលៗទៅកាន់សហគមន៍របស់អ្នកដែរទេ?

៤ តើឧទាហរណ៍ណាមួយដែលត្រឹមត្រូវនៃស្មរបន្ទាល់ផ្ទាល់ខ្លួនបែបវិជ្ជមាន?

ក) ធ្វើអ្វីមួយដែលអ្នកដឹងថាវាមិនត្រឹមត្រូវ ដោយសារមិត្តភក្តិរបស់អ្នកសូមអ្នកឱ្យធ្វើវា ហើយអ្នកមិនចង់ធ្វើឱ្យមិត្តភក្តិរបស់អ្នកអាក់អន់ចិត្ត។

ខ) និយាយថាទេនៅពេលដែលអ្នកនិយាយថាយល់ព្រម ធ្វើឱ្យប៉ះពាល់ដល់ស្មរបន្ទាល់ជាគ្រិស្តបរិស័ទរបស់អ្នក។

គ) បង្ហាញអារម្មណ៍មិនសប្បាយចិត្តនៅពេលផែនការរបស់អ្នកមិនដំណើរការទៅតាមរបៀបដែលអ្នកចង់បាន។

ឃ) ធ្វើការលើសពីតួនាទីរបស់អ្នកនៅក្នុងគម្រោង។

ង) រួសរាយរាក់ទាក់ និងមានចិត្តសប្បុរសទោះបីជានៅពេលអ្នកមិនមានអារម្មណ៍បែបនេះក៏ដោយ។

៥ តើឥរិយាបថមួយណាដែលតំណាងពីការយកចិត្តទុកដាក់សម្រាប់អស់អ្នកដែលមិនបានស្គាល់ព្រះគ្រិស្ត?

ក) ខ្ញុំនឹងធ្វើឱ្យអស់ពីសមត្ថភាពរបស់ខ្ញុំដើម្បីធ្វើស្មរបន្ទាល់អំពីព្រះអម្ចាស់ ប៉ុន្តែ ខ្ញុំមិនអាចធ្វើវាបានទេប្រសិនបើមនុស្សមិនបង្ហាញការចាប់អារម្មណ៍ក្នុងការដើរតាមព្រះគ្រិស្ត។

ខ) ពេញមួយជីវិតរបស់ខ្ញុំគួរតែធ្វើជាស្មរបន្ទាល់ទៅកាន់អស់អ្នកដែលមិនស្គាល់មិនព្រះគ្រិស្ត ដើម្បីខ្ញុំនឹងមិនធ្វើឱ្យពួកគេត្រឡប់ទៅជាប្រឆាំងជាមួយព្រះអង្គ។

## គ. ពឹងផ្អែកលើព្រះវិញ្ញាណដ៏វិសុទ្ធ Depend on the Holy Spirit

**គោលដៅទី៣. សរសេរចុះពីហេតុផលដែលព្រះយេស៊ូចាត់បញ្ជូនព្រះវិញ្ញាណដ៏វិសុទ្ធមកកាន់យើង។**

### អ្នកបើកសម្ដែង The Revealer

មុនពេលដែលព្រះយេស៊ូយាងត្រឡប់ទៅឯនគរស្ថានសួគ៌វិញ។ ទ្រង់មានព្រះបន្ទូលទៅកាន់សាវ័ករបស់ព្រះអង្គ «ប៉ុន្តែ ខ្ញុំសូមប្រាប់អ្នករាល់គ្នាតាមត្រង់ថា បើខ្ញុំទៅ ទើបមានប្រយោជន៍ដល់អ្នករាល់គ្នា។ បើខ្ញុំមិនទៅទេ ព្រះដ៏ជួយការពារមិនយាងមករកអ្នករាល់គ្នាឡើយ។ ផ្ទុយទៅវិញ បើខ្ញុំទៅ ខ្ញុំនឹងចាត់ព្រះអង្គអោយមករកអ្នករាល់គ្នា» (យ៉ូហាន ១៦:៧)។ ព្រះដ៏ជួយការពារ គឺជាឈ្មោះមួយក្នុងព្រះគម្ពីរសម្រាប់ព្រះវិញ្ញាណដ៏វិសុទ្ធ។

នៅពេលដែលយើងយល់ពីព័ន្ធកិច្ចនៃព្រះវិញ្ញាណដ៏វិសុទ្ធ យើងអាចទុកចិត្តព្រះអង្គថែមទៀត។ ឧទាហរណ៍ នៅពេលដែលអ្នកដាក់មនុស្សពីនាក់ដែលនិយាយភាសាខុសគ្នានៅក្នុងបន្ទប់តែមួយ ពួកគេនឹងពិបាកក្នុងការទំនាក់ទំនងជាមួយគ្នាទៅវិញទៅមក។ ប៉ុន្តែប្រសិនបើពួកគេមានភាសាតែមួយ ពួកគេនឹងអាចស្គាល់គ្នាទៅវិញទៅមកកាន់តែប្រសើរថែមទៀត។ ការនិយាយជាមួយគ្នានឹងជួយឱ្យពួកគេស្គាល់ពីគ្នាទៅវិញទៅមក។

ការស្គាល់នាំឱ្យមានទំនុកចិត្ត។ វាដូចគ្នាជាមួយព្រះវិញ្ញាណដ៏វិសុទ្ធ។ ខណៈពេលដែលអ្នកយល់ នឹងស្គាល់ព័ន្ធកិច្ចរបស់ព្រះអង្គ អ្នកនឹងរៀនក្នុងការទុកចិត្តលើព្រះអង្គ។ ព័ន្ធកិច្ចមួយក្នុងចំណោមព័ន្ធកិច្ចផ្សេងទៀតរបស់ព្រះវិញ្ញាណដ៏វិសុទ្ធ គឺដើម្បីបើកសម្តែង ឬ បង្ហាញព្រះគ្រិស្តមកកាន់យើង។ នៅពេលដែលយើងស្គាល់ព្រះគ្រិស្ត យើងស្គាល់ពីតម្រូវការរបស់យើងចំពោះព្រះអង្គ។ លោកយ៉ូហានបានសរសេរថា

> រីឯព្រះដ៏ជួយការពារ ដែលខ្ញុំនឹងចាត់ពីព្រះបិតាអោយមករកអ្នករាល់គ្នា គឺជាព្រះវិញ្ញាណដែលសំដែងសេចក្តីពិត ព្រះអង្គចេញពីព្រះបិតាមក។ កាលណាព្រះអង្គយាងមកដល់ទ្រង់នឹងធ្វើជាបន្ទាល់អំពីខ្ញុំ (យ៉ូហាន ១៥:២៦)

គោលបំណងមួយទៀតនៃព្រះវិញ្ញាណដ៏វិសុទ្ធគឺដើម្បីកាត់ទោសអំពើបាប និងនាំមនុស្សថ្វាយព្រះជាម្ចាស់។ ព្រះយេស៊ូមានព្រះបន្ទូលថាព្រះវិញ្ញាណដ៏វិសុទ្ធនិយាយអំពីការសារភាពអំពើបាប និង «ព្រះយេស៊ូមានព្រះបន្ទូលទៅគេថា៖ «ខ្ញុំបានប្រាប់អ្នករាល់គ្នាថា ខ្ញុំហ្នឹងហើយ បើអ្នករាល់គ្នាមករកខ្ញុំ ទុកអោយអ្នកទាំងនេះចេញទៅចុះ។» (យ៉ូហាន ១៦:៨)។

លោកចូ ស្មីត (Joe Smith) មិនដែលធ្លាប់ស្គាល់ព្រះជាម្ចាស់។ ថ្ងៃមួយគាត់បានរឿងអំពីព្រះយេស៊ូ និងក្តីស្រឡាញ់របស់ព្រះអង្គសម្រាប់បុរស និងស្ត្រី។ មួយសប្តាហ៍បានកន្លងផុតទៅ លោកចូមិនអាចលុបរឿងទាំងនេះចេញពីគំនិតរបស់គាត់បានឡើយ។ ហេតុអ្វី? ព្រះវិញ្ញាណបរិសុទ្ធបានបើកសម្តែងព្រះយេស៊ូទៅកាន់លោកចូ និងជំរុញគាត់ឱ្យសោកស្តាយចំពោះអំពើបាបរបស់គាត់។ លោកចូមានអារម្មណ៍ថាលោកត្រូវតែធ្វើអ្វីម្យ៉ាង។ វាមិនចំណាយពេលយូរនោះទេរហូតគាត់ថ្វាយដួងចិត្តរបស់គាត់ទៅកាន់ព្រះអម្ចាស់ និងក្លាយទៅជាគ្រិស្តបរិស័ទ។

ព្រះវិញ្ញាណដ៏វិសុទ្ធមានព័ន្ធកិច្ចក្នុងការត្រាស់ហៅមនុស្សទៅកាន់ព្រះយេស៊ូ។ តើអ្នកមិនរំភើបទេឬ ដែលទ្រង់ជំរុញដួងចិត្តរបស់អ្នក និងបើកសម្តែងអំពីព្រះយេស៊ូទៅកាន់អ្នក? ក្នុងនាមយើងជាអ្នកធ្វើស្មរបន្ទាល់ទៅកាន់មនុស្សផ្សេងទៀត យើងអាចទុកចិត្តទាំងស្រុងទៅលើព្រះវិញ្ញាណដ៏វិសុទ្ធដែលព្រះអង្គធ្វើកិច្ចការរបស់ទ្រង់នៅក្នុងដួងចិត្តរបស់ពួកគេ។

**លំហាត់អនុវត្តន៍**

---

៦ ការសោកស្តាយគឺជាសកម្មភាពនៃ

ក) ស្គាល់នរណាម្នាក់។

ខ) សោកស្តាយចំពោះអំពើបាប និងសារភាពបាបទៅកាន់ព្រះជាម្ចាស់។

គ) ការចូលទៅជិតព្រះជាម្ចាស់តាមរយៈព្រះវិញ្ញាណដ៏វិសុទ្ធ

៧ នៅពេលដែលយើងរៀនក្នុងការទុកចិត្តលើព្រះវិញ្ញាណដ៏វិសុទ្ធ យើងអាច

ក) ពឹងផ្អែកលើព្រះអង្គ

ខ) ថ្វាយព័ន្ធកិច្ចនាំព្រលឹងមនុស្សទៅកាន់ព្រះអង្គ។

គ) រស់នៅគ្មានអំពើបាប។

៨ សរសេរចុះនូវហេតុផលបីដែលព្រះយេស៊ូចាត់បញ្ជូនព្រះវិញ្ញាណដ៏វិសុទ្ធមកកាន់យើង។

ក) ..........................................................................................................................................

ខ)...........................................................................................................................................

គ)...........................................................................................................................................

## ជាគ្រូបង្រៀន និងអ្នករំលឹកដាស់តឿនរបស់យើង Our Teacher and Reminder

អានព្រះបន្ទូលដែលព្រះយេស៊ូបានកត់ត្រាទុកព្រះគម្ពីរយ៉ូហាន ១៤:២៦៖

ប៉ុន្តែ ព្រះដ៏ជួយការពារ គឺព្រះវិញ្ញាណដ៏វិសុទ្ធដែលព្រះបិតាចាត់អោយមកក្នុងនាមខ្ញុំនឹងបង្រៀនសេចក្តីទាំងអស់ដល់អ្នករាល់គ្នា ព្រមទាំងរំលឹកអ្វីៗដែលខ្ញុំបានប្រាប់អ្នករាល់គ្នាផង។

នៅក្នុងខគម្ពីរនេះមានព័ន្ធកិច្ចពីរថែមទៀតរបស់ព្រះវិញ្ញាណដ៏វិសុទ្ធដែលបានលើកឡើង។ ទីមួយ ព្រះវិញ្ញាណដ៏វិសុទ្ធនឹងបង្រៀនយើងពីអត្ថន័យរបស់ព្រះបន្ទូលព្រះជាម្ចាស់ និងពីរបៀបអនុវត្តន៍ព្រះបន្ទូលនៅក្នុងជីវិតរបស់យើង។ ព្រះវិញ្ញាណដ៏វិសុទ្ធគឺមានព្រះប្រាជ្ញាញាណ ហើយទ្រង់អាចប្រទានប្រាជ្ញាមកកាន់យើងផងដែរ។

លោក ថម គ្រីន (Tom Green) ជាបុរសម្នាក់ដែលមិនមានការអប់រំ ប៉ុន្តែ គាត់គឺអាចមានសមត្ថភាពបង្រៀនបាន។ បន្ទាប់ពីថ្ងៃធ្វើការរបស់គាត់ត្រូវបានបញ្ចប់ ថមអាន និងសិក្សាព្រះគម្ពីររបស់គាត់។ គាត់រៀនបានរឿងរ៉ាវយ៉ាងច្រើនពីព្រះគម្ពីរ។ លោកថម និងអ្នកស្រី បេថី គ្រីន (Tom and Betty Green) មានកូនប្រុសពីរនាក់។ ការបង្រៀនក្នុងព្រះគម្ពីរជួយពួកគេក្នុងការបង្រៀនកូនរបស់គេ ដូច្នេះកូនរបស់ពួកគេស្រឡាញ់ព្រះជាម្ចាស់ និងចង់ស្តាប់បង្គាប់ព្រះអង្គផងដែរ។ ឥឡូវនេះកូនរបស់ពួកគេទាំងពីរបានរៀបការនឹងមានកូន។ ពួកគេអប់រំរបៀបកូនរបស់ពួកគេនៅក្នុងរបៀបដូចគ្នា។ ដោយសារលោកថម និងអ្នកស្រីបេថី គ្រីន(Tom and Betty Green) បានសិក្សាព្រះបន្ទូលរបស់ព្រះជាម្ចាស់ និង អនុញ្ញាតឱ្យព្រះវិញ្ញាណដ៏វិសុទ្ធបង្រៀនពួកគេ ធ្វើឱ្យក្រុមគ្រួសារទាំងមូលរបស់ពួកគេទទួលបានព្រះពរ។

ព្រះគម្ពីរបានបង្ហាញពីរបៀបជាច្រើនដែលព្រះវិញ្ញាណដ៏វិសុទ្ធបង្រៀនយើង។ សូមស្វែងរកខគម្ពីរដែលមានក្នុងបញ្ជីខាងក្រោមនៅក្នុងព្រះគម្ពីររបស់អ្នក និងសរសេរខគម្ពីរទាំងនេះទុកដើម្បីអោយអ្នកចងចាំខគម្ពីរទាំងនេះ។

១. អេភេសូ ១:១៧ _ ទ្រង់ប្រទានប្រាជ្ញាដល់យើង និងសម្ដែងឱ្យយើងស្គាល់ព្រះជាម្ចាស់កាន់តែច្បាស់។

២. អេភេសូ ៦:១៨ _ ទ្រង់បង្រៀន និងដឹងនាំយើងក្នុងសេចក្ដីអធិស្ឋាន។

៣. ១កូរិនថូស ២:១០-១២ _ ទ្រង់បង្រៀនយើងស្គាល់សេចក្ដីពិតរបស់ព្រះជាម្ចាស់ និងជម្រៅព្រះហឫទ័យរបស់ព្រះអង្គ។

៤. កាឡាទី ៥:១៦ ២២-២៣ ២៥ _ ទ្រង់ដឹកនាំជីវិតរបស់យើង និងបង្កើតផលខាងឯវិញ្ញាណនៅក្នុងយើង គឺសេចក្ដីស្រឡាញ់ អំណរ សេចក្ដីសុខសាន្ត ចិត្តអត់ធ្មត់ ចិត្តសប្បុរស ចិត្តសន្ដោស មេត្តា ជំនឿ ចិត្តស្លូតបូត ចេះទប់ចិត្តខ្លួនឯង។

ព័ន្ធកិច្ចទីពីរ ដោយយោងទៅខគម្ពីរយ៉ូហាន ១៤:២៦ ព្រះវិញ្ញាណដ៏វិសុទ្ធនឹងជួយយើងឱ្យចងចាំនូវអ្វីដែលព្រះយេស៊ូបានមានព្រះបន្ទូល។ ខណៈពេលដែលយើងសិក្សាព្រះបន្ទូលរបស់ព្រះជាម្ចាស់ ព្រះវិញ្ញាណដ៏វិសុទ្ធនឹងដាក់ពាក្យនៅក្នុងគំនិតរបស់យើងនៅពេលដែលយើងត្រូវការវា។ យើងមិនអាចចងចាំគ្រប់អត្ថបទខគម្ពីរពេលយើងអានព្រះគម្ពីរនោះទេ។ ប៉ុន្តែ ពេលណាដែលយើងត្រូវការចងចាំ ព្រះវិញ្ញាណដ៏វិសុទ្ធដាក់សេចក្ដីបង្រៀនទាំងនោះនៅក្នុងគំនិតរបស់អ្នកនឹងជួយអ្នកនៅក្នុងពេលណាមួយ។

តើអ្នកធ្លាប់និយាយជាមួយនរណាម្នាក់អំពីព្រះជាម្ចាស់ ហើយវាហាក់ដូចជាអ្នកដឹងចម្លើយទាំងអស់ដែរឬទេ? ព្រះវិញ្ញាណដ៏វិសុទ្ធបានដាក់ខគម្ពីរដែលត្រឹមត្រូវនៅក្នុងគំនិតរបស់អ្នកដើម្បីបំពេញទៅកាន់កាលៈទេសៈណាមួយដែរឬទេ? វាពិតជារំភើបដែលយើងដឹងថាព្រះជាម្ចាស់ជួយយើងនៅក្នុងពេលកាលៈទេសៈបែបណឹង។ គ្មានជំនួយដែលមកពីព្រះវិញ្ញាណដ៏វិសុទ្ធ មានឱកាសជាច្រើនដែលយើងមានអារម្មណ៍ថាវាបាត់បង់ខណៈពេលយើងព្យាយាមធ្វើស្មរបន្ទាល់ទៅកាន់នរណាម្នាក់។

ពេលខ្លះនៅពេលដែលយើងជួបការល្បួងឱ្យធ្វើអ្វីដែលខុស ព្រះវិញ្ញាណដ៏វិសុទ្ធនឹងបង្ហាញយើងពីរបៀបក្នុងការស្តាប់បង្គាប់ព្រះជាម្ចាស់។ ទ្រង់រំលឹកយើងឱ្យរក្សាឥរិយាបថដែលត្រឹមត្រូវនៅក្នុងទំនាក់ទំនងរបស់យើងជាមួយមនុស្សដទៃទៀតខណៈពេលដែលយើងខិតខំរក្សាដួងចិត្តនៃសហគមន៍។

៩ ហេតុអ្វីបានជាយើងត្រូវការពឹងផ្អែកលើព្រះវិញ្ញាណដ៏វិសុទ្ធធ្វើជាគ្រូបង្រៀន និងអ្នករំលឹករបស់យើង?

……………………………………………………………………………………………………

……………………………………………………………………………………………………

……………………………………………………………………………………………………

១០ សូមមើលមេរៀននេះឡើងវិញ ហើយសរសេរគ្រប់ទាំងរបៀបដែលព្រះវិញ្ញាណដ៏វិសុទ្ធជួយអ្នកនៅក្នុងសៀវភៅសរសេររបស់អ្នក។ រំលឹកពីកំណត់ត្រារបស់អ្នក និងគូរបន្ទាត់ពីគ្រប់របៀបដែលទ្រង់ជួយអ្នកដោយផ្ទាល់។

## សូមផ្ទៀងចម្លើយរបស់អ្នក

៦ ខ) សោកស្តាយចំពោះអំពើបាប និងសារភាពបាបទៅកាន់ព្រះជាម្ចាស់។

១ ពួកគេអាចទូលសូមព្រះវិញ្ញាណដ៏វិសុទ្ធដើម្បីផ្លាស់ប្តូរពួកគេ ហើយបន្ទាប់មកពួកគេអាចអនុវត្តរស់នៅលក្ខណៈបុគ្គលដែលពួកគេចង់ក្លាយទៅជា។

៧ ពឹងផ្អែកលើព្រះអង្គ

២ ពីព្រោះមនុស្សមិនចង់ធ្វើតាមគំរូរបស់អ្នក និងទទួលព្រះគ្រិស្តប្រសិនបើពួកគេមិនពេញចិត្តចំណុចណាមួយនៅក្នុងអ្នក។

៨ មួយនៅក្នុងចំណុចនេះៈ ព្រះវិញ្ញាណដ៏វិសុទ្ធបានយាងមកដើម្បីនាំយើងចូលទៅជិតព្រះជាម្ចាស់ ដើម្បីរួចពីការចោទប្រកាន់ពីអំពើបាប ហើយដើម្បីបើកសម្តែងពីព្រះយេស៊ូដល់យើង ហើយប្រាប់យើងអំពីការវិនិច្ឆ័យទោសរបស់ព្រះជាម្ចាស់ ហើយនឹងជួយយើងដើម្បីធ្វើជាបន្ទាល់សម្រាប់អ្នកដទៃដែរ។

៣ គ) រក្សាឥរិយាបថត្រឹមត្រូវគ្រប់ពេលវេលា។

៩ ចម្លើយរបស់អ្នក។ យើងត្រូវការព្រះវិញ្ញាណដើម្បីជួយយើងធ្វើជាទីបន្ទាល់ នៅក្នុងព័ន្ធកិច្ច និងសហគមន៍របស់យើង និងជួយយើងក្នុងការសម្រេចចិត្តដែលត្រឹមត្រូវ ដើម្បីឱ្យជីវិតរបស់យើងជាជីវិតដែលថ្វាយសិរីរុងរឿងដល់ព្រះជាម្ចាស់។

៤ ឃ្លា ខ) ឃ) និង ង) ជាចម្លើយត្រូវ

១០ ចម្លើយរបស់អ្នក

៥ ខ) ពេញមួយជីវិតរបស់ខ្ញុំគួរតែធ្វើជាស្មរបន្ទាល់ទៅកាន់អស់អ្នកដែលមិនស្គាល់មិនព្រះគ្រិស្ត ដូច្នេះខ្ញុំនឹងមិន ធ្វើឱ្យពួកគេត្រឡប់ទៅជាប្រឆាំងជាមួយព្រះអង្គ។

អ្នកបានមកដល់ចុងបញ្ចប់នៃការសិក្សានេះហើយ។ ខ្ញុំសង្ឃឹមថាអ្នកទទួលបានជំនួយជាច្រើនសម្រាប់ការដើរនៅក្នុងជីវិតគ្រិស្តបរិស័ទរបស់អ្នកតាមរយៈមេរៀនទាំងនេះ។ អ្នកបានចាប់ផ្តើមយល់ដឹងពីព័ន្ធកិច្ចរបស់គ្រិស្តបរិស័ទនៅក្នុងសហគមន៍របស់ពួកគេ។ អ្នកអាចយកការបង្រៀនទាំងនេះយកទៅអនុវត្តបានលុះត្រាតែអ្នកអនុញ្ញាតឱ្យព្រះវិញ្ញាណដ៏វិសុទ្ធជួយដល់អ្នក។ មានតែអំណាចរបស់ព្រះវិញ្ញាណដ៏វិសុទ្ធមួយប៉ុណ្ណោះដែលអាចជួយយើងធ្វើកិច្ចការដែលយើងគួរធ្វើ។ យើងត្រូវទុកចិត្តព្រះអង្គ ហើយព្រះអង្គនឹងជួយអ្នកអនុវត្តសេចក្តីបង្រៀនទាំងនេះនៅក្នុងជីវិតរបស់ និងព័ន្ធកិច្ចទៅកាន់អ្នកដទៃ។ សូមឱ្យមានការលើកទឹកចិត្តតាមរយៈអត្ថបទគម្ពីរខាងក្រោមះ

ចំពោះអ្នក ត្រូវកាន់តាមសេចក្តីដែលអ្នកបានរៀន និងយកធ្វើជាគោលជំនឿ អោយខ្ជាប់ខ្ជួនឡើង ! អ្នកដឹងច្បាស់ហើយថា អ្នកបានរៀនសេចក្តីទាំងនេះពីនរណាមក! (២ធីម៉ូថេ ៣:១៤)

ចំពោះអ្នករាល់គ្នាវិញ ចូរទុកអោយសេចក្តីដែលអ្នករាល់គ្នាធ្លាប់បានឮ តាំងពីដើមដំបូងរៀងមក ស្ថិតនៅជាប់នឹងអ្នករាល់គ្នាចុះ។ ប្រសិនបើសេចក្តីដែលអ្នករាល់គ្នាបានឮតាំងពីដើមដំបូងរៀងមក ស្ថិតនៅជាប់នឹងអ្នករាល់គ្នាមែន នោះអ្នករាល់គ្នាក៏ស្ថិតនៅជាប់នឹងព្រះបុត្រា និងព្រះបិតាដែរ។ (១យ៉ូហាន ២:២៤)

ឥឡូវនេះអ្នកត្រៀមខ្លួនដើម្បីចូលមកដល់ការវាយតម្លៃជំពូកទី២។ សូមរលឹកមេរៀនទី៦ ដល់១០ បន្ទាប់មកធ្វើតាមការណែនាំក្រដាសចម្លើយដូចខាងក្រោម។ នៅពេលអ្នកយកក្រដាសចម្លើយទៅឱ្យអ្នកចាត់ចែង សូមសួរគាត់អំពីការសិក្សាមុខវិជ្ជាផ្សេងទៀត។ សូមព្រះអម្ចាស់ប្រទានពរអ្នក ដើម្បីឱ្យអ្នកបន្តការអនុវត្តខាងឯព្រលឹងវិញ្ញាណនៅក្នុងសហគមន៍។

## ក្រដាសចម្លើយជំពូកទីមួយ

សូមបំពេញចន្លោះខាងក្រោម៖

ឈ្មោះ………………………………………………………………………………………………………………

លេខរៀងសិស្ស……………………………………………………………………………………………………….

(ទុកចន្លោះចោលប្រសិនជាអ្នកមិនស្គាល់លេខរបស់អ្នក។)

អាសយដ្ឋាន…………………………………………………………………………………………………………

……………………………………………………………………………………………………………………

……………………………………………………………………………………………………………………

ប្រទេស………………………………………………………………………………………………………………

## ការណែនាំ

ពេលអ្នកបានបញ្ចប់ការសិក្សាជំពូកនីមួយៗ សូមបំពេញក្រដាសចម្លើយការវាយតម្លៃតាមជំពូក។ សូមអានសំណួរនីមួយៗដោយយកចិត្តទុកដាក់។ មានចម្លើយមួយដែលល្អបំផុតសម្រាប់សំណួរនីមួយៗ។ ចូរដាក់ពណ៌ខ្មៅ សម្រាប់ចម្លើយដែលអ្នកបានជ្រើសរើស។ *សូមប្រាកដថា លេខដែលនៅលើក្រដាសចម្លើយ គឺដូចគ្នានឹងលេខនៃសំណួរដែលអ្នកកំពុងតែឆ្លើយ។*

*ឧទាហរណ៍*

១. ការកើតជាថ្មីមានន័យថា

ក) នៅវ័យក្មេង។

ខ) ទទួលព្រះយេស៊ូជាព្រះសង្គ្រោះ។

គ) ចាប់ផ្តើមឆ្នាំថ្មី។

ចម្លើយត្រឹមត្រូវគឺ **ខទទួល (ព្រះយេស៊ូជាព្រះសង្គ្រោះ។** ដូច្នេះ អ្នកគួរតែដាក់ពណ៌ខ្មៅ (ខ) ដូចនេះ៖

១. (ក) ● (គ) (ឃ)

*សូមបើកទំព័របន្ទាប់មួយទៀត នៅពេលអ្នកចង់ចាប់ផ្តើម។*

# ក្រដាសចម្លើយជំពូកទីមួយ

សូមដាក់ពណ៌ខ្មៅ នៅកន្លែងដែលត្រឹមត្រូវដោយប្រុងប្រយ័ត្ន សម្រាប់លេខនីមួយៗ។

| | | | | | | | | | |
|---|---|---|---|---|---|---|---|---|---|
| ១. | ក | ខ | គ | ឃ | ១១. | ក | ខ | គ | ឃ |
| ២. | ក | ខ | គ | ឃ | ១២. | ក | ខ | គ | ឃ |
| ៣. | ក | ខ | គ | ឃ | ១៣. | ក | ខ | គ | ឃ |
| ៤. | ក | ខ | គ | ឃ | ១៤. | ក | ខ | គ | ឃ |
| ៥. | ក | ខ | គ | ឃ | ១៥. | ក | ខ | គ | ឃ |
| ៦. | ក | ខ | គ | ឃ | ១៦. | ក | ខ | គ | ឃ |
| ៧. | ក | ខ | គ | ឃ | ១៧. | ក | ខ | គ | ឃ |
| ៨. | ក | ខ | គ | ឃ | ១៨. | ក | ខ | គ | ឃ |
| ៩. | ក | ខ | គ | ឃ | ១៩. | ក | ខ | គ | ឃ |
| ១០. | ក | ខ | គ | ឃ | ២០. | ក | ខ | គ | ឃ |

នេះជាការបញ្ចប់នៃតម្រូវការសម្រាប់ជំពូកទី១។ សម្រាប់ពិន្ទុ សូមផ្ញើក្រដាសចម្លើយជំពូកទី១ ទៅឱ្យគ្រូរបស់អ្នក ឬក៏ ទៅការិយាល័យដែលនៅក្នុងតំបន់របស់អ្នក។ សូមបន្តការសិក្សារបស់អ្នកនៅជំពូកទី២។

សម្រាប់ប្រើនៅការិយាល័យនៃសកលវិទ្យាល័យគ្លូបល ប៉ុណ្ណោះ

ថ្ងៃទី……………………………………

ពិន្ទុ…………………………………

PN 06.13

# ការវាយតម្លៃជំពូកទី១

១ កូនសោសំខាន់ដែលនៅពីក្រោយសហគមន៍គ្រិស្តបរិស័ទគឺ

ក) ភាពជាដៃគូ

ខ) ទំនាក់ទំនងរវាងម្ចាស់និងអ្នកបម្រើ

គ) សេចក្តីលំអិតតាមតួនាទី

២ តើចម្លើយខាងក្រោមមួយណាដែលបង្ហាញពីសហគមន៍ខាងព្រលឹងវិញ្ញាណ?

ក) សាសន៍សាម៉ារីមានចិត្តសប្បុរស

ខ) បុរសអ្នកមាននៅក្នុងលូកាជំពូក ១៦

គ) អ្នកចំការជាមួយត្រាក់ទ័រ

៣ សហគមន៍ដែលល្អឥតខ្ចោះរវាងលោកអដាំ អេវ៉ា និងព្រះជាម្ចាស់ត្រូវបានបំផ្លាញនៅពេលដែល

ក) លោកអដាំ និងនាងអេវ៉ាបានដាក់ឈ្មោះឱ្យសត្វទាំងអស់

ខ) លោកអដាំ និងអេវ៉ា ចាកចេញពីសួនអេដែន

គ) លោកអដាំ និងនាងអេវ៉ាមិនស្តាប់បង្គាប់ព្រះជាម្ចាស់

៤ អត្ថន័យដែលល្អបំផុតសម្រាប់ពាក្យ ក្រុមជំនុំដែលបានផ្តល់ឱ្យនៅក្នុងមុខវិជ្ជានេះគឺ

ក) ជារូបកាយរបស់អ្នកជឿទាំងអស់នៅក្នុងព្រះយេស៊ូគ្រីស្ត

ខ) ជាអាគារដែលគ្រិស្តបរិស័ទជួបប្រជុំគ្នា

គ) ជាក្រុមនៃអ្នកជឿតទាំងអស់ជួបជុំគ្នានៅកន្លែងមួយ

៥ ទីតាំងដែលជាកន្លែងសាក្សីរបស់យើង "ក្រុងយេរូសាឡឹម" គឺ

ក) ប្រទេសដែលយើងកំពុងតែរស់នៅ

ខ) សហកមន៍ដែលយើងធ្វើការ និងរស់នៅ

គ) ប្រទេសដែលនៅជុំវិញប្រទេសរបស់យើង

៦ សេចក្តីអធិស្ឋានសម្រាប់ការបើកសម្តែងនៅក្នុងប្រទេសមានន័យថាជាការធ្វើព័ន្ធកិច្ចទៅកាន់

ក) "ក្រុងយេរូសាឡឹម"

ខ) "ស្រុកសាម៉ារី"

គ) "ស្រុកយូដា"

៧ នៅពេលដែលព្រះជាម្ចាស់ត្រាស់ហៅលោកយ៉ូណាសឱ្យក្លាយជាព័ន្ធកិច្ចទៅកាន់ទីក្រុងនីនីវេ វាដូចជាធ្វើដំណើរទៅ

ក) ស្រុកយូដា

ខ) ស្រុកសាម៉ារី

គ) ចុងបញ្ចប់នៃផែនដី

៨ ការធ្វើព័ន្ធកិច្ចទៅកាន់មនុស្សនៅកន្លែងដែលឆ្ងាយសម្រេចតាមការត្រាស់ហៅរបស់ព្រះជាម្ចាស់ទៅ

ក) ស្រុកសាម៉ារី

ខ) ស្រុកយូដា

គ) ទីដាច់ស្រយាលនៃផែនដី

៩ ការល្បួងសាកល្បងព្រះយេស៊ូមិនបានសម្រេច នឹងត្រូវបានលាតត្រដាងដោយសារតែមានការខ្វះ

ក) ចំណេះនៃព្រះបន្ទូល

ខ) ចំណេះ នៅខាងក្នុងកិច្ចការរបស់មនុស្ស

គ)ការយល់ចិត្តបញ្ហារបស់មនុស្ស

១០ ផ្លូវដ៏សំខាន់នៅក្នុងការរីកចំរើនទំនាក់ទំនងគឺ

ក) គិតអំពីការទទួលខុសត្រូវរបស់យើងទាំងអស់គ្នា

ខ) គិតអំពីព្រះជាម្ចាស់ និងផ្លូវរបស់ព្រះអង្គ

គ) ពង្រឹងកំម្លាំងរបស់យើងផ្ទាល់

១១ ទំនាក់ទំនងរវាងបុគ្គលម្នាក់ និងព្រះគ្រិស្តនឹងគ្មានការបែកបាក់ឡើយទោះបីជាមានបញ្ហាចូលមកដល់ ប្រសិនបើគាត់

ក) ធ្វើកិច្ចការដែលគាត់ចូលចិត្តធ្វើ

ខ) រស់នៅស្តាប់បង្គាប់ព្រះគ្រិស្ត

គ) ធ្វើកិច្ចការអ្វីដែលរំពឹងឱ្យគាត់ធ្វើ

១២ សេចក្តីត្រូវការក្នុងការលូតលាស់ខាងឯព្រលឹងវិញ្ញាណគឺយើងថ្វាយបង្គំ

ក) រួមជាមួយគ្នាជាមួយអ្នកដទៃ

ខ) នៅពេលដែលយើងសប្បាយចិត្ត

គ) នៅក្នុងឱកាសពិសេសៗ

១៣ គោលការណ៍នៅក្នុងការលុតលាស់ខាងឯព្រលឹងវិញ្ញាណត្រូវបានញែកចេញពីពិភពលោកមានន័យថា

ក) គ្មានការសហការចូលរួមណាមួយជាមួយអ្នកដែលមិនជឿ

ខ) រស់នៅក្រៅកន្លែងណាដែលមិនសូវមានមនុស្សច្រើន

គ) ធ្វើយ៉ាងណាមិនត្រូវមានដៃគូរស្និទ្ធស្នាលជាមួយអ្នកដែលមិនជឿ

១៤ នៅពេលដែលយើងចេះអត់អោន យើងនឹង

ក) ធ្វើអ្វីដែលយើងអាចធ្វើបាន ដោយយោគយល់ដល់អារម្មណ៍អ្នកដទៃ

ខ) ឱ្យតម្លៃជំនឿរបស់មនុស្សដទៃ

គ) ឱ្យតម្លៃជំនឿរបស់មនុស្សគ្រប់ដូចដែលគេបានធ្វើសម្រាប់យើងដែរ។

១៥ ដើម្បីការពារពីសត្រូវខាងឯព្រលឹងវិញ្ញាណរបស់យើង យើងត្រូវ

ក) ឈរមាំនៅក្នុងកម្លាំងផ្ទាល់របស់យើង

ខ) ផ្តល់ប្រាក់ឱ្យទៅក្រុមជំនុំ

គ) ពាក់គ្រឿងសាស្ត្រាវុធរបស់ព្រះជាម្ចាស់។

១៦ ការណែនាំតាមបែបព្រះគម្ពីរទៅកាន់ទំនៀមទំលាប់នៅក្នុងសហគមន៍គឺ

ក) ចូលរួមជាមួយពួកគេនៅក្នុងរបៀបមួយដែលគាប់ព្រះហឫទ័យព្រះជាម្ចាស់

ខ) បដិសេធមិនចូលរួមជាមួយពួកគេ

គ) ប្រៀបធៀបជំនឿរបស់យើងជំហរជំនឿរបស់យើង។

១៧ នៅក្នុងសហគមន៍ដែលមានថ្ងៃឈប់សម្រាកសម្រាប់ថ្វាយបង្គំមនុស្សស្លាប់ គ្រិស្តបរិស័ទត្រូវ

ក) ចូលរួមសកម្មភាពជាមួយពួកគេ

ខ) ប្រើប្រាស់ថ្ងៃនោះជាឱកាសនៅក្នុងការធ្វើជាទីបន្ទាល់

គ) ទៅសង្កេត ប៉ុន្តែ មិនចូលរួមជាមួយពួកគេ

១៨ បុរសដែលបានសាងសង់ផ្ទះនៅលើថ្មដាគឺមនុស្សដែល

ក) មិនចង់ស្តាប់បង្គាប់ព្រះជាម្ចាស់

ខ) ជ្រើសរើសការចាក់គ្រឹះមិនរឹងមាំ

គ) ស្តាប់បង្គាប់ការបង្រៀនរបស់ព្រះគ្រិស្ត

១៩ បុគ្គលដែលចេះសម្របខ្លួនគឺជាមនុស្សដែលនឹង

ក) ទាមទារធ្វើកិច្ចការដោយខ្លួនឯង

ខ) ទុកឱ្យទំនៀមទំលាប់ដែលពេញដោយអំពើបាបនៅតែមាននៅក្នុងជីវិតរបស់ពួកគេ

គ) សម្របទៅតាមគម្រោងការរបស់អ្នកដទៃដើម្បីសម្រេចគោលដៅដូចគ្នា។

២០ តើមួយណាជាគំរូនៃការសាងសង់សម្ពន្ធមេត្រីរវាងមនុស្ស និងមនុស្ស

ក) និយាយរឿងអាស្រូវគ្នាទៅវិញទៅមក

ខ) ការអញ្ជើញនរណាម្នាក់មកផ្ទះរបស់អ្នក

គ) បដិសេធការអញ្ជើញទៅផ្ទះនរណាម្នាក់

# ក្រដាសចម្លើយជំពូកទីពីរ

សូមបំពេញចន្លោះខាងក្រោម៖

ឈ្មោះ……………………………………………………………………………………………………

លេខរៀងសិស្ស………………………………………………………………………………………….

(ទុកចន្លោះចោលប្រសិនជាអ្នកមិនស្គាល់លេខរបស់អ្នក។)

អាសយដ្ឋាន……………………………………………………………………………………………

………………………………………………………………………………………………………………

………………………………………………………………………………………………………………

ប្រទេស…………………………………………………………………………………………………

## ការណែនាំ

ពេលអ្នកបានបញ្ចប់ការសិក្សាមេរៀននីមួយៗរបស់អ្នក សូមបំពេញក្រដាសចម្លើយការវាយតម្លៃតាមជំពូក។ សូមអានសំណួរនីមួយៗដោយយកចិត្តទុកដាក់។ មានចម្លើយមួយដែលល្អបំផុតសម្រាប់សំណួរនីមួយៗ។ ចូរដាក់ពណ៌ខ្មៅសម្រាប់ចម្លើយដែលអ្នកបានជ្រើសរើស។ *សូមប្រាកដថា លេខដែលនៅលើក្រដាសចម្លើយ គឺដូចគ្នានឹងលេខនៃសំណួរដែលអ្នកកំពុងតែឆ្លើយ។*

*ឧទាហរណ៍*

១. ការកើតជាថ្មីមានន័យថា

ក) នៅវ័យក្មេង។

ខ) ទទួលព្រះយេស៊ូជាព្រះសង្គ្រោះ។

គ) ចាប់ផ្ដើមឆ្នាំថ្មី។

ចម្លើយត្រឹមត្រូវគឺ **ខ) ទទួលព្រះយេស៊ូជាព្រះសង្គ្រោះ។** ដូច្នេះ អ្នកគួរតែដាក់ពណ៌ខ្មៅ (ខ) ដូចនេះ៖

១. (ក) ● (គ) (ឃ)

*សូមបើកទំព័របន្ទាប់មួយទៀត នៅពេលអ្នកចង់ចាប់ផ្ដើម។*

# ក្រដាសចម្លើយជំពូកទីពីរ

សូមដាក់ពណ៌ខ្មៅ នៅកន្លែងដែលត្រឹមត្រូវដោយប្រុងប្រយ័ត្ន សម្រាប់លេខនីមួយៗ។

| | | | | | | | | | |
|---|---|---|---|---|---|---|---|---|---|
| ១. | ក | ខ | គ | ឃ | ១១. | ក | ខ | គ | ឃ |
| ២. | ក | ខ | គ | ឃ | ១២. | ក | ខ | គ | ឃ |
| ៣. | ក | ខ | គ | ឃ | ១៣. | ក | ខ | គ | ឃ |
| ៤. | ក | ខ | គ | ឃ | ១៤. | ក | ខ | គ | ឃ |
| ៥. | ក | ខ | គ | ឃ | ១៥. | ក | ខ | គ | ឃ |
| ៦. | ក | ខ | គ | ឃ | ១៦. | ក | ខ | គ | ឃ |
| ៧. | ក | ខ | គ | ឃ | ១៧. | ក | ខ | គ | ឃ |
| ៨. | ក | ខ | គ | ឃ | ១៨. | ក | ខ | គ | ឃ |
| ៩. | ក | ខ | គ | ឃ | ១៩. | ក | ខ | គ | ឃ |
| ១០. | ក | ខ | គ | ឃ | ២០. | ក | ខ | គ | ឃ |

នេះជាការបញ្ចប់នៃតម្រូវការសម្រាប់ជំពូកទី២។ សម្រាប់ពិន្ទុ សូមផ្ញើក្រដាសចម្លើយជំពូកទី២ ទៅឱ្យគ្រូរបស់អ្នក ឬក៏ ទៅការិយាល័យដែលនៅក្នុងតំបន់របស់អ្នក។

សម្រាប់ប្រើនៅការិយាល័យនៃសកល
វិទ្យាល័យ គ្លូបល ប៉ុណ្ណោះ

ថ្ងៃទី……………………………………

ពិន្ទុ……………………………………

PN 06.13

## ការវាយតម្លៃជំពូកទី២

១ នៅពេលដែលព្រះយេស៊ូនៅជាកុមារ ព្រះអង្គត្រូវបាន

ក) ព្រះអង្គត្រូវទទួលការស្អប់ប្រមាថពីសហគមន៍របស់ព្រះអង្គ

ខ) ព្រះអង្គទទួលការចូលចិត្តច្រើនពីសហគមន៍របស់ព្រះអង្គ

គ) ព្រះអង្គមិនសូវចូលរួមជាមួយសហគមន៍របស់ព្រះអង្គឡើយ។

២ នៅពេលដែលព្រះយេស៊ូមានព្រះជន្ម១២វស្សា ព្រះអង្គ

ក) ចាប់ផ្ដើមព័ន្ធកិច្ចរបស់ព្រះអង្គនៅទីសាធារណៈ

ខ) ព្រះអង្គបានសម្ដែងការអស្ចារ្យ

គ) បង្ហាញពីការយកព្រះទ័យទុកដាក់ជីវិតខាងឯព្រលឹងវិញ្ញាណ

៣ តើឃ្លាខាងក្រោមនេះមួយណាដែលជាសេចក្ដីពិតអំពីព្រះយេស៊ូ?

ក) ព្រះអង្គជៀសវាងការមានទំនាក់ទំនងជាមួយមនុស្សអាក្រក់

ខ) ព្រះអង្គបានបង្ហាញព្រះទ័យព្រួយបារម្ភចំពោះមនុស្ស

គ) ព្រះអង្គយកព្រះទ័ទុកដាក់ចំពោះតែអ្នកក្រប៉ុណ្ណោះ។

៤ លទ្ធផលនៃព្រះជន្មរបស់ព្រះយេស៊ូនៅលើផែនដីគឺ

ក) មានមនុស្សជាច្រើនព្រមទទួលថ្ងៃអាទិត្យជាថ្ងៃសម្រាក និងជាថ្ងៃថ្វាយបង្គំ

ខ) គ្មានការចាំបាច់ទៀតទេនៅក្នុងការមានថ្ងៃសម្រាកទៀតឡើយ

គ) ការសាងសង់ក្រុមជំនុំគឺជាព្រះរាជ្យរបស់ព្រះយេស៊ូនៅលើផែនដី។

៥ ជាគ្រិស្តបរិស័ទដែលឆ្លុះបញ្ចាំងអំពីពន្លឺរបស់ព្រះយេស៊ូ ពួកគេគឺ

ក) បង្ហាញផ្លូវទៅកាន់ព្រះយេស៊ូដល់អ្នកដទៃ

ខ) ចោទប្រកាន់អ្នកដទៃដោយសារអំពើបាបរបស់គេ

គ) ទទួលបានការសសើរថាជាមនុស្សពិសេស

៦ ព្រះយេស៊ូមានព្រះបន្ទូលថា "ខ្ញុំជាពន្លឺបំភ្លឺពិភពលោក" ក្នុងនាមជាគ្រិស្តបរិស័ទយើងត្រូវ

ក) ឆ្លុះបញ្ចាំងអំពីពន្លឺរបស់ព្រះគ្រិស្ត

ខ) មិនមែនជាផ្នែកណាមួយនៃសហគមន៍

គ) ព្យាយាមគ្របបាំងពន្លឺរបស់យើង។

៧ នៅពេលដែលគ្រិស្តបរិស័ទជាអំពិលនៅក្នុងសហគមន៍ ពួកគេដូចជា

ក) មានកំហឹងធ្វើអំពើបាប

ខ) ជាភ្នាក់ដែលប្រោសឱ្យដែលនឹងបង្ហាញអំពើបាប

គ) វិនិច្ឆ័យអស់អ្នកដែលមានបញ្ហា។

៨ គ្រិស្តបរិស័ទដូចជាអំបិលដោយសារតែពួកគេ

ក) ជួយរក្សាទុកនូវសេចក្ដីសុចរិត

ខ) មានសេរីភាពពីអំពើបាប

គ) មានសំលៀកបំពាក់ពណ៌ស។

៩ យើងអាចមានគំនិតថ្មីបាននៅពេលដែលយើង

ក) ទទួលព្រះគ្រិស្ត និងអនុញ្ញាតឱ្យព្រះអង្គគ្រប់គ្រងចិត្តគំនិតរបស់យើង

ខ) សម្រេបទៅតាមស្តង់ដារបស់មនុស្សដែលនៅជុំវិញយើង

គ) អនុញ្ញាតឱ្យគំនិតផ្សេងបំពេញចិត្តគំនិតរបស់យើង

១០ តម្លៃនៃការថ្វាយបង្គំព្រះជាម្ចាស់ជាមួយអ្នកជឿដទៃទៀតគឺ

ក) ការឈរមាំដែលបានផ្តល់ឱ្យយើង

ខ) ជាឱកាសសម្រាប់យើងនៅក្នុងការប្រើប្រាស់អំណោយទានរបស់យើង

គ) ជាកំលាំងដើម្បីបំពីដែលព្រះជាម្ចាស់បានផ្តល់ឱ្យ។

១១ ជាកម្មសិទ្ធនៅក្នុងក្រុមជំនុំសហគមន៍គឺទទួលការថែរក្សាតាមរយៈ

ក) មានការប្រកបរួមជាមួយគ្នា

ខ) ថែរក្សាគ្នាទៅវិញទៅមក

គ) ស្តាប់ព្រះបន្ទូលនៅក្នុងក្រុមជំនុំ

១២ តើអ្វីជាគោលបំណងរបស់ក្រុមជំនុំដែលនៅស្ថិតស្ថេរ?

ក) គឺសាងស់ក្រុមជំនុំដែលស្រស់ស្អាត

ខ) គឺជាកន្លែងមួយដើម្បីបង្ហាញពីសមត្ថភាពលេងតន្ត្រីរបស់ពួកយើង

គ) អធិប្បាយនៅក្នុងក្រុមជំនុំ។

១៣ យើងបានរៀនរួចមកហើយថាព្រះសង្គ្រោះរបស់យើងយាងមកតាមរយៈ

ក) ការបំរើរបស់យើងចំពោះព្រះជាម្ចាស់

ខ) អំពើល្អដែលយើងធ្វើសម្រាប់អ្នកដទៃ

គ) ព្រះគុណរបស់ព្រះជាម្ចាស់

១៤ ព្រះវិញ្ញាណដ៏វិសុទ្ធបានផ្តល់ឱ្យយើងដើម្បីបង្រៀនយើងអំពីរបៀប

ក) ដើម្បីបង្ហាញថាយើងមានចំណេះដឹងផ្នែកព្រះគម្ពីរ

ខ) ដើម្បីយល់អំពីសេចក្តីពិតអំពីព្រះគម្ពីរ

១៥ យើងមិនគួរចូលរួមសកម្មភាពរបស់សហគមន៍ឡើយប្រសិនបើ

ក) វត្តមានរបស់មនុស្សបាបនៅទីនោះ

ខ) វានឹងអាចធ្វើឱ្យប៉ះពាល់ដល់ទីបន្ទាល់អំពីគ្រិស្តបរិស័ទយើង

គ) វាជាសកម្មភាពអត្តពលកម្ម/កីឡាប៉ុណ្ណោះ

១៦ ទីបន្ទាល់របស់យើងនៅក្នុងសហគមន៍នឹងមានឥទ្ធិពលដ៏អស្ចារ្យប្រសិនបើយើង

ក) ផ្តល់ការរិះគន់ និងដំបូងន្មានអំពីទីក្រុង

ខ) ប្រើប្រាស់ជំនាញរបស់យើងសម្រាប់ប្រយោជន៍របស់អ្នកដទៃ

គ) ធ្វើឱ្យខ្លួនយើងនៅឱ្យឆ្ងាយពីសកម្មភាពលោកកិយ៍។

១៧ វិធីល្អនៅក្នុងការធ្វើជាតំណាងរបស់ព្រះគ្រិស្តនៅក្នុងសហគមន៍របស់យើងគឺយើងត្រូវធ្វើ

ក) ធ្វើជាអ្វីដែលមិនមែនជាខ្លួនយើង

ខ) ទន្ទេញខនៅក្នុងព្រះគម្ពីរឱ្យចាំ

គ) មានឥរិយាបថល្អត្រឹមត្រូវគ្រប់ពេលវេលា

១៨ ការប្រកាន់ភ្ជាប់ជាក់លាក់នូវសេក្ខីភាពវិជ្ជមានផ្ទាល់ខ្លួន យើងត្រូវតែ

ក) មិនធ្វើអ្វីទាំងអស់ដែលធ្វើឱ្យនរណាម្នាក់បដិសេធមិនទទួលព្រះគ្រិស្ត

ខ) ដឹងពីចម្លើយត្រឹមត្រូវទាំងអស់

គ) សម្របសម្រួលគ្នា មិនមែនមើលងាយគ្នាឡើយ។

១៩ អ្នកជឿនៅក្នុងសហគមន៍អាចបំពេញតាមបំណងព្រះហឫទ័យរបស់ព្រះជាម្ចាស់បានលុះត្រាតែពួកគេ

ក) ស្ដាប់បង្គាប់ការបង្រៀន និងធ្វើតាមព្រះវិញ្ញាណដ៏វិសុទ្ធ

ខ) បដិសេធមិនចុះចូលនៅក្នុងអំណាចរបស់នរណាម្នាក់

គ) ក្លាយជាដែលមានការពាក់ព័ន្ធនៅក្នុងការងាររដ្ឋាភិបាល

២០ ទុកចិត្តលើព្រះវិញ្ញាណដ៏វិសុទ្ធឱ្យទ្រង់ធ្វើជាគ្រូរបស់អ្នក

ក) គឺជាការចាំបាច់នៅពេលដែលយើងអស់កំលាំង

ខ) វាមិនជាការណែនាំ ដូចជាការបង្ហាញថាយើង

គ) បង្កើនប្រាជ្ញារបស់យើង

សូមប្រគល់ក្រដាសចម្លើយជំពូកទី២ របស់អ្នកទៅឱ្យអ្នកបង្រៀនរបស់អ្នក។ ឥឡូវនេះអ្នកបានបញ្ចប់ការសិក្សានៅក្នុងមុខវិជ្ជានេះហើយ សូមសួរអ្នកបង្រៀនរបស់អ្នកឱ្យផ្ដល់ការណែនាំទៅកាន់មុខវិជ្ជាផ្សេងទៀត។

# ពាក្យពេចន៍ចុងក្រោយ

ជូនចំពោះសិស្សានុសិស្សជាទីស្រឡាញ់

យើងសង្ឃឹមថាការសិក្សានេះនឹងធ្វើឱ្យអ្នកគិតអំពីទំនាក់ទំនងរបស់អ្នកជាមួយនឹងព្រះជាម្ចាស់។ បន្ទាប់ពីការសិក្សាមេរៀន និងការឆ្លើយសំណួរទាំងអស់មក តើអ្នកបានឆ្លល់ថា "តើខ្ញុំពិតជាគ្រិស្តបរិស័ទឬ? តើខ្ញុំស្គាល់ព្រះជាម្ចាស់ដែរឬទេ? តើទ្រង់ពិតជាគង់នៅក្នុងជីវិតខ្ញុំដែរឬទេ?" យើងចង់ផ្តល់ឱកាសឱ្យអ្នកនៅពេលនេះ ដើម្បីមានទំនាក់ទំនងជាមួយព្រះជាម្ចាស់។

យើងទាំងអស់គ្នាតែងតែមានកំហុស។ យើងបានធ្វើឱ្យខ្លួនឯង និងអ្នកដទៃឈឺចាប់។ ព្រះគម្ពីរបានហៅកិច្ចការនោះថាអំពើបាប ហើយយើងទាំងអស់គ្នាមានទោសកំហុស: "គ្រប់ៗគ្នាសុទ្ធតែបានប្រព្រឹត្តអំពើបាប ហើយគ្មានសិរីរុងរឿងរបស់ព្រះជាម្ចាស់នៅជាមួយ" ( រ៉ូម ៣:២៣)។ អំពើបាបរបស់យើងបានរារាំងយើងមិនឱ្យស្គាល់ព្រះហឫទ័យស្រឡាញ់របស់ព្រះបិតា។ ក៏ប៉ុន្តែ ព្រះជាម្ចាស់ស្រឡាញ់យើង ថ្វីបើយើងមានអំពើបាបក៏ដោយ។ "ព្រះជាម្ចាស់ស្រឡាញ់មនុស្សលោកខ្លាំងណាស់ ហេតុនេះហើយបានជាព្រះអង្គប្រទានព្រះបុត្រាតែមួយរបស់ព្រះអង្គមក ដើម្បីអោយអស់អ្នកដែលជឿលើព្រះបុត្រា មានជីវិតអស់កល្បជានិច្ច គឺមិនអោយគេវិនាសឡើយ" ( យ៉ូហាន ៣:១៦)។ ព្រះយេស៊ូបានទទួលយកទារុណកម្ម ដែលយើងសមនឹងទទួលសម្រាប់អំពើបាបរបស់យើង នៅពេលដែលទ្រង់បានសុគត។

តើអ្នកចង់ឱ្យប្រាកដថា ព្រះយេស៊ូជាព្រះសង្គ្រោះអ្នកដែរឬទេ? វាពិតជាសាមញ្ញណាស់៖

- ចូរទទួលស្គាល់ថាអ្នកជាមនុស្សមានបាប ដែលបានដាច់ចេញពីព្រះជាម្ចាស់ ហើយទូលសូមឱ្យព្រះអង្គអត់ទោសឱ្យ។
- ចូរជឿលើព្រះយេស៊ូឱ្យអស់ពីចិត្ត ហើយឱ្យទ្រង់ជ្រាបថា អ្នកបានទទួលព្រះអង្គជាព្រះសង្គ្រោះរបស់អ្នក។

អ្នកអាចនិយាយទៅកាន់ព្រះជាម្ចាស់ដោយពាក្យរបស់អ្នកផ្ទាល់ ដោយនិយាយនូវសេចក្តីអធិស្ឋានដូចនេះ៖ *ឱព្រះយេស៊ូអើយ ទូលបង្គំដឹងថាទូលបង្គំជាមនុស្សមានបាប។ សូមអត់ទោសដល់ទូលបង្គំផង។ ទូលបង្គំជឿថាទ្រង់ជាព្រះរាជបុត្រាដ៏នៅអស់កល្បរបស់ព្រះជាម្ចាស់។ អរគុណព្រះអង្គដែលសុគតនៅលើឈើឆ្កាងជំនួសអំពើបាបរបស់ទូលបង្គំ។ សូមយាងមកគង់ក្នុងជីវិតរបស់ទូលបង្គំ។ សូមធ្វើការនៅក្នុងជីវិតរបស់ទូលបង្គំ។ សូមធ្វើជាព្រះអម្ចាស់របស់ទូលបង្គំនៅថ្ងៃនេះ។ សូមអរព្រះគុណព្រះអង្គដែលបានសង្គ្រោះទូលបង្គំ! អាម៉ែន។*

ប្រសិនជាអ្នកបានអធិស្ឋាននូវសេចក្តីអធិស្ឋាននេះឱ្យអស់ពីចិត្ត អ្នកនឹងទទួលបានការអត់ទោសពីអំពើបាប និងជីវិតអស់កល្បជានិច្ច។ ព្រះយេស៊ូជាព្រះអម្ចាស់នៃជីវិតរបស់អ្នក។ ព្រះគម្ពីរបានប្រាប់ថា " ប៉ុន្តែ បើយើងទទួលសារភាពអំពើបាបរបស់យើង នោះព្រះជាម្ចាស់ដែលមានព្រះហឫទ័យស្មោះស្ម័គ្រ និងសុចរិត ទ្រង់នឹងអត់ទោសយើងអោយរួចពីបាប ព្រមទាំងជំរះយើងអោយបានបរិសុទ្ធ រួចពីគ្រប់អំពើទុច្ចរិតទាំងអស់ផង" (១យ៉ូហាន ១:៩)។

សូមស្វាគមន៍ការចូលរួមក្នុងគ្រួសាររបស់ព្រះជាម្ចាស់។ យើងមានអំណរជាមួយអ្នក ដូច្នេះ សូមសរសេរ និងប្រាប់យើងពីអ្វីដែលព្រះជាម្ចាស់បានធ្វើក្នុងជីវិតរបស់អ្នក។

សូមព្រះជាម្ចាស់ប្រទានពរដល់អ្នក!

……………………………………………………………………………………………………………

……………………………………………………………………………………………………………

……………………………………………………………………………………………………………

……………………………………………………………………………………………………………

……………………………………………………………………………………………………………

……………………………………………………………………………………………………………

……………………………………………………………………………………………………………

……………………………………………………………………………………………………………

……………………………………………………………………………………………………………

……………………………………………………………………………………………………………

……………………………………………………………………………………………………………

……………………………………………………………………………………………………………

……………………………………………………………………………………………………………

……………………………………………………………………………………………………………

……………………………………………………………………………………………………………

……………………………………………………………………………………………………………

……………………………………………………………………………………………………………

……………………………………………………………………………………………………………

……………………………………………………………………………………………………………

……………………………………………………………………………………………………………

ឈ្មោះ………………………………………………………………………………………………

## តើអ្នកមានមិត្តភក្តិដែលត្រូវការស្គាល់បន្ថែមអំពីព្រះយេស៊ូដែរឬទេ?

សូមផ្ញើឈ្មោះ និងអាសយដ្ឋានមិត្តភក្តិរបស់អ្នកសម្រាប់ចម្លើយដ៏អស្ចារ្យនៃជីវិត។

ឈ្មោះ ………………………………………………………………………………………………

អាសយដ្ឋាន……………………………………………………………………………………………

……………………………………………………………………………………………………………